# ព្រះរាជក្រម

នស/រកម/១០១០/០១៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរស្សិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

## ស្ដីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
## បង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ដែលបានចុះហត្ថលេខានៅទីក្រុងចាអាំ ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម/១០១០/០៤២

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋមន្ត្រីស្ដីទី

**ហត្ថលេខា**

**គឹម ស៊ីថន**

**លេខ:៧៣៩ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

2/2

# កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរី
# អាស៊ាន~អូស្ត្រាលី~ណូវែលហ្សេឡង់

# មាតិកា


| | | ទំព័រ |
|---|---|---|
| បុព្វកថា | | ១-២ |
| ជំពូក ១- | ការបង្កើតតំបន់ពាណិជ្ជកម្មសេរី គោលបំណង និង និយមន័យទូទៅ | ៣-៦ |
| ជំពូក ២- | ពាណិជ្ជកម្មទំនិញ | ៧-១៣ |
| ជំពូក ៣- | វិធានដើមកំណើត | ១៤-២៨ |
| | ឧបសម្ព័ន្ធ ស្តីពីនីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត | ២៩-៤០ |
| | - សេចក្តីបន្ថែម - គំរូវការទិន្នន័យអប្បបរមា - ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត | ៤១ |
| | - សេចក្តីបន្ថែម - គំរូវការទិន្នន័យអប្បបរមា - វិញ្ញាបនបត្រដើមកំណើត | ៤២ |
| ជំពូក ៤- | នីតិវិធីគយ | ៤៣-៤៨ |
| ជំពូក ៥- | វិធានការអនាម័យ និងភូតគាមអនាម័យ | ៤៩-៥៣ |
| ជំពូក ៦- | ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតំលៃភាពស្របគ្នា | ៥៤-៦១ |
| ជំពូក ៧- | វិធានការការពារ | ៦២-៦៩ |
| ជំពូក ៨- | ពាណិជ្ជកម្មសេវាកម្ម | ៧០-៩២ |
| | ឧបសម្ព័ន្ធ ស្តីពីសេវាហិរញ្ញវត្ថុ | ៩៣-១០១ |
| | ឧបសម្ព័ន្ធ ស្តីពីទូរគមនាគមន៍ | ១០២-១១២ |
| | - សេចក្តីបន្ថែម ស្តីពីការរៀបចំអន្តរកាល | ១១៣-១១៥ |
| ជំពូក ៩- | ការបំលាស់ទីនៃរូបវន្តបុគ្គល | ១១៦-១២០ |
| ជំពូក ១០- | ពាណិជ្ជកម្មអេឡិចត្រូនិច | ១២១-១២៥ |
| ជំពូក ១១- | វិនិយោគ | ១២៦-១៥៣ |
| | ឧបសម្ព័ន្ធ ស្តីពីការដកហូត និងសំណង | ១៥៤ |
| ជំពូក ១២- | សហប្រតិបត្តិការសេដ្ឋកិច្ច | ១៥៥-១៥៧ |
| ជំពូក ១៣- | កម្មសិទ្ធិបញ្ញា | ១៥៨-១៦៥ |

| | | |
|---|---|---|
| ជំពូក ១៤- | ការប្រកួតប្រជែង | ១៦៦-១៦៧ |
| ជំពូក ១៥- | បទប្បញ្ញត្តិទូទៅ និងការលើកលែង | ១៦៨-១៧៣ |
| ជំពូក ១៦- | បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន | ១៧៤-១៧៦ |
| ជំពូក ១៧- | ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ | ១៧៧-១៩៧ |
| | ឧបសម្ព័ន្ធ ស្តីពីវិធាននៃនីតិវិធីសម្រាប់ទម្រង់ការសាលាក្តី | ១៩៨-២០៣ |
| | ឧបសម្ព័ន្ធ ស្តីពីនីតិវិធីជ្រើសរើសសមាសភាពសាលាក្តី | ២០៤-២០៥ |
| ជំពូក ១៨- | អវសានប្បញ្ញត្តិ | ២០៦-២០៩ |

ឧបសម្ព័ន្ធផ្សេងៗ :

| | |
|---|---|
| ឧបសម្ព័ន្ធ ១ | តារាងការសន្យាពន្ធគយ |
| ឧបសម្ព័ន្ធ ២ | វិធានផលិតផលជាក់លាក់ |
| | សេចក្តីបន្ថែម ស្តីពីបញ្ជីចង្អុលបង្ហាញនៃដំណើរការកែច្នៃចុងក្រោយ |
| | ផលិតផលសម្លៀកបំពាក់ |
| ឧបសម្ព័ន្ធ ៣ | តារាងនៃការសន្យាសេវាកម្មជាក់លាក់ |
| ឧបសម្ព័ន្ធ ៤ | តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវន្តបុគ្គល |

# បុព្វកថា

រដ្ឋាភិបាល នៃប្រទេស ប្រ៊ុយណេដារុស្សាឡាម ព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សាធារណៈរដ្ឋឥណ្ឌូនេស៊ី (ឥណ្ឌូនេស៊ី) សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ (ឡាវ) ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា (មីយ៉ាន់ម៉ា) សាធារណរដ្ឋហ្វីលីពីន (ហ្វីលីពីន) សាធារណរដ្ឋសឹង្ហបុរី (សឹង្ហបុរី) ព្រះរាជាណាចក្រថៃឡង់ដ៍ (ថៃឡង់ដ៍) និងសាធារណរដ្ឋសង្គមនិយមវៀតណាម (វៀតណាម) ជារួម ប្រទេសសមាជិករបស់សមាគមនៃប្រជាជាតិអាស៊ីអាគ្នេយ៍ និង អូស្ត្រាលី និង ណូវែលហ្សេឡង់ :

***ពង្រឹងឡើងវិញ*** នូវចំណងទំនាក់ទំនងយូរអង្វែងនៃមិត្តភាព និង កិច្ចសហប្រតិបត្តិរវាងភាគីទាំងអស់។

***រំលឹកឡើងវិញ*** នូវក្របខ័ណ្ឌសំរាប់ភាពជាដៃគូសេដ្ឋកិច្ចជិតស្និទ្ធ រវាងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និង អូស្ត្រាលី និង ណូវែលហ្សេឡង់ ដែលអនុមត័ដោយរដ្ឋមន្ត្រីទាំងអស់ នៅទីក្រុងហាណូយ ប្រទេសវៀតណាម នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០១។

***មានបំណង*** ចង់កាត់បន្ថយជាអតិបរមានូវរបាំងនានា និង ពង្រឹង និងពង្រីកនូវចំណងសេដ្ឋកិច្ច រវាងភាគីទាំងអស់ ដើម្បីកាត់បន្ថយការចំណាយធ្វើអាជីវកម្ម ដើម្បីលើកតម្កើងពាណិជ្ជកម្ម និង វិនិយោគ ដើម្បីលើកកំពស់ប្រសិទ្ធភាពសេដ្ឋកិច្ច បង្កើតនូវទីផ្សារដ៏ធំមួយ ជាមួយនឹងឱកាសជាច្រើន និង សេដ្ឋកិច្ចក្នុងទ្រង់ទ្រាយកាន់តែធំសំរាប់អាជីវកម្ម។

***មានទំនុកចិត្តថា*** កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ នេះនឹងពង្រឹងនូវភាពជាដៃគូសេដ្ឋកិច្ច បំរើជាមូលដ្ឋានដ៏សំខាន់សំរាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

***ទទួលស្គាល់នូវ*** តួនាទីសំខាន់ និងការចូលរួមរបស់ផ្នែកអាជីវកម្មក្នុងការលើកកំពស់ពាណិជ្ជកម្ម រវាងភាគីនានា និងសេចក្តីត្រូវការដើម្បីបន្តជំរុញ និងសំរួលកិច្ចសហប្រតិបត្តិការ និងការប្រើប្រាស់នូវឱកាសពាណិជ្ជកម្មកាន់តែច្រើនឡើងៗ ដែលផ្តល់ដោយកិច្ចព្រមព្រៀងនេះ។

***ដោយគិតដល់*** កំរិតខុសគ្នានៃការអភិវឌ្ឍរវាងរដ្ឋជាសមាជិកអាស៊ាន និងរវាងអាស៊ាន និងអូស្ត្រាលី និង ណូវែលហ្សេឡង់ និងតម្រូវការសំរាប់ភាពអនុគ្រោះ ដែលរួមមានប្រព្រឹត្តិកម្មពិសេស និងភាពខុសគ្នា ជាពិសេសសំរាប់ប្រទេសសមាជិកអាស៊ានថ្មី ក៏ដូចជាសេចក្តីត្រូវការ ដើម្បីសំរួលដល់ការចូលរួមកាន់តែច្រើនរបស់ប្រទេស

សមាជិកអាស៊ានថ្មី នៅក្នុងកិច្ចព្រមព្រៀងនេះ ដែលរួមមានដូចជា : តាមរយៈការពង្រឹងនូវសមត្ថភាពប្រសិទ្ធភាព និង ភាពប្រកួតប្រជែងក្នុងស្រុក ។

***បញ្ជាក់សារជាថ្មី*** នូវសិទ្ធិ និងកាតព្វកិច្ចនានារបស់ប្រទេសនីមួយៗ និងការសន្យានានារបស់ភាគីទាំងអស់ ក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និង កិច្ចព្រមព្រៀងអន្តរជាតិដែលមានស្រាប់ដទៃទៀត ។

***ទទួលស្គាល់*** នូវឱកាសជាវិជ្ជមានថា កិច្ចព្រមព្រៀងពាណិជ្ជកម្មតំបន់សេរីអាចនាំទៅដល់ការពន្លឿន នូវសេរីភាវូបនីយកម្មពាណិជ្ជកម្មតំបន់ និងជាសកល និង តួនាទីរបស់វា ជាមូលដ្ឋានកសាងសំរាប់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី ។

***បានឯកភាពដូចតទៅ :***

## ជំពូក ១
## ការបង្កើតតំបន់ពាណិជ្ជកម្មសេរី
## គោលបំណង និង និយមន័យទូទៅ

### មាត្រា ១
### គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បី :

(ក) ធ្វើសេរីភាវូបនីយកម្មជាជាបណ្តើរៗ និងសម្រួលពាណិជ្ជកម្មទំនិញរវាងភាគីទាំងអស់ តាមរយៈការលុបបំបាត់ជាបណ្តើរៗនូវពន្ធគយ និងរបាំងមិនមែនពន្ធគយឱ្យបានច្រើន នៅក្នុងពាណិជ្ជកម្មទំនិញរវាងភាគីទាំងអស់

(ខ) ធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្មជាបណ្តើរៗ រវាងភាគីទាំងអស់ ដោយគ្របដណ្តប់ទៅលើវិស័យជាច្រើន

(គ) សម្រួល ជម្រុញ និងបង្កើនឱកាសវិនិយោគរវាងភាគីទាំងអស់ តាមរយៈការអភិវឌ្ឍបន្ថែមទៀតនូវបរិស្ថានវិនិយោគល្អ

(ឃ) បង្កើតក្របខ័ណ្ឌសហប្រតិបត្តិការមួយ សម្រាប់ពង្រឹងការធ្វើពិពិធភាព និងលើកស្ទួយពាណិជ្ជកម្ម វិនិយោគ និងទំនាក់ទំនងសេដ្ឋកិច្ចរវាងភាគីទាំងអស់ និង

(ង) ផ្តល់នូវប្រព្រឹត្តិកម្មពិសេស និងដោយឡែក ដល់រដ្ឋជាសមាជិកអាស៊ាន ជាពិសេសដល់រដ្ឋជាសមាជិកអាស៊ានថ្មី ដើម្បីសម្រួលឱ្យសមាជិកទាំងនោះធ្វើសមាហរណកម្មសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព។

### មាត្រា ២
### ការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់

តាមរយៈនេះ ភាគីទាំងអស់បង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ អនុលោមតាមមាត្រា XXIV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ១៩៩៤ និងមាត្រា V នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម។

## មាត្រា ៣
## និយមន័យទូទៅ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យថា :

(ក) **AANZFTA** មានន័យថា តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់

(ខ) **កិច្ចព្រមព្រៀង** មានន័យថា កិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់

(គ) **កិច្ចព្រមព្រៀងស្តីពីការវាយតម្លៃពន្ធគយ** មានន័យថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តមាត្រា ៧ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO)

(ឃ) **អាស៊ាន** មានន័យថា សមាគមនៃបណ្តាប្រជាជាតិអាស៊ីភាគអាគ្នេយ៍ រួមមាន ប្រទេសប្រ៊ុយណេដារ៉ូស្សាឡាម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ហើយសមាជិកទាំងនោះ ត្រូវបានហៅនៅក្នុងកិច្ចព្រមព្រៀងនេះជារួមថា រដ្ឋជាសមាជិកអាស៊ានទាំងអស់ ហើយសមាជិកនីមួយៗហៅថា រដ្ឋជាសមាជិកអាស៊ានមួយ

(ង) **ពន្ធគយ** មានន័យថា ពន្ធគយ ឬពន្ធនាំចូលណាមួយ និងការយកថ្លៃប្រភេទណាមួយ រាប់ទាំងពន្ធអាករ ឬពន្ធបន្ថែមណាមួយ ដែលដាក់ទៅលើការនាំចូលទំនិញមួយ ប៉ុន្តែមិនរាប់បញ្ចូលនូវ :

(i) ការយកពន្ធណាមួយប្រហែលគ្នាទៅនឹងការយកពន្ធក្នុងស្រុក ដែលមានចែងក្នុងកថាខ័ណ្ឌ២ ក្នុងមាត្រា ៣ នៃ GATT ឆ្នាំ១៩៩៤ ចំពោះផលិតផលដូចក្នុងស្រុក ឬចំពោះផលិតផលមួយ ដែលជាផលិតផលនាំចូល ដែលត្រូវបានកែច្នៃ ឬផលិតទាំងស្រុង ឬជាផ្នែកក្នុងស្រុក

(ii) ពន្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ ឬពន្ធប៉ះប៉ូវ ត្រូវបានអនុវត្តស្របគ្នានឹងប្រការមាត្រា ៦ នៃ GATT ឆ្នាំ១៩៩៤, *កិច្ចព្រមព្រៀងស្តីពីការអនុវត្តនៃមាត្រា ៦ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤*, អាចត្រូវបានធ្វើវិសោធនកម្ម និង *កិច្ចព្រមព្រៀង*

*ស្តីពីឧបត្ថម្ភធន និងវិធានការប៉ះប៉ូវ* នៅក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក អាចត្រូវបានធ្វើវិសោធនកម្ម ឬ

(iii) កម្រៃ ឬការយកថ្លៃណាមួយ ប្រហាក់ប្រហែលគ្នានឹងតម្លៃសេវាដែលបានផ្តល់

(ច) **ថ្ងៃ** មានន័យថា ជាបណ្តាថ្ងៃនៃប្រតិទិន រាប់ទាំងថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សំរាក

(ឆ) **គណៈកម្មាធិការចំរុះ FTA** មានន័យថា គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ ត្រូវបានបង្កើតឡើងតាមមាត្រា ១ (គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី) នៃជំពូក ១៦ (បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន)

(ជ) **GATS** មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម នៅក្នុងឧបសម្ព័ន្ធ ១ ខ នៃកិច្ចព្រមព្រៀង WTO

(ឈ) **GATT 1994** មានន័យថា កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ នៅក្នុងឧបសម្ព័ន្ធ ១ ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

(ញ) **HS Code** មានន័យថា ប្រព័ន្ធបរិយាយ និងលេខកូដទំនិញរួម បង្កើតឡើងដោយអនុសញ្ញាស្តីពីប្រព័ន្ធបរិយាយ និងលេខកូដទំនិញរួម ត្រូវបានចុះហត្ថលេខានៅទីក្រុងប្រ៊ុសសែល នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៣ អនុសញ្ញានេះត្រូវបានធ្វើវិសោធនកម្ម

(ដ) **មាត្រានៃកិច្ចព្រមព្រៀងរបស់ IMF** មានន័យថា ជាមាត្រានៃកិច្ចព្រមព្រៀងរបស់អង្គការរូបិយវត្ថុអន្តរជាតិ

(ឋ) **រដ្ឋជាសមាជិកអាស៊ានថ្មី** មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

(ឌ) **ដើមកំណើតទំនិញ** មានន័យថា ជាទំនិញមួយដែលគ្រប់លក្ខណៈជាទំនិញដែលមានដើមកំណើត នៅក្រោមជំពូក ៣ (វិធានដើមកំណើត)

(ឍ) **ភាគីទាំងអស់** មានន័យថា រដ្ឋជាសមាជិកអាស៊ាន អូស្ត្រាលី និងណូវែលហ្សេឡង់ រួមគ្នា

(ណ) **ភាគី** មានន័យថា សមាជិកអាស៊ានមួយ ឬអូស្ត្រាលី ឬណូវែលហ្សេឡង់

(ត) **កិច្ចព្រមព្រៀង TRIPS** មានន័យថា ជាកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពនៃសិទ្ធិកម្មសិទ្ធិបញ្ញាទាក់ទងនឹងពាណិជ្ជកម្ម នៅក្នុងឧបសម្ព័ន្ធ ១ គ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

(ថ) **WTO** មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក និង

(ទ) **កិច្ចព្រមព្រៀង WTO** មានន័យថា ជាកិច្ចព្រមព្រៀងទីក្រុងម៉ារ៉ាកែត បង្កើតអង្គការពាណិជ្ជកម្មពិភពលោក ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៤។

## ជំពូក ២
## ពាណិជ្ជកម្មទំនិញ

### មាត្រា ១
### ការកាត់បន្ថយ និង/ឬ ការលុបចំបាត់ពន្ធគយ

លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗត្រូវធ្វើការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធគយលើទំនិញដែលមានដើមកំណើតនៅបណ្តាភាគី ទៅតាមកម្មវិធីនៃការសន្យាពន្ធគយ ក្នុងឧបសម្ព័ន្ធ ១ (តារាងការសន្យាពន្ធគយ) ។

### មាត្រា ២
### ការពន្លឿនការសន្យាពន្ធគយ

១. គ្មានអ្វីដែលកិច្ចព្រមព្រៀងនេះ ត្រូវរារាំងបណ្តាភាគីពីការចរចា និង ការចូលរួមក្នុងការរៀបចំពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយ ដែលបានធ្វើនៅក្រោមកិច្ចព្រមព្រៀងនេះ ។ ការរៀបចំរវាងបណ្តាភាគី ដើម្បីពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយ ត្រូវបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះអនុលោមទៅតាមមាត្រា ៩ (វិសោធនកម្ម) នៃជំពូក ១៨ (អវសានប្បញ្ញត្តិ) ។ ការពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយ ត្រូវអនុវត្តដោយបណ្តាភាគី ។

២. ភាគីពីរ ឬច្រើន អាចពិភាក្សា ដើម្បីពិចារណាក្នុងការពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយ ដែលមានចែងនៅក្នុងកម្មវិធីសន្យាពន្ធគយនៅក្នុងឧបសម្ព័ន្ធ ១ (តារាងការសន្យាពន្ធគយ) ។ ការព្រមព្រៀងរវាងភាគីទាំងនោះក្នុងការពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយរបស់ពួកគេក្រោមកិច្ចព្រមព្រៀងនេះ អនុលោមតាមមាត្រា ៩ (វិសោធនកម្ម) នៃជំពូក ១៨ (អវសានប្បញ្ញត្តិ) ។ សម្បទានពន្ធគយកើតពីការពន្លឿន និង/ឬ ការលើកកំពស់ការសន្យាពន្ធគយត្រូវផ្តល់ទៅដល់បណ្តាភាគី ។

៣. គ្រប់ពេលវេលាជាឯកតោភាគី ភាគីមួយអាចពន្លឿនការកាត់បន្ថយ និង/ឬ ការលុបបំបាត់ពន្ធគយលើទំនិញដែលមានដើមកំណើតនៅបណ្តាភាគី ទៅតាមកម្មវិធីសន្យាពន្ធគយនៅក្នុងឧបសម្ព័ន្ធ ១ (តារាងការសន្យាពន្ធគយ) ។

ភាគីដែលមានបំណងធ្វើដូចនេះ ត្រូវជូនពត៌មានទៅភាគីដទៃទៀត មុនពេលដែលអត្រាពន្ធគយថ្មីចូលជាធរមាន ឬទៅតាមស្ថានការណ៍ណាមួយដែលលឿនដូចដែលអាចអនុវត្ត។

## មាត្រា ៣

## ការលុបបំបាត់ការឧបត្ថម្ភធននាំចេញកសិផល

ស្របទៅតាមសិទ្ធិ និងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង WTO ភាគីនីមួយៗ ព្រមព្រៀងលុប និងមិនប្រើឡើងវិញនូវគ្រប់ទម្រង់ឧបត្ថម្ភធនសំរាប់ផលិតផលកសិកម្មទៅលើភាគីដទៃ។

## មាត្រា ៤

## ប្រព្រឹត្តិកម្មជាតិ ស្តីពីពន្ធដារ និងបញ្ញត្តិក្នុងស្រុក

ភាគីនីមួយៗត្រូវយល់ព្រមលើប្រព្រឹត្តិកម្មជាតិទៅនឹងទំនិញរបស់ភាគីដទៃ អនុលោមទៅតាមមាត្រា III នៃ GATT ១៩៩៤។ ក្នុងន័យនេះ មាត្រា III នៃ GATT ១៩៩៤ ត្រូវបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ដូចដែលមានការកែប្រែសមរម្យ*។

## មាត្រា ៥

## កម្រៃ និង ថ្លៃសេវា ទាក់ទងនឹងការនាំចូល និង ការនាំចេញ

១. ភាគីនីមួយៗ ត្រូវធានាថា កម្រៃ និង ថ្លៃសេវាទាក់ទងនឹងការនាំចូល និងការនាំចេញ ត្រូវស្របទៅតាមសិទ្ធិ និងកាតព្វកិច្ច ក្រោម GATT ១៩៩៤។

២. ភាគីនីមួយៗ ត្រូវធ្វើឱ្យពត៌មាន ដែលអាចរកបានមានលក្ខណៈលំអិតពីកម្រៃ និងថ្លៃសេវាដែលត្រូវបង់ចំពោះការនាំចូល និងការនាំចេញ និងតាមកម្រិតដែលអាច និងអនុលោមតាមច្បាប់ និងបញ្ញត្តិក្នុងស្រុក ត្រូវដាក់ពត៌មានទាំងនោះនៅលើអ៊ីនធឺណែត។

៣. ភាគីមួយអាចមិនត្រូវបានទាមទារឱ្យបញ្ជាក់ពីស្ថានកុងស៊ុល រួមបញ្ចូលទាំង កម្រៃ និងថ្លៃសេវាទាក់ទងនឹងការនាំចូលទំនិញណាមួយ ពីភាគីដទៃណាមួយ។

## មាត្រា ៦

## ការបោះពុម្ពផ្សាយ និង ការរៀបចំបទប្បញ្ញត្តិពាណិជ្ជកម្ម

១.	មាត្រា X នៃ GATT ១៩៩៤ ត្រូវបញ្ចូល និងត្រូវបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ដូចដែលមានការកែប្រែសមរម្យ*។

២.	អនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុក និងតាមកម្រិតដែលអាច ភាគីនីមួយៗ ត្រូវដាក់ឱ្យច្បាប់ បទប្បញ្ញត្តិ សេចក្តីសម្រេច និង វិធាននានា នៃប្រភេទដូចមានចែងនៅក្នុងកថាខណ្ឌ ១ ទៅលើអ៊ីនធឺណែត ។

## មាត្រា ៧
## ការដាក់កម្រិតបរិមាណ និងវិធានការមិនមែនពន្ធគយ

១.	គ្មានភាគីណាមួយត្រូវអនុម័ត ឬ រក្សារាល់ការហាមឃាត់ ឬ ការដាក់កម្រិតបរិមាណលើការនាំចូលទំនិញពីបណ្តាភាគីដទៃ ឬ លើការនាំចេញទំនិញពីដែនដីនៃភាគីដទៃណាមួយ លើកលែងតែអនុលោមទៅតាមសិទ្ធិ និង កាតព្វកិច្ចក្រោម WTO ឬ កិច្ចព្រមព្រៀងនេះ។ ក្នុងន័យនេះ មាត្រា XI នៃ GATT ១៩៩៤ ត្រូវបញ្ចូល និងបង្កើតជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ *ដូចដែលមានការកែប្រែសមរម្យ*។

២.	លើកលែងតែមានចែងផ្សេងនៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីមួយមិនត្រូវអនុម័ត ឬរក្សាវិធានការមិនមែនពន្ធគយណាមួយ នៅពេលនាំចូលទំនិញណាមួយពីភាគីដទៃណាមួយ ឬ ការនាំចេញទំនិញណាមួយពីដែនដីរបស់ភាគីដទៃទៀតណាមួយ លើកលែងតែអនុលោមទៅតាមសិទ្ធិ និងកាតព្វកិច្ច WTO ឬអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ ។

៣.	ភាគីនីមួយៗ ត្រូវធានានូវតំលាភាពនៃវិធានការមិនមែនពន្ធគយ ដែលអនុញ្ញាតក្រោមកថាខ័ណ្ឌ២ និង ត្រូវធានាថា វិធានការទាំងនោះមិនត្រូវបានរៀបចំ អនុម័ត ឬ អនុវត្ត ដោយយល់ថា ឬមានប្រសិទ្ធភាពនៃការបង្កើតឱ្យមានឧបសគ្គមិនចាំបាច់ក្នុងការធ្វើពាណិជ្ជកម្មរវាងបណ្តាភាគី ។

៤.	គណៈកម្មាធិការទំនិញ យោងតាមមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) ត្រូវពិនិត្យឡើងវិញនូវវិធានការមិនមែនពន្ធគយ ដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ក្នុងគំនិតដើម្បីពិចារណាទៅលើទំហំ សម្រាប់ជាមធ្យោបាយបន្ថែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលពាណិជ្ជកម្មទំនិញរវាងបណ្តាភាគី ។ គណៈកម្មាធិការទំនិញ ត្រូវផ្តល់ជូនគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី នូវរបាយការណ៍ដំបូងស្តីពីការរីកចម្រើនក្នុងការងារ រួមទាំង អនុសាសន៍ទាំងឡាយ ក្នុងរយៈពេលពីរឆ្នាំនៃការចូលជាធរមាននៃកិច្ចព្រមព្រៀង ។ ភាគីណាមួយអាចលើកឡើងនូវបណ្តាវិធានការ សម្រាប់ការពិចារណាដោយគណៈកម្មាធិការទំនិញ ។

## មាត្រា ៨

## អាជ្ញាប័ណ្ណនាំចូល

១. ភាគីនីមួយៗត្រូវធានាថា រាល់វិធានការអាជ្ញាប័ណ្ណនាំចូលស្វ័យប្រវត្ត និងមិនស្វ័យប្រវត្ត គឺអនុវត្តដោយតំលាភាព និងអាចប៉ាន់ស្មានជាមុន និងអនុវត្ត ដោយអនុលោមតាម *កិច្ចព្រមព្រៀងស្តីពីនីតិវិធីអាជ្ញាប័ណ្ណនាំចូល* ក្នុងឧបសម្ព័ន្ធ ១A នៃកិច្ចព្រមព្រៀង WTO ។

២. ភាគីនីមួយៗត្រូវប្រញាប់ជូនដំណឹងទៅបណ្តាភាគីដទៃទៀត ពីនីតិវិធីអាជ្ញាប័ណ្ណនាំចូល ដែលមានស្រាប់ ។ បន្ទាប់មក ភាគីនីមួយៗត្រូវជូនដំណឹងទៅបណ្តាភាគីដទៃទៀត ពីនីតិវិធីអាជ្ញាប័ណ្ណនាំចូលថ្មី និងការកែប្រែទៅនឹងនីតិវិធីអាជ្ញាប័ណ្ណនាំចូលដែលមានស្រាប់ តាមកម្រិតដែលអាចទៅបាន ៦០ ថ្ងៃមុនពេលចូលជាធរមាន ប៉ុន្តែក្នុងករណីណាមួយ មិនឱ្យយឺតជាង ៦០ ថ្ងៃនៃការបោះពុម្ពផ្សាយ ។ ពត៌មាននៅក្នុងការជូនដំណឹងក្រោមមាត្រានេះ ត្រូវតែអនុលោមទៅតាមមាត្រា ៥.២ និង ៥.៣ នៃកិច្ចព្រមព្រៀងស្តីពីនីតិវិធីអាជ្ញាប័ណ្ណនាំចូលនៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

៣. នៅពេលដែលមានការស្នើសុំពីភាគីដទៃ ភាគីមួយត្រូវប្រញាប់ប្រញាល់ និង ទៅតាមកម្រិតដែលអាចឆ្លើយតបទៅនឹងការស្នើសុំរបស់ភាគីនោះ រាល់ពត៌មានស្តីពីតម្រូវការអាជ្ញាប័ណ្ណនាំចូលតាមបែបបទជាទូទៅ ។

## មាត្រា ៩

## ការកែប្រែសម្បទាន

នៅក្នុងកាលៈទេសៈពិសេស ពេលដែលភាគីមួយប្រឈមនឹងការលំបាកដោយមិនបានព្រាងទុកក្នុងការអនុវត្តការសន្យាពន្ធគយ ដោយមានព្រមព្រៀងពីបណ្តាភាគីដែលមានចំណាប់អារម្មណ៍ដទៃទៀត ភាគីនោះអាចធ្វើការកែប្រែ ឬ ដកចេញនូវសម្បទានដែលមាននៅក្នុងកម្មវិធីសន្យាពន្ធគយ ក្នុងឧបសម្ព័ន្ធ ១ (តារាងការសន្យាពន្ធគយ) ។ ដើម្បីឈានទៅរកការព្រមព្រៀងនោះ ភាគីពាក់ព័ន្ធត្រូវផ្សារភ្ជាប់ទៅនឹងការចរចាជាមួយបណ្តាភាគីមានចំណាប់អារម្មណ៍ណាមួយ ។ ក្នុងការចរចានោះ ភាគីដែលសុំកែប្រែ ឬដកចេញនូវសម្បទាន ត្រូវរក្សាសម្បទានជាប្រយោជន៍ទៅវិញទៅមក ដែលភាពអនុគ្រោះពាណិជ្ជកម្មចំពោះភាគីមានចំណាប់អារម្មណ៍ទាំងអស់មិនតិចជាងដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ទៅតាមការចរចា ដែលមានរួមទាំងការកែខៃឱ្យសមរម្យ ការទូទាត់សង ទាក់ទងនឹងទំនិញដទៃទៀត ។ លទ្ធផលនៃការចរចាដែលព្រមព្រៀងទៅវិញទៅមក រួមទាំងការកែខៃឱ្យសមរម្យ ការទូរទាត់សង

ត្រូវអនុវត្តចំពោះបណ្តាភាគី និងត្រូវបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងនេះ អនុលោមទៅតាមមាត្រា ៩ (វិសោធនកម្ម) នៃជំពូក ១៨ ( អវសានប្បញ្ញត្តិ) ។

## មាត្រា ១០
## ចំណុចទំនាក់ទំនង និងការពិគ្រោះយោបល់

១. ភាគីនីមួយៗត្រូវជ្រើសតាំងចំណុចទំនាក់ទំនង ដើម្បីសម្របសម្រួលទំនាក់ទំនងរវាងបណ្តាភាគី ចំពោះបញ្ហាពាក់ព័ន្ធទៅនឹងជំពូកនេះ ។

២. នៅពេលដែលភាគីពិចារណាថា ការស្នើសុំ ឬ វិធានការជាក់ស្តែងរបស់ភាគីដទៃទៀត ឬ បណ្តាភាគី ភាគីនោះអាច តាមរយៈចំណុចទំនាក់ទំនង ស្នើសុំពត៌មានលំអិតដែលពាក់ព័ន្ធទៅនឹងវិធានការនោះ និងប្រសិនបើចាំបាច់ ស្នើសុំពិគ្រោះក្នុងគំនិតដើម្បីដោះស្រាយកង្វល់អំពីវិធានការ ។ ភាគីដទៃទៀត ឬបណ្តាភាគីត្រូវឆ្លើយតបជាបន្ទាន់ទៅនឹងការស្នើសុំពត៌មាន និង ពិគ្រោះ ។

## មាត្រា ១១
## គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ

១. បណ្តាភាគី តាមរយៈនេះ បង្កើតគណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ (គណៈកម្មាធិការទំនិញ) រួមមានតំណាងពីបណ្តាភាគី ។ គណៈកម្មាធិការទំនិញ អាចជួបនៅពេលមានការស្នើសុំដោយភាគីណាមួយ ឬ គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី ដើម្បីពិចារណារាល់បញ្ហាដែលកើតឡើងក្រោមជំពូកនេះ ឬ ក្រោម :

(ក) ជំពូក ៣ (វិធានដើមកំណើត)

(ខ) ជំពូក ៤ (នីតិវិធីគយ)

(គ) ជំពូក ៥ (វិធានការអនាម័យ និងភូតគាមអនាម័យ)

(ឃ) ជំពូក ៦ (ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និង នីតិវិធីវាយតម្លៃភាពស្របគ្នា) និង

(ង) ជំពូក ៧ (វិធានការការពារ) ។

២. មុខងាររបស់គណៈកម្មាធិការទំនិញ រួមមាន :

(ក) ពិនិត្យការអនុវត្តឡើងវិញ និងវិធានការដែលប្រើប្រាស់ ទៅតាមបណ្ដាជំពូកដែលមានចែងនៅក្នុងកថាខណ្ឌ ១

(ខ) ទទួលរបាយការណ៍ ពិនិត្យឡើងវិញការងាររបស់ :

(i) អនុគណៈកម្មការវិធានដើមកំណើត ដែលបានបង្កើតអនុលោមតាមមាត្រា ១៨ (អនុគណៈកម្មការស្ដីពីវិធានដើមកំណើត) នៃជំពូក ៣ (វិធានដើមកំណើត)

(ii) អនុគណៈកម្មការវិធានការអនាម័យ និងភូតគាមអនាម័យ ដែលបានបង្កើតអនុលោម តាមមាត្រា ១០ (ជំនួបក្នុងចំណោមបណ្ដាភាគីស្ដីពីបញ្ហាអនាម័យ និងភូតគាមអនាម័យ) នៃជំពូក ៥ (វិធានការអនាម័យ និងភូតគាមអនាម័យ) និង

(iii) អនុគណៈកម្មការស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ដែលបង្កើតអនុលោមតាមមាត្រា ១៣ (អនុគណៈកម្មការស្ដីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា) នៃជំពូក ៦ (ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា)

(គ) អនុវត្តកម្មវិធីការងារដែលមាននៅក្នុងមាត្រា ៧.៤ (ការដាក់កម្រិតបរិមាណ និងវិធានការមិនមែនពន្ធគយ)

(ឃ) កំណត់ និងផ្ដល់អនុសាសន៍ពីវិធានការ ដើម្បីជំរុញ និងសម្របសម្រួល លើកកំពស់ច្រកចូលទីផ្សាររួមទាំងការពន្លឿនណាមួយនៃការសន្យាពន្ធគយក្រោមមាត្រា ២.១ (ការពន្លឿនការសន្យាពន្ធគយ) និង

(ង) រាយការណ៍ នៅពេលដែលមានការស្នើសុំ ជូនគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី ។

៣. គណៈកម្មាធិការទំនិញអាចឯកភាពក្នុងការបង្កើតក្រុមការងារក្រោមបង្គាប់ ឬ បញ្ជូនបញ្ហាសំរាប់ពិចារណាទៅអនុគណៈកម្មាធិការវិធានដើមកំណើត ។

៤. រាល់កិច្ចប្រជុំរបស់គណៈកម្មាធិការទំនិញអាចកើតឡើងដោយបុគ្គល ឬ ដោយមធ្យោបាយដទៃណាមួយ ដែលឯកភាពដោយបណ្ដាភាគី ។

## មាត្រា ១២

## ការអនុវត្ត

ភាគីនីមួយៗត្រូវអនុវត្តវិធានការសមហេតុផល ដែលអាចរកបាន ដើម្បីធានាការប្រតិបត្តិទៅតាមបទប្បញ្ញត្តិនៃជំពូកនេះ ដោយរដ្ឋាភិបាលតំបន់ និងមូលដ្ឋាន និងអាជ្ញាធរក្នុងដែនដីនោះ ។

# ជំពូក ៣
# វិធានដើមកំណើត

## មាត្រា ១
## និយមន័យ

គោលបំណងនៃជំពូកនេះ ពាក្យ :

(ក) **វារីវប្បកម្ម** មានន័យថា របរកសិកម្ម នៃសរីរាង្គរស់នៅក្នុងទឹក រួមមាន ត្រី ពួកសត្វសន្តាន ខ្យង ត្រីបង្កង ក្តាម កំពឹស ។ល។ និបិដ្យាឆ្អិកសត្វដែលគ្មានឆ្អឹងខ្នងរស់នៅក្នុងទឹកផ្សេងៗទៀត និង រុក្ខជាតិតូចៗ ដែលរស់នៅក្នុងទឹក ដែលមានអាហារបំរុងដូចជាពង (ពងសត្វ និងរុក្ខជាតិក្នុងទឹក) កូនត្រីបួង់តុង និងកូនក្អុក ដោយអន្តរាគមន៍ក្នុងដំណើរការចិញ្ចឹម ឬជួយធ្វើឱ្យមានការរីកធំធាត់ ដើម្បីលើកកំពស់ផលិតកម្ម ដូចជា ការចិញ្ចឹម ការឱ្យចំណី ឬការការពារជំងឺ ។

(ខ) **ការចេញវិញ្ញាបនប័ត្រដើមកំណើតបន្ត** មានន័យថា វិញ្ញាបនប័ត្រដើមកំណើត ដែលចេញដោយអាជ្ញាធរ/អង្គភាពនៃភាគីនាំចេញកណ្តាលមួយ ដោយផ្អែកលើវិញ្ញាបនប័ត្រដើមកំណើត ដែលចេញដោយប្រទេសនាំចេញដំបូង ។

(គ) **ថ្លៃទំនិញ បូកថ្លៃធានារ៉ាប់រង បូកថ្លៃដឹកជញ្ជូន (CIF)** មានន័យថា ថ្លៃទំនិញនាំចូល និងរួមបញ្ចូលថ្លៃដឹកជញ្ជូន និងថ្លៃធានារ៉ាប់រង ចាប់ពីកន្លែងអាជីវកម្មរបស់អ្នកលក់រហូតដល់កំពង់ផែ ឬទីកន្លែងនៃច្រកចូលរបស់ប្រទេសនាំចូល។ ការវាយតម្លៃគួរតែធ្វើឡើងដោយផ្អែកទៅលើមាត្រា VII នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងស្តីពីការវាយតម្លៃគយ ។

(ឃ) **ថ្លៃទំនិញដឹកជញ្ជូនមកដល់លើនាវា (FOB)** មានន័យថា ថ្លៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវាដែលរាប់បញ្ចូល ថ្លៃដឹកជញ្ជូនទំនិញទៅកំពង់ផែ ឬទីកន្លែងចុងក្រោយនៃការដឹកចេញទៅក្រៅប្រទេស។ ការវាយតម្លៃ គួរតែធ្វើឡើងដោយផ្អែកទៅលើមាត្រា ៧ នៃ GATT ១៩៩៤ និងកិច្ចព្រមព្រៀងការវាយតម្លៃគយ ។

(ង) **គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ** មានន័យថា ការទទួលស្គាល់ដោយមតិរួម ឬមានការគាំទ្រពីអាជ្ញាធរនៅក្នុងភាគី ដោយគោរពទៅតាមការកត់ត្រានៃចំណូល ចំណាយ ថ្លៃអចលនទ្រព្យបំណុល ការផ្សាយចេញពត៌មាន និងការរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុ។ ស្តង់ដាទាំងនេះអាច ជាការណែនាំទូលំទូលាយជុំវិញការអនុវត្តទូទៅ ក៏ដូចជា ការរ៉ាយរ៉ាប់លំអិតនៃស្តង់ដា ការអនុវត្ត និងនីតិវិធីផ្សេងៗ។

(ច) **ទំនិញ** មានន័យថា បណ្តាទំនិញ. ផលិតផល ឬវត្ថុធាតុដើម។

(ឆ) **វត្ថុធាតុដើមដែលមានលក្ខណៈដូច និងវត្ថុធាតុដើមដែលអាចផ្លាស់ប្តូរគ្នាបាន** មានន័យថា វត្ថុធាតុដើម ដែលអាចផ្លាស់ប្តូរគ្នាបាន ដែលជាលទ្ធផលនៃការធ្វើឡើងពីប្រភេទ និងគុណភាពពាណិជ្ជកម្មដូចគ្នា ដែលមានលក្ខណៈបច្ចេកទេស និងរូបរាងដូចគ្នា ហើយនៅពេលដែលត្រូវបានដាក់បញ្ចូលក្នុងផលិតផលសំរេច គេមិនអាចមើលឃើញភាពខុសគ្នាពីមួយទៅមួយផ្សេងទៀត សំរាប់គោលបំណងដើមកំណើត ដោយគុណធម៌ នៃផ្លាកសញ្ញា ឬគ្រាន់តែជាការត្រួតពិនិត្យដោយភ្នែក ។

(ជ) **វត្ថុធាតុដើមមិនចំពោះ** មានន័យថា ទំនិញដែលប្រើប្រាស់នៅក្នុងផលិតកម្ម ការសាកល្បង ឬការត្រួតពិនិត្យទំនិញ ប៉ុន្តែមិនមានរូបរាងចូលលាយជាមួយទំនិញ ឬទំនិញដែលប្រើប្រាស់ក្នុងការថែរក្សាអគារ ឬ ប្រតិបត្តិការនៃបរិក្ខារផលិត ដែលទាក់ទងទៅនឹងផលិតកម្មនៃទំនិញ ដែលរួមមាន :

(i) ប្រេងឥន្ធនៈ និងថាមពល

(ii) គ្រឿងប្រដាប់ប្រដា ពុម្ព និងចាក់ពុម្ព

(iii) គ្រឿងបន្លាស់ និងសម្ភារៈដែលប្រើក្នុងការរក្សាសម្ភារៈបរិក្ខារ និងអគារ

(iv) ប្រេងសំរាប់ដាក់គ្រឿងយន្ត ខ្លាញ់ វត្ថុធាតុផ្សំ និងសម្ភារៈផ្សេងៗទៀតដែលប្រើប្រាស់ក្នុងផលិតកម្ម ឬប្រើដើម្បីប្រតិបត្តិឧបករណ៍ ឬអគារ

(v) ស្រោមដៃ វ៉ែនតា ស្បែកជើង សម្លៀកបំពាក់ ឧបករណ៍សុវត្ថិភាព និងវត្ថុធាតុផ្គត់ផ្គង់ផ្សេងៗ

(vi) ឧបករណ៍ គ្រឿង និងវត្ថុធាតុផ្គត់ផ្គង់ ដែលប្រើប្រាស់សំរាប់ការសាកល្បង ឬការត្រួតពិនិត្យទំនិញ

(vii) សារធាតុដាក់បន្ថែមដើម្បីឱ្យឆាប់ទទួលប្រតិកម្មគីមី និងទឹកសំរាប់រំលាយ និង

(viii) រាល់ទំនិញផ្សេងៗដែលមិនបានលាយចូលគ្នាឱ្យទៅជាទំនិញ ប៉ុន្តែបានប្រើប្រាស់នៅក្នុងការផលិតទំនិញ ដែលអាចមានហេតុផលសមរម្យក្នុងការបង្ហាញថាជាផ្នែកមួយនៃការផលិត ។

(ឈ) **វត្ថុធាតុដើម** មានន័យថា រាល់រូបធាតុ ឬសារធាតុដែលប្រើប្រាស់ ឬប្រើប្រាស់ក្នុងការផលិតទំនិញ ឬ ដែលលាយចូលគ្នាមានរូបរាងទៅជាទំនិញ ឬជាប្រធានបទ ដើម្បីប្រើក្នុងការផលិតទំនិញផ្សេងៗទៀត ។

(ញ) **ទំនិញមិនមែនដើមកំណើត ឬ វត្ថុធាតុមិនមែនដើមកំណើត** មានន័យថា ទំនិញ ឬ វត្ថុធាតុដើម ដែលមិនបំពេញបានទៅតាមលក្ខខណ្ឌដើមកំណើត ដូចដែលមានចែងនៅក្នុងជំពូកនេះ ។

(ដ) **វត្ថុធាតុ ដើមកំណើត** មានន័យថា ទំនិញ ឬវត្ថុធាតុដើម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាដើមកំណើត ដូចមានចែងនៅក្នុងជំពូកនេះ ។

(ឋ) **អ្នកផលិត** មានន័យថា មនុស្សដែលដាំដុះ ជីករ៉ែ ចិញ្ចឹម ប្រមូលផល នេសាទ ដាក់អន្ទាក់ ឬអង្គប់ធ្វើស្រែចំការ បរបាញ់ បេះ ប្រមែប្រមូល ផលិត កែច្នៃ ឬតម្លើងទំនិញ ។

(ឌ) **ផលិតកម្ម** មានន័យថា វិធីសាស្ត្រនៃការធ្វើឱ្យបានជាទំនិញ ដែលរួមមាន ការដាំដុះ ការជីករ៉ែ ការច្រូតកាត់ ការចិញ្ចឹម ការបង្កាត់ពូជ ការចំរាញ់ចេញ ការប្រមូលផល ការចាប់ ការនេសាទ ការដាក់អន្ទាក់ ការបរបាញ់ ការផលិត ការកែឆ្នៃ ឬការតម្លើងទំនិញ ។

(ឍ) **វិធានផលិតផលជាក់លាក់** ជាវិធានដែលមាននៅក្នុងឧបសម្ព័ន្ធ ២ (វិធានផលិតផលជាក់លាក់) ដែលបង្ហាញថា វត្ថុធាតុដើមដែលប្រើដើម្បីផលិតទំនិញ បានទទួលរងនូវការកែប្រែចំណាត់ថ្នាក់ពន្ធគយ ឬការផលិតជាក់លាក់ ឬការប្រតិបត្តិកែច្នៃ ឬជាការបំពេញឱ្យលក្ខណៈវិនិច្ឆ័យនៃសមាសធាតុតម្លៃចំណុះតំបន់ ឬការបញ្ចូលគ្នានៃលក្ខណៈវិនិច្ឆ័យផ្សេងៗទៀត និង

(ណ) **ការវេចខ្ចប់វត្ថុធាតុដើម និងកេសសម្រាប់ការដឹកជញ្ជូន** មានន័យថា អីវ៉ាន់ដែលប្រើសម្រាប់ការពារទំនិញ ក្នុងកំឡុងពេលដឹកជញ្ជូន ដែលខុសគ្នាពីកេស ឬវត្ថុធាតុណាដែលបានប្រើប្រាស់សម្រាប់ការលក់រាយ ។

## មាត្រា ២
## ទំនិញដើមកំណើត

១. សម្រាប់គោលបំណងនៃជំពូកនេះ ទំនិញដែលអាចចាត់ទុកថាជា ទំនិញដើមកំណើត ប្រសិនបើមាន ៖

(ក) បានផលិតទាំងស្រុង ឬទទួលបានទាំងស្រុង នៅក្នុងភាគីដែលមានចែងនៅក្នុងមាត្រា ៣ (ទំនិញផលិតទាំងស្រុង ឬទទួលបានទាំងស្រុង)

(ខ) មិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង នៅក្នុងភាគី ដោយថាទំនិញបានបំពេញ ទៅនឹងតម្រូវការនៅក្នុងមាត្រា ៤ (ទំនិញមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង) ឬ

(គ) ផលិតទាំងស្រុងនៅក្នុងភាគី ដោយមិនគិតរួមចូលវត្ថុធាតុដើមកំណើតពីភាគីមួយ ឬច្រើននៃភាគីនានា និងបំពេញបានទៅនឹងរាល់ការទាមទារនៅក្នុងជំពូកនេះ ។

២. ទំនិញដែលបំពេញបានតាមតម្រូវការប្រភពដើមនៃកថាខ័ណ្ឌ១ នឹងរក្សាសិទ្ធិសំរាប់ការអនុគ្រោះពន្ធនាំចូល ប្រសិនបើបាននាំចេញទៅភាគីណាមួយ និងបន្តនាំចេញទៅបណ្តាភាគីណាមួយផ្សេងទៀត ។

## មាត្រា ៣
## ទំនិញផលិតទាំងស្រុង ឬទទួលបានទាំងស្រុង

គោលបំណងនៃមាត្រា ២.១(ក) (ទំនិញដើមកំណើត) ទំនិញខាងក្រោមនេះ គួរតែត្រូវបានពិចារណាថា បានផលិតទាំងស្រុង ឬទទួលបានទាំងស្រុង ៖

(ក) រុក្ខជាតិ និងទំនិញពីរុក្ខជាតិ រួមមាន ផ្លែឈើ ផ្កា បន្លែ ដើមឈើ រុក្ខជាតិតូចៗនៅក្នុងសមុទ្រ សារាយសមុទ្រ និងការដាំរុក្ខជាតិ ច្រូតកាត់ បេះ ឬប្រមូល នៅក្នុងភាគី[១]

[១] សម្រាប់គោលបំណងនៃមាត្រានេះ "នៅក្នុងភាគីមួយ" មានន័យថា ដែនដី ដែនសមុទ្រ តំបន់សេដ្ឋកិច្ចពិសេស ស្រទាប់ Continental Shelf ផុតពីតំបន់អធិបតេយ្យភាពនៃភាគីដែលមានសិទ្ធិគ្រប់គ្រង ឬ អំណាចគ្រប់គ្រង ក្នុងករណីដែលអាចមាន ដោយផ្អែកទៅលើច្បាប់អន្តរជាតិ ។

(ខ) សត្វរស់ដែលកើត និងចិញ្ចឹមនៅក្នុងភាគី

(គ) ទំនិញដែលបានមកពីសត្វរស់នៅក្នុងភាគី

(ឃ) ទំនិញដែលបានមកពី ការបរបាញ់ ការដាក់អន្ទាក់ ការនេសាទ ការចិញ្ចឹមវារីវប្បកម្ម ការប្រមូល និងការចាប់ ដែលបានធ្វើឡើងនៅក្នុងភាគី ។

(ង) រ៉ែ និងសារធាតុកើតឡើងដោយធម្មជាតិផ្សេងទៀត ដែលយកចេញពី ដី ទឹក បាតសមុទ្រ ឬ នៅក្រោមបាតសមុទ្រ នៅក្នុងភាគី ។

(ច) ទំនិញដែលបានមកពីការនេសាទសមុទ្រ និងបណ្តាទំនិញក្នុងសមុទ្រដទៃទៀត ដែលយកចេញពីសមុទ្រទឹកជ្រៅ ដោយយោងទៅលើច្បាប់អន្តរជាតិ[២] ដោយរាល់នាវាទាំងអស់ត្រូវចុះបញ្ជី ឬធ្វើការកត់ត្រានៅក្នុងភាគីណាមួយ និងដើម្បីទទួលបានសិទ្ធិលើកទង់ជាតិរបស់ភាគីនោះ ។

(ឆ) ទំនិញដែលផលិតនៅក្នុងបណ្តានាវា រោងចក្រ ត្រូវបានចុះបញ្ជី ឬបានកត់ត្រានៅក្នុងភាគី និងដើម្បីបានទទួលសិទ្ធិលើកទង់ជាតិរបស់ភាគីនោះ រួមទាំងទំនិញដែលមានចែងនៅក្នុងកថាខណ្ឌរង (ច)

(ជ) ទំនិញដែលយកចេញដោយភាគី ឬដោយបុគ្គលណាម្នាក់នៅក្នុងភាគី ពីសមុទ្រ ឬបាតសមុទ្រ ផុតពីតំបន់សេដ្ឋកិច្ចពិសេស និងជិតគ្នាទៅនឹងស្រទាប់ Continental Sell នៃភាគីនោះ និងផុតពីតំបន់ដែលភាគីទី៣ មានសិទ្ធិគ្រប់គ្រង ក្រោមការអនុញ្ញាតឱ្យសិទ្ធិធ្វើអាជីវកម្ម ដោយយោងទៅលើច្បាប់អន្តរជាតិ[៣] ។

(ឈ) ទំនិញដែលមាន :

(i) កំទិច និងកាកសំណល់ដែលបានមកពីផលិតកម្ម និងការប្រើប្រាស់នៅក្នុងភាគីបានកំណត់ថា ទំនិញនោះសមចំពោះតែការទាញយកនូវវត្ថុធាតុដើម ឬ

---

ដើម្បីចៀសវាងនូវការមន្ទិលសង្ស័យ ការកត់សំគាល់ដែលមាននៅក្នុងនិយមន័យខាងលើ គួរតែបកស្រាយឱ្យមានការទទួលស្គាល់ ឬទទួលយកដោយភាគីមួយ នូវការងារដែលពុំទាន់បានដោះស្រាយតាមសមុទ្រ និងការប្តឹងតវ៉ាដែលធ្វើឡើងដោយគ្រប់ភាគី មិនគួរមានការវិនិច្ឆ័យសម្រេចទុកជាមុននៃការប្តឹងតវ៉ានោះទេ ។

[២] ច្បាប់អន្តរជាតិ សំដៅច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ដូចជា អនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ

[៣] ច្បាប់អន្តរជាតិ សំដៅច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ដូចជា អនុសញ្ញាសហប្រជាជាតិ ស្តីពីច្បាប់នៃសមុទ្រ

(ii) ទំនិញប្រមែប្រមូលប្រើប្រាស់នៅក្នុងភាគី ដូចជា ទំនិញប្រើប្រាស់សម្រាប់តែការទាញយកនូវវត្ថុធាតុដើម និង

(ញ) ទំនិញផលិតទាំងស្រុង ឬទទួលបានទាំងស្រុង នៅក្នុងភាគីតែមួយគត់ តាំងតែពីផលិតផលដែលមានយោងនៅក្នុងខថាខណ្ឌរង (ក) ដល់ (ឈ) ឬធ្វើមកពីអ្វីមួយផ្សេងទៀត។

## មាត្រា ៤
## ទំនិញមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង

១. សម្រាប់គោលបំណងនៃមាត្រា ២.១ (ខ) (ទំនិញដើមកំណើត) លើកលែងតែទំនិញទាំងនោះ មាននៅក្នុងកថាខណ្ឌ ២ ទំនិញដែលគួរតែចាត់ទុកជាទំនិញដើមកំណើត ប្រសិនបើ :

(ក) ទំនិញដែលមានសមាធាតុតម្លៃចំណុះតំបន់មិនតិចជាង ៤0 ភាគរយ នៃ FOB ដែលគណនា ដោយប្រើរូបមន្ត ដូចដែលបានពិពណ៌នានៅក្នុងមាត្រា ៥ (ការគណនាសមាសធាតុតម្លៃតំបន់) និងដំណើរការចុងក្រោយនៃសង្វាក់ផលិតកម្ម ដែលបានធ្វើឡើងដោយភាគី ឬ

(ខ) គ្រប់វត្ថុធាតុដើមដែលមិនមែនដើមកំណើត ប្រើនៅក្នុងការផលិតទំនិញ បានទទួលរងនូវការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយក្នុងកំរិត ៤ ខ្ទង់ (ឧ. ការផ្លាស់ប្តូរទីតាំង) នៃប្រព័ន្ធស៊ីចង្វាក់គ្នាសម្រាប់កំណត់លេខកូដទំនិញនៅក្នុងភាគី។

២. យោងតាមកថាខណ្ឌ ១ (ក) ទំនិញដែលស្របទៅនឹងវិធាននៃផលិតផលជាក់លាក់ គួរត្រូវបានចាត់ទុកជាទំនិញដើមកំណើត ប្រសិនបើទំនិញទាំងនោះបំពេញបានទៅនឹងការទាមទារ នៃវិធានលើផលិតផលជាក់លាក់។

៣. សម្រាប់ទំនិញដែលមិនមានចែងនៅក្នុងឧបសម្ព័ន្ធ ២ (វិធានផលិតផលជាក់លាក់) ភាគីនីមួយៗ គួរតែអនុញ្ញាតឱ្យអ្នកផលិត ឬអ្នកនាំចេញទំនិញ ធ្វើការសម្រេចថា តើគួរប្រើកថាខណ្ឌ ១ (ក) ឬ (ខ) នៅពេលកំណត់ថាទំនិញនោះជាទំនិញដើមកំណើត។

៤. ប្រសិនបើទំនិញដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ២ (វិធានផលិតផលជាក់លាក់) និងទាក់ទងទៅនឹងបទប្បញ្ញត្តិនៃឧបសម្ព័ន្ធ២ (វិធានផលិតផលជាក់លាក់) បានផ្តល់នូវជម្រើសនៃវិធាន រវាងសមាសធាតុតម្លៃតំបន់ដោយផ្អែកលើវិធានដើមកំណើត ការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយផ្អែកលើវិធានដើមកំណើត ដំណើរការច្បាស់លាស់

នៃសង្វាក់ផលិតកម្ម ឬការបញ្ចូលគ្នាណាមួយនៃវិធានទាំងអស់ខាងលើ ភាគីមួយគួរតែអនុញ្ញាតឱ្យអ្នកផលិត ឬអ្នកនាំចេញទំនិញ ធ្វើការសម្រេចជ្រើសរើសយកវិធានណាមួយ ដើម្បីប្រើប្រាស់នៅក្នុងការកំណត់ថា តើទំនិញនោះមានដើមកំណើត ឬក៏អត់។

## មាត្រា ៥
## ការគណនាសមាសធាតុតម្លៃតំបន់

១. សម្រាប់គោលបំណងនៃមាត្រា ៤ (ទំនិញមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង) វិធីសាស្ត្រ សម្រាប់គណនាសមាសធាតុតម្លៃតំបន់ មានពីរប្រភេទ ដូចខាងក្រោម :

(ក) រូបមន្តផ្ទាល់ ឬវិធីបង្កើនតម្លៃ

$$\frac{\text{AANNZFTA Material Cost} + \text{Labour Cost} + \text{Overhead Cost} + \text{Profit} + \text{Other Cost}}{\text{FOB}} \times 100\%$$

ឬ

(ខ) រូបមន្តប្រយោល ឬវិធីបញ្ចុះតម្លៃ

$$\frac{\text{FOB - Value of Non-Originating Materials}}{\text{FOB}} \times 100\%$$

ក្នុងនោះ :

(ក) តម្លៃវត្ថុធាតុដើមនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ គឺជា តម្លៃវត្ថុធាតុដើមកំណើត ចំណែក ឬផលិតផលដែលទទួលបាន ឬផលិតខ្លួនឯងផ្ទាល់ នៅក្នុងផលិតកម្មទំនិញ

(ខ) ថ្លៃពលកម្ម រួមមាន ប្រាក់បៀវត្ស លាភការ និងផលប្រយោជន៍របស់និយោជិតផ្សេងៗទៀត

(គ) ថ្លៃចំណាយសរុប គឺជាប្រាក់សរុបលើការចំណាយផ្សេងៗទាំងអស់

(ឃ) ថ្លៃចំណាយផ្សេងៗ គឺជាថ្លៃដែលចំណាយ (ឬកើតឡើង) នៅក្នុងការទុកដាក់ទំនិញនៅក្នុងនាវា ឬមធ្យោបាយដឹកជញ្ជូនផ្សេងៗទៀត សម្រាប់នាំចេញ រាប់បញ្ចូលប៉ុន្តែមិនកំណត់ត្រឹម ថ្លៃដឹកជញ្ជូន

ក្នុងស្រុក ការរក្សាទុក ឬទុកដាក់ក្នុងឃ្លាំង ការប្រើប្រាស់កំពង់ផែ កំរៃជើងសា និងសេវាកម្មទទួលរ៉ាប់រង

(ង) FOB គឺជាថ្លៃទំនិញដែលដឹកជញ្ជូនមកដល់លើនាវា ដូចមានចែងនៅក្នុងនិយមន័យ នៃមាត្រា ១ (និយមន័យ) និង

(ច) តម្លៃវត្ថុធាតុមិនមែនដើមកំណើត គឺជាតម្លៃ CIF នៅពេលដែលនាំទំនិញចូល ឬតម្លៃបង់ពន្ធមុនដំបូងបង្អស់ សម្រាប់គ្រប់វត្ថុធាតុមិនមែនដើមកំណើត ចំណែក ឬផលិតដែលបានមកដោយផលិតករនៅក្នុងផលិតកម្មទំនិញ ។ វត្ថុធាតុដើមមិនមែនដើមកំណើត រួមមាន វត្ថុធាតុដែលមិនទាន់កំណត់ ជាប្រភពដើម ប៉ុន្តែមិនរាប់បញ្ចូលវត្ថុធាតុដើម ដែលផលិតដោយខ្លួនឯងផ្ទាល់នោះទេ ។

២. តម្លៃទំនិញនៅក្នុងជំពូកនេះ គួរតែកំណត់ដោយយោងទៅលើបទប្បញ្ញត្តិក្នុងមាត្រា VII នៃ GATT ១៩៩៤ និង កិច្ចព្រមព្រៀងការវាយតម្លៃគយ ។

## មាត្រា ៦
## វិធានដើមកំណើតបូកបន្ថែម

គោលដៅនៃមាត្រា ២ (ទំនិញដើមកំណើត) ទំនិញដែលបំពេញបាននូវតម្រូវការដើមកំណើត និងដែលបានប្រើប្រាស់នៅក្នុងភាគីផ្សេងៗទៀត ដូចជា វត្ថុធាតុដើមសម្រាប់ការផលិតទំនិញណាមួយផ្សេងទៀត គួរត្រូវបានពិចារណាថា ជាដើមកំណើតនៅក្នុងភាគីនោះ ដែលនៅទីនោះសង្វាក់ផលិតកម្ម នៃការផលិតទំនិញចុងក្រោយបានត្រូវធ្វើឡើង។

## មាត្រា ៧
## ប្រតិបត្តិការ និងដំណើរការអប្បបរមា

នៅពេលដែលមានការប្តឹងតវ៉ាសម្រាប់ដើមកំណើត គឺត្រូវតែយោងទៅលើសមាសធាតុតម្លៃចំណុះតំបន់ តែមួយគត់ ប្រតិបត្តិការ ឬសង្វាក់ផលិតកម្ម មានរៀបរាប់ដូចខាងក្រោម ធ្វើដោយខ្លួនគេផ្ទាល់ ឬធ្វើការបញ្ចូលគ្នាទៅវិញទៅមក គឺត្រូវបានពិចារណាជាអប្បបរមា និងមិនគួរគិតជាចរមានក្នុងការកំណត់ថា តើទំនិញនោះជាទំនិញដើមកំណើតឬ ក៏អត់។

(ក) ធ្វើឱ្យប្រាកដថា ការថែរក្សាការពារទំនិញនៅក្នុងលក្ខខណ្ឌមួយល្អប្រសើរ សម្រាប់គោលដៅនៃការដឹកជញ្ជូន ឬរក្សាទុក

(ខ) ជួយសំរួលដល់ការដឹកជញ្ជូន ឬនាំវា

(គ) ការវេចខ្ចប់[៤] ឬការបង្ហាញទំនិញ សម្រាប់ការដឹកជញ្ជូន ឬ សម្រាប់លក់

(ឃ) ការធ្វើដោយងាយស្រួល រួមមានការប្តូរទីកន្លែង ការចាត់ថ្នាក់ ការបោសសំអាត ការកាត់ ការរេះ ការបត់ ការមូរជារង្វង់ និងការពន្លា និងការប្រតិបត្តិការស្រដៀងគ្នាផ្សេងៗទៀត

(ង) ការបិទផ្លាកយីហោ ឬសញ្ញាសំគាល់ផ្សេងៗទៀត នៅលើផលិតផល ឬនៅលើកញ្ចប់របស់ពួកគេ និង

(ច) គ្រាន់តែលាយជាមួយទឹក ឬសារធាតុផ្សេងៗទៀត ដែលមិនធ្វើឱ្យមានការផ្លាស់ប្តូរលក្ខណៈពិតប្រាកដនៃទំនិញ ។

## មាត្រា ៨

## អប្បបរមា

១. ទំនិញដែលមិនបំពេញបានទៅនឹងការទាមទារ នៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ ទាក់ទងទៅនឹងមាត្រា ៤ (ទំនិញមិនផលិតទាំងស្រុង ឬមិនទទួលបានទាំងស្រុង) ទោះជាយ៉ាងណាក៏ដោយវាជាទំនិញដើមកំណើត ប្រសិនបើ :

(ក) (i) សម្រាប់ទំនិញដែលមាននៅក្នុងមាត្រា ៥០ ដល់មាត្រា ៦៣ នៃប្រព័ន្ធស៊ីចង្វាក់គ្នា សម្រាប់កំណត់លេខកូដទំនិញ តម្លៃនៃវត្ថុធាតុដែលមិនមែនដើមកំណើតទាំងអស់ដែលបានប្រើនៅក្នុងផលិតកម្មទំនិញ ដែលមិនបានទទួលរងនូវការទាមទារនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយមិនលើស ពី ១០ ភាគរយនៃទំនិញ

(ii) សម្រាប់ទំនិញដែលមាននៅក្នុងមាត្រា ៥០ ដល់មាត្រា ៦៣ នៃប្រព័ន្ធស៊ីចង្វាក់គ្នាសម្រាប់កំណត់លេខកូដទំនិញ ទម្ងន់នៃវត្ថុធាតុដែលមិនមែនដើមកំណើតទាំងអស់ ដែលប្រើនៅក្នុងផលិតកម្ម ដែលមិនបានទទួលរងនូវការទាមទារ នៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយមិនលើសពី ១០ ភាគរយនៃទម្ងន់សរុបនៃទំនិញ ឬតម្លៃវត្ថុធាតុដែលមិនមែនប្រភពដើម

---

[៤] នេះមិនរាប់បញ្ចូល encapsulation ដែលហៅថា "ការវេចខ្ចប់ " ដោយឧស្សាហកម្មអេឡិចត្រូនិច

ទាំងស្រុងដែលប្រើនៅក្នុងការផលិតទំនិញ ដែលមិនទទួលរងនូវការទាមទារនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយ មិនលើសពី ១០ ភាគរយនៃតម្លៃ FOB ចំពោះទំនិញ និង

(ខ) ទំនិញដែលបំពេញបានទៅនឹងលក្ខណៈវិនិច្ឆ័យដែលអាចអនុវត្តបាន (ឬដែលអាចធ្វើទៅបាន) នៃជំពូកនេះ ។

២. តម្លៃនៃវត្ថុធាតុដើម ទោះបីជាយ៉ាងណាក៏ដោយ ក៏ត្រូវរាប់បញ្ចូលទៅក្នុងតម្លៃនៃវត្ថុធាតុដែលមិនមែនដើមកំណើត សម្រាប់តម្រូវការអនុវត្ត សមាសធាតុតម្លៃចំណុះតំបន់ ។

## មាត្រា ៩
## របស់បន្ទាប់បន្សំ គ្រឿងបន្លាស់ និងឧបករណ៍

១. គោលដៅនៃការកំណត់ដើមកំណើតរបស់បន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងសម្ភារៈអប់រំ ឬការបង្ហាញពត៌មានវិទ្យាផ្សេងៗទៀតចំពោះទំនិញ គួរតែត្រូវពិចារណាថា ជាចំណែកនៃទំនិញនោះ និងមិនគួរធ្វេសប្រហែសនៅក្នុងការកំណត់ថា តើគ្រប់វត្ថុធាតុដែលមិនមែនដើមកំណើតបានប្រើនៅក្នុងផលិតកម្មនៃទំនិញដើមកំណើត ដែលបានទទួលរងនូវការអនុវត្តនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយឬក៏អត់ ដោយកំណត់ថា :

(ក) របស់បន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងសម្ភារៈ សម្រាប់អប់រំ ឬពត៌មានវិទ្យាផ្សេងៗទៀត ដែលបង្ហាញនៅក្នុងទំនិញ មិនត្រូវបានចេញវិក្កយបត្រដោយឡែក ពីទំនិញដើមកំណើត និង

(ខ) បរិមាណ និងតម្លៃ របស់បន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងសម្ភារៈ សម្រាប់អប់រំ ឬពត៌មានវិទ្យាផ្សេងៗទៀត ដែលមាននៅក្នុងទំនិញ គឺជាទម្លាប់នៃទំនិញ ។

២. ថ្វីបើមានកថាខណ្ឌ ១ ប្រសិនទំនិញជាប្រធានបទនៃការទាមទារសមាសធាតុតម្លៃចំណុះតំបន់ តម្លៃនៃរបស់បន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និងសម្ភារៈសម្រាប់អប់រំ ឬពត៌មានវិទ្យាផ្សេងៗទៀត ដែលមានវត្តមាននៅក្នុងទំនិញ គួរតែគិតគូរជាវត្ថុធាតុដើមកំណើត ឬមិនមែនដើមកំណើត ប្រសិនបើអាចជាករណីនេះ នៅក្នុងការគណនាសមាសធាតុតម្លៃចំណុះតំបន់នៃទំនិញ ។

៣. កថាខណ្ឌ ១ និង ២ មិនអាចបំពេញបានទេ កាលបើរបស់បន្ទាប់បន្សំ គ្រឿងបន្លាស់ ឧបករណ៍ និង សម្ភារៈសម្រាប់អប់រំ ឬពត៌មានវិទ្យាផ្សេងៗទៀត ដែលមានវត្តមាននៅក្នុងទំនិញត្រូវបានបន្ថែមតែមួយគត់ ដើម្បីធ្វើក្លែង

ក្លាយ នូវសមាសធាតុតម្លៃចំណុះតំបន់នៃទំនិញ ដោយផ្តល់ជាការបង្ហាញភស្តុតាងជាបន្តបន្ទាប់ ដោយភាគីនាំចូល ដែលពួកគេ មិនមែនជាអ្នកលក់នោះ ។

## មាត្រា ១០

## វត្ថុធាតុដែលមានលក្ខណៈដូច និងវត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបាន

ការកំណត់ថាតើវត្ថុធាតុនោះ ជាវត្ថុធាតុដែលមានលក្ខណៈដូចនឹងវត្ថុធាតុដែលអាចផ្លាស់ប្តូរគ្នាបាន ជាវត្ថុធាតុដើមកំណើត គួរត្រូវធ្វើឡើងដោយសរីរាង្គវិយោគកម្មនៃវត្ថុធាតុដើមនីមួយៗ ឬដោយប្រើគោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ ដើម្បីរក្សាទុកធ្វើការត្រួតពិនិត្យការប្រតិបត្តិ ឬការអនុវត្ត ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌរបស់ភាគីនាំចេញ ។

## មាត្រា ១១

## ការកំណត់បែបបទវេចខ្ចប់វត្ថុធាតុ និងភាជនៈសម្រាប់ដាក់អីវ៉ាន់

១. ការវេចខ្ចប់វត្ថុធាតុ និងភាជនៈដាក់អីវ៉ាន់ សម្រាប់ការដឹកជញ្ជូនទំនិញ មិនគួរគិតក្នុងការកំណត់ដើមកំណើតនៃទំនិញនោះទេ ។

២. ការវេចខ្ចប់វត្ថុធាតុ និងភាជនៈ សម្រាប់ដាក់អីវ៉ាន់ ចំពោះទំនិញដែលខ្ចប់សម្រាប់លក់រាយ នៅពេលដែលចាត់ចំណាត់រួមគ្នាជាមួយគ្នា និងទំនិញទាំងនោះ មិនត្រូវចាត់ទុកក្នុងការកំណត់ថា តើចំពោះគ្រប់វត្ថុធាតុ ដែលមិនមែនដើមកំណើត ប្រើនៅក្នុងផលិតកម្មទំនិញ បំពេញបានទៅនឹងការអនុវត្តនូវតម្រូវការនៃការផ្លាស់ប្តូរចំណាត់ថ្នាក់ពន្ធគយចំពោះទំនិញនោះ ឬក៏អត់ ។

៣. ប្រសិនបើទំនិញជាប្រធានបទនៃតម្រូវការសមាសធាតុតម្លៃចំណុះតំបន់ តម្លៃវេចខ្ចប់វត្ថុធាតុដើម និងភាជនៈសម្រាប់ដាក់អីវ៉ាន់ពេលដែលខ្ចប់ទំនិញសម្រាប់លក់រាយ ដោយគិតជាដើមកំណើត ឬវត្ថុធាតុមិនមែនដើមកំណើត ក្នុងករណីបែបនេះ ត្រូវគណនាសមាសធាតុតម្លៃតំបន់ ចំពោះទំនិញ ។

## មាត្រា ១២

## វត្ថុធាតុមិនផ្ទាល់

វត្ថុធាតុមិនផ្ទាល់ គួរតែកំណត់ជាវត្ថុធាតុដើមកំណើត ដោយមិនទាក់ទងទៅនឹងទីកន្លែងដែលផលិត និងតម្លៃរបស់ទំនិញទាំងនោះ វាគួរតែជាថ្លៃសម្រាប់ចុះបញ្ជីនៅក្នុងការកត់ត្រាគណនេយ្យ របស់អ្នកផលិតទំនិញ ។

## មាត្រា ១៣

## ការកត់ត្រាថ្លៃដើម

សម្រាប់គោលដៅនៅក្នុងជំពូកនេះ ថ្លៃដើមទាំងអស់គួរតែកត់ត្រា និងរក្សាទុក ដោយផ្អែកទៅលើការអនុវត្ត គោលការណ៍គណនេយ្យទទួលស្គាល់ទូទៅ នៅក្នុងភាគី ដែលទំនិញត្រូវបានផលិត ។

## មាត្រា ១៤

## ការបញ្ជូនទំនិញដោយផ្ទាល់

ទំនិញដែលនឹងរក្សាឋានៈជាដើមកំណើត ដូចដែលបានកំណត់នៅក្នុងមាត្រា ២ (ទំនិញដើមកំណើត) ប្រសិនបើបានបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ ៖

(ក) ទំនិញត្រូវបានដឹកជញ្ជូនទៅភាគីនាំចូល ដោយមិនឆ្លងកាត់ភាគីដែលមិនមែនជាដៃគូ ឬ

(ខ) ទំនិញដែលដឹកឆ្លងកាត់តាមប្រទេសដែលមិនមែនជាភាគីដៃគូ ដោយកំណត់ថា ៖

(i) ទំនិញមិនបានទទួលរងនូវការផលិតបន្ត ឬរាល់ការប្រតិបត្តិការផ្សេងៗទៀត ក្រៅពីដែនដីនៃភាគីដោយគ្រាន់តែលើកចេញ ដាក់ចូល រក្សាទុក ឬរាល់ប្រតិបត្តិការផ្សេងៗទៀត ក្នុងការចាំបាច់ ដើម្បីថែរក្សាទុកនៅក្នុងលក្ខខណ្ឌដ៏ល្អ ឬដើម្បីដឹកជញ្ជូនទំនិញទាំងនោះ ទៅភាគីនាំចូល ។

(ii) ទំនិញមិនបានចូលទៅក្នុងការលក់ដូរនៃប្រទេសមិនមែនភាគីជាដៃគូ និង

(iii) ការឆ្លងកាត់ផ្លូវចូល គឺបានបង្ហាញភស្តុតាងតាមរយៈហេតុផលភូមិសាស្ត្រសេដ្ឋកិច្ចហេតុផលផ្សេងៗនៃវិជ្ជាដឹកនាំ។

## មាត្រា ១៥

## វិញ្ញាបនបត្រដើមកំណើត

ការទាមទារចំពោះទំនិញ ដែលមានសិទ្ធិទទួលបាននូវប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល គួរតែផ្តល់ឱ្យនូវវិញ្ញាបនបត្រដើមកំណើតទំនិញដែលចេញដោយអាជ្ញាធរ ព្រមទាំងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីមួយផ្សេងទៀត ដូចដែលបានចែងក្នុងជំពូកនៃឧបសម្ព័ន្ធ១ ស្តីពីនីតិវិធីប្រតិបត្តិវិញ្ញាបនបត្រ ។

## មាត្រា ១៦
## ការបដិសេធ ការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ

អាជ្ញាធរគយនៃភាគីនាំចូល អាចបដិសេធការទាមទារសម្រាប់ការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ នៅពេលដែល :

(ក) ទំនិញមិនមានលក្ខណៈគ្រប់គ្រាន់ជាទំនិញដើមកំណើត ឬ

(ខ) អ្នកនាំចេញ នាំចូល ឬ ផលិតករ មិនបានប្រតិបត្តិតាម នូវរាល់ការទាមទារនៃជំពូកនេះ

## មាត្រា ១៧
## ការពិនិត្យឡើងវិញ និងការអំពាវនាវ

ភាគីនាំចូលគួរតែផ្តល់សិទ្ធិនៃការអំពាវនាវ ក្នុងបញ្ហាទាក់ទងទៅនឹងសិទ្ធិ សម្រាប់ទទួលបាននូវប្រព្រឹត្តិកម្មពិសេសនៃការអនុគ្រោះពន្ធនាំចូលចំពោះ ផលិតករ អ្នកនាំចេញ ឬអ្នកនាំចូល ដែលធ្វើការលក់ដូរទំនិញ ឬធ្វើពាណិជ្ជកម្មរវាងភាគី ដោយផ្អែកលើច្បាប់ក្នុងស្រុក ការអនុវត្តត្រឹមត្រូវតាមច្បាប់ និងកិច្ចសហប្រតិបត្តិការរដ្ឋបាល ។

## មាត្រា ១៨
## អនុគណៈកម្មការស្តីពីវិធានដើមកំណើត

១. សម្រាប់គោលបំណងនៃការអនុវត្តឱ្យមានប្រសិទ្ធភាពនៅក្នុងជំពូកនេះ ភាគីនីមួយៗត្រូវបង្កើតអនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត (អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត)។ មុខងាររបស់អនុគណៈកម្មាធិការនេះ រួមមាន :

(ក) ត្រួតពិនិត្យការអនុវត្ត និងការគ្រប់គ្រង នៅក្នុងជំពូកនេះ

(ខ) ធ្វើការពិភាក្សារាល់បញ្ហាដែលអាចមានការកើតឡើង នៅក្នុងខណៈដែលកំពុងអនុវត្ត រួមបញ្ចូលរាល់បញ្ហា ដែលអាចបញ្ជូនទៅអនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត ដោយគណៈកម្មាធិការ

ទំនិញដែលបានបង្កើតឡើងទាក់ទងទៅនឹងមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ) ឬគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី

(គ) ពិភាក្សារាល់ការកែប្រែ នៃវិធានដើមកំណើត នៅក្នុងជំពូកនេះ, និង

(ឃ) សុំយោបល់ លើបញ្ហាទាក់ទងនឹងដើមកំណើត និងកិច្ចសហប្រតិបត្តិការរដ្ឋបាល

២. អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត គួរតែបញ្ចូលតំណាងនៃភាគីនីមួយៗ ដែលភាគីនីមួយៗ គួរតែជួបគ្នានៅពេលណាមួយ ដើម្បីធ្វើការសម្រេចទៅវិញទៅមក ។

៣. អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត គួរតែចាប់ផ្តើមពិនិត្យឡើងវិញនៃមាត្រា ៦ (វិធានដើមកំណើតបូកបន្ថែម) មិនលឿនជាង ១២ ខែ និងមិនយឺតជាង ១៨ ខែ នៅពេលដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមាន។ ការពិនិត្យឡើងវិញ និងពិចារណាការដុះដាលនៃការអនុវត្តលើការរីកចំរើននៃតម្លៃបន្ថែមរបស់ទំនិញនៅក្នុងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់។ អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត ត្រូវផ្តល់ជូនគណៈកម្មាធិការទំនិញ ដែលបង្កើតឡើងទាក់ទងទៅនឹងមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ) នូវរបាយការណ៍ចុងក្រោយ រួមទាំងអនុសាសន៍ផ្សេងៗទៀត នៅក្នុងរយៈពេល ៣ ឆ្នាំ នៅពេលដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមាន ។

៤. អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត គួរតែចាប់ផ្តើមពិនិត្យឡើងវិញនូវការអនុវត្តវិធានប្រតិកម្មគីមី និងការប្រើវិធានគីមីផ្សេងៗទៀត ក្នុងជំពូក ២៨-៤០ នៃប្រព័ន្ធស៊ីចង្វាក់គ្នា សម្រាប់កំណត់លេខកូដទំនិញ និងវិធានលើផលិតផលជាក់លាក់ផ្សេងៗទៀត ដែលទទួលស្គាល់ដោយភាគីនីមួយៗ មិនលឿនជាង ១២ ខែ និង មិនយឺតជាង ១៨ ខែ តាមដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមាន ។ អនុគណៈកម្មាធិការស្តីពីវិធានដើមកំណើត ត្រូវផ្តល់ជូនគណៈកម្មាធិការពាណិជ្ជកម្មទំនិញ ដែលបានបង្កើតឡើងទាក់ទងនឹងមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ) នូវរបាយការណ៍ការចុងក្រោយ រួមទាំងរាល់អនុសាសន៍ផ្សេងៗទៀត នៅក្នុងរយៈពេល ៣ ឆ្នាំ ពេលដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមាន ។

## មាត្រា ១៩
## ការពិគ្រោះ ការពិនិត្យឡើងវិញ និងការកែសម្រួល

១. ភាគីនីមួយៗគួរតែធ្វើការពិគ្រោះគ្នាដោយទៀងទាត់ ដើម្បីធានាថានៅក្នុងជំពូកនេះ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពមានលក្ខណៈជាឯកសណ្ឋានហើយស៊ីសង្វាក់គ្នា ដើម្បីសំរេចបាននូវស្មារតីនៃការគ្រប់គ្រង ដើម្បីគោលបំណងនៃកិច្ចព្រមព្រៀង ។

២. ជំពូកនេះ អាចធ្វើការពិនិត្យឡើងវិញ និងអាចធ្វើការកែសម្រួល ដោយផ្អែកលើមាត្រា ៦ (វិសោធនីកម្ម) នៃជំពូក ១៨ (អវសានបញ្ញត្តិ) នៅពេលដែលមានការចាំបាច់ ការស្នើសុំរបស់ភាគី និងដែលជាប្រធានបទនៃការព្រមព្រៀងដោយបណ្តាភាគី និងអាចធ្វើការពិនិត្យឡើងវិញ និងធ្វើការកែសម្រួល ដូចដែលអាចព្រមព្រៀងដោយគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី ។

# ឧបសម្ព័ន្ធ ស្តីពីនីតិវិធីប្រតិបត្តិវិញ្ញាបនបត្រដើមកំណើត

សម្រាប់គោលបំណងនៃការអនុវត្តជំពូក ៣ (វិធានដើមកំណើត) នីតិវិធីប្រតិបត្តិខាងក្រោមស្តីពីការចេញ និង បញ្ជាក់វិញ្ញាបនបត្រដើមកំណើត និងកិច្ចការរដ្ឋបាលពាក់ព័ន្ធត្រូវតែប្រតិបត្តិតាមដោយភាគីនីមួយៗ។

## អាជ្ញាធរ

### វិធាន ១

វិញ្ញាបនបត្រដើមកំណើត ត្រូវចេញដោយអាជ្ញាធរ/ស្ថាប័ននៃភាគីនាំចេញ។ ពត៌មានលំអិតពីអាជ្ញាធរ/ស្ថាប័ន ត្រូវតែជូនពត៌មានដោយភាគីនីមួយៗ តាមរយៈលេខាធិការដ្ឋានអាស៊ានឱ្យបានមុនការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ។ រាល់ការកែប្រែជាបន្តបន្ទាប់ណាមួយ ត្រូវប្រញាប់ជូនពត៌មានដោយភាគីនីមួយៗ តាមរយៈលេខាធិការដ្ឋានអាស៊ាន។

### វិធាន ២

១. អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវផ្តល់ឈ្មោះ អាសយដ្ឋាន ហត្ថលេខាសង្ខេប ហត្ថលេខា និង គំរូពុម្ពត្រាផ្លូវការរបស់អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ទៅបណ្តាភាគីដទៃ តាមរយៈលេខាធិការដ្ឋានអាស៊ាន។ អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវផ្តល់ជាអេឡិចត្រូនិចទៅលេខាធិការដ្ឋានអាស៊ាននូវពត៌មានខាងលើ និងគំរូ សំរាប់ចែកចាយទៅបណ្តាភាគីដទៃទៀត។ រាល់ការកែប្រែត្រូវប្រញាប់ជូនពត៌មានតាមរយៈលេខាធិការដ្ឋានអាស៊ាន។

២. រាល់វិញ្ញាបនបត្រដើមកំណើតទំនិញ ចេញដោយបុគ្គលដែលមិនមាននៅក្នុងបញ្ជី អាចនឹងមិនទទួលស្គាល់ដោយអាជ្ញាធរគយនៃប្រទេសនាំចូល។

### វិធាន ៣

សម្រាប់គោលបំណងក្នុងការកំណត់ដើមកំណើតទំនិញ អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវមានសិទ្ធិក្នុងការហៅរក ឯកសារភស្តុតាងសំរាប់គាំទ្រ និង/ឬ ពត៌មានពាក់ព័ន្ធដទៃទៀត ដើម្បីដំណើរការការត្រួតពិនិត្យណាមួយដែលពិចារណា ថាសមរម្យ ដោយអនុលោមទៅតាមច្បាប់ បទបញ្ញត្តិក្នុងស្រុក និងកិច្ចការជាក់ស្តែង។

## ផែបបទ

## វិធាន ៤

១. សហគ្រិន អ្នកផលិត ឬ អ្នកនាំចេញទំនិញ ឬ តំណាងដែលផ្តល់សិទ្ធិ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរ ឬ ដោយមធ្យោបាយអេឡិចត្រូនិច ទៅអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ អនុលោមទៅតាមច្បាប់ បទបញ្ញត្តិ និងនីតិវិធីអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រក្នុងស្រុករបស់ភាគីនាំចេញ ស្នើសុំឱ្យមានការពិនិត្យមុននាំចេញនូវដើមទំនិញសំរាប់នាំចេញ។

២. លទ្ធផលនៃការពិនិត្យ ត្រូវតែរំលឹកឡើងវិញតាមពេលកំណត់ ឬ នៅពេលដែលសមរម្យត្រូវតែទទួលយកជាភស្តុតាងគាំទ្រក្នុងការចេញវិញ្ញាបនបត្រដើមកំណើតចំពោះទំនិញ ដែលត្រូវនាំចេញបន្ទាប់ពីនោះ។

៣. ការត្រួតពិនិត្យមុននាំចេញ មិនចាំបាច់ក្នុងការអនុវត្តចំពោះទំនិញដែលជាលក្ខណៈធម្មជាតិ ដើមកំណើតមានលក្ខណៈងាយស្រួលក្នុងការកំណត់។

## វិធាន ៥

សហគ្រិន អ្នកផលិត ឬ អ្នកនាំចេញទំនិញ ឬ តំណាងដែលផ្តល់សិទ្ធិ អាចស្នើសុំវិញ្ញាបនបត្រដើមកំណើត តាមការផ្តល់ឯកសារគាំទ្រសមរម្យ និងពត៌មានពាក់ព័ន្ធដទៃទៀត ដែលផ្តល់ថាទំនិញដែលត្រូវនាំចេញនោះគ្រប់លក្ខណៈជាដើមកំណើត។

## ការត្រួតពិនិត្យមុនពេលនាំចេញ

## វិធាន ៦

អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវខិតខំទៅតាមសមត្ថភាព និងលទ្ធភាព ធ្វើការត្រួតពិនិត្យឱ្យបានត្រឹមត្រូវអនុលោមតាមច្បាប់ និងបទបញ្ញត្តិក្នុងស្រុករបស់ភាគីនាំចេញ ឬនីតិវិធីរបស់អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ នៅពេលដែលបែបបទនីមួយៗ សំរាប់វិញ្ញាបនបត្រដើមកំណើតដោយធានាថា :

(i) បែបបទ និង វិញ្ញាបនបត្រ ត្រូវបំពេញឱ្យគ្រប់ និង ចុះហត្ថលេខាដោយហត្ថលេខីដែលផ្តល់សិទ្ធិ។

(ii) ទំនិញដែលមានដើមកំណើត អនុលោមទៅតាមមាត្រា ២ ( ដើមកំណើតទំនិញ) នៃជំពូក ៣ (វិធានដើមកំណើត) ។

(iii) សេចក្តីថ្លែងការណ៍ផ្សេងៗ នៅក្នុងវិញ្ញាបនបត្រដើមកំណើត ស៊ីគ្នាទៅនឹងឯកសារគាំទ្រ និងពត៌មានពាក់ព័ន្ធផ្សេងដទៃទៀត និង

(iv) ពត៌មានពីតំរូវការទិន្នន័យអប្បបរមា មានរៀបរាប់នៅក្នុងសេចក្តីបន្ថែម ១ (តំរូវការទិន្នន័យអប្បបរមា-ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត) ដែលបានផ្តល់សម្រាប់ទំនិញដែលនាំចេញ ។

## ការចេញវិញ្ញាបនបត្រដើមកំណើត
## វិធាន ៧

១. គំរូវិញ្ញាបនបត្រដើមកំណើត ត្រូវកំណត់ដោយបណ្តាភាគី និងត្រូវមានតម្រូវការទិន្នន័យអប្បបរមា ដែលមានរៀបរាប់នៅក្នុងសេចក្តីបន្ថែម ២ ( តម្រូវការទិន្នន័យអប្បបរមា-វិញ្ញាបនបត្រដើមកំណើត) ។

២. វិញ្ញាបនបត្រដើមកំណើត ត្រូវមានច្បាប់ដើមមួយ និងច្បាប់ចំលងពីរ

៣. វិញ្ញាបនបត្រដើមកំណើតត្រូវ :

(i) ជាក្រដាស

(ii) មានចុះលេខដោយឡែក ដែលផ្តល់ដោយទីកន្លែងណាមួយ នៃការិយាល័យចេញវិញ្ញាបនបត្រ

(iii) ជាភាសាអង់គ្លេស និង

(iv) មានហត្ថលេខាដែលមានសិទ្ធិ និងត្រាផ្លូវការ របស់អាជ្ញាធរ/ស្ថាប័ន ចេញវិញ្ញាបនបត្រ ។ ហត្ថលេខា និងត្រាផ្លូវការ អាចអនុវត្តតាមអេឡិចត្រូនិច ។

៤. វិញ្ញាបនប័ត្រដើមកំណើត ត្រូវបញ្ជូនដោយអ្នកនាំចេញទៅអ្នកនាំចូល ដើម្បីផ្តល់ទៅអាជ្ញាធរគយ នៃភាគីនាំចូល ។ ច្បាប់ចំលងត្រូវរក្សាដោយអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ និងអ្នកនាំចេញ ។

៥. ទំនិញច្រើនប្រភេទអាចប្រកាសលើវិញ្ញាបនបត្រតែមួយ ត្រូវតែអនុញ្ញាតដោយផ្តល់ថា ទំនិញនីមួយៗ ជាទំនិញមានដើមកំណើតទៅតាមសិទ្ធិរបស់វា ។

## វិធាន ៨

ដើម្បីអនុវត្តមាត្រា២ (ទំនិញដើមកំណើត) នៃជំពូក៣ (វិធានដើមកំណើត) វិញ្ញាបនបត្រដើមកំណើតទំនិញដែលបានចេញដោយអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវតែមានបញ្ជាក់លក្ខខណ្ឌដើមកំណើតទំនិញពាក់ព័ន្ធ។

## វិធាន ៩

ទាំងការលុប និងការដាក់ខុសទីតាំង ត្រូវបានអនុញ្ញាតលើវិញ្ញាបនបត្រដើមកំណើត។ ការផ្លាស់ប្តូរត្រូវតែធ្វើការឆូតចោលកន្លែងខុស និងធ្វើការបន្ថែមណាមួយតាមតម្រូវ។ ការផ្លាស់ប្តូរ ត្រូវតែយល់ព្រមដោយបុគ្គលដែលបានផ្តល់សិទ្ធិក្នុងការចុះហត្ថលេខាវិញ្ញាបនបត្រដើមកំណើត និងបញ្ជាក់ដោយអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ។ ចន្លោះដែលមិនបានប្រើ ត្រូវឆូតចេញដើម្បីការពារការបន្ថែមបន្តបន្ទាប់។

## វិធាន ១០

១. វិញ្ញាបនបត្រដើមកំណើត ត្រូវចេញឱ្យបានឆាប់តាមដែលអាចធ្វើបាន ប៉ុន្តែមិនឱ្យយឺតជាងបីថ្ងៃ នៃម៉ោងធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនាំចេញ។

២. ពេលដែលវិញ្ញាបនបត្រមិនទាន់ត្រូវបានចេញ ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ១ ដោយមូលហេតុ កំហុសអចេតនា ឬ បាត់ ឬ មូលហេតុត្រឹមត្រូវដទៃទៀត វិញ្ញាបនបត្រថ្មីអាចនឹងត្រូវចេញជាប្រតិសកម្ម ប៉ុន្តែមិនឱ្យយូរជាង ១២ ខែ ពីកាលបរិច្ឆេទនៃការនាំចេញដោយបញ្ជាក់ពាក្យ "ចេញជាប្រតិសកម្ម"។

៣. អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីកណ្តាល ត្រូវចេញវិញ្ញាបនបត្រដើមកំណើតបន្ត (back-to-back) ប្រសិនបើបែបបទដែលបានធ្វើដោយអ្នកនាំចេញពេលដែលទំនិញឆ្លងកាត់ភាគីកណ្តាលនោះ ដោយផ្តល់ថា :

(i) វិញ្ញាបនបត្រដើមកំណើតដើមដែលមានសុពលភាព ឬ ដែលមានបញ្ជាក់ច្បាប់ចំលងពិតត្រូវបង្ហាញ។

(ii) រយៈពេលសុពលភាពនៃវិញ្ញាបនបត្របន្ត មិនត្រូវហួសរយៈពេលសុពលភាពនៃវិញ្ញាបនបត្រដើមកំណើតដើម។

(iii) ការបញ្ជូនទំនិញដែលត្រូវនាំចេញបន្តដោយប្រើវិញ្ញាបនបត្រដើមកំណើតបន្ត មិនត្រូវឆ្លងកាត់ការកែច្នៃនៅក្នុងភាគីកណ្តាល លើកលែងតែវេចខ្ចប់ឡើងវិញ ឬសកម្មភាពដឹកជញ្ជូន លើកចេញ ដាក់ចូល រក្សាក្នុងឃ្លាំង ឬ ប្រតិបត្តិការផ្សេងៗដែលចាំបាច់ ក្នុងការរក្សាទុកទំនិញឱ្យស្ថិតនៅក្នុងលក្ខខណ្ឌល្អ ឬ សំរាប់ដឹកជញ្ជូនទៅភាគីនាំចូល ។

(iv) វិញ្ញាបនបត្រដើមកំណើតបន្ត រួមមានពត៌មានពាក់ព័ន្ធពីវិញ្ញាបនបត្រដើមកំណើតដើម អនុលោមទៅតាមតំរូវការទិន្នន័យអប្បបរមាក្នុងសេចក្តីបន្ថែម ២ (តំរូវការទិន្នន័យអប្បបរមា-វិញ្ញាបនបត្រដើមកំណើត) ។ តម្លៃ FOB ជាតម្លៃ FOB នៃទំនិញ ដែលនាំចេញពីភាគីកណ្តាល. និង

(v) នីតិវិធីការពិនិត្យបញ្ជាក់នៃវិធាន១៧ និងវិធាន១៨ ត្រូវអនុវត្តចំពោះវិញ្ញាបនបត្រដើមកំណើតបន្ត ។

## វិធាន ១១

នៅក្នុងហេតុការណ៍ដែលវិញ្ញាបនបត្រដើមកំណើតត្រូវ ចោរកម្ម បាត់បង់ ឬ វិនាសកម្ម សហគ្រិន អ្នកផលិត អ្នកនាំចេញ ឬ តំណាងដែលផ្តល់សិទ្ធិ អាចស្នើសុំទៅអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រឱ្យបញ្ជាក់ច្បាប់ចំលងពិត លើវិញ្ញាបនបត្រដើមកំណើតដើម ។ ច្បាប់ចំលងត្រូវតែធ្វើលើមូលដ្ឋានឯកសារនាំចេញ ដែលមានពាក្យ "CERTIFIED TRUE COPY" ។ ច្បាប់ចំលងនេះ ត្រូវចុះកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើតដើម ។ វិញ្ញាបនបត្រដើមកំណើតបញ្ជាក់ច្បាប់ចំលងពិត ត្រូវចេញមិនឱ្យលើសពី ១២ ខែ ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រដើមកំណើតដើម ។

## ការបង្ហាញ

## វិធាន ១២

១. សម្រាប់គោលបំណងនៃការទាមទារប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល អ្នកនាំចូលត្រូវផ្តល់ទៅអាជ្ញាធរគយ នៅពេលដែលប្រកាសនាំចូលវិញ្ញាបនបត្រដើមកំណើត និងឯកសារផ្សេងដទៃទៀតដូចដែលតម្រូវ អនុលោមទៅតាមនីតិវិធីអាជ្ញាធរគយ ឬ ច្បាប់ និង បទបញ្ញត្តិក្នុងស្រុករបស់ភាគីនាំចូល ។

២. ថ្វីបើមានចែងនៅក្នុងកថាខណ្ឌ ១ ភាគីមួយអាចជ្រើសរើសការមិនតម្រូវឱ្យផ្តល់វិញ្ញាបនបត្រដើមកំណើត ។

## វិធាន ១៣

ពេលវេលាខាងក្រោមសំរាប់ការបង្ហាញវិញ្ញាបនបត្រដើមកំណើតត្រូវប្រតិបត្តិតាម :

(i) វិញ្ញាបនបត្រដើមកំណើត ត្រូវមានសុពលភាពរយៈពេល ១២ ខែ គិតពីកាលបរិច្ឆេទនៃការចេញ និងត្រូវផ្តល់ទៅអាជ្ញាធរគយរបស់ភាគីនាំចូលក្នុងកំឡុងពេលនោះ ។

(ii) ពេលដែលវិញ្ញាបនបត្រដើមកំណើតត្រូវបានផ្តល់ទៅអាជ្ញាធរគយនៃភាគីនាំចូល បន្ទាប់ពីផុតកាលបរិច្ឆេទកំណត់ វិញ្ញាបនបត្រដើមកំណើតនោះនឹងត្រូវតែទទួលស្គាល់ ផ្អែកតាមច្បាប់ និងបទបញ្ញត្តិក្នុងស្រុក ឬរដ្ឋបាលអនុវត្តរបស់ភាគីនាំចូល នៅពេលដែលមិនបានបំពេញតាមកាលបរិច្ឆេទប្រតិបត្តិដែលជាលទ្ធផលមកពីករណី *ប្រធានសក្តិ (forces majeure)* ឬ មូលហេតុដទៃទៀត ដែលកើតឡើងក្រោយការត្រួតពិនិត្យរបស់អ្នកនាំចូល និង/ឬ អ្នកនាំចេញ, និង

(iii) អាជ្ញាធរគយនៃភាគីនាំចូល អាចទទួលស្គាល់វិញ្ញាបនបត្រដើមកំណើតនោះ ដោយហេតុថា ទំនិញបាននាំចូលមុនពេលផុតកាលបរិច្ឆេទកំណត់នៃវិញ្ញាបនបត្រដើមកំណើតនោះ ។

## វិធាន ១៤

វិញ្ញាបនបត្រដើមកំណើតមិនតម្រូវចំពោះ :

(i) ទំនិញមានដើមកំណើតនៅក្នុងភាគីនាំចេញ និងមានតម្លៃ FOB មិនលើស ២០០.០០ ដុល្លាអាមេរិក ឬ មានតម្លៃលើសពីអ្វីដែលមានចែងនៅក្នុងច្បាប់ និង បទបញ្ញត្តិក្នុងស្រុក ឬ រដ្ឋបាលអនុវត្ត ឬ

(ii) ទំនិញដែលផ្ញើតាមប្រៃសណីយ៍មានតម្លៃ FOB មិនលើស ២០០.០០ ដុល្លាអាមេរិក ឬ មានតម្លៃលើសពីអ្វីដែលមានចែងនៅក្នុងច្បាប់ និង បទបញ្ញត្តិក្នុងស្រុក ឬ រដ្ឋបាលអនុវត្តជាក់ស្តែង។ ដោយហេតុថា ការនាំចូលទាំងនោះមិនប្រមូលផ្តុំជាផ្នែកមួយ ឬ ការនាំចូលច្រើន ដែលអាចមានមូលហេតុគ្រប់គ្រាន់ក្នុងការពិចារណាថា បានប្រព្រឹត្ត ឬរៀបចំក្នុងគោលបំណងចៀសវាងការផ្តល់វិញ្ញាបនបត្រដើមកំណើត ។

## វិធាន ១៥

១. នៅពេលដែលដើមកំណើតនៃទំនិញមិនត្រូវបានសង្ស័យ ការរកឃើញកំហុសតិចតួច ឬ ភាពមិនសមស្រប ដោយអន្លើនៅក្នុងឯកសារ មិនត្រូវ *ដោយហេតុនោះ* អស់សុពលភាពវិញ្ញាបនបត្រ ប្រសិនបើវាជាក់ស្តែងឆ្លើយតប ទៅនឹងទំនិញដែលបានផ្តល់ ។

២. ចំពោះទំនិញច្រើនប្រភេទដែលប្រកាសលើវិញ្ញាបនបត្រ ដូចបញ្ហាដែលពាក់ព័ន្ធតែទំនិញមួយមុខ ដែលមានរៀបរាប់នៅក្នុងបញ្ជីមិនត្រូវប៉ះពាល់ ឬ ពន្យារក្នុងការផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះ និង ការបំពេញបែបបទទទួលទំនិញពីគយ ចំពោះទំនិញនៅសល់ ដែលរៀបរាប់នៅក្នុងវិញ្ញាបនបត្រដើមកំណើត ។

## វិធាន ១៦

១. ភាគីនីមួយៗត្រូវតម្រូវថា អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ សហគ្រិន អ្នកផលិត អ្នកនាំចេញ អ្នកនាំចូល និង តំណាងដែលផ្តល់សិទ្ធិរបស់ពួកគេ រក្សាក្នុងរយៈពេលមិនតិចជាង ៣ ឆ្នាំបន្ទាប់កាលបរិច្ឆេទ នាំចេញ ឬ នាំចូល ដែលករណីនេះអាច រាល់ឯកសារពាក់ព័ន្ធទៅនឹងការនាំចេញ និង នាំចូលទាំងអស់ ដែលចាំបាច់សំរាប់បង្ហាញក្នុងការទាមទារប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល ដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល។ រាល់ឯកសារទាំងនោះអាចជាទំរង់អេឡិចត្រូនិច ។

២. ពត៌មានពាក់ព័ន្ធនឹងសុពលភាពនៃវិញ្ញាបនបត្រ ត្រូវផ្តល់ឱ្យនៅពេលដែលមានការស្នើសុំពីភាគីនាំចូល ដោយមន្ត្រីដែលមានសិទ្ធិចុះហត្ថលេខាលើវិញ្ញាបនបត្រដើមកំណើត និងបានបញ្ជាក់ពីអាជ្ញាធរ/ស្ថាប័ន ចេញវិញ្ញាបនបត្រ។

៣. រាល់ពត៌មានដែលបានទំនាក់ទំនងរវាងបណ្តាភាគីពាក់ព័ន្ធ ត្រូវចាត់ទុកថា សម្ងាត់ និងត្រូវប្រើប្រាស់ ចំពោះតែវិញ្ញាបនបត្រដើមកំណើត ដែលមានសុពលភាពតែប៉ុណ្ណោះ[5] ។

[5] កថាខណ្ឌនេះ ត្រូវអានជាមួយនឹងឯកសារយោង មាត្រា ៥ (ការសម្ងាត់) នៃជំពូក ១៨ (អវសានបញ្ញត្តិ)

## ការបញ្ជាក់ដើមកំណើត

## វិធាន ១៧

១. អាជ្ញាធរគយនៃភាគីនាំចូល អាចបញ្ជាក់ពីការទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធគយ អនុលោមទៅតាមច្បាប់ បទបញ្ញត្តិក្នុងស្រុក ឬ រដ្ឋបាលអនុវត្តជាក់ស្តែង ។

២. ប្រសិនបើអាជ្ញាធរគយនៃភាគីនាំចូល មានការសង្ស័យទៅនឹងភាពត្រឹមត្រូវ និងច្បាស់លាស់នៃពត៌មាន ដែលមាននៅក្នុងវិញ្ញាបនបត្រដើមកំណើត ឬ ឯកសារភស្តុតាងដទៃទៀត អាច :

(i) បង្កើតវិធានការត្រួតពិនិត្យជាប្រតិសកម្ម ដើម្បីបង្កើតសុពលភាពវិញ្ញាបនបត្រដើមកំណើត ឬ ឯកសារ ភស្តុតាងដទៃទៀតនៃដើមកំណើត

(ii) ស្នើសុំពត៌មានពីអ្នកនាំចូល ពាក់ព័ន្ធទៅនឹងទំនិញដែលបានទាមទារប្រព្រឹត្តិកម្មអនុគ្រោះពន្ធ និង

(iii) ស្នើជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរ/ស្ថាប័ននៃភាគីនាំចេញ ចំពោះពត៌មានពីអ្នកនាំចេញ ឬ អ្នកផលិត ។

៣. ការស្នើសុំពត៌មាន អនុលោមទៅតាមកថាខណ្ឌ ២ (iii) មិនត្រូវបានច្រានចោលក្នុងការប្រើប្រាស់សំរាប់ការចុះត្រួតពិនិត្យបញ្ជាក់ដែលមានចែងនៅក្នុងវិធាន ១៨ ។

៤. អ្នកដែលទទួលការស្នើសុំពត៌មានក្រោមកថាខណ្ឌ ២ ត្រូវផ្តល់ពត៌មានដែលបានស្នើសុំក្នុងកំឡុង ៩០ ថ្ងៃ គិតពីកាលបរិច្ឆេទនៃការសរសេរពាក្យស្នើសុំ ។

៥. អាជ្ញាធរគយនៃភាគីនាំចូល ត្រូវផ្តល់ជាលាយលក្ខណ៍អក្សរនូវការណែនាំ ទោះបីជាទំនិញនោះ មិនគ្រប់លក្ខណៈក្នុងការទទួលបានប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ទៅដល់បណ្តាភាគីក្នុងកំឡុង ៦០ ថ្ងៃ ពីការទទួលពត៌មានចាំបាច់សម្រាប់ធ្វើការសម្រេច ។

## ការត្រួតពិនិត្យបញ្ជាក់

## វិធាន ១៨

១. ប្រសិនបើអាជ្ញាធរគយនៃភាគីនាំចូលមានបំណងត្រួតពិនិត្យបញ្ជាក់ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ស្នើសុំទៅអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ យ៉ាងហោចណាស់ ៣០ ថ្ងៃមុនការត្រួតពិនិត្យបញ្ជាក់ ។

២.	ប្រសិនបើអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ មិនមែនជាស្ថាប័នរដ្ឋាភិបាល អាជ្ញាធរគយនៃភាគីនាំចូល ត្រូវជូនពត៌មានទៅអាជ្ញាធរគយនៃភាគីនាំចេញ ជាលាយលក្ខណ៍អក្សរ ស្នើសុំការត្រួតពិនិត្យបញ្ជាក់។

៣.	ការស្នើសុំជាលាយលក្ខណ៍អក្សរ ដែលចែងនៅក្នុងកថាខណ្ឌ ១ និង ២ ត្រូវស្ថិតក្នុងកំរិតអប្បបរមា មាន :

(i) អត្តសញ្ញាណរបស់អាជ្ញាធរគយដែលស្នើសុំ

(ii) ឈ្មោះអ្នកនាំចេញ ឬ អ្នកផលិតនៃភាគីនាំចេញ ដែលទំនិញរបស់ពួកគេជាប្រធានបទនៃការចុះត្រួតពិនិត្យ

(iii) កាលបរិច្ឆេទនៃការសរសេរពាក្យស្នើសុំ

(iv) កាលបរិច្ឆេទ និងទីកន្លែងស្នើសុំត្រួតពិនិត្យបញ្ជាក់

(v) កម្មវត្ថុ និងទំហំនៃការចុះ ដែលរួមមានទាំងឯកសារយោងចំពោះទំនិញដែលជាប្រធានបទ នៃការត្រួតពិនិត្យ និង

(vi) ឈ្មោះ និងពត៌មានលំអិតនៃមន្ត្រីអាជ្ញាធរគយ ឬអាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃភាគីនាំចូល ដែលចូលរួម ក្នុងការពិនិត្យបញ្ជាក់។

៤.	អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រនៃភាគីនាំចេញ ត្រូវជូនពត៌មានទៅអ្នកនាំចេញ ឬ អ្នកផលិត ពីគោលបំណង នៃការត្រួតពិនិត្យបញ្ជាក់ដោយអាជ្ញាធរគយ ឬអាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃភាគីនាំចូល និង ស្នើឱ្យអ្នកនាំចេញ និងអ្នកផលិត :

(i) អនុញ្ញាតឱ្យអាជ្ញាធរគយ ឬ អាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃភាគីនាំចូល ចុះពិនិត្យការប្រតិបត្តិ ឬរោងចក្ររបស់ពួកគេ និង

(ii) ផ្តល់ពត៌មានពាក់ព័ន្ធទៅនឹងដើមកំណើតនៃទំនិញ។

៥.	អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវផ្តល់ការណែនាំទៅអ្នកនាំចេញ ឬ អ្នកផលិតថា ប្រសិនបើខកខានមិនបានឆ្លើយតបទៅតាមកាលបរិច្ឆេទ ចំពោះប្រព្រឹត្តិកម្មអនុគ្រោះពន្ធ អាចនឹងត្រូវបានបដិសេធ។

៦. អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ត្រូវផ្តល់ការណែនាំទៅអាជ្ញាធរគយនៃភាគីនាំចូល ក្នុងកំឡុង ៣០ ថ្ងៃ នៃកាលបរិច្ឆេទនៃការសរសេរស្នើសុំពីអាជ្ញាធរគយនៃភាគីនាំចូល ទោះបីជាអ្នកនាំចេញ ឬ អ្នកផលិត ព្រមព្រៀងទៅនឹងការស្នើសុំត្រួតពិនិត្យបញ្ជាក់។

៧. អាជ្ញាធរគយនៃភាគីនាំចូលមិនត្រូវចុះពិនិត្យការប្រតិបត្តិ ឬ រោងចក្ររបស់អ្នកនាំចេញ ឬ អ្នកផលិតណាមួយនៅក្នុងដែលដីនៃភាគីនាំចេញ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ដោយអ្នកនាំចេញ ឬ អ្នកផលិត។

៨. អាជ្ញាធរគយនៃភាគីនាំចូល ត្រូវបញ្ចប់រាល់សកម្មភាពដើម្បីបញ្ជាក់ពីលក្ខខណ្ឌ ដែលអាចទទួលប្រព្រឹត្តិកម្មអនុគ្រោះពន្ធនាំចូល និងធ្វើការសម្រេចក្នុងកំឡុង ១៥០ ថ្ងៃ នៃការស្នើសុំទៅអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រក្រោមកថាខណ្ឌ ១។ អាជ្ញាធរគយនៃភាគីនាំចូល ត្រូវផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរ ទោះបីថាទំនិញ ទាំងនោះមានលក្ខណៈទទួលប្រព្រឹត្តិកម្មអនុគ្រោះទៅបណ្តាភាគីក្នុងកំឡុង ១០ថ្ងៃ បន្ទាប់ពីបានធ្វើការសម្រេច។

៩. បណ្តាភាគីត្រូវរក្សាជាសម្ងាត់នូវពត៌មានដែលចាត់ទុកថាជាសម្ងាត់ ដែលប្រមូលបានក្នុងដំណើរការចុះពិនិត្យបញ្ជាក់ និងត្រូវការពារពត៌មានទាំងនោះពីការផ្សាយចេញដែលខូចខាតដល់ជំហរប្រកួតប្រជែងរបស់បុគ្គល ដែលផ្តល់ពត៌មាន។ ពត៌មានដែលចាត់ទុកជាសម្ងាត់អាចបើកចំហចំពោះតែអាជ្ញាធរដែលទទួលបន្ទុករដ្ឋបាល និង កំណត់ដើមកំណើត[6]។

## ការព្យួរប្រព្រឹត្តិកម្មអនុគ្រោះពន្ធ

## វិធាន ១៩

១. អាជ្ញាធរគយនៃភាគីនាំចូលអាចព្យួរប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ចំពោះទំនិញណាដែលជាប្រធានបទនៃសកម្មភាពពិនិត្យបញ្ជាក់ដើមកំណើតក្រោមឧបសម្ព័ន្ធនេះ ក្នុងកំឡុងពេលសកម្មភាពទាំងនោះ ឬផ្នែកណាមួយនៃសកម្មភាពនោះ។

២. ភាគីនាំចូលអាចបញ្ចេញទំនិញទៅឱ្យអ្នកនាំចូល ដោយវិធានការរដ្ឋបាលណាមួយដែលយល់ថាចាំបាច់ ដោយផ្តល់ថា ទំនិញទាំងនោះមិនមែនជាទំនិញជាប់អាយ័ត ឬទំនិញជាប់កម្រិតកំណត់ និងមិនសង្ស័យថា ក្លែងក្លាយ។

៣. នៅក្នុងហេតុការណ៍នៃការកំណត់ ដែលបានធ្វើដោយអាជ្ញាធរគយនៃភាគីនាំចូល ថាទំនិញនោះមានលក្ខណៈគ្រប់គ្រាន់ជាទំនិញដើមកំណើតរបស់ភាគីនាំចេញ រាល់ការព្យួរប្រព្រឹត្តិកម្មអនុគ្រោះ ត្រូវតែធ្វើឱ្យដូចដើម។

---

[6] កថាខណ្ឌនេះ ត្រូវអានជាមួយនឹងមាត្រា ៩ (ការសម្ងាត់) នៃជំពូក ១៨ (អវសានបញ្ញត្តិ)

## វិធាន ២០

ពេលដែលទិសដៅនាំចេញ នៃទំនិញណាមួយដែលបាននាំចេញទៅកាន់ភាគីមួយច្បាស់លាស់ ត្រូវបានផ្លាស់ប្តូរ បន្ទាប់ពីនាំចេញពីភាគីនាំចេញ ប៉ុន្តែមុនពេលជំរះបញ្ជីគយនៃភាគីនាំចូល អ្នកនាំចេញ សហគ្រិន អ្នកផលិត ឬតំណាងដែលផ្តល់សិទ្ធិ ត្រូវស្នើសុំបែបបទជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ឱ្យផ្តល់វិញ្ញាបនបត្រដើមកំណើតថ្មី ចំពោះទំនិញដែលបានផ្លាស់ប្តូរទិសដៅ។ បែបបទត្រូវភ្ជាប់ទាំងវិញ្ញាបនបត្រដើមកំណើតដើមពាក់ព័ន្ធទៅនឹងទំនិញទាំងនោះ។

## វិធាន ២១

សម្រាប់គោលដៅនៃការអនុវត្តមាត្រា ១៤ (ការបញ្ជូនទំនិញដោយផ្ទាល់) នៃជំពូក ៣ (វិធានដើមកំណើត) ពេល ដែលការដឹកជញ្ជូនត្រូវឆ្លងកាត់ដែនដីប្រទេសមិនមែនភាគី ឯកសារដូចខាងក្រោម ត្រូវផ្តល់ជូនអាជ្ញាធរគយនៃភាគី នាំចូល :

(i) ប័ណ្ណផ្ទុកទំនិញដែលបានចេញដោយភាគីនាំចេញ

(ii) វិញ្ញាបនបត្រដើមកំណើត ដែលចេញដោយអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ នៃភាគីនាំចេញ លើកលែងតែមិនតម្រូវទៅតាមវិធាន ១២.២ ឬវិធាន ១៤

(iii) ច្បាប់ដើមនៃវិក្កយបត្រពាណិជ្ជកម្មទំនិញ និង

(iv) ឯកសារគាំទ្រដែលជាភស្តុតាងតម្រូវនៅក្នុងមាត្រា ១៤ (ការបញ្ជូនទំនិញដោយផ្ទាល់) នៃជំពូក ៣ (វិធានដើមកំណើត) ដែលត្រូវអនុវត្តជាមួយ។

## វិធាន ២២

១. អាជ្ញាធរគយនៃភាគីនាំចូល អាចទទួលយកវិញ្ញាបនបត្រដើមកំណើត ក្នុងករណីដែលវិក្កយបត្រលក់ បានចេញដោយក្រុមហ៊ុនដែលមានទីតាំងស្ថិតនៅក្នុងប្រទេសទីបី ឬ ដោយអ្នកនាំចេញសំរាប់គណនីនៃក្រុមហ៊ុននោះ ដោយបញ្ជាក់ថា ទំនិញបំពេញបានតាមតម្រូវការនៃជំពូក ៣ (វិធានដើមកំណើត)។

២. ពាក្យថា "SUBJECT OF THIRD-PARTY INVOICE *(ឈ្មោះក្រុមហ៊ុនដែលប្រើវិក្កយបត្រ)*" ត្រូវមាននៅលើវិញ្ញាបនបត្រដើមកំណើត ។

## វិធានការប្រឆាំងនឹងសកម្មភាពក្លែងបន្លំ

## វិធាន ២៣

ពេលដែលមានការសង្ស័យពីការក្លែងបន្លំទាក់ទងនឹងវិញ្ញាបនបត្រដើមកំណើត អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធត្រូវសហការជាមួយភាគីអនុវត្តប្រឆាំងនឹងបុគ្គលដែលចូលរួមក្លែងបន្លំ ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិរបស់ភាគីនីមួយៗ ។

## ទំនិញដែលកំពុងដឹកជញ្ជូន ឬ រក្សាទុកក្នុងឃ្លាំង

## វិធាន ២៤

ទំនិញដើមកំណើតដែលកំពុងតែស្ថិតនៅក្នុងដំណើរការដឹកជញ្ជូនពីភាគីនាំចេញ ទៅភាគីនាំចូល ឬកំពុងតែស្ថិតនៅក្នុងឃ្លាំងជាបណ្តោះអាសន្ននៅក្នុងប្រទេសនាំចូល ត្រូវតែព្រមផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះពន្ធ ប្រសិនបើទំនិញទាំងនោះ ត្រូវបាននាំចូលទាំងស្រុងទៅក្នុងភាគីនាំចូល ក្នុងពេល ឬបន្ទាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ អាស្រ័យលើការផ្តល់វិញ្ញាបនបត្រដើមកំណើតដែលចេញជាប្រតិសកម្មទៅអាជ្ញាធរគយនៃភាគីនាំចូល និងអនុលោមទៅតាមច្បាប់ បទបញ្ញត្តិក្នុងស្រុក និងរដ្ឋបាលអនុវត្តជាក់ស្តែងរបស់ភាគីនាំចូល ។

## ការដោះស្រាយវិវាទ

## វិធាន ២៥

១. ក្នុងករណីដែលវិវាទពាក់ព័ន្ធទៅនឹងការកំណត់ដើមកំណើត ចំណាត់ថ្នាក់ទំនិញ ឬ ករណីផ្សេងទៀត អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធនៅក្នុងភាគីនាំចូល និងនាំចេញ ត្រូវពិគ្រោះគ្នា ដើម្បីស្វែងរកដំណោះស្រាយ ហើយលទ្ធផលត្រូវរាយការណ៍ទៅបណ្តាភាគីដទៃទៀត ដើម្បីជាពត៌មាន ។

២. ប្រសិនបើគ្មានដំណោះស្រាយជាទ្វេភាគី វិវាទអាចត្រូវស្នើឡើងទៅអនុគណៈកម្មការវិធានដើមកំណើត ដែលបានបង្កើតក្រោមមាត្រា ១៨ (អនុគណៈកម្មការស្តីពីវិធានដើមកំណើត) នៃជំពូក ៣ (វិធានដើមកំណើត) ។

# សេចក្ដីបន្ថែម ១

## តម្រូវការទិន្នន័យអប្បបរមា ~ ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើមកំណើត

តម្រូវការទិន្នន័យអប្បបរមា សម្រាប់ដាក់បញ្ចូលទៅក្នុងការស្នើសុំវិញ្ញាបនបត្រដើមកំណើត មាន :

| | |
|---|---|
| ១. លំអិតពីអ្នកនាំចេញ | ឈ្មោះ អាសយដ្ឋាន លំអិតទំនាក់ទំនងនៃអ្នកនាំចេញ |
| ២. លំអិតពីការដឹកជញ្ជូន (បែបបទផ្សេងៗគ្នាតម្រូវសម្រាប់ការដឹកជញ្ជូននីមួយៗ) | (i) ឈ្មោះអ្នកដឹកជញ្ជូន និង អាសយដ្ឋាន<br>(ii) ពត៌មានលំអិតគ្រប់គ្រាន់ សម្រាប់សម្គាល់ការដឹកជញ្ជូនដូចជា លេខបញ្ជាទិញរបស់អ្នកនាំចូល លេខវិក្កយបត្រ និងកាលបរិច្ឆេទ និងប័ណ្ណដឹកតាមយន្តហោះ ឬ ប័ណ្ណដឹកតាមនាវា ឬ ប័ណ្ណផ្ទុកទំនិញ<br>(iii) កំពង់ផែរើទំនិញ ប្រសិនបើដឹង |
| ៣. បរិយាយនៃទំនិញ | (i) លំអិតបរិយាយនៃទំនិញដែលរួមមានទាំង Harmonized System Code (កំរិត ៦ ខ្ទង់) និង ប្រសិនបើអាច លេខផលិតផល និងឈ្មោះយីហោ<br>(ii) ពត៌មានផ្សេងៗទាក់ទងទៅនឹងលក្ខណៈដើមកំណើត |
| ៤. ប្រកាសរបស់អ្នកនាំចេញ | ប្រកាសដែលបំពេញដោយអ្នកនាំចេញ ឬ តំណាងផ្តល់សិទ្ធិចុះហត្ថលេខា និងកាលបរិច្ឆេទ និង សេចក្តីពន្យល់ដែលមានឈ្មោះ និងតួនាទីអ្នកចុះហត្ថលេខា។ ប្រកាសត្រូវតែរួមមានសេចក្តីថ្លែងការណ៍លំអិត ដែលផ្តល់នៅក្នុងបែបបទពិត និងត្រឹមត្រូវ។ |

# សេចក្តីបន្ថែម ២

## តម្រូវការទិន្នន័យអប្បបរមា ~ វិញ្ញាបនបត្រដើមកំណើត

តម្រូវការទិន្នន័យអប្បបរមាសម្រាប់ដាក់បញ្ចូលទៅក្នុងវិញ្ញាបនបត្រដើមកំណើត មាន :

| | |
|---|---|
| ១. លំអិតពីអ្នកនាំចេញ | ឈ្មោះ អាសយដ្ឋាន លំអិតទំនាក់ទំនងនៃអ្នកនាំចេញ |
| ២. លំអិតពីការដឹកជញ្ជូន (វិញ្ញាបនបត្រ អាចអនុវត្តបានចំពោះតែការដឹកជញ្ជូនម្តង១) | (i) ឈ្មោះអ្នកដឹកជញ្ជូន និង អាសយដ្ឋាន<br>(ii) ពត៌មានលំអិតគ្រប់គ្រាន់សម្រាប់សម្គាល់ការដឹកជញ្ជូន ដូចជា លេខបញ្ជាទិញរបស់អ្នកនាំចូល លេខវិក្កយបត្រ និងកាលបរិច្ឆេទ និង ប័ណ្ណដឹកតាមយន្តហោះ ឬ ប័ណ្ណដឹកតាមនាវា ឬ ប័ណ្ណផ្ទុកទំនិញ<br>(iii) កំពង់ផែរើទំនិញ ប្រសិនបើដឹង |
| ៣. បរិយាយនៃទំនិញ | (i) លំអិតបរិយាយនៃទំនិញដែលរួមមានទាំង Harmonized System Code (កំរិត ៦ ខ្ទង់) និង ប្រសិនបើអាច លេខផលិតផល និងឈ្មោះយីហោ<br>(ii) ពត៌មានផ្សេង១ទាក់ទងទៅនឹងលក្ខណៈដើមកំណើត<br>(iii) តម្លៃ FOB |
| ៤. ការបញ្ជាក់របស់អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ | ការបញ្ជាក់របស់អាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រ ដោយផ្អែកលើភ័ស្តុតាងដែលបានផ្តល់ ទំនិញដែលបញ្ជាក់នៅក្នុងវិញ្ញាបនបត្រដើមកំណើត ត្រូវបំពេញតាមតម្រូវការពាក់ព័ន្ធនៃជំពូកនេះ។ |
| ៥. លេខរៀងវិញ្ញាបនបត្រដើមកំណើត | លេខរៀងដែលផ្តល់ទៅវិញ្ញាបនបត្រដោយអាជ្ញាធរ/ស្ថាប័នចេញវិញ្ញាបនបត្រដើមកំណើត។ |

# ជំពូក ៤
# នីតិវិធីគយ

## មាត្រា ១
## គោលបំណង

គោលបំណងនៃជំពូកនេះ គឺ :

ក- ធានានូវភាពអាចព្យាករបាន សង្គតភាព និងតម្លាភាពនៅក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ របស់បណ្តាប្រទេសភាគីនៃកិច្ចព្រមព្រៀង

ខ- ជម្រុញឱ្យមាននូវការអនុវត្តនីតិវិធីគយ និងការបំពេញបែបបទបញ្ចេញទំនិញពីគយ ប្រកបដោយប្រសិទ្ធភាព និងការសន្សំសំចៃ

គ- ធ្វើសាមញ្ញកម្ម និងសុខដុមនីយកម្ម លើកិច្ចប្រតិបត្តិ និងនីតិវិធីគយ ឱ្យដល់កម្រិតអតិបរមា ដែលអាចធ្វើបាន និង

ឃ- ជម្រុញកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរគយ ។

## មាត្រា ២
## វិសាលភាព

ជំពូកនេះអនុវត្តដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយរបស់ប្រទេសភាគី នៃកិច្ចព្រមព្រៀងនីមួយៗ ចំពោះនីតិវិធីគយលើទំនិញ ដែលធ្វើពាណិជ្ជកម្មក្នុងចំណោមប្រទេសភាគីទាំងឡាយ ។

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ :

ក- **ច្បាប់គយ** គឺជាបណ្តាច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រង និងដាក់ឱ្យប្រតិបត្តិ ដោយអាជ្ញាធរគយនៃប្រទេសភាគីកិច្ចព្រមព្រៀង ដែលពាក់ព័ន្ធនឹងការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់ទំនិញ ហើយដែលពាក់ព័ន្ធនឹងពន្ធគយ អាករ និងកម្រៃនានា ឬការហាមឃាត់ ការកម្រិតកំណត់ និង

វិធានការគ្រប់គ្រងប្រហាក់ប្រហែលលើការចរាចរនៃទំនិញពាក់ព័ន្ធឆ្លងកាត់ព្រំដែនគយ នៃប្រទេសភាគីកិច្ចព្រមព្រៀង ។

ខ- **នីតិវិធីគយ** គឺជាប្រព្រឹត្តិកម្មដែលអនុវត្តដោយរដ្ឋបាលគយនៃប្រទេសភាគីកិច្ចព្រមព្រៀងលើទំនិញដែលស្ថិតក្រោមច្បាប់គយនៃប្រទេសភាគីកិច្ចព្រមព្រៀង ។

## មាត្រា ៤
## នីតិវិធីគយ និង ការសម្របសម្រួល

១- ភាគីនីមួយៗត្រូវធានាថា កិច្ចប្រតិបត្តិការ និងនីតិវិធីគយ មានភាពអាចព្យាករបាន មានសង្គតភាព មានតម្លាភាព និងការសម្រួលពាណិជ្ជកម្ម រួមបញ្ចូលទាំង តាមរយៈបែបបទបញ្ចេញទំនិញពីគយដ៏ឆាប់រហ័ស ។

២- តាមលទ្ធភាពដែលអាចធ្វើបាន និងតាមកម្រិតអតិបរមាដែលអនុញ្ញាតដោយច្បាប់គយ នីតិវិធីគយរបស់ភាគីនីមួយៗ ត្រូវអនុលោមទៅតាមស្តង់ដា និងការអនុវត្តដែលបានផ្តល់ដោយអង្គការគយពិភពលោក ។

៣- អាជ្ញាធរគយរបស់ប្រទេសភាគីនីមួយៗ ត្រូវពិនិត្យឡើងវិញនូវនីតិវិធីគយរបស់ខ្លួន ក្នុងគំនិតធ្វើសាមញ្ញកម្ម ដើម្បីសម្រួលពាណិជ្ជកម្ម ។

## មាត្រា ៥
## កិច្ចសហប្រតិបត្តិការគយ

១- តាមកម្រិតអតិបរមាដែលអនុញ្ញាតដោយច្បាប់ រដ្ឋបាលគយនៃភាគីនីមួយៗ ក្នុងករណីយល់ថាត្រឹមត្រូវ អាចជួយរដ្ឋបាលគយនៃភាគីដទៃ ពាក់ព័ន្ធនឹង ៈ

ក- ការអនុវត្ត និងការប្រតិបត្តិតាមបញ្ញត្តិនៃជំពូកនេះ

ខ- ការកសាង និងការអនុវត្តនូវកិច្ចប្រតិបត្តិល្អជាអន្តរជាតិរបស់គយ និងបច្ចេកទេសគ្រប់គ្រងហានិភ័យ

គ- ការផ្តល់តាមលទ្ធភាពដែលអាចធ្វើទៅបាន នូវការជូនដំណឹងជាមុន អំពីការកែប្រែបទប្បញ្ញត្តិច្បាប់ នីតិវិធី និង ការណែនាំពាក់ព័ន្ធ ដែលអាចមានផលប៉ះពាល់ដល់ការអនុវត្តកិច្ចព្រមព្រៀងនេះ

ឃ- ការធ្វើសាមញ្ញកម្ម សុខដុមនីយកម្មនីតិវិធីគយ

ង- ទំនើបកម្មជំនាញបច្ចេកទេស និងការប្រើប្រាស់បច្ចេកវិទ្យាទំនើប

ច- ការអនុវត្តកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ ។

២- អាស្រ័យទៅតាមធនធានដែលមាន រដ្ឋបាលគយនៃប្រទេសភាគី ក្នុងករណីយល់ថាត្រឹមត្រូវ អាចស្វែងរក និង ទទួលយកនូវគម្រោងកិច្ចសហប្រតិបត្តិការ ដូចជា ៖

ក- កម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីពង្រឹងសមត្ថភាពជំនាញមន្ត្រីគយនៃប្រទេសអាស៊ាន

ខ- កម្មវិធីជំនួយបច្ចេកទេសដើម្បីជួយសម្រួលដល់ការកសាង និងការអនុវត្តនូវប្រព័ន្ធបញ្ជរតែមួយ របស់ប្រទេសភាគីកិច្ចព្រមព្រៀង។

## មាត្រា ៦
## ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម

១- រដ្ឋបាលគយនៃប្រទេសភាគីនីមួយៗ ក្នុងករណីអាចអនុវត្តបាន ត្រូវខិតខំកសាងនូវប្រព័ន្ធរបស់ខ្លួន ដែលគាំទ្រ ដល់កិច្ចប្រតិបត្តិការគយតាមមធ្យោបាយអេឡិចត្រូនិច។

២- នៅក្នុងការអនុវត្តនូវគំនិតផ្តួចផ្តើមនេះ រដ្ឋបាលគយនៃប្រទេសភាគីនីមួយៗ ត្រូវផ្អែកតាមស្តង់ដា នៃការ អនុវត្តល្អបំផុតជាអន្តរជាតិ តាមអនុសាសន៍របស់អង្គការគយពិភពលោក និងដោយផ្អែកលើសមត្ថភាព និងហេដ្ឋារចនា សម្ព័ន្ធដែលមានស្រាប់របស់ប្រទេសនីមួយៗ។

## មាត្រា ៧
## ការកំណត់តម្លៃគិតពន្ធគយ

ប្រទេសភាគីត្រូវធ្វើការកំណត់តម្លៃគិតពន្ធគយលើទំនិញ ដែលធ្វើពាណិជ្ជកម្មនៅក្នុងចំណោមប្រទេសជា សមាជិក ដោយអនុលោមតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយ[១]។

## មាត្រា ៨
## វិធានជាមុន

១- តាមរយៈរដ្ឋបាលគយ ឬតាមរយៈស្ថាប័នពាក់ព័ន្ធផ្សេងទៀត តាមកម្រិតអតិបរមាដែលអនុញ្ញាត ដោយច្បាប់ បទប្បញ្ញត្តិ និងសេចក្តីសម្រេចផ្នែករដ្ឋបាលនានារបស់ជាតិ ប្រទេសភាគីនីមួយៗត្រូវផ្តល់ជាលាយលក្ខណ៍អក្សរ នៅលើ

---

[១] នៅក្នុងករណីកម្ពុជា កិច្ចព្រមព្រៀងស្តីពីការកំណត់តម្លៃគិតពន្ធគយដែលបានអនុវត្តតាមបញ្ញត្តិពិធីសារ នៃការចូលជាសមាជិករបស់ ព្រះរាជាណាចក្រកម្ពុជាទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ត្រូវអនុវត្តតាមបញ្ញត្តិនៃការកែប្រែ។

ពាក្យស្នើសុំរបស់បុគ្គលដូចរៀបរាប់ក្នុងវាក្យខ័ណ្ឌ ២-ក ខាងក្រោមនូវ "វិធានជាមុន" ពាក់ព័ន្ធនឹងចំណាត់ថ្នាក់ទំនិញ បញ្ហានានាកើតឡើងអំពីការអនុវត្តគោលការណ៍នៃកិច្ចព្រមព្រៀងស្ដីពីការកំណត់តម្លៃគិតពន្ធគយ និង/ឬដើមកំណើតទំនិញ។

២- ក្នុងករណីដែលមាន ភាគីនីមួយៗត្រូវអនុម័ត ឬរក្សានូវនីតិវិធីសម្រាប់វិធានជាមុន ដែលត្រូវ :

ក- ចែងថា អ្នកនាំចូលស្ថិតនៅក្នុងដែនគយរបស់ខ្លួន ឬអ្នកនាំចេញ ឬផលិតករនៅក្នុងដែនគយនៃប្រទេសជាសមាជិកដទៃទៀត អាចធ្វើការស្នើសុំនូវវិធានជាមុនបាន មុនពេលធ្វើការនាំចូលទំនិញ

ខ- តម្រូវឱ្យបុគ្គលស្នើសុំវិធានជាមុននោះផ្ដល់នូវការពណ៌នាលម្អិតស្ដីពីទំនិញ និងព័ត៌មានពាក់ព័ន្ធនានាចាំបាច់ ដំណើរការពាក្យស្នើសុំសម្រាប់វិធានជាមុន

គ- ចែងថា រដ្ឋបាលគយរបស់ខ្លួន ពេលណាក៏បានក្នុងកំឡុងពេលនៃការវាយតម្លៃលើពាក្យស្នើសុំវិធានជាមុន អាចតម្រូវឱ្យបុគ្គលស្នើសុំនោះផ្ដល់នូវព័ត៌មានបន្ថែមទៀតក្នុងរយៈពេលកំណត់ណាមួយ

ឃ- ចែងថា វិធានជាមុនណាក៏ដោយ ផ្អែកទៅលើហេតុការណ៍ និងកាលៈទេសៈដែលបង្ហាញដោយបុគ្គលស្នើសុំ និងផ្អែកទៅលើព័ត៌មានពាក់ព័ន្ធផ្សេងទៀតរបស់អ្នកធ្វើសេចក្ដីសម្រេច

ង- ចែងថា វិធានជាមុនត្រូវផ្ដល់ជូនដល់បុគ្គលស្នើសុំឱ្យបានឆាប់រហ័ស តាមរយៈពេលកំណត់ណាមួយដែលមានចែង នៅក្នុងច្បាប់ បទប្បញ្ញត្តិ ឬសេចក្ដីសម្រេចរដ្ឋបាលរបស់ប្រទេសភាគីនីមួយៗ

៣- ប្រទេសភាគី អាចបដិសេធការស្នើសុំវិធានជាមុន ក្នុងករណីព័ត៌មានបន្ថែមដែលបានតម្រូវ ដូចមានចែងក្នុងវាក្យខ័ណ្ឌ ២-គ ខាងលើ មិនត្រូវបានផ្ដល់ជូននៅក្នុងរយៈពេលដែលបានកំណត់។

៤- យោងតាមកថាខ័ណ្ឌ ១ និង ៥ និងក្នុងករណីដែលមាន ប្រទេសភាគីនីមួយៗ ត្រូវអនុវត្តវិធានជាមុន លើរាល់ការនាំចូលទំនិញដែលបានរៀបរាប់នៅក្នុងវិធាននោះ មកក្នុងដែនគយរបស់ខ្លួន រយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃវិធាននោះ ឬរយៈពេលកំណត់ណាមួយផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ បទប្បញ្ញត្តិ ឬសេចក្ដីសម្រេចរដ្ឋបាលរបស់ប្រទេសនោះ។

៥- ប្រទេសភាគី អាចធ្វើវិសោធនកម្ម ឬលុបចោលនូវវិធានជាមុន ក្នុងករណីដែលរកឃើញថាវិធាននោះ ផ្អែកទៅលើកំហុសនៃហេតុការណ៍ ឬច្បាប់ (រួមទាំងកំហុសរបស់មនុស្ស) ព័ត៌មានដែលបានផ្ដល់ឱ្យខុស ឬមិនត្រឹមត្រូវ ក្នុងករណីមានការកែប្រែច្បាប់ជាតិដែលមានសង្គតភាពជាមួយកិច្ចព្រមព្រៀងនេះ ឬប្រសិនបើមានការកែប្រែហេតុការណ៍ ឬ កាលៈទេសៈនានាដែលវិធាននោះផ្អែកលើ។ ក្នុងករណីអ្នកនាំចូលទាមទារថា ប្រព្រឹត្តកម្មលើទំនិញនាំចូលមួយត្រូវ

អនុវត្តតាមវិធានជាមុន រដ្ឋបាលគយអាចធ្វើការវាយតម្លៃថាតើហេតុការណ៍ និងកាលៈទេសៈនានា នៃការនាំចូលនោះ មានសង្គតភាពជាមួយហេតុការណ៍ និង កាលៈទេសៈដែលវិធានជាមុនផ្អែកលើឬទេ ។

## មាត្រា ៩
## ការគ្រប់គ្រងហានិភ័យ

១- ប្រទេសភាគីនីមួយៗ ត្រូវអនុវត្តនូវនីតិវិធីគយ ដែលសម្រួលដល់ការបំពេញបែបបទនៃទំនិញ មានហានិភ័យទាប ហើយដែលផ្តោតការយកចិត្តទុកដាក់ទៅលើទំនិញមានហានិភ័យខ្ពស់ ដើម្បីពង្រឹងនូវការគ្រប់គ្រងលំហូរទំនិញឆ្លងកាត់ព្រំដែន រដ្ឋបាលគយនៃប្រទេសភាគីនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញលើនីតិវិធីនេះឱ្យបានទៀងទាត់ ។

២- ក្នុងករណីដែលរដ្ឋបាលគយនៃប្រទេសមួយ យល់ថាការត្រួតពិនិត្យរូបវ័ន្តលើទំនិញពុំចាំបាច់ក្នុងការអនុញ្ញាតឱ្យទំនិញនោះបញ្ចេញផុតពីការគ្រប់គ្រងរបស់គយ ប្រទេសភាគីនោះត្រូវខិតខំផ្តល់នូវពិន្ទុមួយសម្រាប់ការត្រួតពិនិត្យឯកសារ ឬដំណើរការបំពេញបែបបទតាមមធ្យោបាយអេឡិចត្រូនិចនៃទំនិញនោះ ។

## មាត្រា ១០
## ការសម្ងាត់វិជ្ជាជីវៈ

១- គ្មានចំណុចណាមួយក្នុងជំពូកនេះ តម្រូវឱ្យប្រទេសភាគីណាមួយផ្តល់ ឬអនុញ្ញាតឱ្យទទួលបាននូវព័ត៌មានសម្ងាត់ ដែលការលេចចេញនៃព័ត៌មានបែបនេះនឹង :

- ក- ផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិ ច្បាប់របស់ខ្លួន
- ខ- ផ្ទុយទៅនឹងបទប្បញ្ញត្តិរបស់ខ្លួន រួមទាំងបញ្ញត្តិពាក់ព័ន្ធនឹងការការពារការសម្ងាត់បុគ្គល ឬកិច្ចការហិរញ្ញវត្ថុ និង គណនីអតិថិជនរបស់ស្ថាប័នហិរញ្ញវត្ថុ
- គ- រារាំងដល់ការអនុវត្តច្បាប់
- ឃ- ប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ ដែលអាចរួមបញ្ចូលនូវជំហរនៃការប្រកួតប្រជែងនៃសហគ្រាសណាមួយ ទាំងរបស់សាធារណៈ ឬរបស់ផ្នែកឯកជន ។

២- ក្នុងករណីដែលប្រទេសមួយផ្តល់ព័ត៌មានជូនប្រទេសមួយទៀត ក្នុងក្របខ័ណ្ឌនៃជំពូកនេះ ហើយកំណត់ថា ជាព័ត៌មានសម្ងាត់ ប្រទេសអ្នកទទួលព័ត៌មាននោះ ត្រូវរិចាត់ចែងរក្សាជាការសម្ងាត់ ហើយត្រូវប្រើប្រាស់ ព័ត៌មាននោះ សម្រាប់តែក្នុងគោលបំណងដែលកំណត់ដោយប្រទេសអ្នកផ្តល់ព័ត៌មានប៉ុណ្ណោះ និងមិនត្រូវបញ្ចេញព័ត៌មាននោះទៅក្រៅ ដោយពុំមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីប្រទេសអ្នកផ្តល់ព័ត៌មានឡើយ ។

## មាត្រា ១១

## ផ្នែកផ្តល់ព័ត៌មាន

១- ប្រទេសភាគីនីមួយៗ ត្រូវបង្កើតនូវផ្នែកផ្តល់ព័ត៌មានមួយ ឬច្រើនដើម្បីដោះស្រាយនូវរាល់ចម្ងល់ របស់បុគ្គល ពាក់ព័ន្ធស្តីពីបញ្ហាគយនានា ហើយត្រូវផ្តល់តាមប្រព័ន្ធអ៊ិនធឺណែត និង/ឬប្រព័ន្ធផ្សព្វផ្សាយលើក្រដាសនានាផ្សេងទៀត នូវព័ត៌មានពាក់ព័ន្ធនឹងនីតិវិធីសម្រាប់ធ្វើការសាកសួរ ។

២- ប្រទេសភាគីនីមួយៗត្រូវធ្វើការផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ិនធឺណែត និង/ឬ ប្រព័ន្ធផ្សព្វផ្សាយលើក្រដាស នានា នូវបទប្បញ្ញត្តិច្បាប់ និងនីតិវិធីគយដែលអនុវត្តដោយរដ្ឋបាលគយរបស់ខ្លួន ដោយមិនរាប់បញ្ចូលនូវនីតិវិធី នៃការ អនុវត្តច្បាប់ និងសេចក្តីណែនាំការអនុវត្តផ្ទៃក្នុងឡើយ ។

## មាត្រា ១២

## ការប្រឹក្សា

រដ្ឋបាលគយនៃប្រទេសភាគីនានា នឹងត្រូវលើកទឹកចិត្តឱ្យមានការប្រឹក្សាយោបល់ជាមួយគ្នាទៅវិញទៅមក លើបញ្ហាពាក់ព័ន្ធនៃនីតិវិធីគយសំខាន់ៗ ដែលមានផលប៉ះពាល់ដល់ទំនិញ ដែលបានធ្វើពាណិជ្ជកម្មនៅក្នុងចំណោម ប្រទេសទាំងនោះ ។

## មាត្រា ១៣

## ការពិនិត្យឡើងវិញ និងបណ្តឹងឧទ្ធរណ៍

១- រដ្ឋបាលគយនៃប្រទេសភាគីនីមួយៗត្រូវធានាថា អ្នកនាំចូលនៅក្នុងដែនគយរបស់ខ្លួន អាចស្នើសុំឱ្យមានការ ត្រួតពិនិត្យឡើងវិញផ្នែករដ្ឋបាល ក្នុងក្របខ័ណ្ឌរដ្ឋបាលគយនោះ ដែលបានចេញសេចក្តីសម្រេចមួយដែលអាចត្រូវបាន ត្រួតពិនិត្យឡើងវិញ ឬក្នុងករណីចាំបាច់អាចត្រូវបានត្រួតពិនិត្យដោយអាជ្ញាធរមានសមត្ថកិច្ចថ្នាក់ខ្ពស់ផ្សេងទៀតដែល គ្រប់គ្រងរដ្ឋបាលគយ និង/ឬ ការត្រួតពិនិត្យឡើងវិញតាមផ្នែកតុលាការ លើសេចក្តីសម្រេចដែលបានធ្វើឡើង ក្នុង កម្រិតការត្រួតពិនិត្យរដ្ឋបាលចុងក្រោយបំផុត ដោយអនុលោមតាមច្បាប់នៃប្រទេសភាគីនីមួយៗ ។

២- សេចក្តីសម្រេចនៃបណ្តឹងឧទ្ធរណ៍ ត្រូវផ្តល់ជូនទៅបុគ្គលដើមបណ្តឹង និង ហេតុផលនៃសេចក្តីសម្រេចនោះ ត្រូវ ធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

៣- កម្រិតនៃការឡើងវិញផ្នែករដ្ឋបាលអាចរួមបញ្ចូលអាជ្ញាធរនានា ដែលគ្រប់គ្រងរដ្ឋបាលគយនៃប្រទេសភាគី ។

# ជំពូក ៥
# វិធានការអនាម័យ និងភូតគាមអនាម័យ

## មាត្រា ១
## គោលបំណង

គោលបំណងនៃជំពូកនេះ គឺ :

(ក) សម្រួលពាណិជ្ជកម្មក្នុងចំណោមបណ្ដាភាគី ដើម្បីការពារមនុស្ស សត្វ ឬរុក្ខជាតិមានជីវិត ឬសុខភាព នៅក្នុងដែនដីនៃភាគីនីមួយៗ

(ខ) ផ្ដល់ឱ្យបានច្រើននូវតម្លាភាព នៅក្នុងការយល់ដឹងបែបបទនៃនីតិវិធី និងបទបញ្ញត្តិទាំងឡាយពាក់ព័ន្ធនឹងវិធានការអនាម័យ និងភូតគាមអនាម័យ (SPS)

(គ) ពង្រឹងសហប្រតិបត្តិការ ក្នុងចំណោមអាជ្ញាធរមានសមត្ថភាពនៃបណ្ដាភាគី ដែលទទួលបន្ទុករាល់បញ្ហាដែលគ្របដណ្ដប់ដោយជំពូកនេះ និង

(ឃ) ពង្រឹងការអនុវត្តជាក់ស្ដែងនៃគោលការណ៍ និងវិន័យ ដែលមាននៅក្នុងកិច្ចព្រមព្រៀង SPS ។

## មាត្រា ២
## វិសាលភាព

ជំពូកនេះត្រូវតែអនុវត្តរាល់គ្រប់វិធានការអនាម័យ និងភូតគាមអនាម័យនៃភាគីមួយ ដែលអាចដោយផ្ទាល់ ឬប្រយោល ប៉ះពាល់ពាណិជ្ជកម្មក្នុងចំណោមបណ្ដាភាគី ។

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ :

(ក) **អាជ្ញាធរមានសមត្ថភាព** មានន័យថា អាជ្ញាធរទាំងឡាយនៅក្នុងភាគីនីមួយៗ ដែលទទួលស្គាល់ដោយរដ្ឋាភិបាលជាតិ ក្នុងការទទួលបន្ទុកសម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងវិធានការអនាម័យ និងភូតគាមអនាម័យ នៅក្នុងភាគីនោះ

(ខ) **ស្តង់ដារអន្តរជាតិ ការណែនាំ និងអនុសាសន៍** ត្រូវមានន័យដូចគ្នា ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ៣ ឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀង SPS

(គ) **វិធានការអនាម័យ ឬភូតគាមអនាម័យ** មានន័យដូចគ្នា ដូចដែលមានចែងនៅក្នុងកថាខណ្ឌ ១ ឧបសម្ព័ន្ធ ក នៃកិច្ចព្រមព្រៀង SPS និង

(ឃ) **កិច្ចព្រមព្រៀង SPS** មានន័យថា *កិច្ចព្រមព្រៀងស្តីពីបែបបទនៃវិធានការអនាម័យ ឬភូតគាមអនាម័យ* ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ A នៃកិច្ចព្រមព្រៀង WTO ។

## មាត្រា ៤
## បទប្បញ្ញត្តិទូទៅ

១. ភាគីនីមួយៗត្រូវបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ច ដោយគោរពតាមភាគីដទៃទៀត ក្រោមកិច្ចព្រមព្រៀង SPS ។

២. ភាគីនីមួយៗ សន្យាអនុវត្តគោលការណ៍នៃកិច្ចព្រមព្រៀង SPS នៅក្នុងការអភិវឌ្ឍបែបបទ ឬការទទួលស្គាល់នូវវិធានការអនាម័យ ឬភូតគាមអនាម័យណាមួយ ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម ក្នុងចំណោមបណ្តាភាគី ដើម្បីការពារមនុស្ស សត្វ ឬរុក្ខជាតិមានជីវិត ឬសុខភាព នៅក្នុងដែនដីនៃភាគីនីមួយៗ ។

## មាត្រា ៥
## សមមូលភាព

១. បណ្តាភាគី ត្រូវពង្រឹងសហប្រតិបត្តិការស្តីពីសមមូលភាព ដោយផ្អែកទៅលើកិច្ចព្រមព្រៀង SPS និងពាក់ព័ន្ធនឹងស្តង់ដាអន្តរជាតិ ការណែនាំ និងអនុសាសន៍ ដើម្បីសម្រួលពាណិជ្ជកម្មក្នុងចំណោមបណ្តាភាគី ។

២. ដើម្បីសម្រួលពាណិជ្ជកម្ម អាជ្ញាធរមានសមត្ថភាពនៃបណ្តាភាគីពាក់ព័ន្ធ អាចអភិវឌ្ឍការរៀបចំសមមូលភាព និងធ្វើការសំរេចសមមូលភាពដោយឡែកផ្អែកតាមមាត្រា ៤ នៃកិច្ចព្រមព្រៀង SPS ទៅតាមការណែនាំដែលបានផ្តល់ដោយស្ថាប័នស្តង់ដាអន្តរជាតិពាក់ព័ន្ធ និងដោយគណៈកម្មាធិការ WTO ស្តីពីវិធានការអនាម័យ ឬភូតគាមអនាម័យដែលបានបង្កើត អនុលោមតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង SPS ។

៣. ភាគីមួយត្រូវនៅពេលមានការស្នើសុំ ដើម្បីពិគ្រោះក្នុងគោលបំណងសំរេចឱ្យបាននូវការរៀបចំការទទួលស្គាល់ជាទ្វេភាគី នៃសមមូលភាព ដែលបានបញ្ជាក់វិធានការអនាម័យ ឬភូតគាមអនាម័យ ។

## មាត្រា ៦

## អាជ្ញាធរមានសមត្ថភាព និងចំណុចទំនាក់ទំនង

១. ភាគីនីមួយៗ ត្រូវផ្តល់ឱ្យភាគីដទៃទៀតនូវការរៀបរាប់ពីអាជ្ញាធរមានសមត្ថកិច្ច និងផ្នែកទទួលបន្ទុក ។

២. ភាគីនីមួយៗ ត្រូវផ្តល់ឱ្យភាគីដទៃទៀតនូវចំណុចទំនាក់ទំនង ដើម្បីសម្រួលការចែកចាយនៃការស្នើសុំ ឬការជូនព័ត៌មាន ដែលបានធ្វើក្រោមជំពូកនេះ ។

៣. ភាគីនីមួយៗត្រូវប្រាកដថា ព័ត៌មានដែលបានផ្តល់ក្រោមកថាខណ្ឌ ១ និង ២ គឺត្រូវតែទាន់ហេតុការណ៍ ។

## មាត្រា ៧

## ការជូនដំណឹង

១. ភាគីនីមួយៗត្រូវជូនព័ត៌មានត្រឡប់វិញពីការផ្លាស់ប្តូរព័ត៌មានស្តីពីវិធានការអនាម័យ ភូតគាមអនាម័យ ។

២. ភាគីនីមួយៗ យល់ព្រមផ្តល់ព័ត៌មានឱ្យទាន់ពេលវេលា និងត្រឹមត្រូវ ដោយផ្ទាល់ទៅចំណុចទំនាក់ទំនងនៃភាគីពាក់ព័ន្ធ កាលបើ :

(ក) ការផ្លាស់ប្តូរនៃស្ថានភាពសុខភាពសត្វ ឬរុក្ខជាតិ ដែលប៉ះពាល់ដល់ពាណិជ្ជកម្ម

(ខ) អនាម័យ ឬភូតគាមអនាម័យចាំបាច់ មិនស្របតាមទំនិញនាំចេញ ដូចបានកំណត់ដោយភាគីនាំចូល និង

(គ) បទប្បញ្ញត្តិវិធានការអនាម័យ ឬភូតគាមអនាម័យ ដែលប្រឆាំង ឬប៉ះពាល់ដល់ការនាំចេញរបស់ភាគីដទៃទៀត ត្រូវបានចាត់ទុកថាចាំបាច់ ដើម្បីការពារមនុស្ស សត្វ ឬរុក្ខជាតិមានជីវិត ឬសុខភាព នៅក្នុងភាគីនាំចូល ។

៣. ភាគីនាំចេញត្រូវ ដូចដែលអាចធ្វើទៅបាន ខិតខំប្រឹងប្រែងផ្តល់ព័ត៌មាន ទៅភាគីនាំចូល ប្រសិនបើភាគីនាំចេញរកឃើញថា ទំនិញនាំចេញ អាចពាក់ព័ន្ធនឹងហានិភ័យ SPS សំខាន់ៗ ដែលបាននាំចេញ ។

## មាត្រា ៨

## កិច្ចសហប្រតិបត្តិការ

១. ភាគីនីមួយៗ ត្រូវស្វែងរកឱកាសសម្រាប់សហប្រតិបត្តិការបន្ថែម និងផ្លាស់ប្តូរព័ត៌មានជាមួយបណ្តាភាគីដទៃទៀត លើផលប្រយោជន៍សង្គតភាពទៅវិញទៅមក ស្តីពីបញ្ហាអនាម័យ និងភូតគាមអនាម័យក្នុងគោលបំណងនៃជំពូកនេះ ។

២.	ពាក់ព័ន្ធទៅនឹងកថាខណ្ឌ ១ ភាគីនីមួយៗត្រូវព្យាយាមសម្របសម្រួលកម្មវិធីតំបន់ ឬពហុភាគី ក្នុងគោលបំណងចៀសវាងការត្រួតគ្នាដែលមិនចាំបាច់ និងផ្តល់ផលប្រយោជន៍អតិបរមាពីការប្រើប្រាស់ធនធាន។

៣.	ភាគីនីមួយៗ ឯកភាពស្វែងរកបន្ថែមទៀត ត្រូវធ្វើយ៉ាងដូចម្តេចដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការស្តីពីបទប្បញ្ញត្តិ ជំនួយបច្ចេកទេស ជាពិសេសពាក់ព័ន្ធទៅនឹងការសម្រួលពាណិជ្ជកម្ម។

៤.	ភាគីទាំងពីរណាមួយ តាមការព្រមព្រៀងទៅវិញទៅមក សហការសម្របទៅនឹងលក្ខខណ្ឌតំបន់ យោងតាមកិច្ចព្រមព្រៀង SPS និងពាក់ព័ន្ធស្តង់ដាអន្តរជាតិ ការណែនាំ និងអនុសាសន៍ ដើម្បីសម្រួលពាណិជ្ជកម្ម ក្នុងចំណោមបណ្តាភាគី។

## មាត្រា ៩
## ការពិគ្រោះយោបល់

នៅពេលដែលភាគីមួយពិចារណាថា វិធានការអនាម័យ ឬភូតគាមអនាម័យ ប៉ះពាល់ពាណិជ្ជកម្មរវាងខ្លួន និងភាគីដទៃទៀត អនុញ្ញាតឱ្យពិភាក្សាបន្ថែម តាមរយៈចំណុចទំនាក់ទំនង ស្នើសុំឱ្យមានការពន្យល់លំអិត ពីវិធានការអនាម័យ ឬភូតគាមអនាម័យ និងប្រសិនបើចាំបាច់ ស្នើសុំឱ្យមានការពិគ្រោះយោបល់ ក្នុងការខិតខំប្រឹងប្រែងដោះស្រាយកង្វល់ណាមួយ លើបញ្ហាដែលកើតឡើងពីបែបបទនៃវិធានការអនាម័យ ឬភូតគាមអនាម័យ។ ភាគីដទៃទៀតត្រូវឆ្លើយតបយ៉ាងរហ័សទៅនឹងសំណើសម្រាប់ការពន្យល់ និងប្រសិនបើការស្នើសុំ ត្រូវតែចាប់ផ្តើមពិគ្រោះក្នុងរយៈពេល ៣០ថ្ងៃ ពីកាលបរិច្ឆេទនៃការស្នើសុំ។ បណ្តាភាគីពិគ្រោះ ត្រូវខំប្រឹងប្រែងដើម្បីឈានទៅរកដំណោះស្រាយជាទីពេញចិត្តទៅវិញទៅមក តាមការពិគ្រោះក្នុងរយៈពេល ៦០ ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការស្នើសុំ ឬតាមពេលវេលាដែលព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគីពិគ្រោះ។ ប្រសិនបើការពិគ្រោះបរាជ័យ បញ្ហាត្រូវបញ្ជូនបន្តទៅគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី។

## មាត្រា ១០
## ជំនួបក្នុងចំណោមបណ្តាភាគីស្តីពីបញ្ហាអនាម័យ និងភូតគាមអនាម័យ

១.	បណ្តាភាគីតាមរយៈនេះ បង្កើតអនុគណៈកម្មាធិការស្តីពីបញ្ហាអនាម័យ និងភូតគាមអនាម័យ (អនុគណៈកម្មាធិការ SPS) ដែលរួមមានតំណាងពីស្ថាប័នរដ្ឋពាក់ព័ន្ធនៃភាគីនីមួយៗ។ អនុគណៈកម្មាធិការ SPS ត្រូវជួបគ្នាក្នុងរយៈពេល ១ ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងបន្ទាប់មកធ្វើការកំណត់នៃការជួបទៅវិញទៅមកដោយបណ្តាភាគី។

២. អនុគណៈកម្មាធិការ SPS ត្រូវពិនិត្យឡើងវិញនូវការរីកចម្រើនដែលបានធ្វើដោយបណ្តាភាគី ក្នុងការអនុវត្តការសន្យាក្រោមជំពូកនេះ និងអាចបង្កើតក្រុមការងារជំនួយ ដូចដែលបានព្រមព្រៀងរវាង ឬក្នុងចំណោមបណ្តាភាគីពាក់ព័ន្ធ ដើម្បីពិចារណាចំពោះបញ្ហាទាក់ទងជំពូកនេះ។

៣. អាជ្ញាធរមានសមត្ថកិច្ច នៃភាគីទាំងពីរ អាចជួបគ្នាដើម្បីធ្វើការសំរេចទ្វេភាគី ដើម្បីអនុវត្តការសន្យាក្រោមជំពូកនេះ។ ភាគីនីមួយៗត្រូវផ្តល់ឱ្យទាន់ហេតុការណ៍ ទៅអនុគណៈកម្មាធិការ SPS នូវស្ថានភាពការងាររបស់ពួកគេ ។

៤. ប្រធានបទទៅនឹងកថាខណ្ឌ ១ កិច្ចប្រជុំនៅក្រោមមាត្រានេះ ត្រូវកើតឡើង និងនៅពេលដែលមានការកំណត់ទៅវិញទៅមកដោយបណ្តាភាគីពាក់ព័ន្ធ និងគ្រប់ការសម្រេចចិត្ត និង/ឬ ការរក្សាទុកឯកសារ ដែលបានធ្វើត្រូវមានការព្រមព្រៀងទៅវិញទៅមកពីបណ្តាភាគីពាក់ព័ន្ធ។ កិច្ចប្រជុំអាចកើតឡើងតាមរយៈប្រព័ន្ធសន្និសីទទូរគមនាគមន៍ សន្និសីទវីដេអូ ឬតាមរយៈមធ្យោបាយផ្សេងៗដទៃទៀត ដែលបានកំណត់ទៅវិញទៅមក ដោយបណ្តាភាគី។

## មាត្រា ១១
## ការមិនអនុវត្តជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ)

ជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) មិនត្រូវបានអនុវត្ត ចំពោះបញ្ហាណាមួយដែលកើតឡើងក្រោមជំពូកនេះ។

# ជំពូក ៦
# ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស
# និងនីតិវិធីវាយតម្លៃភាពស្របគ្នា

## មាត្រា ១
## គោលបំណង

គោលបំណងនៃជំពូកនេះគឺ សម្រួលពាណិជ្ជកម្មទំនិញក្នុងចំណោមបណ្តាភាគី ដោយ :

(ក) ធ្វើឱ្យប្រាកដថា ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា មិនបង្កើតឧបសគ្គដែលមិនចាំបាច់ដល់ពាណិជ្ជកម្ម

(ខ) ជម្រុញការយល់ដឹងគ្នាទៅវិញទៅមក ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា របស់ភាគីនីមួយៗ

(គ) ពង្រឹងការផ្លាស់ប្តូរព័ត៌មាន សហប្រតិបត្តិការក្នុងចំណោមបណ្តាភាគី ដែលពាក់ព័ន្ធទៅនឹងការរៀបចំ អនុម័ត និងបែបបទ ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

(ឃ) ពង្រឹងសហប្រតិបត្តការក្នុងចំណោមបណ្តាភាគី ក្នុងការងាររបស់ស្ថាប័នអន្តរជាតិពាក់ព័ន្ធទៅនឹង ស្តង់ដា និងការវាយតម្លៃភាពស្របគ្នា និង

(ង) ផ្តល់ក្របខ័ណ្ឌសម្រាប់អនុវត្តយន្តការគាំទ្រ ដើម្បីសំរេចគោលបំណងទាំងនោះ ។

## មាត្រា ២
## វិសាលភាព

១. សម្រាប់ផលប្រយោជន៍ទៅវិញទៅមកនៃបណ្តាភាគី ជំពូកនេះអនុវត្តចំពោះស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា នៃបណ្តាភាគីដែលអាចប៉ះពាល់ពាណិជ្ជកម្មទំនិញរវាងបណ្តាភាគី លើកលែងតែ :

(ក) ការទិញនូវការបញ្ជាក់នានា ដែលរៀបចំដោយស្ថាប័នរដ្ឋាភិបាល សម្រាប់តម្រូវការផលិតកម្ម ឬ ការប្រើប្រាស់នៃស្ថាប័ននោះ និង

(ខ) វិធានការអនាម័យ និងភូតគាមអនាម័យដែលបានកំណត់នៅក្នុងជំពូក ៥ (វិធានការអនាម័យ និងភូតគាមអនាម័យ)។

២. គ្មានអ្វីក្នុងជំពូកនេះត្រូវដាក់កម្រិតដល់សិទ្ធិនៃភាគីមួយសម្រាប់រៀបចំ អនុម័ត និងអនុវត្តស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា លើកលែងតែភាពចាំបាច់ដើម្បីបំពេញគោលបំណងស្របច្បាប់។ គោលបំណងស្របច្បាប់ទាំងនោះមាន ដូចជា តម្រូវការសន្តិសុខជាតិ ការពារការអនុវត្តខុសពីភាពជាក់ស្តែង ការការពារសុខភាព ឬសុវត្ថិភាពមនុស្ស សត្វ រុក្ខជាតិមានជីវិត ឬសុខភាព ឬបរិស្ថាន។

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ១ នៃ*កិច្ចព្រមព្រៀងស្តីពីរបាំងបច្ចេកទេសពាណិជ្ជកម្ម* (កិច្ចព្រមព្រៀង TBT) ក្នុងឧបសម្ព័ន្ធ ១A នៃកិច្ចព្រមព្រៀង WTO ត្រូវអនុវត្ត។

## មាត្រា ៤
## ការអះអាងនៃកិច្ចព្រមព្រៀងរបាំងបច្ចេកទេសពាណិជ្ជកម្ម

១. ភាគីនីមួយៗអះអាងពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដោយគោរពតាមភាគីដទៃទៀតក្រោមកិច្ចព្រមព្រៀង TBT។

២. ភាគីនីមួយៗត្រូវប្រើប្រាស់វិធានការសមហេតុផលដែលអាចរកបាន ដើម្បីធ្វើឱ្យប្រាកដពីភាពស្រប នៅក្នុងការអនុវត្តជំពូកនេះដោយរដ្ឋាភិបាលក្នុងស្រុក និងស្ថាប័នក្រៅរដ្ឋាភិបាលនៅក្នុងដែនដីរបស់ខ្លួន ដែលទទួលបន្ទុករៀបចំ អនុម័ត និងអនុវត្តស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា។

## មាត្រា ៥
## ស្តង់ដា

១. ដោយគោរពទៅតាមការរៀបចំ អនុម័ត និងអនុវត្តស្តង់ដា ភាគីនីមួយៗត្រូវប្រាកដថា ស្ថាប័ន ឬបណ្តាស្ថាប័នរបស់ខ្លួនទទួល និងប្រតិបត្តិតាមឧបសម្ព័ន្ធ ៣ នៃកិច្ចព្រមព្រៀង TBT ។

២.    ភាគីនីមួយៗត្រូវលើកទឹកចិត្ត ស្ថាប័ន និងបណ្តាស្ថាប័នស្តង់ដានៅក្នុងដែនដីរបស់ខ្លួន សហការជាមួយស្ថាប័ន ឬបណ្តាស្ថាប័នស្តង់ដានៃបណ្តាភាគីដទៃទៀត។ ការសហការទាំងនោះ រួមបញ្ចូលទាំង តែមិនត្រូវដាក់កម្រិត ចំពោះ :

(ក)    ការផ្លាស់ប្តូរព័ត៌មានស្តីពីស្តង់ដា

(ខ)    ការផ្លាស់ប្តូរព័ត៌មានដែលពាក់ព័ន្ធទៅនឹងនីតិវិធីរៀបចំស្តង់ដា និង

(គ)    សហការជាមួយបណ្តាស្ថាប័នស្តង់ដាអន្តរជាតិ ចំពោះវិស័យដែលមានផលប្រយោជន៍ទៅវិញទៅមក

## មាត្រា ៦

## បទប្បញ្ញត្តិបច្ចេកទេស

១.    ទីណាដែលពាក់ព័ន្ធស្តង់ដាបច្ចេកទេសដែលមានស្រាប់ ឬការបញ្ចប់របស់វាមានរយៈពេលជិតមកដល់ភាគីនីមួយៗត្រូវប្រើប្រាស់វា ឬ ផ្នែកពាក់ព័ន្ធរបស់វា ជាមូលដ្ឋានសម្រាប់បទប្បញ្ញត្តិបច្ចេកទេស លើកលែងតែ ស្តង់ដាអន្តរជាតិ ឬផ្នែកពាក់ព័ន្ធរបស់វា មិនមែនជាមធ្យោបាយមានប្រសិទ្ធភាព ឬមិនសមរម្យសម្រាប់បំពេញគោលបំណងស្របច្បាប់ដែលស្វែងរក ដោយហេតុថាបញ្ហាពីមូលដ្ឋានបរិយាកាស កត្តាភូមិសាស្ត្រ ឬមូលដ្ឋានបច្ចេកវិទ្យា។

២.    ភាគីនីមួយៗត្រូវពិចារណាដោយវិជ្ជមាន ដើម្បីទទួលយកបទប្បញ្ញត្តិបច្ចេកទេសនៃបណ្តាភាគីដទៃទៀតដែលស្មើគ្នា ទោះបីជាបទប្បញ្ញត្តិទាំងនោះខុសពីរបស់ខ្លួនក៏ដោយ ដោយផ្តល់ថាខ្លួនពេញចិត្តបទប្បញ្ញត្តិទាំងនោះត្រឹមត្រូវសម្រាប់បំពេញគោលបំណងនៃបទប្បញ្ញត្តិរបស់ខ្លួន។

៣.    ពេលដែលភាគីមួយមិនទទួលយកបទប្បញ្ញត្តិបច្ចេកទេសនៃភាគីដទៃទៀត ដែលស្មើនឹងបទប្បញ្ញត្តិរបស់ខ្លួន នៅពេលដែលមានការស្នើសុំពីភាគីដទៃ ត្រូវពន្យល់ពីមូលហេតុនៃការសំរេចចិត្តរបស់ខ្លួន។

## មាត្រា ៧

## នីតិវិធីនៃការវាយតម្លៃភាពស្របគ្នា

១.    ភាគីនីមួយៗត្រូវពិចារណាដោយវិជ្ជមាន ដើម្បីទទួលយកលទ្ធផលនៃនីតិវិធីវាយតម្លៃភាពស្របគ្នារបស់បណ្តាភាគីដទៃទៀត ទោះបីនីតិវិធីទាំងនោះខុសពីនីតិវិធីរបស់ខ្លួនក៏ដោយ ដោយផ្តល់ថាខ្លួនពេញចិត្តនីតិវិធីទាំងនោះប្រាកដជាមានភាពស្រមគ្នា ជាមួយបែបបទបទប្បញ្ញត្តិបច្ចេកទេស ឬស្តង់ដា ដែលស្មើនឹងនីតិវិធីរបស់ខ្លួន។

២. ភាគីនីមួយៗ ត្រូវបង្កើនការទទួលស្គាល់នូវលទ្ធផលនៃនីតិវិធីវាយតម្លៃភាពស្របគ្នា ដែលបានធ្វើឡើងក្នុងដែនដីនៃបណ្តាភាគី ក្នុងគំនិតបង្កើនប្រសិទ្ធភាព ចៀសវាងការជាន់គ្នា និងប្រាកដពីប្រសិទ្ធភាពនៃការវាយតម្លៃភាពស្របគ្នា។ ពាក់ព័ន្ធទៅនឹងការងារនេះ ភាគីនីមួយៗអាចជ្រើសរើស ផ្អែកលើស្ថានការណ៍នៃភាគី និងកត្តាដោយឡែក ចូលរួមវិធីសាស្ត្រដោះស្រាយទូលំទូលាយ ។ ទាំងនេះអាចរួមបញ្ចូល ប៉ុន្តែមិនដាក់កម្រិតចំពោះ :

(ក) ការទទួលស្គាល់ដោយភាគីមួយពីលទ្ធផលនៃការប្រតិបត្តិវាយតម្លៃភាពស្របគ្នា នៅក្នុងដែនដី នៃភាគីដទៃទៀត

(ខ) ទទួលស្គាល់នៃការរៀបចំសហការរវាង ស្ថាប័នដែលមានអំណាចជំនាញនៅក្នុងដែនដីនៃបណ្តាភាគី

(គ) ការទទួលស្គាល់នីតិវិធីវាយតម្លៃភាពស្របគ្នាទៅវិញទៅមក ដែលបានធ្វើដោយស្ថាប័នដែលមានទីតាំងនៅក្នុងដែនដីនៃភាគីនីមួយៗ

(ឃ) ស្ថាប័នដែលមានអំណាចជំនាញនៃការវាយតម្លៃភាពស្របគ្នា នៅក្នុងដែនដីភាគីដទៃទៀត

(ង) ប្រើកិច្ចព្រមព្រៀង និងការរៀបចំដែលទទួលស្គាល់ ដែលមានស្រាប់នៅក្នុងតំបន់ និងពហុភាគីអន្តរជាតិ

(ច) ចាត់តាំងស្ថាប័នវាយតម្លៃភាពស្របគ្នាដែលមានទីតាំងនៅក្នុងដែនដីនៃភាគីដទៃទៀត ដើម្បីប្រតិបត្តិការវាយតម្លៃភាពស្របគ្នា និង

(ឆ) ប្រកាសនៃភាពស្របគ្នារបស់អ្នកផ្គត់ផ្គង់

៣. ភាគីនីមួយៗត្រូវផ្លាស់ប្តូរព័ត៌មានជាមួយបណ្តាភាគីដទៃទៀត ស្តីពីបទពិសោធន៍ក្នុងការអភិវឌ្ឍ និងបែបបទនៃវិធីសាស្ត្រដោះស្រាយនៅក្នុងកថាខណ្ឌ ២ (ក) ដល់ (ឆ) និងវិធីសាស្ត្រដោះស្រាយសមរម្យដទៃទៀតក្នុងគំនិតដើម្បីសម្រួលការទទួលស្គាល់លទ្ធផលនៃនីតិវិធីវាយតម្លៃភាពស្របគ្នា។

៤. ភាគីមួយត្រូវ នៅពេលដែលមានការស្នើសុំពីភាគីដទៃទៀត ពន្យល់ពីមូលហេតុដែលខ្លួនមិនទទួលស្គាល់លទ្ធផលនៃនីតិវិធីវាយតម្លៃភាពស្របគ្នាណាមួយ ដែលបានប្រតិបត្តិនៅក្នុងដែនដីនៃបណ្តាភាគីដទៃទៀតនោះ។

## មាត្រា ៨
## កិច្ចសហប្រតិបត្តិការ

១.	បណ្តាភាគីត្រូវខិតខំប្រឹងប្រែងចូលរួមឱ្យបានខ្លាំងក្លានៅក្នុងវិស័យស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ក្នុងគំនិតសម្រួលការចូលទីផ្សារគ្នាទៅវិញទៅមក។

២.	ភាគីនីមួយៗ នៅពេលដែលមានការស្នើសុំពីបណ្តាភាគីដទៃទៀត ការពិចារណាវិជ្ជមានទៅនឹងសំណើ ដើម្បីបន្ថែមកិច្ចសហប្រតិបត្តិការដែលមានស្រាប់ស្តីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា។ កិច្ចសហប្រតិបត្តិការទាំងនោះ អាចរួមបញ្ចូលលក្ខខណ្ឌនៃការសំរេចចិត្តទៅវិញទៅមក ប៉ុន្តែមិនដាក់កម្រិត ចំពោះ :

(ក)	ការណែនាំ ឬជំនួយបច្ចេកទេសពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ និងបែបបទស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

(ខ)	សហប្រតិបត្តិការរវាងស្ថាប័នវាយតម្លៃភាពស្របគ្នា ទាំងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលក្នុងបណ្តាដែនដីនៃបណ្តាភាគីនីមួយៗ ដូចជា :

(i)	ប្រើប្រាស់ស្ថាប័នគុណភាពជំនាញដើម្បីបញ្ជាក់ការវាយតម្លៃភាពស្របគ្នា និង

(ii)	ពង្រឹងហេដ្ឋារចនាសម្ព័ន្ធចំពោះ មាត្រដ្ឋាន សាកល្បង ត្រួតពិនិត្យ វិញ្ញាបនបត្រ និងគុណភាព ដើម្បីតម្រូវទៅដល់ការពាក់ព័ន្ធស្តង់ដាអន្តរជាតិ អនុសាសន៍ និងការណែនាំ។

(គ)	សហប្រតិបត្តិការក្នុងវិស័យការងារមានប្រយោជន៍ទៅវិញទៅមក ដែលពាក់ព័ន្ធទៅនឹងស្ថាប័ន នៅក្នុងតំបន់ និងអន្តរជាតិ ចំពោះការអភិវឌ្ឍ និងបែបបទនៃស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ដូចជាការពង្រឹងការចូលរួមនៅក្នុងក្របខណ្ឌដែលមានស្រាប់ សម្រាប់ទទួលស្គាល់ទៅវិញទៅមកដែលបានបង្កើតដោយស្ថាប័នតំបន់ និងអន្តរជាតិដែលពាក់ព័ន្ធ និង

(ឃ)	ពង្រឹងសហប្រតិបត្តិការក្នុងការអភិវឌ្ឍ និងលើកកំពស់បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធី វាយតម្លៃភាពស្របគ្នា ដូចជា :

(i)	សហប្រតិបត្តិការនៅក្នុងការអភិវឌ្ឍ និងជម្រុញបែបបទការអនុវត្តជាក់ស្តែងដែលល្អៗ

(ii)	តម្លាភាព រួមទាំងវិធីដើម្បីជម្រុញលើកកំពស់ការប្រើប្រាស់ព័ត៌មានស្តីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា និង

(iii) គ្រប់គ្រងហានិភ័យពាក់ព័ន្ធ សុខភាព សុវត្ថិភាព បរិដ្ឋាន និងការអនុវត្តខុសពីភាពជាក់ស្តែង

៣. នៅពេលដែលមានការស្នើសុំពីភាគីដទៃទៀត ភាគីមួយត្រូវផ្តល់ការពិចារណាវិជ្ជមាន ចំពោះវិស័យជាក់លាក់ ដែលភាគីបានស្នើធ្វើសហប្រតិបត្តិការបន្ថែមក្រោមជំពូកនេះ ។

## មាត្រា ៩
## ការពិគ្រោះយោបល់

១. ភាគីនីមួយៗត្រូវផ្តល់យ៉ាងរហ័ស និងការពិចារណាវិជ្ជមានចំពោះការស្នើសុំណាមួយពីភាគីដទៃទៀត សម្រាប់ពិគ្រោះយោបល់លើបញ្ហាពាក់ព័ន្ធនៃការអនុវត្តជំពូកនេះ ។

២. ពេលដែលបញ្ហាមួយបានគ្របដណ្តប់ ក្រោមជំពូកនេះមិនអាចបញ្ជាក់ឱ្យច្បាស់លាស់ និងដោះស្រាយបាន ដែលជាលទ្ធផលទទួលបានពីការពិគ្រោះយោបល់ បណ្តាភាគីចំណាប់អារម្មណ៍អាចបង្កើតក្រុមការងារក្នុងគំនិត ដើម្បីកំណត់ដំណោះស្រាយ ដែលអាចប្រើការ និងអនុវត្តបានសម្រាប់សម្រួលពាណិជ្ជកម្ម ។ ក្រុមការងារត្រូវរួមមានតំណាងពីបណ្តាភាគីចំណាប់អារម្មណ៍ ។

៣. ពេលដែលភាគីមួយបដិសេធការស្នើសុំពីភាគីដទៃទៀតដើម្បីបង្កើតក្រុមការងារ នៅពេលដែលមានការស្នើសុំពីភាគីដទៃទៀត ត្រូវតែពន្យល់ពីមូលហេតុនៃការសំរេចចិត្តនេះ ។

## មាត្រា ១០
## កិច្ចព្រមព្រៀងនានា ឬ ការរៀបចំនានា

១. បណ្តាភាគីត្រូវកំណត់គំនិតផ្តួចផ្តើម សម្រួលពាណិជ្ជកម្មពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិបច្ចេកទេស និង នីតិវិធីវាយតម្លៃភាពស្របគ្នា ដែលសមរម្យសម្រាប់បញ្ហា ឬវិស័យដោយឡែក ។

២. គំនិតផ្តួចផ្តើមសម្រួលពាណិជ្ជកម្មនោះ អាចរួមមានបណ្តាកិច្ចព្រមព្រៀង ឬបណ្តាការរៀបចំ ស្តីពីបទប្បញ្ញត្តិបញ្ហា ដូចជា ការតម្រាប់ស្តង់ដា ការរួមគ្នា ឬស្មើភាពនៃបទប្បញ្ញត្តិបច្ចេកទេស និតិវិធីវាយតម្លៃភាពស្របគ្នា និងបញ្ហាប្រតិបត្តិ ។

៣. បណ្តាភាគីនៃកិច្ចព្រមព្រៀង ឬការរៀបចំដែលមានស្រាប់ ត្រូវពិចារណាផ្តល់កិច្ចព្រមព្រៀង ឬការរៀបចំនោះទៅភាគីដទៃទៀត នៅពេលមានការស្នើសុំដោយភាគីនោះ ។ ការពិចារណានោះអាចជាប្រធានបទសម្រាប់នីតិវិធី

បង្កើតការជឿជាក់ដែលត្រឹមត្រូវ ដើម្បីប្រាកដពីភាពស្មើគ្នានៃស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និង/ឬ នីតិវិធីវាយតម្លៃភាពស្របគ្នា ។

៤. ពេលដែលភាគីមួយបដិសេធការស្នើសុំពីភាគីដទៃទៀត ដើម្បីពិចារណាផ្តល់ឱ្យនូវបែបបទនៃកិច្ចព្រមព្រៀង ឬ ការរៀបចំដែលមានស្រាប់ ពេលដែលមានការស្នើសុំពីភាគីនោះ ត្រូវពន្យល់ពីមូលហេតុនៃការសំរេចចិត្តរបស់ខ្លួន ។

## មាត្រា ១១

## តម្លាភាព

១. ភាគីនីមួយៗអះអាងពីការសន្យា ដើម្បីប្រាកដថា ព័ត៌មានពាក់ព័ន្ធទៅនឹងសំណើថ្មី ឬការកែប្រែពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ត្រូវធ្វើឱ្យរកបានទៅតាមតម្រូវការពាក់ព័ន្ធនៃកិច្ចព្រមព្រៀង TBT ។

២. ភាគីនីមួយៗត្រូវប្រាកដថា ព័ត៌មានពាក់ព័ន្ធទៅនឹងស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នាត្រូវបានផ្សព្វផ្សាយ ។ ព័ត៌មានទាំងនោះត្រូវធ្វើឱ្យរកបាន ។

## មាត្រា ១២

## ចំណុចទំនាក់ទំនង

១. ភាគីនីមួយៗត្រូវចាត់តាំងចំណុចទំនាក់ទំនង ឬបណ្តាចំណុចទំនាក់ទំនង ទទួលបន្ទុកសម្រាប់សម្របសម្រួលការអនុវត្តនៃជំពូកនេះរបស់ភាគីនោះ ។

២. ភាគីនីមួយៗ ត្រូវផ្តល់ឱ្យបណ្តាភាគីនូវឈ្មោះចំណុចទំនាក់ទំនង ឬបណ្តាចំណុចទំនាក់ទំនង ដែលបានចាត់តាំង និងលំអិតពីចំណុចទំនាក់ទំនងសម្រាប់មន្ត្រីពាក់ព័ន្ធនៅក្នុងស្ថាប័ននោះ ដែលរួមមាន ទូរស័ព្ទ ទូរសារ អ៊ីម៉ែល និងលំអិតពីព័ត៌មានពាក់ព័ន្ធដទៃទៀត ។

៣. ភាគីនីមួយៗ ត្រូវជូនដំណឹងទៅភាគីនីមួយៗនៃបណ្តាភាគីដទៃទៀតជាប្រញាប់ពីការផ្លាស់ប្តូរចំណុច ទំនាក់ទំនងរបស់ពួកគេ ឬការកែប្រែណាមួយទៅនឹងលំអិតនៃមន្ត្រីដែលពាក់ព័ន្ធ ។

៤.	ភាគីនីមួយៗ ត្រូវប្រាកដថាចំណុចទំនាក់ទំនង ឬបណ្តាចំណុចទំនាក់ទំនងរបស់ខ្លួន ជួយសម្រួលការផ្លាស់ប្តូរព័ត៌មានរវាងបណ្តាភាគីស្តីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា ដើម្បីឆ្លើយតបទៅនឹងការស្នើសុំ ដែលសមហេតុផលចំពោះព័ត៌មានពីភាគីមួយ ។

## មាត្រា ១៣

## អនុគណៈកម្មការស្តីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា

១.	បណ្តាភាគី តាមរយៈនេះ បង្កើតអនុគណៈកម្មាធិការស្តីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា (អនុគណៈកម្មាធិការ STRACAP) ដែលរួមមានតំណាងពីបណ្តាភាគី ដើម្បីជម្រុញការត្រួតពិនិត្យការអនុវត្ត និងគ្រប់គ្រងនៃជំពូកនេះ ។

២.	អនុគណៈកម្មាធិការ STRACAP ត្រូវជួបតាមការកំណត់ទៅវិញទៅមកដោយបណ្តាភាគី ។ កិច្ចប្រជុំអាចធ្វើឡើងតាមការជួបគ្នា ឬតាមមធ្យោបាយផ្សេងដទៃទៀតដូចដែលបានកំណត់ទៅវិញទៅមក ដោយបណ្តាភាគី ។

៣.	អនុគណៈកម្មាធិការ STRACAP ត្រូវកំណត់លក្ខខណ្ឌការងារ អនុលោមតាមជំពូកនេះ ។

៤.	អនុគណៈកម្មាធិការ STRACAP ត្រូវកំណត់កម្មវិធីការងារ ដើម្បីឆ្លើយតបទៅនឹងអាទិភាពទាំងឡាយដែលបានកំណត់ដោយបណ្តាភាគី ។

# ជំពូក ៧
# វិធានការការពារ

## មាត្រា ១
## វិសាលភាព

ជំពូកនេះអនុវត្តទៅលើវិធានការការពារទាំងឡាយណា ដែលបានទទួលបានការអនុម័ត ឬ គោរពតាមដោយភាគីមួយ ដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មលើទំនិញ ក្នុងចំណោមភាគីដទៃទៀតក្នុងអំឡុងពេលនៃវិធានការជាអន្តរកាល។

## មាត្រា ២
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ :

ក- **ឧស្សាហកម្មក្នុងស្រុក** ដែលទាក់ទងទៅទំនិញនាំចូល មានន័យថាផលិតករទាំងអស់ក្នុងប្រភេទដូច ឬ ទំនិញដែលមានលក្ខណៈប្រកួតប្រជែងដោយផ្ទាល់ ធ្វើប្រតិបត្តិការនៅក្នុងភាគីមួយ ឬផលិតករទាំងឡាយណា ដែលមានផលិតផលដូចគ្នា ឬ ទំនិញដែលមានលក្ខណៈប្រកួតប្រជែងដោយផ្ទាល់ ដែលមានបរិមាណមួយភាគធំនៃផលិតកម្មក្នុងស្រុកសរុបនៃទំនិញទាំងនោះ

ខ- **វិធានការការពារសកល** មានន័យថា វិធានការដែលអនុវត្តអនុលោមទៅតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅស្តីអំពីពន្ធគយ និងពាណិជ្ជកម្ម (GATT) ឆ្នាំ១៩៩៤ និង *កិច្ចព្រមព្រៀងស្តីអំពីវិធានការការពារ* នៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (កិច្ចព្រមព្រៀងនៃវិធានការការពារ) ឬ មាត្រា ៥ នៃ *កិច្ចព្រមព្រៀងស្តីអំពីកសិកម្ម* នៅក្នុងឧបសម្ព័ន្ធ ១ក នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (កិច្ចព្រមព្រៀងស្តីពីកសិកម្ម)

គ- **វិធានការបណ្តោះអាសន្ន** មានន័យថា វិធានការបណ្តោះអាសន្នដែលមានចែងនៅក្នុងមាត្រា ៧ (វិធានការការពារបណ្តោះអាសន្ន)

ឃ- **វិធានការការពារ** មានន័យថា ជាវិធានការការពារបណ្តោះអាសន្ន ដែលមានចែងនៅក្នុងមាត្រា ៦ (វិសាលភាព និងរយៈពេលនៃវិធានការការពារបណ្តោះអាសន្ន)

ង- **ការខូចខាតធ្ងន់ធ្ងរ** មានន័យថា ជាការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក ដែលមានលក្ខណៈខ្លាំង ជាទូទៅ

ច- **ការគំរាមកំហែងដល់ការខូចខាតធ្ងន់ធ្ងរ** មានន័យថា ការខូចខាតធ្ងន់ធ្ងរ ដែលនឹងកើតមានឡើង មិនអាចចៀសបានដោយផ្អែកទៅលើអង្គហេតុ និងមិនមែនផ្អែកតែលើការចោទប្រកាន់ការប៉ាន់ប្រមាណ ឬ លទ្ធភាពវិភាគណាមួយប៉ុណ្ណោះ, និង

ឆ- **រយៈពេលវិធានការការពារអន្តរកាល** មានន័យថា ពេលវេលាចាប់ពីពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន រហូតដល់បីឆ្នាំបន្ទាប់ពីអត្រាពន្ធលើទំនិញនោះនឹងត្រូវគេលុបចោល ឬ កាត់បន្ថយមកត្រឹមកម្រិត នៃការសន្យាចុងក្រោយបង្អស់ អនុលោមតាមកាលវិភាគរបស់ភាគីស្តីអំពីការសន្យា លើអត្រាពន្ធដែលទាក់ទងទៅនឹងទំនិញជាក់លាក់ណាមួយ ដូចមាននៅក្នុងឧបសម្ព័ន្ធ ១ (តារាងសន្យាពន្ធគយ) ។

## មាត្រា ៣
## ការចេញវិធានការការពារ

កើតចេញពីលទ្ធផលនៃការកាត់បន្ថយ ឬ លុបចោលពន្ធគយក្រោមកិច្ចព្រមព្រៀងនេះ ប្រសិនបើទំនិញដើមនៃភាគីណាមួយផ្សេងទៀត ឬ ច្រើន កំពុងត្រូវបានគេនាំចូលដែលមានបរិមាណច្រើន មកក្នុងដែនដីនៃភាគីមួយ ក្នុងអំឡុងពេលនៃរយៈពេល វិធានការការពារអន្តរកាលលើទំនិញនោះ នៅក្នុងលក្ខខ័ណ្ឌដាច់ខាត ឬ ដែលទាក់ទងទៅនឹងផលិតកម្មក្នុងស្រុក និងស្ថិតក្រោមលក្ខខ័ណ្ឌដែលនឹងធ្វើឱ្យ ឬគំរាមកំហែងធ្វើឱ្យមានការខូតខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុកដែលផលិតទំនិញដូចគ្នា ឬ ទំនិញដែលមានលក្ខណៈប្រកួតប្រជែងដោយផ្ទាល់ភាគីនោះអាច :

ក- ផ្អាកការកាត់បន្ថយបន្ថែមទៀតនៃអត្រាណាមួយ នៃពន្ធគយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីទំនិញនេះ ឬ

ខ- បង្កើនអត្រាពន្ធគយលើទំនិញ មកត្រឹមកម្រិតដែលមិនតិចជាងនៃ :

(i) អត្រាពន្ធដែលអនុវត្តចំពោះប្រទេសដែលអនុគ្រោះបំផុត លើទំនិញនោះដែលមានប្រសិទ្ធភាព នៅពេលដែលវិធានការនោះត្រូវបានគេដាក់ចេញ, ឬ

(ii) អត្រាពន្ធដែលអនុវត្តចំពោះប្រទេសដែលអនុគ្រោះបំផុត លើទំនិញនោះដែលមានប្រសិទ្ធភាព នៅថ្ងៃបន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមានភ្លាម ។

## មាត្រា ៤
## ការស៊ើបអង្កេត

១. ភាគីអាចដាក់ចេញវិធានការការពារ តែនៅពេលបន្ទាប់ពីមានការស៊ើបអង្កេតធ្វើឡើង ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនោះ អនុលោមទៅតាមនីតិវិធីដូចមានចែងនៅក្នុងមាត្រា ៣ និង មាត្រា ៤.២ នៃកិច្ចព្រមព្រៀងនៃវិធានការការពារ និងចុងបញ្ចប់មាត្រា ៣ និង មាត្រា ៤.២ នៃកិច្ចព្រមព្រៀងវិធានការការពារនឹងត្រូវគេបញ្ចូល និង ត្រូវក្លាយជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ដោយអនុវត្តដូចគ្នា ។

២. ភាគីនីមួយៗត្រូវបញ្ជាក់ថា អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនបានបញ្ចប់នូវការស៊ើបអង្កេតណាមួយឱ្យបានឆាប់រហ័ស និងទោះជាក្នុងកាលៈទេសៈណាក៏ដោយ នៅក្នុងអំឡុងពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមស៊ើបអង្កេតដំបូង ។

## មាត្រា ៥
## ការជូនដំណឹង

១. ភាគីត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីដទៃផ្សេងទៀត ដោយលាយលក្ខណ៍អក្សរ អំពី :

ក- ការចាប់ផ្តើមស៊ើបអង្កេត ដែលមានចែងក្នុងមាត្រា ៤ (ការស៊ើបអង្កេត)

ខ- ធ្វើការស្វែងរកការរងគ្រោះធ្ងន់ធ្ងរ ឬការគំរាមកំហែងតាំងពីនោះ ដោយសារតែមានការកើនឡើងលើបរិមាណនៃការនាំចូលទំនិញដែលមានប្រភពដើមនៃភាគីណាមួយផ្សេងទៀត ឬ ច្រើន ដែលកើតឡើងដោយសារតែមានការកាត់បន្ថយ ឬ លប់បំបាត់នៃពន្ធគយលើទំនិញដែលមានប្រភពដើមនោះ

គ- ធ្វើសេចក្តីសម្រេចចិត្ត ដើម្បីអនុវត្ត ឬ ពន្យារវិធានការការពារ

ឃ- ធ្វើសេចក្តីសម្រេចចិត្ត ធ្វើសេរីកម្មទៅមុខទៀតចំពោះវិធានការការពារដែលមានស្រាប់ ឬ

ង- អនុវត្តវិធានការការពារបណ្តោះអាសន្ន។

២.	ភាគីត្រូវផ្តល់ជាបន្ទាន់ទៅភាគីដទៃទៀតនូវច្បាប់ចម្លងមួយច្បាប់ នៃរបាយការណ៍ជាសាធារណៈដែលអាជ្ញាធរមានសមត្ថកិច្ចបានធ្វើឡើងក្រោមមាត្រា ៤ ( ការស៊ើបអង្កេត) ។

៣.	នៅក្នុងការជូនដំណឹងអនុលោមតាមកថាខណ្ឌ១ (គ) ភាគីដែលអនុវត្ត ឬ ពន្យារពេលវិធានការការពារ ដែលមានស្រាប់ ត្រូវផ្តល់នូវភស្តុតាង ឬការគំរាមកំហែងនៃការរងគ្រោះដ៏ធ្ងន់ធ្ងរ ដោយសារការនាំចូលក្នុងបរិមាណមួយធំនៃទំនិញដែលមានប្រភពដើមនៃភាគីមួយផ្សេងទៀត ឬច្រើនដែលកើតឡើងដោយសារតែការកាត់បន្ថយ ឬលុបចោលពន្ធគយ ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ។ ការជូនដំណឹងនេះ រួមមាន :

ក- ការបរិយាយច្បាស់លាស់អំពីទំនិញដែលមានប្រភពដើម អនុលោមទៅតាមវិធានការការពារ ដែលបានស្នើ រួមទាំងលេខជំពូក ឬអនុជំពូក ក្រោមលេខកូដប្រព័ន្ធសុខុមដុមកម្ម (HS) ទៅតាមកាលវិភាគនៃការសន្យាអត្រាពន្ធក្នុងឧបសម្ព័ន្ធ ១ (តារាងការសន្យាពន្ធគយ)

ខ- ការបរិយាយច្បាស់លាស់អំពីវិធានការការពារដែលស្នើឡើង, និង

គ- កាលបរិច្ឆេទនៃវិធានការពារដែលស្នើឡើង រយៈពេលដែលរំពឹងទុក និង កាលបរិច្ឆេទនៃការធ្វើសេរីភាវូបនីយកម្មលើវិធានការនោះ ប្រសិនបើមាន។ នៅក្នុងករណីដែលមានការពន្យាពេលនៃការអនុវត្តវិធានការនោះ ត្រូវផ្តល់ភស្តុតាងដែលអាចបញ្ជាក់ថា ឧស្សាហកម្មក្នុងស្រុកដែលពាក់ព័ន្ធ នឹងមានការកែសម្រួលនោះ។ តាមការស្នើ ភាគីដែលបន្តអនុវត្ត ឬ ពន្យារវិធានការការពារ ត្រូវផ្តល់ព័ត៌មានបន្ថែម ប្រសិនបើភាគីមួយទៀត ឬ ច្រើនទៀតពិចារណាថាចាំបាច់។

៤.	ភាគីដែលស្នើអនុវត្ត ឬពន្យាវិធានការការពារ ត្រូវផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់ការពិគ្រោះយោបល់ជាមួយភាគីទាំងឡាយដែលប៉ះពាល់ពីវិធានការការពារនោះ ដើម្បីធ្វើការពិនិត្យមើលលើព័តមាន ដែលមានចែងក្នុងកថាខណ្ឌទី២ និង ៣ ដែលទទួលជាលទ្ធផលនៃការស៊ើបអង្កេត ដែលមានចែងក្នុងមាត្រា ៤ ( ការស៊ើបអង្កេត) ដើម្បីធ្វើការផ្លាស់ប្តូរយោបល់លើការយល់ឃើញលើវិធានការការពារនោះ និងឈានទៅរកការឯកភាពលើសំណង ដូចដែលមានចែងនៅក្នុងមាត្រា ៨ ( សំណង) ។

៥.	នៅពេលដែលភាគីអនុវត្តវិធានការបណ្តោះអាសន្ន ដូចមានលើកក្នុងមាត្រា ៧ (វិធានការការពារបណ្តោះអាសន្ន) តាមការស្នើពីភាគីណាមួយផ្សេងទៀត ឬភាគីច្រើន ការពិគ្រោះយោបល់ត្រូវចាប់ផ្តើមធ្វើភ្លាម បន្ទាប់ពីពេលអនុវត្តនៃវិធានការនោះ ។

៦.	ការចែងអំពីការជូនដំណឹងនៅក្នុងជំពូកនេះ មិនតម្រូវឱ្យភាគីផ្សព្វផ្សាយព័ត៌មានសំងាត់ ដែលការផ្សព្វផ្សាយនោះរំលោភលើការអនុវត្តច្បាប់ ឬដែលផ្សេងពីនេះផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬអាចធ្វើឱ្យមានបុរេវិនិច្ឆ័យលើផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាស គ្រឹះស្ថានសាធារណៈ ឬ គ្រឹះស្ថានឯកជនណាមួយនោះទេ ។

## មាត្រា ៦
## វិសាលភាព និង រយៈពេលនៃវិធានការការពារអន្តរកាល

១.	ភាគីអាចមិនរក្សាបន្តអនុវត្តវិធានការការពារ :

ក-	លើកលែងតែក្នុងករណី និង សម្រាប់ពេលវេលានោះ ដែលចាំបាច់ដើម្បីបង្ការ ឬ ការពារការខូតខាតធ្ងន់ធ្ងរ និង ដើម្បីសម្របសម្រួលការកែប្រែណាមួយ ។

ខ-	សម្រាប់រយៈពេលលើសពី ២ ឆ្នាំ លើកលែងតែពេលវេលានោះ ត្រូវបានពន្យាររហូតដល់រយៈពេល ១ ឆ្នាំទៀត ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចនៃភាគីនោះ កំណត់ដោយស្របទៅតាមនីតិវិធី ដែលចែងក្នុងមាត្រា ៤ (ការស៊ើបអង្កេត) ថា វិធានការការពារនោះនៅមានភាពចាំបាច់ ដើម្បីបង្ការ ឬ ការពារការខូតខាតធ្ងន់ធ្ងរ និងដើម្បីសម្របសម្រួលការកែប្រែណាមួយ និង មានភស្តុតាងបញ្ជាក់ថា ឧស្សាហកម្ម កំពុងធ្វើការកែប្រែ. ឬ

គ-	សម្រាប់រយៈពេលលើសពី ៣ ឆ្នាំ រួមបញ្ចូលទាំងរយៈពេលដែលពន្យារណាមួយ ។

២.	វិធានការការពារមិនត្រូវអនុវត្តប្រឆាំងនឹងទំនិញដែលមានប្រភពដើម ពីភាគីជាប្រទេសសមាជិកអាស៊ាន លុះត្រាតែបរិមាណទំនិញនាំចូលដែលពាក់ព័ន្ធនោះ នៅក្នុងប្រទេសជាភាគីនាំចូល មិនមានបរិមាណលើសពីបីភាគរយ នៃបរិមាណទំនិញនោះនាំចូលសរុបពីប្រទេសជាភាគីដទៃទៀត ដោយកំណត់ថា ភាគីដែលនាំចូលទាំងនោះតិចជាងបីភាគរយដូចគ្នា និងសរុបមិនលើសពីប្រាំបួនភាគរយ នៃការនាំចូលទំនិញដែលពាក់ព័ន្ធពីភាគីដទៃទៀត ។

៣.	នៅពេលរយៈពេលដែលបានគ្រោងទុកនៃវិធានការការពារនោះ លើសពីមួយឆ្នាំ ភាគដែលនាំចូលត្រូវធានាថា វិធានការការពារនោះ នឹងត្រូវធ្វើសេរីកម្មទៅតាមរយៈពេលធម្មតានៅក្នុងអំឡុងពេលអនុវត្ត ។

៤.	នៅពេលដែលភាគីបញ្ឈប់វិធានការការពារលើទំនិញ យោងទៅលើកាលបរិច្ឆេទនៃការសន្យាបន្ថយអត្រាពន្ធរបស់ភាគីក្នុងឧបសម្ព័ន្ធ១ (តារាងការសន្យាពន្ធគយ) អត្រាពន្ធគយលើទំនិញនោះ មិនត្រូវឱ្យលើសពីអត្រាដែលនឹងត្រូវអនុវត្ត នៅពេលមិនមានវិធានការការពារនោះទេ ។

៥. វិធានការការពារលើទំនិញមួយ នឹងត្រូវបញ្ឈប់នៅចុងបញ្ចប់នៃអំឡុងពេលវិធានការការពារបណ្តោះអាសន្ន លើទំនិញនោះ ដោយមិនគិតអំពីអំឡុងពេលនៃវិធានការនោះ ឬ ថាតើវិធានការនោះនឹងត្រូវពន្យារយ៉ាងនោះទេ ។

៦. មិនត្រូវអនុវត្តវិធានការការពារណាមួយម្តងទៀត ទៅលើទំនិញប្រភពដើមជាក់លាក់ណាមួយ ដែលត្រូវបានអនុវត្តវិធានការនោះពីមុន សម្រាប់រយៈពេលស្មើគ្នាដែលបានអនុវត្តចំពោះវិធានការពីមុន ឬ រយៈពេលពីរឆ្នាំ ទោះបីជាមួយណាវែងជាងក៏ដោយនោះទេ ។

៧. ភាគីមិនត្រូវអនុវត្តវិធានការការពារលើទំនិញដែលមានប្រភពដើម ដែលត្រូវបាននាំចូលទៅតាមកម្រិតបរិមាណកូតា ដែលបានអនុញ្ញាតទៅតាមអត្រាពន្ធកូតា ដែលអនុលោមទៅតាមតារាងការសន្យាពន្ធគយ របស់ភាគីក្នុងឧបសម្ព័ន្ធ១ (តារាងការសន្យាពន្ធគយ) ។

## មាត្រា ៧
## វិធានការការពារបណ្តោះអាសន្ន

១. នៅក្នុងកាលៈទេសៈសំខាន់ ដែលការពន្យារពេលអាចធ្វើឱ្យខូចខាត លំបាកក្នុងការជួសជុល ភាគីអាចអនុវត្តវិធានការការពារបណ្តោះអាសន្ន អនុលោមទៅតាមការកំណត់ជាបឋម ដែលមានភស្តុតាងច្បាស់លាស់បញ្ជាក់ថា ការនាំចូលទំនិញដែលមានប្រភពដើមពីភាគីណាមួយ ឬ ភាគីច្រើនបានធ្វើឱ្យ ឬ គម្រាមកំហែង ដែលនាំឱ្យមានការខូចខាតដល់ឧស្សាហកម្មក្នុងស្រុក ។

២. រយៈពេលនៃវិធានការការពារនោះ មិនត្រូវលើសពី ២០០ ថ្ងៃ ដោយរាប់បញ្ចូលទាំងរយៈពេល ដែលពាក់ព័ន្ធនឹងតម្រូវការ ដូចមានចែងក្នុងមាត្រា ២ (និយមន័យ) មាត្រា ៣ (ការចេញវិធានការការពារ) មាត្រា ៤ (ការស៊ើបអង្កេត) មាត្រា ៥ (ការជូនដំណឹង) និងមាត្រា ៦ (វិសាលភាព និង រយៈពេលនៃវិធានការការពារអន្តរកាល) ។ រយៈពេលនៃវិធានការការពារបណ្តោះអាសន្នណាមួយ ត្រូវរាប់បញ្ចូលជាផ្នែកនៃរយៈពេលបឋម និងការពន្យាណាមួយ ដូចមានចែងនៅក្នុងមាត្រា ៦ (វិសាលភាព និង រយៈពេលនៃវិធានការការពារអន្តរកាល) ។

៣. ពន្ធគយដែលទទួលបាន មកពីការអនុវត្តវិធានការបណ្តោះអាសន្ននេះ ត្រូវបង់ត្រឡប់មកវិញ ប្រសិនបើ ការស៊ើបអង្កេតបន្ទាប់មកដូចមានចែងក្នុងមាត្រា ៤ (ការស៊ើបអង្កេត) មិនមានបញ្ជាក់ថា ការកើនឡើងនូវការនាំចូលទំនិញដែលមានប្រភពដើមបានធ្វើឱ្យ ឬ បានគម្រាមកំហែង ធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ឧស្សាហកម្មក្នុងស្រុក ។

## មាត្រា ៨

## សំណង

១. ដោយមានការពិគ្រោះយោបល់ជាមួយភាគីនាំចេញណាមួយ ឬភាគីច្រើន ដែលអាចប៉ះពាល់ដោយវិធានការការពារនោះ ភាគីដែលស្នើវិធានការការពារត្រូវផ្តល់ដល់ភាគីណាមួយ ឬភាគីច្រើន នូវមធ្យោបាយសំណងពាណិជ្ជកម្មគ្រប់គ្រាន់ ដែលមានការឯកភាពគ្នាទៅវិញទៅមក នៅក្នុងទម្រង់សមមូលនឹងការអនុគ្រោះពាណិជ្ជកម្ម ឬកាតព្វកិច្ចផ្សេងទៀតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ រវាងភាគីដែលអនុវត្តវិធានការការពារ និង ភាគីនាំចេញណាមួយ ឬ ច្រើន ដែលនឹងអាចប៉ះពាល់ពីវិធានការនោះ ។

២. នៅក្នុងការស្វែងរកសំណងពីវិធានការការពារ ដូចមានចែងក្នុងកថាខណ្ឌទី១ ប្រសិនបើភាគីមានការឯកភាពគ្នាទៅវិញទៅមក ពួកគេអាចធ្វើការពិគ្រោះយោបល់នៅក្នុងគណៈកម្មាធិការទំនិញ ដែលបង្កើតឡើងអនុលោមតាមមាត្រា ១១ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ) ដើម្បីកំណត់នូវកម្រិតសមមូលភាពនៃការអនុគ្រោះពាណិជ្ជកម្ម ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ រវាងភាគីដែលអនុវត្តវិធានការការពារ និងភាគីនាំចេញ ឬ ភាគីដែលអាចប៉ះពាល់ពីវិធានការការពារនោះ នៅមុនពេលផ្អាកការអនុគ្រោះពាណិជ្ជកម្មដែលសមមូលណាមួយ។ ការអនុវត្តនីតិវិធី នៃការពិគ្រោះយោបល់នោះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ គិតពីកាលបរិច្ឆេទដែលវិធានការការពារនោះ ត្រូវបានអនុវត្តន៍ ។

៣. ប្រសិនបើមិនមានការឯកភាពលើសំណង ទៅតាមរយៈពេលដូចមានចែងក្នុងកថាខណ្ឌ ២ ខាងលើ ភាគីដែលទំនិញផលិតចេញពីប្រទេសរបស់ខ្លួន ទទួលរងផលប៉ះពាល់ពីវិធានការការពារនោះ អាចផ្អាកការអនុវត្តភាពអនុគ្រោះពាណិជ្ជកម្មដែលសមមូលសំខាន់ៗ ចំពោះការធ្វើពាណិជ្ជកម្មជាមួយភាគីដែលអនុវត្តវិធានការការពារនោះ។ ភាគីអាចធ្វើការផ្អាកនូវការអនុគ្រោះពាណិជ្ជកម្ម ក្នុងរយៈពេលអប្បបរមាដែលចាំបាច់ ដើម្បីទទួលបាននូវប្រសិទ្ធភាពដែលសមមូលវិញ និង នៅពេលណាដែលវិធានការការពារនោះនៅមានប្រសិទ្ធិភាពតែប៉ុណ្ណោះ។ សិទ្ធិនៃការផ្អាកការអនុវត្តភាពអនុគ្រោះណាមួយ ដែលមានចែងនៅក្នុងកថាខណ្ឌនេះ មិនត្រូវអនុវត្តនៅក្នុងរយៈពេល ២ ឆ្នាំដំបូង ដែលវិធានការការពារមួយកំពុងមានអានុភាពអនុវត្ត ដោយចាត់ទុកថាមានវិធានការការពារមួយត្រូវបានគេអនុវត្ត នៅពេលដែលមានការកើនឡើងបរិមាណនាំចូល និង វិធានការការពារនោះ អនុលោមទៅតាមជំពូកនេះ ។

៤. ភាគីមួយត្រូវជូនដំណឹងទៅភាគីផ្សេងទៀតជាលាយលក្ខណ៍អក្សរ យ៉ាងហោចណាស់រយៈពេល ៣០ (សាមសិប) ថ្ងៃ នៅមុនពេលផ្អាកការអនុគ្រោះពាណិជ្ជកម្ម ដូចមានចែងក្នុងកថាខណ្ឌ៣។

៥.	កាតព្វកិច្ចក្នុងការផ្តល់សំណង អនុលោមតាមកថាខណ្ឌ១ និង សិទ្ធិក្នុងការផ្អាកការអនុគ្រោះពាណិជ្ជកម្ម ដែលសមមូលសំខាន់ៗ អនុលោមតាមកថាខណ្ឌ៣ នឹងត្រូវអស់អនុភាពអនុវត្តទៅពេលវិធានការការពារនោះ បញ្ចប់សុពលភាពរបស់ខ្លួន ។

## មាត្រា ៩
## ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក

១.	ភាគីនីមួយៗរក្សាសិទ្ធិ និងកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្ម និងពន្ធគយ (GATT) ឆ្នាំ១៩៩៤ និងកិច្ចព្រមព្រៀងស្តីអំពីវិធានការការពារ និងមាត្រា៥ នៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម ។ កិច្ចព្រមព្រៀងនេះមិនផ្តល់សិទ្ធិ ឬកាតព្វកិច្ចបន្ថែមទៀតទៅដល់ភាគីនោះទេ ទាក់ទងនឹងវិធានការការពារសកល ។

២.	ភាគីមិនត្រូវអនុវត្តវិធានការការពារមួយ ឬ វិធានការបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា ៦ (រយៈពេល និងវិសាលភាពនៃវិធានការការពារបណ្តោះអាសន្ន) ឬ មាត្រា ៧ (វិធានការការពារបណ្តោះអាសន្ន) ទៅលើទំនិញដែលជាកម្មវត្ថុនៃវិធានការដែលភាគីបានអនុវត្ត អនុលោមតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្ម និង ពន្ធគយ (GATT) ឆ្នាំ ១៩៩៤ និង កិច្ចព្រមព្រៀងស្តីអំពីវិធានការការពារ មាត្រានៃកិច្ចព្រមព្រៀងស្តីអំពីកសិកម្ម ឬមាត្រាណាមួយដែលទាក់ទងនៅក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក និង ភាគីមិនត្រូវបន្តការអនុវត្តវិធានការការពារ ឬ វិធានការបណ្តោះអាសន្នលើទំនិញដែលត្រូវបានក្លាយជាកម្មវត្ថុនៃវិធានការដែលភាគីបានអនុវត្ត អនុលោមតាមមាត្រា XIX នៃកិច្ចព្រមព្រៀងទូទៅលើពាណិជ្ជកម្ម និងពន្ធគយ (GATT) ឆ្នាំ១៩៩៤ និង កិច្ចព្រមព្រៀងស្តីអំពីវិធានការការពារ មាត្រានៃកិច្ចព្រមព្រៀងស្តីពីកសិកម្ម ឬមាត្រាណាមួយដែលទាក់ទង នៅក្នុងកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ។

៣.	ក្នុងការពិចារណាអនុវត្តវិធានការការពារសកលទៅលើ ទំនិញដែលមានប្រភពដើមរបស់ភាគីមួយផ្សេងទៀត ឬ ដទៃទៀត ត្រូវផ្តួចផ្តើមការពិគ្រោះយោបល់ជាមួយភាគីនោះ ឬ ទាំងនោះ ឱ្យបានជាមុនពេល ដាក់ឱ្យអនុវត្តវិធានការនោះ តាមដែលអាចអនុវត្តទៅបាន ។

# ជំពូក ៨
# ពាណិជ្ជកម្មសេវាកម្ម

## មាត្រា ១
## ទំហំ និង វិសាលភាព

១. ជំពូកនេះអនុវត្តចំពោះបណ្តាវិធានការរបស់ភាគីមួយ ដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មសេវាកម្ម ។

២. នៅក្នុងជំពូកនេះ វិធានការរបស់ភាគីមួយ មានន័យថា បណ្តាវិធានការដែលអនុវត្តដោយៈ

(ក) រដ្ឋាភិបាលកណ្តាល តំបន់ ឬ មូលដ្ឋាន និងអាជ្ញាធរដទៃទៀត

(ខ) បណ្តាស្ថាប័នមិនមែនរដ្ឋាភិបាល ដែលត្រូវបានផ្តល់សិទ្ធិដោយរដ្ឋាភិបាលកណ្តាល តំបន់ ឬ មូលដ្ឋាន ឬអាជ្ញាធរដទៃទៀត

៣. ដើម្បីបំពេញបានតាមកាតព្វកិច្ច និងការសន្យានៅក្រោមជំពូកនេះ ភាគីនីមួយៗត្រូវប្រកាន់យកនូវវិធានការសមស្របដែលមាន ដើម្បីធានាឱ្យបាននូវអនុលោមភាពនៃរដ្ឋាភិបាលតំបន់ ឬ មូលដ្ឋាន និងអាជ្ញាធរដទៃទៀត ព្រមទាំងបណ្តាស្ថាប័នមិនមែនរដ្ឋាភិបាល នៅក្នុងទឹកដីរបស់ខ្លួន

៤. ជំពូកនេះមិនអនុវត្តចំពោះបណ្តាវិធានការដែលមានផលប៉ះពាល់លើ :

(ក) លទ្ធកម្មរបស់រដ្ឋាភិបាល

(ខ) ឧបត្ថម្ភធន ឬអំណោយ រួមមាន កំចីដែលផ្តល់ដោយរដ្ឋាភិបាល ការសន្យា និងធានារ៉ាប់រង ដែលផ្តល់ដោយភាគីមួយ ឬលក្ខខ័ណ្ឌណាមួយដែលភ្ជាប់ទៅនឹងការទទួលឧបត្ថម្ភធន ឬអំណោយ ដោយមិនគិតថា ឧបត្ថម្ភធន ឬអំណោយនោះត្រូវបានផ្តល់ឱ្យជាពិសេសតែចំពោះសេវាកម្មនៅក្នុងស្រុកសេវាកម្ម អតិថិជន ឬ សេវាកម្មអ្នកផ្គត់ផ្គង់ ។

(គ) សេវាកម្មដែលបានផ្គត់ផ្គង់ ដោយប្រើប្រាស់សិទ្ធិអំណាចដែលផ្តល់ដោយរដ្ឋាភិបាល នៅក្នុងទឹកដី នៃភាគីនីមួយៗ ដូចដែលបានចែងនៅក្នុងមាត្រា ២ (ផ) (និយមន័យ) ឬ

(ឃ) ចំពោះផ្នែកសេវាដឹកជញ្ជូនផ្លូវអាកាស បណ្តាវិធានការដែលមានផលប៉ះពាល់ទៅលើសិទ្ធិធ្វើចរាចរ ឬ បណ្តាវិធានការដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើសេវាកម្ម ដែលទាក់ទងនឹងការប្រើប្រាស់សិទ្ធិធ្វើចរាចរ ក្រៅពីបណ្តាវិធានការដែលមានផលប៉ះពាល់ទៅលើ:

(i) សេវាកម្មថែទាំ និងជួសជុលអាកាសយាន

(ii) ការលក់ និងការរកទីផ្សារចំពោះសេវាកម្មដឹកជញ្ជូនផ្លូវអាកាស

(iii) សេវាកម្មប្រព័ន្ធបំរុងសំបុត្រទុកតាមកុំព្យូទ័រ

៥. ភាគីទាំងឡាយកត់សំគាល់នូវការចរចាពហុភាគី យោលទៅតាមការពិនិត្យឧបសម្ព័ន្ធ របស់កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។ បន្ទាប់ពីធ្វើការសន្និដ្ឋាន ទៅលើការចរចាពហុភាគី ភាគីទាំងឡាយត្រូវធ្វើការត្រួតពិនិត្យសំដៅពិភាក្សាអំពីវិសោធនកម្ម ដែលសមស្របចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីដាក់បញ្ចូលលទ្ធផលនៃការចរចាពហុភាគីនេះ។

៦. ជំពូកនេះមិនអនុវត្តចំពោះវិធានការដែលមានផលប៉ះពាល់លើរូបវ័ន្តបុគ្គល ដែលស្វែងរកការងារនៅភាគីមួយទៀត និងមិនអនុវត្តចំពោះបណ្តាវិធានការដែលទាក់ទងនឹងសញ្ជាតិ ការស្នាក់អាស្រ័យ ឬការងារអចិន្ត្រៃយ៍ទេ។

## មាត្រា ២
## និយមន័យ

នៅក្នុងជំពូកនេះ :

(ក) សេវាកម្មថែទាំ និងជួសជុលអាកាសយានមានន័យថា សកម្មភាពទាំងឡាយណាដែលធ្វើឡើងដើម្បីបំរើសេវាកម្មចំពោះអាកាសយាន ឬផ្នែកនៃអាកាសយាន សេវាកម្ម ប៉ុន្តែមិនរាប់បញ្ចូលការថែទាំបន្ទាប់បន្សំទេ។

(ខ) វត្តមានស្ថាប័នពាណិជ្ជកម្ម មានន័យថាគ្រប់ប្រភេទនៃស្ថាប័នអាជីវកម្ម ឬស្ថាប័នវិជ្ជាជីវៈ រួមមានតាមរយៈ :

(i) ការបង្កើតការទិញ ឬការរក្សានិរន្តភាពរបស់នីតិបុគ្គល ឬ

(ii) ការបង្កើត ឬការរក្សានិរន្តភាពរបស់សាខាមួយ ឬការិយាល័យតំណាង

(គ) សេវាកម្មប្រព័ន្ធបំរុងសំបុត្រទុកតាមកុំព្យូទ័រ មានន័យថាសេវាកម្មដែលផ្តល់ដោយប្រព័ន្ធកុំព្យូទ័រ ដែលផ្ទុកពត៌មានអំពីតារាងពេលវេលានៃការហោះហើរ វត្តមាននៃជើងហោះហើរ វិធានអំពីថ្លៃ ដែលតាមរយៈនេះ ការបំរុងសំបុត្រទុក និងការចេញសំបុត្រអាចប្រព្រឹត្តទៅបាន ។

(ឃ) នីតិបុគ្គល មានន័យថាអង្គភាពទាំងឡាយណាដែលត្រូវបង្កើតឡើងដោយសមស្រប ឬគ្រប់គ្រង ដោយច្បាប់ដែលកំពុងប្រើប្រាស់ណាមួយ ទោះបីជាសំដៅ ឬមិនសំដៅប្រាក់ចំណេញ និងកាន់កាប់ ដោយឯកជន ឬរដ្ឋក្តី រាប់បញ្ចូលទាំងសាជីវកម្ម ក្រុមហ៊ុនហិរញ្ញវត្ថុ ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុន បណ្តាក់ទុនរួម ក្រុមហ៊ុនឯកកម្មសិទ្ធិ ឬសមាគម ។

(ង) នីតិបុគ្គលនៃភាគីមួយ មានន័យថាជានីតិបុគ្គលដែល :

(i) ត្រូវបានបង្កើតឡើង ឬគ្រប់គ្រងក្រោមច្បាប់នៃភាគីនោះ និងចូលរួមក្នុងសកម្មភាព អាជីវកម្ម ទ្រង់ទ្រាយធំ នៅក្នុងទឹកដីនៃភាគីនោះ ឬភាគីដទៃទៀតណាមួយ ឬ

(ii) នៅក្នុងករណីនៃការផ្តល់សេវាកម្មណាមួយ តាមរយៈវត្តមានស្ថាប័នពាណិជ្ជកម្ម ដែលកាន់ កាប់ ឬ គ្រប់គ្រងដោយៈ

ក. រូបវ័ន្តបុគ្គលនៃភាគីនោះ ឬ

ខ. នីតិបុគ្គលនៃភាគីនោះ ដែលមានចែងនៅក្នុងកថាខ័ណ្ឌរង ង (i)

(ច) ចំពោះថៃ និងវៀតណាម នីតិបុគ្គលគឺ :

(i) កាន់កាប់ដោយបណ្តាបុគ្គលនៃភាគីមួយ ប្រសិនបើដើមទុនច្រើនជាង ៥០ភាគរយ កាន់កាប់ ដោយបណ្តាបុគ្គលនៃភាគីនោះ

(ii) គ្រប់គ្រងដោយបណ្តាបុគ្គលនៃភាគីមួយ ប្រសិនបើបណ្តាបុគ្គលនោះមានសិទ្ធិអំណាចតែង តាំងនាយកភាគច្រើន ឬបើពុំនោះទេ មានសិទ្ធិដឹកនាំតាមផ្លូវច្បាប់

(iii) មានសម្ព័ន្ធភាពទៅនឹងបុគ្គលដទៃទៀត នៅពេលដែលត្រួតពិនិត្យ ឬត្រូវបានត្រួតពិនិត្យ ដោយបុគ្គលដទៃទៀតនោះ ឬនៅពេលនីតិបុគ្គលនោះ និងបុគ្គលដទៃទៀតត្រូវបានគ្រប់ គ្រងដោយបុគ្គលតែមួយ ។

(ឆ) វិធានការមានន័យថា វិធានការទាំងឡាយណារបស់ភាគីមួយ ទោះបីជានៅក្នុងរូបភាព ជាច្បាប់ បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច វិធានការរដ្ឋបាល ឬរូបភាពដទៃទៀត

(ជ) បណ្តាវិធានការរបស់ភាគីមួយ ដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មផ្នែកសេវាកម្ម រួមមាន បណ្តាវិធានការដែលទាក់ទងទៅនឹង :

(i) ការទិញ ឬការប្រើប្រាស់ ឬការទូទាត់សេវាកម្មណាមួយ

(ii) ទាក់ទងនឹងការផ្តល់សេវាកម្ម ការទទួល និងការប្រើប្រាស់សេវាកម្ម ដែលបណ្តាភាគីនោះតំរូវឱ្យផ្តល់ទៅឱ្យសាធារណជនទូទៅ និង

(iii) វត្តមាននៃបណ្តាបុគ្គលនៃភាគីមួយ ដើម្បីផ្តល់សេវាកម្មនៅក្នុងទឹកដីនៃភាគីដទៃទៀត រួមទាំងវត្តមាន ស្ថាប័នពាណិជ្ជកម្ម

(ឈ) អ្នកផ្គត់ផ្គង់សេវាកម្មផ្តាច់មុខ មានន័យថា បុគ្គលទាំងឡាយណា ទោះបីជាសាធារណៈ ឬឯកជនក្តី ដែលនៅក្នុងទីផ្សារនៅក្នុងទឹកដីនៃភាគីមួយត្រូវបានផ្តល់សិទ្ធិ ឬត្រូវបង្កើតជាផ្លូវការ ឬជាអ្នកផ្គត់ផ្គង់សេវាកម្មតែមួយគត់ ដែលកំណត់ដោយភាគីនោះ ។

(ញ) រូបវន្តបុគ្គលនៃភាគីមួយ មានន័យថា ជារូបវន្តបុគ្គលដែលស្នាក់អាស្រ័យនៅក្នុងទឹកដីនៃភាគីនោះ ឬកន្លែងដទៃទៀត និងជាអ្នកដែលនៅក្រោមច្បាប់នៃភាគីនោះ :

(i) គឺជាពលរដ្ឋនៃភាគីនោះ ឬ

(ii) មានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍នៅក្នុងភាគីនោះ នៅក្នុងករណីដែលភាគីមួយ ផ្តល់នូវប្រព្រឹត្តិកម្មដល់អ្នកស្នាក់នៅអចិន្ត្រៃយ៍ដូចគ្នាទៅនឹងពលរដ្ឋរបស់ខ្លួន ចំពោះបណ្តាវិធានការ ដែលមានផលប៉ះពាល់ដល់ពាណិជ្ជកម្មផ្នែកសេវាកម្ម និងប្រសិនបើគ្មានភាគីណា ដែលត្រូវបានតំរូវឱ្យផ្តល់នូវប្រព្រឹត្តកម្ម ដល់អ្នកស្នាក់នៅអចិន្ត្រៃយ៍មានលក្ខណៈអនុគ្រោះជាងអ្វីដែលផ្តល់ឱ្យដល់អ្នកស្នាក់នៅអចិន្ត្រៃយ៍ដោយភាគីនោះទេ ។

(ដ) បុគ្គលមានន័យថា ជារូបវន្តបុគ្គល ឬនីតិបុគ្គល

(ឋ) ផ្នែកនៃសេវាកម្ម មានន័យថា :

(i) យោលទៅតាមការសន្យាសេវាកម្មជាក់លាក់ ផ្នែករងនៃសេវាកម្មមួយ ឬច្រើន ឬទាំងអស់ ដូចមានចែងនៅក្នុងតារាងការនៃសន្យាសេវាកម្មជាក់លាក់របស់ភាគីមួយ នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) និង

(ii) បើមិនដូច្នោះទេ ជាវិស័យសេវាកម្មទាំងអស់ រាប់បញ្ចូលទាំងគ្រប់វិស័យរងទាំងអស់ផងដែរ

(ទ) ការលក់ និងការរកទីផ្សារនៃសេវាកម្មដឹកជញ្ជូនផ្លូវអាកាស មានន័យថា ជាឱកាសដល់ក្រុមហ៊ុនអាកាសចរដែលពាក់ព័ន្ធ រួមមានគ្រប់ទិដ្ឋភាពទាំងអស់នៃការរកទីផ្សារ ដូចជា ការស្រាវជ្រាវទីផ្សារ ការផ្សាយពាណិជ្ជកម្ម និងការចែកចាយ ។ សកម្មភាពទាំងនេះ មិនរាប់បញ្ចូលនូវការកំណត់ថ្លៃចំពោះសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងលក្ខខ័ណ្ឌដទៃទៀតទេ ។

(ធ) សេវាកម្ម រួមមានសេវាកម្មនៅគ្រប់វិស័យទាំងអស់ លើកលែងតែសេវាកម្មទាំងឡាយណា ដែលផ្តល់នៅក្រោមសិទ្ធិអំណាចរបស់រដ្ឋាភិបាល ។

(ន) សេវាកម្មរបស់ភាគីមួយទៀត មានន័យថា ជាសេវាកម្មដែលផ្តល់ :

(i) ពី ឬនៅក្នុងទឹកដីនៃភាគីដទៃទៀតនោះ ឬ

(ii) នៅក្នុងករណីនៃការផ្តល់សេវាកម្មតាមរយៈវត្តមានស្ថាប័នពាណិជ្ជកម្ម ឬតាមរយៈវត្តមាននៃរូបវន្តបុគ្គល ដោយអ្នកផ្តល់សេវាកម្មនៃភាគីដទៃនោះ ។

(ប) អ្នកផ្តល់សេវាកម្ម មានន័យថា ជាបុគ្គលដែលផ្តល់សេវាកម្ម[6]

(ផ) សេវាកម្មដែលផ្តល់នៅក្រោមសិទ្ធិអំណាចរបស់រដ្ឋាភិបាល មានន័យថាសេវាកម្មទាំងឡាយណា ដែលត្រូវបានផ្តល់ឱ្យដោយមិនសំដៅទៅលើការធ្វើពាណិជ្ជកម្ម ឬប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាកម្មណាមួយទេ ។

(ព) ការផ្គត់ផ្គង់សេវាកម្ម រួមមាន ផលិតកម្ម ការចែកចាយ ការរកទីផ្សារ លក់ និងការផ្តល់សេវាកម្ម ។

---

[6] សេវាកម្មដែលមិនត្រូវបានផ្តល់ឱ្យដោយផ្ទាល់ដោយនីតិបុគ្គល ប៉ុន្តែតាមរយៈទំរង់ដទៃទៀតនៃវត្តមានការិយាល័យតំណាង ដូចជា សាខា ឬការិយាល័យតំណាងអ្នកផ្តល់សេវាកម្ម (នីតិបុគ្គល) ទោះបីជាយ៉ាងណាក៏ដោយ តាមរយៈការិយាល័យតំណាង នឹងត្រូវបានផ្តល់ឱ្យនូវប្រព្រឹត្តិកម្មនោះ ចំពោះអ្នកផ្តល់សេវាកម្ម ក្រោមកិច្ចព្រមព្រៀងនេះ ។ ប្រព្រឹត្តិកម្មនេះអាចអនុវត្តផងដែរ ចំពោះការិយាល័យតំណាងដែលផ្តល់សេវាកម្ម និងមិនអនុវត្តចំពោះផ្នែកដទៃទៀតរបស់អ្នកផ្គត់ផ្គង់ ដែលស្ថិតនៅក្រៅទឹកដីដែលផ្តល់សេវាកម្ម ។

(ភ) ពាណិជ្ជកម្មផ្នែកសេវាកម្ម មានន័យថា ការផ្តល់សេវាកម្មៈ

(i) ពីទឹកដីនៃភាគីមួយទៅក្នុងទឹកដីនៃភាគីដទៃទៀតណាមួយ

(ii) នៅក្នុងទឹកដីនៃភាគីមួយទៅអ្នកប្រើប្រាស់សេវាកម្មនៃភាគីដទៃទៀតណាមួយ

(iii) ដោយអ្នកផ្តល់សេវាកម្មនៃភាគីមួយ តាមរយៈវត្តមានស្ថាប័នពាណិជ្ជកម្ម នៅក្នុងទឹកដីនៃភាគីដទៃទៀតណាមួយ

(iv) ដោយអ្នកផ្តល់សេវាកម្មនៃភាគីមួយ តាមរយៈវត្តមាននៃរូបវ័ន្តបុគ្គលរបស់ភាគីមួយ នៅក្នុងទឹកដីនៃភាគីដទៃទៀតណាមួយ

(ម) សិទ្ធិធ្វើចរាចរ មានន័យថា សិទ្ធិចំពោះសេវាកម្មដែលមាន និងមិនមានកម្មវិធី ដើម្បីធ្វើប្រតិបត្តិការ ឬដឹកជញ្ជូនអ្នកដំណើរ ទំនិញ និងការផ្ញើប្រាក់បៀវត្ស ឬ ជូលពីក្នុង ឬនៅលើទឹកដីនៃភាគីមួយ រួមមាន កន្លែងផ្តល់សេវាកម្ម ផ្លូវប្រតិបត្តិការ ប្រភេទនៃចរាចរ កំលាំងដែលត្រូវផ្តល់ កំរៃដែលត្រូវយក និងលក្ខខ័ណ្ឌ ព្រមទាំងលក្ខណៈវិនិច្ឆ័យ សំរាប់កំណត់ក្រុមហ៊ុនអាកាសចរ រួមមានលក្ខណៈវិនិច្ឆ័យ ដូចជាលេខ ភាពជាម្ចាស់ និងការគ្រប់គ្រង ។

## មាត្រា ៣
## ប្រព្រឹត្តិកម្មជាតិ

១. នៅក្នុងបណ្តាវិស័យដែលចែងនៅក្នុងតារាងការសន្យាសេវាកម្មជាក់លាក់ នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) ឬ ឧបសម្ព័ន្ធ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល) និងចំពោះលក្ខខ័ណ្ឌ និងលក្ខណៈសម្បត្តិ ដូចដែលមានចែងនៅក្នុងនោះ ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យមានសេវាកម្ម និងអ្នកផ្តល់សេវាកម្មនៃភាគីដទៃទៀត ហើយផ្តល់នូវប្រព្រឹត្តិកម្មដែលមិនតិចជាងអ្វីដែលបានផ្តល់ទៅឱ្យសេវាកម្ម និងអ្នកផ្តល់សេវាកម្មរបស់ខ្លួនទេ[7] ចំពោះវិធានការទាំងឡាយណា ដែលមានផលប៉ះពាល់ដល់ការផ្តល់សេវាកម្ម ។

---

[7] ការសន្យាសេវាកម្មជាក់លាក់ដែលចែងនៅក្រោមមាត្រានេះ មិនសំដៅទៅលើការតំរូវឱ្យភាគីណាមួយធ្វើការសងជំងឺចិត្តចំពោះការបាត់ឧត្តមភាពប្រកួតប្រជែង ដែលជាលទ្ធផលបណ្តាលមកពីវត្តមាននៃសេវាកម្ម និងអ្នកផ្តល់សេវាកម្មបរទេសទេ ។

២. ភាគីមួយអាចបំពេញបានតាមលក្ខខ័ណ្ឌតំរូវនៃកថាខ័ណ្ឌ១ ដោយយោលទៅតាមសេវាកម្ម និងអ្នកផ្គត់ផ្គង់សេវាកម្មនៃភាគីដទៃទៀតណាមួយ តាមរយៈការផ្តល់នូវប្រព្រឹត្តិកម្មដូចគ្នាដែលទទួលស្គាល់ជាផ្លូវការ និងប្រព្រឹត្តិកម្មខុសគ្នាដែលទទួលស្គាល់ជាផ្លូវការចំពោះសេវាកម្ម និងអ្នកផ្តល់សេវាកម្មនៅក្នុងស្រុកដែលស្រដៀងគ្នា។

៣. ប្រព្រឹត្តិកម្មដូចគ្នា និងប្រព្រឹត្តិកម្មខុសគ្នាដែលទទួលស្គាល់ជាផ្លូវការ ជាប្រព្រឹត្តិកម្មដែលមិនសូវមានលក្ខណៈអនុគ្រោះ ប្រសិនបើប្រព្រឹត្តិកម្មនោះធ្វើឱ្យមានការប្រែប្រួលដល់បណ្តាលក្ខខ័ណ្ឌនៃការប្រកួតប្រជែងនៃសេវាកម្ម ឬអ្នកផ្គត់ផ្គង់សេវានៃភាគីនោះ បើប្រៀបធៀបទៅនឹងសេវា និងការផ្តល់សេវាដែលស្រដៀងគ្នានៃភាគីដទៃណាមួយ។

## មាត្រា ៤
## ការបើកចំហទីផ្សារ

១. ទាក់ទងនឹងការបើកចំហទីផ្សារតាមរយៈម៉ូតនៃការផ្គត់ផ្គង់ដែលបានចែងនៅក្នុងមាត្រា ២(ក)(និយមន័យ) ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យមានសេវាកម្ម និងអ្នកផ្តល់សេវាកម្មនៃភាគីផ្សេងទៀត នូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលបានផ្តល់ឱ្យនៅក្រោមលក្ខខ័ណ្ឌ វិសាលភាព និងលក្ខខ័ណ្ឌដែលបានព្រមព្រៀង និងចែងនៅក្នុងតារាងនៃការសន្យាសេវាកម្មជាក់លាក់នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) ឬឧបសម្ព័ន្ធ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល) ទេ។[៨]

២. នៅក្នុងបណ្តាវិស័យដែលការសន្យាបើកចំហទីផ្សារត្រូវបានអនុវត្ត បណ្តាវិធានការដែលភាគីមួយមិនត្រូវរក្សាទុក ឬប្រកាន់យកទោះបីជាចំពោះផ្នែកតូចតាចនៅកំរិតមូលដ្ឋាន ឬកំរិតជាតិក៏ដោយ ប្រសិនបើមិនបានចែងផ្ទុយពីនេះនៅក្នុងតារាងនៃការសន្យាសេវាកម្មជាក់លាក់នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) ឬឧបសម្ព័ន្ធ ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល) ត្រូវបានកំណត់ថា ជា :

(ក) ការកំណត់ទៅលើចំនួនអ្នកផ្តល់សេវាកម្ម នៅក្នុងទំរង់ជាកូតាចំនួន សិទ្ធិផ្តាច់មុខអ្នកផ្តល់សេវាកម្មពិសេស ឬលក្ខខ័ណ្ឌតំរូវចំពោះការធ្វើតេសលើតំរូវការសេដ្ឋកិច្ច

(ខ) ការកំណត់ទៅលើតំលៃសរុបនៃប្រតិបត្តិការសេវាកម្ម ឬ ទ្រព្យសកម្មនៅក្នុងទំរង់ជាកូតា ចំនួន ឬលក្ខខ័ណ្ឌតំរូវចំពោះការធ្វើតេសលើតំរូវការសេដ្ឋកិច្ច

---

[8] ប្រសិនបើភាគីមួយ អនុវត្តការសន្យាបើកចំហទីផ្សារទាក់ទងនឹងការផ្គត់ផ្គង់សេវាតាមរយៈម៉ូតនៃការផ្គត់ផ្គង់ ដូចមានក្នុងមាត្រា ២ (ក)(i) (និយមន័យ) និងប្រសិនបើការចល័តទ្រព្យធនឆ្លងកាត់ព្រំដែន គឺជាផ្នែកសំខាន់មួយនៃសេវានោះ ភាគីនោះព្រមអនុញ្ញាតឱ្យមានការចល័តទ្រព្យធន។ ប្រសិនបើភាគីមួយអនុវត្តការសន្យាបើកចំហទីផ្សារតាមរយៈម៉ូតនៃការផ្គត់ផ្គង់ ដែលក្នុងមាត្រា ២(ក)(iii)(និយមន័យ) ភាគីនោះព្រមឱ្យមានការផ្ទេរទ្រព្យធនទៅក្នុងទឹកដីរបស់ខ្លួន។

(គ) ការកំណត់ទៅលើចំនួនសរុបប្រតិបត្តិសេវាកម្ម ឬបរិមាណសរុបនៃទិន្នផលសេវាកម្ម ជាឯកតាចំនួន នៅក្នុងទំរង់ជាកូតា ឬលក្ខខ័ណ្ឌទាមទារឱ្យមានការធ្វើតេសលើតំរូវការសេដ្ឋកិច្ច។[៩]

(ឃ) ការកំណត់ទៅលើចំនួនសរុបនៃរូបវ័ន្តបុគ្គល ដែលនឹងត្រូវបានផ្តល់ការងារឱ្យធ្វើក្នុងវិស័យសេវាកម្ម ជាក់លាក់ណាមួយ ឬអ្នកផ្តល់សេវាកម្មមួយអាចជួល និងអ្នកដែលចាំបាច់ចំពោះការផ្តល់សេវាកម្ម ជាក់លាក់ក្នុងរូបភាពជាកូតាបរិមាណ ឬលក្ខខ័ណ្ឌទាមទារឱ្យមានការធ្វើតេសលើតំរូវការសេដ្ឋកិច្ច។

(ង) បណ្តាវិធានការដែលរឹតត្បិត ឬទាមទារឱ្យមានស្ថាប័នប្រភេទជាក់លាក់ស្របច្បាប់ ឬក្រុមហ៊ុនរកស៊ី បណ្តាក់ទុនរួមគ្នា ដែលតាមរយៈនេះ អ្នកផ្តល់សេវាកម្មអាចផ្តល់សេវាកម្មបាន។

(ច) ការកំណត់ទៅលើដើមទុនបរទេស ក្នុងរូបភាពជាការប្រើការកំណត់ភាគរយអតិបរមានៃភាគហ៊ុន បរទេស ឬតំលៃសរុបនៃការបណ្តាក់ទុនបរទេសរបស់បុគ្គល ឬសរុប។

## មាត្រា ៥
## ការសន្យាបន្ថែម

បណ្តាភាគីចរចាការសន្យាទៅលើបណ្តាវិធានការ ដែលមានផលប៉ះពាល់ទៅលើពាណិជ្ជកម្មផ្នែកសេវាកម្ម ដែលទាក់ទងនឹងមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) ឬមាត្រា ៤ (ការបើកច្រកទីផ្សារ) រួមមាន បណ្តាវិធានការដែល ទាក់ទងនឹងលក្ខណៈសម្បត្តិ ស្តង់ដា ឬការផ្តល់អាជ្ញាប័ណ្ណ។ ការសន្យាទាំងនេះ ត្រូវបានចែងនៅក្នុងបណ្តាតារាងការ សន្យាសេវាកម្មជាក់លាក់របស់ភាគីមួយ នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) ឧបសម្ព័ន្ធ ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល)។

## មាត្រា ៦
## ការពិនិត្យឡើងវិញនូវការសន្យា

ភាគីទាំងឡាយត្រូវចរចាជាច្រើនជុំ បន្ទាប់ពីរយៈពេល ០៣ ឆ្នាំនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងទៅតាមពេលវេលាដែលបានកំណត់ដោយគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី ក្នុងគោលបំណងកែលំអការ សន្យាជាក់លាក់នៅក្រោមជំពូកនេះ ដើម្បីធ្វើសេរីកម្មពាណិជ្ជកម្មផ្នែកសេវាកម្មជាបណ្តើរៗក្នុងចំណោមភាគីទាំងអស់។

---

[៩] កថាខ័ណ្ឌរង (គ) មិនគ្របដណ្តប់លើបណ្តាវិធានការរបស់ភាគីមួយដែលរិតត្បិតទៅលើការរៀបចំផ្សេងៗ សំរាប់ការផ្តល់សេវាកម្ម។

## មាត្រា ៧
## ការពិគ្រោះយោបល់ស្តីពីប្រព្រឹត្តិកម្មចំពោះប្រទេសដែលទទួលបានការអនុគ្រោះបំផុត

១. ដោយមិនអនុវត្តចំពោះកថាខ័ណ្ឌ ២ ប្រសិនបើបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីមួយចុះកិច្ចព្រមព្រៀងជាមួយប្រទេសដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀង ដែលនៅក្នុងនោះប្រព្រឹត្តិកម្មចំពោះសេវាកម្ម ឬអ្នកផ្តល់សេវាកម្មមានលក្ខណៈអនុគ្រោះជាងនោះ ភាគីដទៃទៀតអាចស្នើសុំឱ្យមានការពិគ្រោះយោបល់ ដើម្បីពិភាក្សាអំពីលទ្ធភាពនៃការផ្តល់នូវប្រព្រឹត្តិកម្មនោះ ឱ្យបានប្រសើរជាងអ្វីដែលបានផ្តល់ឱ្យទៅប្រទេសមិនមែនភាគី នៅក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីដែលត្រូវបានស្នើសុំនោះ ត្រូវទទួលយកនូវសំណើពិគ្រោះយោបល់ពីភាគីស្នើសុំដោយថ្លឹងថ្លែងពីផលប្រយោជន៍ទូទៅ។ ភាគីស្នើសុំត្រូវជូនដំណឹងដល់ភាគីដទៃទៀត ពីការសុំពិគ្រោះយោបល់នៅក្រោមកថាខ័ណ្ឌនេះ។

២. គ្មានភាគីណាមួយត្រូវបានបង្ខំឱ្យអនុវត្តកថាខ័ណ្ឌ ១ ដែលទាក់ទងនឹងប្រព្រឹត្តិកម្មដែលត្រូវបានផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី រវាងរដ្ឋសមាជិកអាស៊ានមួយ ឬ រដ្ឋសមាជិកនីមួយៗ និងប្រទេសមិនមែនសមាជិក ឬអូស្ត្រាលី ឬណូវែលហ្សេឡង់។

៣. បណ្តាភាគីពិគ្រោះយោបល់ ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិគ្រោះយោបល់ទៅបណ្តាភាគីដទៃទៀត ឱ្យបានឆាប់ និងឱ្យបានមុនកិច្ចប្រជុំគណៈកម្មាធិការស្តីពីពាណិជ្ជកម្មសេវាកម្មលើកក្រោយ ដែលបានបង្កើតឡើងយោងទៅតាមមាត្រា ២៤ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មសេវាកម្ម) បន្ទាប់ពីការបញ្ចប់ការពិគ្រោះយោបល់។

៤. អនុវត្តចំពោះកថាខ័ណ្ឌ១ ផងដែរ ភាគីមួយមិនត្រូវបានបង្ខំឱ្យព្រមទទួលយកការពិគ្រោះយោបល់ទាក់ទងនឹងប្រព្រឹត្តកម្មដែលផ្តល់ឱ្យក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលចូលជាធរមាន ឬបានចុះហត្ថលេខាមុនពេលចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ រួមមានរាល់បណ្តាវិធានការដែលអនុវត្តជាផ្នែកមួយដ៏ធំនៃដំណើការ នៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច ឬការធ្វើសេរីកម្មពាណិជ្ជកម្មក្នុងចំណោមភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ ចំពោះបណ្តាកិច្ចព្រមព្រៀងស្តីពីការធ្វើសេរីកម្មពាណិជ្ជកម្មផ្នែកទំនិញ ឬសេវាកម្ម ឬ វិនិយោគ។

## មាត្រា ៨
## តារាងនៃការសន្យាសេវាកម្មជាក់លាក់

១. ភាគីនីមួយៗត្រូវបញ្ជាក់នៅក្នុងតារាងនៃការសន្យាសេវាកម្មជាក់លាក់ ដែលត្រូវអនុវត្តនៅក្រោមមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ការបើកច្រកទីផ្សារ) និងមាត្រា ៥ (ការសន្យាបន្ថែម)។ ទាក់ទងនឹងបណ្តាវិស័យដែលត្រូវអនុវត្តការសន្យា តារាងនីមួយៗត្រូវបញ្ជាក់ :

(ក) វាក្យស័ព្ទ ការកំណត់ និងលក្ខខ័ណ្ឌស្តីពីការបើកច្រកទីផ្សារ

(ខ) លក្ខខ័ណ្ឌ និងលក្ខណៈសម្បត្តិស្តីពីប្រព្រឹត្តិកម្មជាតិ

(គ) ការអនុវត្តដែលទាក់ទងនឹងការសន្យាបន្ថែម

(ឃ) កាលបរិច្ឆេទសំរាប់ការអនុវត្តការសន្យា ក្នុងករណីសមស្រប

(ង) កាលបរិច្ឆេទនៃការចូលជាធរមាននៃការសន្យានេះ

២. បណ្តាវិធានការដែលមិនស្របទៅនឹងការបើកច្រកទីផ្សារ និងប្រព្រឹត្តិកម្មជាតិ ត្រូវដាក់បញ្ចូលក្នុងកូលោន ដែលទាក់ទងនឹងការបើកច្រកទីផ្សារ។ នៅក្នុងករណីនេះ ការដាក់បញ្ចូលក៏ផ្តល់នូវលក្ខខ័ណ្ឌ ឬលក្ខណៈសម្បត្តិ ចំពោះប្រព្រឹត្តិកម្មជាតិផងដែរ។

៣. តារាងនៃការសន្យាសេវាកម្មជាក់លាក់ ត្រូវចែងក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) នៃកិច្ចព្រមព្រៀងនេះ។ ការសន្យាសេវាកម្មជាក់លាក់ទាក់ទងនឹងការផ្តល់សេវាកម្មដោយអ្នកផ្តល់សេវាកម្មនៃភាគីមួយ តាមរយៈវត្តមាននៃរូបវ័ន្តបុគ្គលរបស់ភាគីមួយ នៅក្នុងទឹកដីនៃភាគីដទៃទៀត ត្រូវចែងក្នុងឧបសម្ព័ន្ធ ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល) នៃកិច្ចព្រមព្រៀងនេះ។

## មាត្រា ៩
## ការកែប្រែតារាងនៃការសន្យាសេវាកម្ម

១. ភាគីមួយអាចកែប្រែ ឬលុបចោលការសន្យាណាមួយនៅក្នុងតារាងនៃការសន្យាជាក់លាក់ នៅក្នុងឧបសម្ព័ន្ធ ៣ (តារាងនៃការសន្យាសេវាកម្មជាក់លាក់) និងឧបសម្ព័ន្ធ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវ័ន្តបុគ្គល) នៅពេលណាក៏បានបន្ទាប់ពីរយៈពេល ០៣ ឆ្នាំនៃការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះស្របទៅតាមនីតិវិធី ដែលចែងនៅក្នុងមាត្រា ២១ នៃ GATS និងនីតិវិធីសំរាប់ការអនុវត្តមាត្រា ២១ នៃ GATS ដែលចែងនៅក្នុងឯកសារអង្គការពាណិជ្ជកម្មពិភពលោកលេខ S/L/80 ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៩ (នីតិវិធីនៃមាត្រា ២១ នៃ GATS) ដែលត្រូវបានកែសម្រួលតាមពេលវេលា។

២. ដើម្បីបញ្ចៀសនូវមន្ទិលសង្ស័យ សេចក្តីយោងក្នុងមាត្រា ២១ នៃ GATS និងនីតិវិធីចំពោះលេខាធិការដ្ឋានអាស៊ាន និងក្រុមប្រឹក្សានៃពាណិជ្ជកម្មផ្នែកសេវាកម្មនៃមាត្រា ២១ នៃ GATS គឺជាសេចក្តីយោងចំពោះគណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី។

## មាត្រា ១០

## បទប្បញ្ញត្តិក្នុងស្រុក

១. នៅក្នុងវិស័យនានាដែលការសន្យាតាមវិស័យត្រូវបានធ្វើឡើង ភាគីនីមួយៗត្រូវធានាថា វិធានការទាំងអស់នៃការអនុវត្តទូទៅដែលជះឥទ្ធិពលដល់ពាណិជ្ជកម្មសេវាកម្ម ត្រូវបានចាត់ចែងក្នុងលក្ខណៈសមស្រប សត្យានុម័ត និងអព្យាក្រឹត្យ ។

២. ដោយមានបំណងចង់ធានាថា វិធានការនានាទាក់ទិននឹងលក្ខខ័ណ្ឌតម្រូវ នីតិវិធីគុណវុឌ្ឍិ បទដ្ឋានបច្ចេកទេស និងលក្ខខ័ណ្ឌតំរូវអាជ្ញាប័ណ្ណ នឹងមិនបង្កឧបសគ្គមិនចាំបាច់ចំពោះពាណិជ្ជកម្មសេវាកម្ម ភាគីទាំងអស់នឹងពិនិត្យឡើងវិញរួមគ្នាលើលទ្ធផលនៃការចរចាស្តីពីវិន័យនៃវិធានការទាំងនោះ អនុលោមតាមមាត្រា ៦.៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម ហើយនឹងកែប្រែមាត្រានេះឱ្យបានសមរម្យ បន្ទាប់ពីការពិគ្រោះក្នុងចំណោមភាគីទាំងអស់ដើម្បីនាំមកនូវលទ្ធផលនៃការចរចារទាំងនោះឱ្យមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងនេះ ។ ភាគីទាំងអស់កត់សម្គាល់ថាវិន័យទាំងអស់ត្រូវបានបង្កើតឡើងចេញពីការចរចាជាច្រើនលើក ដែលមានបំណង ដើម្បីបញ្ជាក់លើលក្ខខ័ណ្ឌតំរូវនីតិវិធីផ្សេងៗ បទដ្ឋានបច្ចេកទេស ឯកសារពាក់ពន្ធ័នឹងការស្នើសុំអាជ្ញាប័ណ្ណ និងនីតិវិធីរួមមាន :

(ក) ផ្អែកលើគោលបំណង និងការចាំបាច់នៃតម្លាភាព ក៏ដូចជាសមត្ថភាព និងភាពប៉ិនប្រសប់ក្នុងការផ្គត់ផ្គង់សេវាកម្ម

(ខ) គ្មានអ្វីស្មុគស្មាញច្រើនទៀត ជាងការចាំបាច់ដើម្បីធានាលើគុណភាពសេវាកម្ម និង

(គ) ក្នុងករណីនីតិវិធីចេញអាជ្ញាប័ណ្ណ មិនមែនជាការកំណត់ដោយពួកគេក្នុងការរឹតត្បិត លើការផ្គត់ផ្គង់សេវាកម្ម។

៣. ក្នុងផ្នែកជាច្រើនដែលភាគីមួយ បានទទួលយកនូវការសន្យាតាមវិស័យ ដោយអនុលោមតាមមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ច្រកចូលទីផ្សារ) និងមាត្រា ៥ (ការសន្យាបន្ថែម) ក្នុងអំឡុងពេលនៃការរួមបញ្ចូលវិន័យយោងទៅតាមកឋាខ័ណ្ឌ ២ ដែលភាគីទាំងអស់នឹងមិនចាំបាច់ដាក់ពាក្យសុំអាជ្ញាប័ណ្ណ លក្ខខ័ណ្ឌតំរូវ និង បទដ្ឋានបច្ចេកទេសដែលចាត់ទុកជាមោឃៈភាព ឬធ្វើឱ្យអន់ថយដូចជាការសន្យាតាមវិស័យក្នុងកិច្ចព្រមព្រៀងនេះក្នុងលក្ខណៈដូចតទៅ :

(ក) មិនប្រតិបត្តិតាមទៅនឹងចំណុចសំខាន់ៗក្នុងកឋាខ័ណ្ឌ ២(ក) (ខ) ឬ (គ) និង

(ខ) មិនអាចលើកយកហេតុផលសមរម្យ ដូចដែលបានរំពឹងទុកពីភាគីនោះ ក្នុងពេលសន្យាតាមវិស័យក្នុងផ្នែកផ្សេងៗដែលត្រូវបានបង្កើតឡើង ។

៤. ក្នុងការសម្រេចថា តើភាគីមួយស្ថិតនៅក្នុងភាពស្របគ្នាជាមួយភាពចាំបាច់ អនុលោមតាមកថាខ័ណ្ឌ ៣ (ក) បញ្ញើគណនេយ្យ នឹងត្រូវបង្កើតឡើងតាមបទដ្ឋានអន្តរជាតិ របស់អង្គការអន្តរជាតិពាក់ព័ន្ធ ដែលត្រូវបានស្នើសុំដោយភាគីនោះ[10] ។

៥. ការផ្តល់សិទ្ធិអំណាច គឺតម្រូវឱ្យមានការដាក់ពាក្យហើយការសន្យាតាមវិស័យមួយនៃសេវាកម្មត្រូវបានបង្កើតឡើងដែលមានសមត្ថភាពផ្តល់សិទ្ធិអំណាចនៃភាគីនោះ :

(ក) ក្នុងករណីពាក្យសុំមិនទាន់បំពេញបានត្រឹមត្រូវនៅឡើយ ការស្នើសុំដើម្បីបំពេញបន្ថែមនូវពត៌មានដែលទើបរកបាន និងផ្តល់ឱកាសនៃការកែតំរូវលក្ខណៈខ្វះចន្លោះ នៅក្នុងហេតុផលអាចទទួលយកបានតាមពេលវេលាកំណត់ ។

(ខ) ក្នុងហេតុផលសមរម្យមួយស្ថិតក្នុងអំឡុងពេលនៃពេលវេលាកំណត់ បន្ទាប់ពីការប្រណិប័តន៍នៃការពិចារណាដើម្បីបំពេញលើពាក្យស្នើសុំក្រោមច្បាប់ក្នុងស្រុក និងបទបញ្ញត្តិផ្សេងៗ ត្រូវផ្តល់ពត៌មានជូនអ្នកស្នើសុំអំពីការពិចារណានៅលើពាក្យស្នើសុំ ។

(គ) សំណើនៃអ្នកស្នើសុំផ្តល់ជូនដោយពុំមានការពន្យារពេលហួសហេតុ អំពីពត៌មាន លក្ខន្តិកៈនៃពាក្យស្នើសុំស្ថិតនៅក្នុងការពិចារណា និង

(ឃ) ប្រសិនបើពាក្យស្នើសុំត្រូវបានបញ្ចប់ ឬបដិសេធដើម្បីពន្យារពេលអាចធ្វើបានជាអតិបរមា ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំដោយមិនបង្អង់ ព្រោះដើម្បីបញ្ជាក់ពីសកម្មភាព។ អ្នកស្នើសុំមានលទ្ធភាពដាក់ជូនពាក្យស្នើសុំជាថ្មីម្តងទៀត ដោយប្រុងប្រយត្ន័នៅលើពាក្យស្នើសុំថ្មី ។

៦. ក្នុងផ្នែកជាច្រើនដែលការសន្យាតាមវិស័យ ចំពោះសេវាកម្មជំនាញត្រូវបានធ្វើឡើង ហើយភាគីនីមួយៗ នឹងផ្តល់នូវនីតិវិធីគ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យសមត្ថភាពនៃជំនាញរបស់ភាគីផ្សេងៗទៀត ។

---

[10] ពាក្យថា "អង្គការអន្តរជាតិពាក់ព័ន្ធ" យោងទៅតាមលក្ខណៈអន្តរជាតិ ដែលសមាជិកភាពបើកចំហ ក្នុងការទាក់ទង អង្គការផ្សេងៗទៀតមកពីគ្រប់ភាគី ។

៧. ប្រធានបទសំរាប់ច្បាប់ក្នុងស្រុក និងបទបញ្ញត្តិផ្សេងៗ ភាគីនិមួយៗនឹងអនុញ្ញាតដល់អ្នកផ្គត់ផ្គង់សេវាកម្ម របស់ភាគីផ្សេងៗទៀត ដើម្បីប្រើប្រាស់ពាណិជ្ជនាមក្នុងការបំពេញធុរកិច្ចធម្មតាក្នុងតំបន់របស់ភាគីផ្សេងទៀត បើមិន ដូច្នោះភាគីនោះត្រូវធានាថា ការប្រើប្រាស់ពាណិជ្ជនាមនោះ គឺមិនកំណត់លក្ខខណ្ឌហួសហេតុពេកទេ ។

## មាត្រា ១១

## តម្លាភាព

១. ភាគីទាំងអស់ទទួលស្គាល់ថា វិធានការគ្រប់គ្រងពាណិជ្ជកម្មសេវាកម្មឱ្យមានតម្លាភាព មានសារសំខាន់ក្នុងការ សម្របសម្រួលភាពប៉ិនប្រសប់ក្នុងការផ្គត់ផ្គង់សេវាកម្ម ដើម្បីទទួលបាននូវច្រកចូល និងប្រតិបត្តិនៅក្នុងទីផ្សាររវាង គ្នា និងគ្នា ។ ភាគីនីមួយៗ នឹងជំរុញតម្លាភាព នៃបទប្បញ្ញត្តិនៅក្នុងពាណិជ្ជកម្មសេវាកម្ម ។

**ការផ្សព្វផ្សាយ**

២. ភាគីនីមួយៗត្រូវផ្សព្វផ្សាយភ្លាមៗ និងលើកលែងតែក្នុងស្ថានភាពបន្ទាន់ចេញ យ៉ាងយឺតបំផុតត្រឹមថ្ងៃចូលជា ធរមាននៃកិច្ចព្រមព្រៀង :

(ក) វិធានការពាក់ពន្ធ័ទាំងឡាយនៃពាក្យស្នើសុំទូទៅ បានជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម និង

(ខ) កិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ពន្ធ័ ឬការជះឥទ្ធិពលទៅលើពាណិជ្ជកម្មសេវាកម្ម ត្រូវ បានចុះហត្ថលេខានៅក្នុងកិច្ចព្រមព្រៀងដោយសមាជិកទាំងអស់នៃភាគីនីមួយៗ ។

៣. យោងតាមវិសាលភាពដែលអាចធ្វើទៅបាន ភាគីនីមួយៗ នឹងបង្កើតវិធានការ និងកិច្ចព្រមព្រៀងអន្តរជាតិ នានា ដូចមានចែងក្នុងកឋាខ័ណ្ឌ ២ ដែលអាចរកបានតាមរយៈអ៊ិនធឺណែត ។

៤. នៅពេលដែលការផ្សព្វផ្សាយដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ មិនអាចអនុវត្តបានពតិមានបែបនេះ[១១] ត្រូវតែ ធ្វើយ៉ាងណាឱ្យបានដឹងជាសាធារណៈ ។

---

[១១] សម្រាប់ភាពជឿជាក់ដ៏សំខាន់ បណ្តាភាគីយល់ស្របថា ពតិមានដែលអាចនឹងត្រូវបោះពុម្ពផ្សាយ គឺជាការជ្រើសរើសទៅតាមភាសាផ្ទាល់របស់ ភាគីនីមួយៗ ។

៥.	យោងតាមការផ្តល់វិសាលភាពក្រោមបណ្តាញការងារស្របច្បាប់ក្នុងស្រុក ភាគីនីមួយៗ នឹងព្យាយាមផ្តល់ឱកាសបញ្ចេញហេតុផលដែលអាចទទួលយកបាន សំរាប់ការធ្វើអត្ថាធិប្បាយដោយមនុស្សសំខាន់របស់ភាគីនោះ ស្តីពីវិធានការដូចមានចែងក្នុងកថាខ័ណ្ឌ ២ (ក) មុនការទទួលយល់ព្រម ។

**ការិយាល័យទំនាក់ទំនងព័ត៌មាន**

៦.	ភាគីនីមួយៗ ត្រូវជ្រើសរើសយកការិយាល័យទំនាក់ទំនង ដើម្បីសម្របសម្រួលការទំនាក់ទំនងក្នុងចំណោមភាគីនានាស្តីពីការគ្រប់គ្រងបញ្ហាដោយផ្នែក ។ ផ្អែកលើសំណូមពររបស់ភាគីដទៃទៀត ការិយាល័យទំនាក់ទំនងត្រូវ :

(ក)	រកការិយាល័យ ឬមន្ត្រីទទួលខុសត្រូវលើបញ្ហាបន្តបន្ទាប់ និង

(ខ)	ជួយជាប្រចាំដល់ការសម្របសម្រួល ការប្រាស្រ័យទាក់ទងនឹងការស្នើឱ្យភាគីណាមួយ គោរពលើបញ្ហានោះ ។

៧.	ភាគីនីមួយៗ នឹងត្រូវទទួលខុសត្រូវជាបន្ទាន់ទៅការស្នើទាំងឡាយដោយភាគីណាមួយ ឬពត៌មានជាក់លាក់អំពី :

(ក)	វិធានការណាមួយដូចមានចែងក្នុងកថាខ័ណ្ឌ ២ (ក) ឬ កិច្ចព្រមព្រៀងអន្តរជាតិណាមួយ ដូចមានចែងក្នុងកថាខ័ណ្ឌ ២ (ខ) និង

(ខ)	មានអ្វីដែលថ្មី ឬការផ្លាស់ប្តូរអ្វីដែលមានស្រាប់ដូចជា ច្បាប់ បទប្បញ្ញត្តិ ឬការណែនាំអំពីរបៀបគ្រប់គ្រង ដែលជះឥទ្ធិពលគួរឱ្យកត់សម្គាល់ ទៅលើពាណិជ្ជកម្មសេវាកម្ម ដោយការសន្យាតាមវិស័យរបស់ភាគីនានាក្នុងជំពូកនេះ ថាតើភាគីផ្សេងទៀតធ្លាប់កត់សម្គាល់ដែរឬអត់កន្លងមកនូវអ្វីថ្មី ឬ មានការផ្លាស់ប្តូរទៅលើច្បាប់ បទប្បញ្ញត្តិ ឬការណែនាំអំពីរបៀបគ្រប់គ្រង ។

## មាត្រា ១២
## តម្លាភាព និងការអនុវត្តបញ្ញត្តិនានា

**នីតិវិធីរដ្ឋបាល**

១.	ទស្សនៈមួយដើម្បីគ្រប់គ្រងឱ្យបានត្រឹមត្រូវឥតខ្ចោះ មិនលំអៀង និងលក្ខណៈសមហេតុផលតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធីនានា និងច្បាប់រដ្ឋបាល នៃការស្នើសុំទូទៅដែលជះឥទ្ធិពលលើពាណិជ្ជកម្មសេវាកម្ម ភាគីនីមួយៗ

បានអះអាងថា ភ្នាក់ងាររដ្ឋបាលរបស់គេបានអនុវត្តតាមច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងច្បាប់រដ្ឋបាល ដើម្បីសេវាកម្មដាច់ដោយឡែក ឬអ្នកផ្គត់ផ្គង់សេវាកម្ម ដោយភាគីផ្សេងទៀតក្នុងករណីជាក់លាក់ តាមរយៈនីតិវិធីរដ្ឋ បានរួមបញ្ចូលទាំងការពិភាក្សាអំពីច្បាប់ បង្កើតច្បាប់ ការចេញអាជ្ញាប័ណ្ណ ការប្តេជ្ញា និងនីតិវិធីក្នុងការអនុមត័នានា ដូចជា :

(ក) ដើម្បីផ្តល់វិសាលភាពក្រោមក្របខណ្ឌការងារស្របច្បាប់ក្នុងស្រុក និងកន្លែងដែលអាចធ្វើបាន ដើម្បីផ្គត់ផ្គង់សេវាកម្មរបស់ភាគីផ្សេងទៀត ដែលជះឥទ្ធិពលផ្ទាល់ដោយនីតិវិធីរដ្ឋបាលនានា ជាមួយនឹងហេតុផលអាចទទួលយកបានគួរឱ្យកត់សំគាល់ថា នីតិវិធីដែលត្រូវការឆ្លងកាត់តាមដំណាក់កាល ។

(ខ) ដើម្បីផ្តល់វិសាលភាពក្រោមក្របខណ្ឌការងារស្របច្បាប់ក្នុងស្រុក ត្រូវព្យាយាមស្តាបស្ទង់ក្នុងការផ្តល់សេវា ដោយកាលានុវត្តភាពសមហេតុផល ធ្វើបទបង្ហាញពីព្រឹត្តិការណ៍ និងវិវាទនានា ក្នុងការគាំទ្រតួនាទីអាទិភាពដល់សកម្មភាពរដ្ឋបាលចុងក្រោយបង្អស់ណាមួយ ដែលពេលវេលា គឺជាចរិតលក្ខណៈនៃបែបបទ និងការអនុញ្ញាតដោយយកចិត្តទុកដាក់ជាសាធារណៈ និង

(គ) ធ្វើតាមនីតិវិធីនានាដែលមាននៅក្នុងការអនុញ្ញាតដោយច្បាប់ រួមទាំងការពិនិត្យឡើងវិញ និងការអំពាវនាវ ។

### ការពិនិត្យឡើងវិញ និងការកោះហៅមកប្រជុំ

២. ភាគីនីមួយៗត្រូវកាន់វិន័យឱ្យបានល្អជាអាជ្ញាកណ្តាល ឬជាតុលាការរដ្ឋបាល ឬជានីតិវិធីនៃគោលបំណង ដើម្បីពិនិត្យឡើងវិញបន្ទាន់[១២] និងដីកាកែតម្រូវ ការកែតម្រូវពីលទ្ធផលសកម្មភាពរដ្ឋបាលចុងក្រោយបង្អស់ អំពីបែបបទដែលមានចែងក្នុងកថាខ័ណ្ឌ ១ ។ នីតិវិធី ឬការកាត់ក្តី គឺឯករាជភាពរបស់ភ្នាក់ងារ ដែលត្រូវបានប្រគល់ការទុកចិត្តជាមួយនឹងសកម្មភាពទាក់ទងនឹងរដ្ឋបាល នៃភាគីនីមួយៗ នឹងធានាថា ការវិនិច្ឆ័យ ឬការផ្តល់បែបបទនានា សំរាប់គោលបំណងមួយ និងការពិនិត្យ ដោយមិនលំអៀង ។

៣. ភាគីនីមួយៗត្រូវអះអាងថា ក្នុងការកាត់សេចក្តីណាមួយ ឬ តាមនីតិវិធី ភាគីទាំងអស់ត្រូវចាត់នីតិវិធី និងផ្តល់ជាមួយនូវសិទ្ធិ ដូចខាងក្រោម :

(ក) ឱកាសផ្តល់ហេតុផលដើម្បីធានា ឬការពារតួនាទីរបស់ពួកគេរៀងៗខ្លួន និង

---

12 សំរាប់ការចៀសវាងនូវភាពមន្ទិលសង្ស័យ "ពិនិត្យសារឡើងវិញ" រួមទាំងការពិនិត្យយ៉ាងល្អិតល្អន់នៅលើកថាខ័ណ្ឌ ដែលបានផ្តល់ឱ្យសំរាប់អនុវត្តដោយច្បាប់របស់ភាគីមួយ ។

(ខ) សេចក្ដីសំរេចមួយដោយយោងតាមច្បាប់នានានៃភាគីមួយ

៤. ភាគីនីមួយៗ ត្រូវបញ្ជាក់ពីប្រធានបទដែលជាកម្មវត្ថុក្នុងការពិភាក្សា ដើម្បីកោះហៅបណ្ដាភាគីមកចូលប្រជុំ ឬពិនិត្យឡើងវិញឱ្យបានលំអិតថែមទៀត ដូចដែលបានផ្ដល់តាមច្បាប់ ដែលសេចក្ដីសំរេចនីមួយៗ ត្រូវយោងតាមកឋាខ័ណ្ឌ ៣ (ខ) ហើយត្រូវអនុវត្តដូចដែលបានចែងក្នុងច្បាប់នានារបស់ភាគីនោះ ។

## មាត្រា ១៣
## ការទម្លាយព័ត៌មានសម្ងាត់

ពុំមានបញ្ញាអ្វីទាំងអស់នៅក្នុងជំពូកនេះ ដែលតំរូវឱ្យបកស្រាយនូវតំរូវការរបស់ភាគីមួយ ដើម្បីផ្ដល់ឱ្យនូវព័ត៌មានសម្ងាត់នានារបស់ភាគីផ្សេងៗទៀត ហើយការទម្លាយព័ត៌មាននេះនឹងរារាំងដល់ការអនុវត្តច្បាប់ ឬផ្ទុយពីផលប្រយោជន៍សាធារណៈ ឬនឹងធ្វើឱ្យខូចខាតផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសសាធារណៈ ឬឯកជនណាមួយឡើយ ។

## មាត្រា ១៤
## ភាពផ្ដាច់មុខ និង អ្នកផ្គត់ផ្គង់សេវាផ្ដាច់មុខ

១. ភាគីនីមួយៗ ត្រូវធានាថា អ្នកផ្គត់ផ្គង់សេវាផ្ដាច់មុខណាមួយនៅក្នុងដែនដីរបស់ខ្លួន នៅក្នុងការផ្គត់ផ្គង់សេវាផ្ដាច់មុខក្នុងទីផ្សារពាក់ព័ន្ធនានា នឹងមិនប្រព្រឹត្តក្នុងលក្ខណៈមួយ ដែលមិនស្របតាមកាតព្វកិច្ចរបស់ភាគីនោះ ដោយអនុលោមតាមមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា ៤ (ការបើកច្រកទីផ្សារ) ។

២. នៅពេលដែលអ្នកផ្គត់ផ្គង់ផ្ដាច់មុខរបស់ភាគីមួយ ប្រកួតប្រជែងដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនសម្ព័ន្ធ ការផ្គត់ផ្គង់សេវាដែលស្ថិតក្រៅវិសាលភាពនៃសិទ្ធិផ្ដាច់មុខរបស់ខ្លួន និងដែលជាកម្មវត្ថុនៃការសន្យាតាមវិស័យ របស់ភាគីនោះភាគីនោះត្រូវធានាថា អ្នកផ្គត់ផ្គង់នេះនឹងមិនប្រើប្រាស់បំពាននូវតួនាទីផ្ដាច់មុខរបស់ខ្លួនក្នុងការផ្គត់ផ្គង់សេវាកម្មនៅក្នុងដែនដីរបស់ភាគីផ្សេងក្នុងលក្ខណៈ មួយដែលមិនសមស្របនឹងការសន្យាទាំងនោះ ។

៣. ប្រសិនបើភាគីណាមួយ មានមូលហេតុដែលគួរឱ្យជឿថា អ្នកផ្គត់ផ្គង់សេវាផ្ដាច់មុខនៃភាគីមួយផ្សេងទៀតកំពុងតែប្រព្រឹត្តមិនស្របនឹងកថាខ័ណ្ឌ ១ ឬកថាខ័ណ្ឌ ២ ភាគីនោះអាចស្នើភាគីដែលបង្កើតរក្សាទុក ឬអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់សេវាកម្មនោះ ផ្ដល់ពត៌មានជាក់លាក់អំពីប្រតិបត្តិការពាក់ព័ន្ធរបស់ខ្លួនបាន ។

៤.	មាត្រានេះក៏ត្រូវអនុវត្តផងដែរចំពោះករណីដែលអ្នកផ្គត់ផ្គង់សេវាផ្ដាច់មុខទាំងឡាយ ដែលភាគីមួយជាផ្លូវការ ឬជាឥទ្ធិពល ៖

(ក)	អនុញ្ញាត ឬបង្កើតឱ្យមានអ្នកផ្គត់ផ្គង់សេវាមួយក្រុមតូច និង

(ខ)	រារាំងស្ទើរតែទាំងស្រុងមិនឱ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកផ្គត់ផ្គង់ទាំងនោះ នៅក្នុងដែនដីរបស់ខ្លួន។

## មាត្រា ១៥
## ការប្រតិបត្តិធុរកិច្ច

១.	បណ្ដាភាគីទទួលស្គាល់ថា ការអនុវត្តធុរកិច្ចមួយចំនួនរបស់អ្នកផ្គត់ផ្គង់សេវា ក្រៅពីការអនុវត្តដែលមានចែងក្នុងមាត្រា ១៤ (ភាពផ្ដាច់មុខ និងការផ្គត់ផ្គង់សេវាផ្ដាច់មុខ) អាចបន្ទុចបង្អាក់ការប្រកួតប្រជែង និងដោយសារ ហេតុផលនេះហើយ ធ្វើឱ្យមានការរឹតត្បិតដល់ពាណិជ្ជកម្មសេវាកម្ម។

២.	ភាគីនីមួយៗ តាមសំណើរបស់ភាគីណាមួយផ្សេងទៀត ត្រូវចូលរួមពិគ្រោះយោបល់ ក្នុងគោលបំណងដើម្បីលុបបំបាត់ការអនុវត្តដែលមានចែងក្នុងកថាខណ្ឌ១។ ភាគីដែលត្រូវបានស្នើសុំនោះត្រូវពិចារណាឱ្យបានពេញលេញ និងប្រកបដោយសមានចិត្តចំពោះសំណើបែបនេះ និងត្រូវធ្វើសហប្រតិបត្តិការតាមរយៈការផ្ដល់ព័ត៌មានមិនសម្ងាត់ ដែលអាចរកបានតាមសំណើរបស់ភាគីស្នើសុំ។ ភាគីដែលត្រូវបានស្នើសុំក៏ត្រូវផ្ដល់ផងដែរនូវព័ត៌មាន ដែលអាចរកបានដទៃទៀតតាមសំណើរបស់ភាគីស្នើសុំផ្អែកតាមច្បាប់ក្នុងស្រុករបស់ភាគីនោះ និងអាស្រ័យលើការព្រមព្រៀងរវាងគ្នា ស្ដីពីកិច្ចការពារការសំងាត់របស់ភាគីស្នើសុំ។

## មាត្រា ១៦
## ការទទួលស្គាល់

១.	សំរាប់គោលបំណងនៃការអនុវត្តទាំងស្រុង ឬដោយផ្អែកនូវបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យសំរាប់ការអនុញ្ញាតផ្ដល់អាជ្ញាប័ណ្ណ ឬចេញវិញ្ញាប័នបត្រចំពោះអ្នកផ្គត់ផ្គង់សេវា និងប្រធានបទតាមអ្វីៗដែលតំរូវឱ្យមានដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៣ ហើយភាគីនីមួយៗអាចទទួលស្គាល់ការសិក្សាអប់រំ ឬបទពិសោធន៍ដែលទទួលបាន ការបំពេញបានតាមលក្ខខ័ណ្ឌតម្រូវ អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រ ដែលបានផ្ដល់ជូនក្នុងប្រទេសរបស់ភាគីមួយទៀត។ ការទទួលស្គាល់បែបនេះ អាចសម្រេចបានតាមរយៈសុខដុមភាវូបនីយកម្ម ឬអាចផ្អែកលើកិច្ចព្រមព្រៀង ឬការរៀបចំរវាងបណ្ដាភាគី ឬអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ ឬត្រូវបានផ្ដល់ជាស្វយ័តភាព។

២. ភាគីដែលជាភាគីមួយនៃប្រភេទកិច្ចព្រមព្រៀង ឬការរៀបចំដែលមានចែងក្នុងកថាខ័ណ្ឌ ១ ទោះជាកំពុងមានអត្ថិភាព ឬនឹងកើតមាននាពេលអនាគតក្តីត្រូវផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីពាក់ព័ន្ធដទៃទៀត ដើម្បីអាចចូលរួមចរចាលើកិច្ចព្រមព្រៀង ឬការរៀបចំបែបនោះ ឬកិច្ចព្រមព្រៀងឬការរៀបចំស្រដៀងគ្នានេះ។ នៅពេលណា ដែលភាគីមួយផ្តល់ការទទួលស្គាល់ដោយស្វយ័តភាព ភាគីនោះត្រូវផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីឱ្យភាគីផ្សេងទៀតបង្ហាញថា ការសិក្សាអប់រំ បទពិសោធន៍ អាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រដែលទទួលបាន ឬដែលបំពេញបានតាមលក្ខខណ្ឌតំរូវនៅក្នុងដែនដីរបស់ភាគីដទៃទៀត ក៏នឹងត្រូវបានទទួលស្គាល់ផងដែរ។

៣. ភាគីមួយមិនត្រូវផ្តល់ការទទួលស្គាល់ក្នុងលក្ខណៈមួយ ដែលនឹងបង្កើតឱ្យមានការរើសអើងរវាងប្រទេសនានានៅក្នុងការអនុវត្តបទដ្ឋាន ឬលក្ខណៈវិនិច្ឆ័យរបស់ខ្លួនសម្រាប់ការផ្តល់ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬ វិញ្ញាបនបត្រ ដល់អ្នកផ្គត់ផ្គង់សេវា ឬការរឹតត្បិតជាលក្ខណៈបិទបាំងលើពាណិជ្ជកម្មសេវាកម្មឡើយ។

៤. នៅពេលណាមួយសមស្រប ការទទួលស្គាល់ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានព្រមព្រៀងគ្នាជាពហុភាគី។ ក្នុងករណីសមស្រប បណ្តាភាគីត្រូវធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដែលពាក់ព័ន្ធសំដៅបង្កើត និងអនុម័តបទដ្ឋានអន្តរជាតិ និងលក្ខណៈវិនិច្ឆ័យរួមសំរាប់ការទទួលស្គាល់ និងបទដ្ឋានអន្តរជាតិរួម សំរាប់ការអនុវត្តសេវាកម្មពាណិជ្ជកម្ម និង វិជ្ជាជីវៈពាក់ព័ន្ធ។

៥. ភាគីនីមួយៗនឹងទទួលបានការលើកទឹកចិត្ត ក្នុងការបង្កើនសមត្ថភាពជារូបវន្តនៅក្នុងដែនដីរបស់ខ្លួន ដើម្បីចូលរួមចរចាសំរាប់កិច្ចព្រមព្រៀងនានា ឬការរៀបចំអំពីការទទួលស្គាល់នៃលក្ខខណ្ឌតម្រូវ លើគុណភាពវិជ្ជាជីវៈ គុណភាពនីតិក្រម ឬតំរូវការផ្សេងៗក្នុងការចុះឈ្មោះ និងការផ្តល់អាជ្ញាប័ណ្ណ ឬនីតិវិធីក្នុងការចុះឈ្មោះដើម្បីទទួលបាននូវលទ្ធផលយ៉ាងឆាប់រហ័ស។

## មាត្រា ១៧

## ការទូទាត់ និងការផ្ទេរ

១. លើកលែងតែស្ថិតក្រោមកាលៈទេសៈដែលបានប្រមើលទុកនៅក្នុងមាត្រា ៤ ចេញ (វិធានការការពារតុល្យ-ភាពចំណាយ) អនុលោមតាមជំពូក១៥ (បទប្បញ្ញត្តិទូទៅ និងការលើកលែង) ភាគីមួយមិនត្រូវដាក់ការរឹតត្បិតចំពោះការផ្ទេរ និងទូទាត់ជាលក្ខណៈអន្តរជាតិ សម្រាប់ប្រតិបត្តិការចរន្តទាំងឡាយ ទាក់ទិននឹងការសន្យាតាមវិស័យរបស់ខ្លួន។

២. គ្មានអ្វីទាំងអស់នៅក្នុងជំពូកនេះ នឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ អនុលោមតាមមាត្រានៃកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ រួមបញ្ចូលទាំងការប្រើប្រាស់សកម្មភាពដោះដូរ ដោយអនុលោមតាមមាត្រានៃកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិ ផ្តល់ឱ្យតែភាគីណាដែលមិនដាក់ការរឹតត្បិតលើប្រតិបត្តិការមូលធនណាមួយ ផ្ទុយពីការសន្យាតាមវិស័យរបស់ខ្លួនពាក់ព័ន្ធនឹងប្រតិបត្តិការនោះ លើកលែងតែការរឹតត្បិតអនុលោមតាមមាត្រា ៤ (វិធានការការពារតុល្យ- ភាពចំណាយ) នៃជំពូក ១៥ (បទប្បញ្ញត្តិទូទៅ និងការលើកលែង) ឬផ្អែកតាមសំណើរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។

## មាត្រា ១៨
## ឧបត្ថម្ភធន

១. ថ្វីបើមានចែងនៅក្នុងមាត្រា១.៤ (ខ) (ទំហំ និងវិសាលភាព) ក៏ដោយ គ្រប់ភាគីទាំងអស់ ត្រូវពិនិត្យឡើងវិញ លើបញ្ហានៃវិន័យស្តីពីឧបត្ថម្ភធនលើពាណិជ្ជកម្មសេវាកម្មធុនស្រាល ដោយរបៀបណាផ្សេងដែលយល់ព្រមតាមមាត្រា XV នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) ។

២. ភាគីទាំងអស់ទទួលស្គាល់ថា ក្នុងកាលៈទេសៈពិតប្រាកដ ឧបត្ថម្ភធនអាចជះឥទ្ធិពលលំអៀងលើពាណិជ្ជកម្មសេវាកម្ម។ មានភាគីខ្លះបានពិចារណាថា វាបានជះឥទ្ធិពលមិនល្អដោយសារតែការឧត្ថម្ភធន ហើយភាគីផ្សេងទៀតអាចនឹងស្នើសុំការពិគ្រោះ លើបញ្ហានោះ។ ការស្នើសុំទាំងនោះ អាចធ្វើបានដោយយោងតាមការពិចារណាដោយការយោគយល់គ្នាពីបណ្តាភាគី ។

## មាត្រា ១៩
## វិធានការរក្សាសុវត្ថិភាព

១. បណ្តាភាគីកត់សំគាល់អំពីកិច្ចចរចាពហុភាគី អនុលោមតាមមាត្រា X នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្មស្តីពីបញ្ហាវិធានការការពារក្នុងសភាពអាសន្ន ផ្អែកលើគោលការណ៍មិនរើសអើង។ នៅពេលបញ្ចប់កិច្ចចរចាពហុភាគីទាំងនោះ បណ្តាភាគីត្រូវធ្វើការពិនិត្យឡើងវិញ សំដៅពិភាក្សាអំពីការធ្វើវិសោធនកម្ម សមស្របចំពោះកិច្ចព្រមព្រៀងនេះ ដើម្បីបញ្ចូលលទ្ធផលនៃកិច្ចចចាពហុភាគីនោះ ។

២. នៅក្នុងករណីដែលការអនុវត្តកិច្ចព្រមព្រៀងនេះ បណ្តាលឱ្យកើតមានផលប៉ះពាល់ធ្ងន់ធ្ងរ ទៅលើវិស័យសេវាកម្មរបស់ភាគីមួយ នៅមុនការបញ្ចប់កិច្ចចរចាពហុភាគី ដែលយោងក្នុងកថាខ័ណ្ឌ ១ ភាគីដែលរងការប៉ះពាល់អាចស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយភាគីណាមួយ ឬភាគីដទៃទៀត។ ភាគីណាមួយ ឬភាគីដទៃទៀត នឹងចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយភាគីស្នើសុំតាមការសន្យាថា ភាគីស្នើសុំ ឬភាគីដទៃទៀតអាចធ្វើការពិចារណាលើហេតុផលដែលបណ្តាលឱ្យមានការជះឥទ្ធិពលមិនល្អយ៉ាងប្រាកដ ទៅលើលទ្ធភាពនៃភាគីអ្នកស្នើសុំ ដើម្បីចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនោះ។ ភាគីស្នើសុំនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ភាគីដទៃទៀត អំពីការស្នើសុំពិគ្រោះរបស់ពួកគេ ដូចមានចែងក្នុងកថាខ័ណ្ឌនេះ។

៣. វិធានការទាំងឡាយត្រូវបានទទួលយក ស្របតាមកថាខ័ណ្ឌ ២ នឹងយល់ព្រមរវាងភាគីពាក់ព័ន្ធ។

៤. លទ្ធផលកិច្ចពិគ្រោះយោបល់របស់ភាគីទាំងឡាយ នឹងធ្វើជាលាយលក្ខណ៍អក្សរ ដើម្បីផ្ញើជូនភាគីដទៃទៀតក្នុងពេលដ៏ខ្លី តាមការដែលអាចប្រព្រឹត្តទៅបាន និងឱ្យបានមុនកិច្ចប្រជុំលើកក្រោយនៃគណៈកម្មាធិការស្តីពីសេវាកម្មអនុលោមតាមមាត្រា ២៤ (គណៈកម្មាធិការស្តីពីពាណិជ្ជកម្មសេវាកម្ម) ស្របតាមលទ្ធផលនៃកិច្ចពិគ្រោះយោបល់។

## មាត្រា ២០
## ការបង្កើនការចូលរួមសម្រាប់រដ្ឋជាសមាជិកអាស៊ានថ្មី

នៅក្នុងជំពូកនេះ គឺដើម្បីបង្កើនអត្ថប្រយោជន៍សំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី និងស្របតាមគោលបំណងនៃលំនាំដើមកិច្ចព្រមព្រៀងនេះ និងគោលបំណងរបស់ជំពូក ១២ (សហប្រតិបត្តិការសេដ្ឋកិច្ច) ភាគីទាំងអស់ទទួលស្គាល់ភាពសំខាន់នៃការព្រមព្រៀងពិសេស និង ភាពខុសគ្នានៃប្រព្រឹត្តិកម្មចំពោះរដ្ឋជាសមាជិកអាស៊ានថ្មី និងកិច្ចសម្របសម្រួលក្នុងការចូលរួមរបស់ពួកគេនៅក្នុងជំពូកនេះ ឆ្លងកាត់ការចរចាលើកិច្ចសន្យាតាមវិស័យទាក់ទងទៅនឹង :

(ក) ការពង្រឹងសមត្ថភាព ការផ្គត់ផ្គង់សេវាក្នុងស្រុក និងប្រសិទ្ធភាពនៃសេវាកម្ម និងភាពប្រកួតប្រជែងតាមរយៈ ការចូលទៅ ប្រើប្រាស់បច្ចេកវិទ្យាមូលដ្ឋានគ្រឹះនៃពាណិជ្ជកម្ម

(ខ) ការកែលម្អច្រកចូលទីផ្សារ តាមរយៈបណ្តាញចែកចាយនានា និងបណ្តាញការងារផ្នែកពត៌មាន

(គ) ការសន្យានៅក្នុងវិស័យផ្សេងៗ សំរាប់ទាក់ទាញការចាប់អារម្មណ៍លើការនាំចេញទៅបណ្តារដ្ឋជាសមាជិកអាស៊ានថ្មី និង

(ឃ) ការទទួលស្គាល់ថា ការសន្យានានាដោយរដ្ឋជាសមាជិកអាស៊ានថ្មី អាចនឹងធ្វើឡើងនៅក្នុងការព្រមព្រៀងជាមួយការអភិវឌ្ឍន៍ក្នុងដំណាក់កាលដោយឡែកពីគ្នា។

## មាត្រា ២១

## ការបដិសេធនូវអត្ថប្រយោជន៍

ភាគីមួយអាចបដិសេធនូវអត្ថប្រយោជន៍នៃជំពូកនេះ :

(ក) ចំពោះការផ្គត់ផ្គង់សេវាមួយ ប្រសិនបើរកឃើញថា សេវានោះត្រូវបានផ្គត់ផ្គង់ចេញមកពី ឬនៅក្នុងដែនដីនៃប្រទេសមិនមែនជាភាគី

(ខ) ករណីនៃការផ្គត់ផ្គង់សេវាដឹកជញ្ជូនផ្លូវសមុទ្រ ប្រសិនបើរកឃើញថា សេវាត្រូវបានផ្គត់ផ្គង់ :

(i) ដោយនាវាដែលបានចុះបញ្ជីតាមច្បាប់របស់ប្រទេសមិនមែនភាគី និង

(ii) ដោយបុគ្គលនៃប្រទេសមិនមែនជាភាគី ដែលប្រតិបត្តិការ និង/ឬប្រើប្រាស់នាវានោះ ទាំងមូល ឬដោយផ្នែក ។

(គ) អ្នកផ្គង់ផ្គង់សេវាដែលជានីតិបុគ្គល ប្រសិនបើរកឃើញថា នីតិបុគ្គលនោះមិនមែនជាអ្នកផ្គត់ផ្គង់សេវាកម្ម នៃភាគីម្ខាងទៀត ។

## មាត្រា ២២

## ប្រត្តិកម្ម និងការការពារទត្តមាននៃធុរកិច្ច

១. ជំពូក ១១ (វិនិយោគ) មិនស្នើសុំបញ្ចូលវិធានការ ឬការរក្សា ដោយភាគីមួយដើម្បីពង្រីកវិសាលភាព ដែលពួកគេគ្រប់គ្រងតាមជំពូកនេះឡើយ ។

២. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ មាត្រាបន្តបន្ទាប់ និងផ្នែកខ្លះនៃជំពូក ១១ (វិនិយោគ) ក៏ដោយ ក៏ការស្នើសុំអនុវត្តដូចគ្នា (mutatis mutandis) ចំពោះការជះឥទ្ធិពល នៃវិធានការទៅលើការផ្គត់ផ្គង់សេវា ដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្មក្នុងតំបន់ ដែលគ្រប់គ្រងដោយភាគីផ្សេងទៀត ដូចមានក្នុង :

(ក) មាត្រា ៦ (ប្រព្រឹត្តកម្មនៃវិនិយោគ)

(ខ) មាត្រា ៧ (សំណងទូទាត់ចំពោះការខាតបង់)

(គ) មាត្រា ៨ (ការផ្ទេរ)

(ឃ) មាត្រា ៩ (ការដកហូត និងសំណង)

(ង) មាត្រា ១0 (ឧបាទេសកម្ម) (Subrogation) និង

(ច) ផ្នែក (ខ) (វិវាទវិនិយោគ រវាងភាគីមួយ និងអ្នកវិនិយោគ) ។

## មាត្រា ២៣

## បទប្បញ្ញត្តិផ្សេងៗ

១. នៅក្នុងឧបសម្ព័ន្ធស្ដីពីទូរគមនាគមន៍ នៃកិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មសេវាកម្ម នឹងភ្ជាប់ជាមួយនូវការបង្កើតទៅជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ អនុវត្តដូចគ្នា (mutatis mutandis) ។

២. បទប្បញ្ញត្តិបន្ថែមទៀត ស្ដីពីសេវាកម្មហិរញ្ញវត្ថុ និងទូរគមនាគមន៍ ត្រូវបានបង្កើតចេញនៅក្នុងជំពូកនៃឧបសម្ព័ន្ធនានា ។

## មាត្រា ២៤

## គណៈកម្មាធិការស្ដីពីពាណិជ្ជកម្មសេវាកម្ម

១. ភាគីទាំងឡាយ បង្កើតគណៈកម្មាធិការស្ដីពីពាណិជ្ជកម្មសេវាកម្មមួយ (គណៈកម្មាធិការសេវាកម្ម) ដែលមានតំណាងពីគ្រប់ភាគីចូលរួម ។

២. មុខងាររបស់គណៈកម្មាធិការសេវាកម្ម នឹង :

(ក) រៀបចំការពិនិត្យឡើងវិញលើការសន្យា ដូចមានចែងក្នុងមាត្រា ៦ (ប្រព្រឹត្តិកម្មវិនិយោគ) នៃកិច្ចព្រមព្រៀង

(ខ) ប្រសិនបើការចរចារពហុភាគីអនុលោមតាមមាត្រា ១៩.១ (វិធានការរក្សាសុវត្ថិភាព) មិនទាន់បានសរុបសេចក្ដី ក្នុងរយៈពេល៣ឆ្នាំចាប់តាំងពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងនេះទេនោះ ការដាក់ឱ្យពិភាក្សាស្ដីពីការស្នើសុំវិធានការរក្សាសុវត្ថិភាពបន្ទាន់ នឹងផ្អែកលើមូលដ្ឋាននៃគោលការណ៍មិនរើសអើង សំរាប់គោលបំណងនៃការពិចារណាលើការធ្វើវិសោធនកម្មលើជំពូកនេះដោយសមស្រប ។

(គ) ដាក់ឱ្យពិភាក្សាស្ដីពីពាក្យស្នើសុំ នៃប្រព្រឹត្តកម្មជាតិសមស្របបំផុតចំពោះពាណិជ្ជកម្មសេវាកម្ម ក្នុងគោលបំណងដើម្បីពិចារណាធ្វើវិសោធនកម្មសមស្របទៅនឹងជំពូកនេះ ក្នុងការជួបប្រាស្រ័យទាក់ទងគ្នាជាមួយនឹងទស្សនៈ នៃការសន្យាដោយអនុលោមតាមមាត្រា ៦ (ប្រព្រឹត្តិកម្មវិនិយោគ)

(ឃ) ពិនិត្យឡើងវិញអំពីការអនុវត្តនៃជំពូកនេះ

(ង) ពិចារណាលើបញ្ហាផ្សេងៗ ដែលរកឃើញដោយបណ្ដាភាគី និង

(ច) រាយការណ៍ជូនគណៈកម្មាធិការចំរុះស្ដីពីតំបន់ពាណិជ្ជកម្មសេរី តាមតម្រូវការចាំបាច់ ។

៣. គណៈកម្មាធិការសេវាកម្មនឹងធ្វើសេចក្តីសន្និដ្ឋានលើការពិភាក្សាដូចមានចែងក្នុងកថាខ័ណ្ឌ ២ (ក) ដល់ (គ) ក្នុងអំឡុងពេល ៥ ឆ្នាំ នៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ លុះត្រាតែភាគីផ្សេងៗទៀតព្រមព្រៀងតាមបែបផ្សេង ។

៤. គណៈកម្មាធិការសេវាកម្ម នឹងជួបប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដែលសំរេចដោយបណ្តាភាគីដូចលក្ខខណ្ឌតំរូវក្នុងមាត្រានេះ និងមាត្រា ៦ (ប្រព្រឹត្តិកម្មវិនិយោគ) ។ បណ្តាជំនួបអាចដំណើរការបាន ដោយផ្ទាល់ខ្លួន ឬតាមមធ្យោបាយផ្សេងទៀត តាមការកំណត់រួមគ្នារវាងភាគីទាំងឡាយ ។

# ឧបសម្ព័ន្ធ
# ស្តីពីសេវាហិរញ្ញវត្ថុ

## ប្រការ ១
## វិសាលភាព និងនិយមន័យ

១. ឧបសម្ព័ន្ធនេះ សំដៅដល់វិធានការទាំងឡាយណា ដែលមានឥទ្ធិពលទៅលើការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ។ ទាក់ទងទៅនឹងពាក្យថា ការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ នៅក្នុងឧបសម្ព័ន្ធនេះ ត្រូវមានន័យថា ការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ដូចបានចែងនៅក្នុងប្រការ ២(ភ) (និយមន័យ) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ។

២- គោលបំណងនៃប្រការ ២(ធ) (និយមន័យ) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម), "សេវាដែលផ្គត់ផ្គង់សម្រាប់ប្រតិបត្តិការក្នុងអាជ្ញាធររដ្ឋាភិបាល" មានន័យដូចតទៅ :

(ក) សកម្មភាពទាំងឡាយណា ដែលធ្វើឡើងដោយធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុ ឬអង្គភាពសាធារណៈផ្សេងទៀត នៅក្នុងការអនុវត្តគោលនយោបាយអត្រាប្តូរប្រាក់ ឬរូបិយវត្ថុ

(ខ) សកម្មភាពទាំងឡាយណា ដែលជាផ្នែកមួយនៃលក្ខន្តិកៈប្រព័ន្ធសន្តិសុខសង្គម ឬគម្រោងសោធននិវត្តន៍សាធារណៈ ឬ

(គ) សកម្មភាពផ្សេងៗទៀត ដែលធ្វើឡើងដោយអង្គភាពសាធារណៈ ដើម្បីរដ្ឋាភិបាល ឬមានការធានារបស់រដ្ឋាភិបាល ឬដែលប្រើប្រាស់ប្រភពទុនហិរញ្ញវត្ថុពីរដ្ឋាភិបាល ។

៣- ក្នុងគោលបំណងនៃប្រការ ២(ភ) (និយមន័យ) នៃជំពូក៨ (ពាណិជ្ជកម្មសេវាកម្ម), ប្រសិនបើភាគីណាមួយអនុញ្ញាតឱ្យធ្វើសកម្មភាពណាមួយ ដែលបានចែងនៅក្នុងកថាខណ្ឌ ២ ចំណុច (ខ) ឬ (គ) ដែលនឹងត្រូវធ្វើឡើងដោយអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុនៃភាគីនោះ ជាការប្រកួតប្រជែងជាមួយអង្គភាពសាធារណៈ ឬអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុណាមួយទៀត នោះពាក្យថា "សេវា" គួរតែរាប់បញ្ចូលនៅក្នុងសកម្មភាពទាំងនោះ។

៤- ប្រការ ២(ផ) (និយមន័យ) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) មិនសំដៅលើសេវា ដែលបានចែងនៅក្នុងឧបសម្ព័ន្ធនេះទេ។

## ប្រការ ២
## និយមន័យ

ចំពោះគោលបំណងនៃឧបសម្ព័ន្ធនេះ :

(ក) **សេវាហិរញ្ញវត្ថុ** គឺជាសេវាមានលក្ខណៈហិរញ្ញវត្ថុ ដែលផ្តល់ដោយអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុនៃភាគីណាមួយ។ សេវាហិរញ្ញវត្ថុ រួមមាន រាល់សេវាធានារ៉ាប់រង និងសេវាផ្សេងៗទាក់ទងនឹងការធានារ៉ាប់រង ព្រមទាំងសេវាធនាគារ និងហិរញ្ញវត្ថុផ្សេងៗទៀត (មិនរាប់បញ្ចូលការធានារ៉ាប់រង)។ សេវាហិរញ្ញវត្ថុរួមមាន សកម្មភាពដូចតទៅ :

*សេវាធានារ៉ាប់រង និងសេវាផ្សេងៗទាក់ទងនឹងការធានារ៉ាប់រង*

(i) ការធានារ៉ាប់រងផ្ទាល់ (រាប់បញ្ចូលទាំងសហធានារ៉ាប់រង):

ក. ជីវិត និង

ខ. មិនមែនជីវិត

(ii) ការធានារ៉ាប់រងបន្ត និងបច្ចានុប្បទាន

(iii) អន្តរការិយកម្មលើការធានារ៉ាប់រង ដូចជា ជើងសាករ និងភ្នាក់ងារ និង

(iv) សេវាបន្ថែមលើការធានារ៉ាប់រង ដូចជា សេវាពិគ្រោះយោបល់, សេវាគណនាតម្លៃធានារ៉ាប់រង, សេវាវាយតម្លៃហានិភ័យ និងសេវាទាមទារការទូទាត់បំណុល។

*សេវាធនាគារ និងហិរញ្ញវត្ថុផ្សេងៗទៀត (មិនរាប់បញ្ចូលការធានារ៉ាប់រង)*

(v) ការទទួលប្រាក់បញ្ញើ និងមូលនិធិដែលអាចសងបានផ្សេងៗពីសាធារណជន

(vi) ការឱ្យខ្ចីគ្រប់ប្រភេទ រួមទាំង ឥណទានដល់អ្នកប្រើប្រាស់ ឥណទាននិក្ខេប ការទិញបំណុលដែលនឹងទទួលសំណង និងហិរញ្ញប្បទាននៃប្រតិបត្តិការពាណិជ្ជកម្ម

(vii) ភតិសន្យាហិរញ្ញវត្ថុ

(viii) រាល់ការទូទាត់ និងសេវាផ្ទេរប្រាក់ រួមទាំង ប័ណ្ណឥណទាន ប័ណ្ណទិញជឿ និងប័ណ្ណឥណពន្ធ មូលប្បទានប័ត្រទេសចរ និងរូបិយាណត្តិ

(ix) ការធានា និងការសន្យា

(x) ការជួញដូរផ្ទាល់ខ្លួន ឬក្នុងនាមរបស់អតិថិជន ទាំងនៅក្នុងទីផ្សារមូលប័ត្រ ទីផ្សាររំលងបញ្ជរ ឬទីផ្សារផ្សេងពីនេះ នូវឧបករណ៍ដូចតទៅ :

(ក) ឧបករណ៍ទីផ្សាររូបិយវត្ថុ (រួមមាន មូលប្បទានប័ត្រ ប័ណ្ណបំណុល វិញ្ញាបនបត្រប្រាក់បញ្ញើ)

(ខ) រូបិយប័ណ្ណបរទេស

(គ) ឧបករណ៍និស្សន្ទ រួមទាំងឧបករណ៍ហ៊្យូចឲ្យូរ (futures) និងអុបស្យុង (options) ព្រមទាំងឧបករណ៍ផ្សេងៗទៀត

(ឃ) ឧបករណ៍អត្រាប្តូរប្រាក់ និងអត្រាការប្រាក់ រួមទាំងឧបករណ៍ ដូចជា កិច្ចព្រមព្រៀងស្វប់ (swaps) កិច្ចព្រមព្រៀងអត្រាហ្យ៊ូចឲ្យូរ (forward rate agreement)

(ង) មូលប័ត្រដែលអាចជួញដូរបាន, និង

(ច) ឧបករណ៍ដែលអាចជួញដូរបានផ្សេងទៀត និងទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំងមាសជាដើម

(xi) ការចូលរួមបោះផ្សាយមូលប័ត្រគ្រប់ប្រភេទ រួមទាំង ការធានាទិញ និងការវិនិយោគ ក្នុងនាមជាភ្នាក់ងារ (ជាសាធារណៈ ឬជាឯកជន) និងការផ្តល់នៃសេវា ដែលទាក់ទងនឹងការបោះផ្សាយនោះ

(xii) ការជួញដូររូបិយវត្ថុ

(xiii) ការគ្រប់គ្រងទ្រព្យសកម្ម ដូចជា ការគ្រប់គ្រងសាច់ប្រាក់ ឬផលប័ត្រ រាល់ទម្រង់នៃការគ្រប់គ្រង វិនិយោគរួម ការគ្រប់គ្រងមូលនិធិសោធននិវត្តន៍ សេវារក្សា សេវាបញ្ញើទុក និងសេវាអាណត្តិព្យាបាល

(xiv) សេវាផាត់ទាត់ និងទូទាត់ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ រួមទាំង មូលប័ត្រ ឧបករណ៍និស្សន្ទ និង ឧបករណ៍ដែលអាចជួញដូរបានផ្សេងទៀត

(xv) ការផ្តល់ និងផ្ទេរព័ត៌មានហិរញ្ញវត្ថុ និងសេវាដំណើរការទិន្នន័យហិរញ្ញវត្ថុ ព្រមទាំងសូហ្វវែរ (software) ដែលពាក់ព័ន្ធ ដោយអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុផ្សេងទៀត និង

(xvi) ការផ្តល់ប្រឹក្សា អន្តរការិយកម្ម និងសេវាហិរញ្ញវត្ថុបន្ថែមផ្សេងទៀត ចំពោះរាល់សកម្មភាពដែលបានចែងក្នុងកថាខ័ណ្ឌរង (v) ដល់ (xv) ដែលរួមមាន ឯកសារយោងនៃឥណទាន និងការវិភាគ ការប្រឹក្សា និងការស្រាវជ្រាវលើវិនិយោគផលប័ត្រ ការប្រឹក្សាអំពីការទិញយក និង អំពីយុទ្ធសាស្ត្រ និងកំណែទម្រង់រចនាសម្ព័ន្ធសាជីវកម្ម

(ខ) **អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ** សំដៅដល់នីតិបុគ្គល ឬរូបវ័ន្តបុគ្គលនៃភាគីមួយ ដែលមានបំណងផ្គត់ផ្គង់ ឬកំពុងផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ប៉ុន្តែពាក្យ "អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ" មិនរាប់បញ្ចូលអង្គភាពសាធារណៈទេ

(គ) **អង្គភាពសាធារណៈ** សំដៅដល់ :

(i) រដ្ឋាភិបាល ធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុនៃភាគីមួយ ឬអង្គភាពមួយ ដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការគ្រប់គ្រងរបស់ភាគីមួយ ហើយអង្គភាពអនុវត្តជាបឋមនូវមុខងាររបស់រដ្ឋាភិបាល ឬរាល់សកម្មភាពនានាបំរើឱ្យគោលបំណងរបស់រដ្ឋាភិបាល ដោយមិនរាប់បញ្ចូលនូវអង្គភាពដែលផ្គត់ផ្គង់សេវាហិរញ្ញវត្ថុក្នុងលក្ខខណ្ឌពាណិជ្ជកម្មឡើយ ឬ

(ii) អង្គភាពឯកជនដែលបំពេញមុខងារដូចធម្មតា ធនាគារកណ្តាល ឬអាជ្ញាធររូបិយវត្ថុបំពេញនៅពេលប្រតិបត្តិមុខងារទាំងនោះ និង

(ឃ) **អង្គការស្វ័យបញ្ញត្តិកម្ម**

(i) ក្នុងករណីប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់ គឺសំដៅដល់អង្គភាពមិនមែនរដ្ឋាភិបាល រួមមាន ទីផ្សារមូលប័ត្រ ឬទីផ្សារហ្វ៊ុចចូរ (futures) ភ្នាក់ងារទូទាត់ ឬផាត់ទាត់ ឬអង្គការ ឬសមាគមផ្សេងទៀត ដែលដំណើរការដោយខ្លួនឯងផ្ទាល់ ឬតាមការចាត់តាំងជាអាជ្ញាធរបញ្ញត្តិកម្ម ឬត្រួតពិនិត្យលើអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ឬគ្រឹះស្ថានហិរញ្ញវត្ថុ និង

(ii) ក្នុងករណីប្រទេសសមាជិកអាស៊ាន គឺសំដៅដល់អង្គភាពមិនមែនរដ្ឋាភិបាល រួមមាន ទីផ្សារមូលប័ត្រ ឬទីផ្សារហ្វ៊ុចចូរ (futures) ភ្នាក់ងារទូទាត់ឬផាត់ទាត់ អង្គការឬសមាគមផ្សេងទៀត ដែលទទួលស្គាល់ដោយច្បាប់ជាអង្គភាពស្វ័យបញ្ញត្តិកម្ម និងអាជ្ញាធរបញ្ញត្តិកម្ម ឬ

ត្រួតពិនិត្យលើអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ឬគ្រឹះស្ថានហិរញ្ញវត្ថុអនុលោមតាមច្បាប់ ឬការចាត់តាំងពីអាជ្ញាធរ ឬរដ្ឋាភិបាលមជ្ឈិម តំបន់ ឬមូលដ្ឋាន ។

## ប្រការ ៣
## បទប្បញ្ញត្តិក្នុងស្រុក

១- ទោះបីមានបទប្បញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះក្តី ភាគីមួយមិនត្រូវបានរារាំងពីការចាត់វិធានការសម្រាប់ហេតុផលប្រុងប្រយ័ត្នឡើយ ដោយរួមទាំងការការពារចំពោះវិនិយោគិន ម្ចាស់ប្រាក់បញ្ញើ អ្នកមានការធានារ៉ាប់រង ឬបុគ្គលណាដែលត្រូវទទួលខុសត្រូវដោយអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ឬដើម្បីធានានូវភាពរឹងមាំ និងស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុ ឬធានានូវស្ថិរភាពអត្រាប្តូរប្រាក់[១] នៅក្នុងលក្ខណៈដូចតទៅ :

(ក) នៅពេលណាវិធានការនោះមិនអនុលោមតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ វិធានការនោះនឹងមិនត្រូវយកមកប្រើប្រាស់ជាមធ្យោបាយដើម្បីបញ្ចៀសការសន្យា កាតព្វកិច្ចរបស់ភាគីដូចមានចែង ក្នុងកិច្ចព្រមព្រៀងនេះឡើយ

(ខ) ចំពោះវិធានការធានាស្ថិរភាពអត្រាប្តូរប្រាក់ វិធានការត្រូវយកមកប្រើមិនហួសពីការចាំបាច់ និងត្រូវបញ្ឈប់បន្តិចម្តងៗកាលណាសភាពការលែងតម្រូវឱ្យមាន ឬលែងគាំទ្រឱ្យមាន និង

(គ) ចំពោះវិធានការធានាស្ថិរភាពអត្រាប្តូរប្រាក់ វិធានការនេះត្រូវតែអនុវត្តផ្អែកលើមូលដ្ឋាននៃប្រជាជាតិ ដែលទទួលការអនុគ្រោះបំផុត (MFN)

២- គ្មានអ្វីត្រូវបកស្រាយនៅក្នុងកិច្ចព្រមពៀងនេះ ដែលតម្រូវឱ្យភាគីមួយបើកចំហព័ត៌មានពាក់ព័ន្ធនឹងកិច្ចការ និងគណនីឯកត្តជននីមួយៗ ឬព័ត៌មានសម្ងាត់ ឬព័ត៌មានផ្ទាល់ខ្លួន ដែលស្ថាប័នសាធារណៈកាន់កាប់នោះឡើយ ។

---

[១] វិធានការដើម្បីធានានូវស្ថិរភាពអត្រាប្តូរប្រាក់ គឺមិនទាន់ត្រូវបានអនុម័ត ឬប្រកាន់យកក្នុងគោលបំណងការពារផ្នែកនេះជាពិសេស ។

## ប្រការ ៤
## ការទទួលស្គាល់

១- ភាគីមួយអាចទទួលស្គាល់ពីវិធានការប្រុងប្រយ័ត្នរបស់អង្គភាពកំណត់ស្តង់ដារអន្តរជាតិ ភាគី ឬមិនមែនភាគីផ្សេងទៀត ក្នុងការកំណត់របៀបអនុវត្តវិធានការរបស់ខ្លួនពាក់ព័ន្ធនឹងសេវាហិរញ្ញវត្ថុ។ ការទទួលស្គាល់នោះ ដែលអាចធ្វើឡើងបានតាមរយៈសុខដុមភាវូបនីយកម្ម ឬផ្សេងពីនេះ អាចនឹងផ្អែកលើកិច្ចព្រមព្រៀង ឬការសម្របសម្រួលជាមួយអង្គភាពកំណត់ស្តង់ដារអន្តរជាតិ ភាគីឬមិនមែនភាគីផ្សេងទៀតដែលពាក់ព័ន្ធ ឬអាចនឹងត្រូវព្រមព្រៀងគ្នាដោយឯកភាព។

២- ភាគីមួយដែលជាភាគីនៃកិច្ចព្រមព្រៀង ឬការសម្របសម្រួលដូចបានរៀបរាប់ក្នុងកថាខ័ណ្ឌ ១ នៅពេលអនាគត ឬបច្ចុប្បន្នត្រូវផ្តល់ឱកាសសមស្របសម្រាប់ភាគីទាំងឡាយណាដែលចាប់អារម្មណ៍ ឱ្យអាចចូលរួមក្នុងកិច្ចព្រមព្រៀង ឬការសម្របសម្រួលនោះ ឬអាចចរចាលើកិច្ចព្រមព្រៀង ឬការសម្របសម្រួលស្រដៀងគ្នានោះជាមួយខ្លួននៅក្រោមលក្ខខណ្ឌដែលមានបទប្បញ្ញត្តិ ការត្រួតពិនិត្យ ការអនុវត្តបទប្បញ្ញត្តិទាំងនោះដូចគ្នា រួមទាំង នីតិវិធីពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានរវាងភាគីនានាក្នុងកិច្ចព្រមព្រៀង ឬការសម្របសម្រួលនោះ ប្រសិនចាំបាច់។

៣- នៅពេលដែលភាគីមួយព្រមព្រៀងទទួលស្គាល់ជាឯកភាព ភាគីនោះត្រូវផ្តល់ឱកាសសមស្របសម្រាប់ភាគីផ្សេងទៀតដើម្បីបង្ហាញថាលក្ខខណ្ឌដូចបានរៀបរាប់ក្នុងកថាខ័ណ្ឌ ២ ខាងលើ ពិតជាមានប្រាកដមែន។

## ប្រការ ៥
## តម្លាភាពនៃបទប្បញ្ញត្តិ

១- បណ្តាភាគីទទួលស្គាល់ថា វិធានការតម្លាភាពដែលគ្រប់គ្រងសកម្មភាពនៃគ្រឹះស្ថានហិរញ្ញវត្ថុ និងអ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុអន្តរជាតិ គឺមានសារៈសំខាន់ក្នុងការជួយសម្រួលលទ្ធភាពរបស់គ្រឹះស្ថានទាំងនោះ ដើម្បីឈានចូល និងធ្វើប្រតិបត្តិការក្នុងទីផ្សាររបស់ភាគីដទៃទៀត។

២- ភាគីនីមួយៗត្រូវធានាថា វិធានការដែលត្រូវអនុវត្តជាទូទៅ ឬត្រូវគោរពដោយភាគីមួយ នឹងត្រូវបានបោះផ្សាយយ៉ាងឆាប់រហ័ស ឬឱ្យមានប្រើប្រាស់ជាសាធារណៈ[២] តាមវិធីណាមួយផ្សេងទៀត។

[២] ដើម្បីឱ្យច្បាស់ជាងនេះ ភាគីទាំងអស់បានឯកភាពគ្នាថាភាគីនីមួយៗអាចផ្សាយព័ត៌មានជាភាសារបស់ខ្លួន

៣-	ភាគីនីមួយៗត្រូវចាត់វិធានការសមស្របតាមតែអាចធ្វើបាន ដើម្បីធានាថា វិធានដែលត្រូវអនុវត្ត ឬគោរពតាមជាទូទៅដោយអង្គភាពស្វ័យបញ្ញត្តិកម្មរបស់ខ្លួន[៣] ត្រូវបានបោះផ្សាយយ៉ាងឆាប់ ឬឱ្យមានប្រើប្រាស់ជាសាធារណៈតាមវិធីណាមួយផ្សេងទៀត[៤] ។

៤-	ភាគីនីមួយៗ ត្រូវរក្សា ឬបង្កើតយន្តការសមស្រប ដើម្បីឆ្លើយតបទៅនឹងការសាកសួរពីសំណាក់អ្នកចាប់អារម្មណ៍នៃភាគីដទៃទៀត ពាក់ព័ន្ធនឹងវិធានការដែលត្រូវអនុវត្តជាទូទៅ និងដែលស្ថិតនៅក្រោមឧបសម្ព័ន្ធនេះ[៥] ។

៥-	អាជ្ញាធរបញ្ញត្តិកម្មនៃភាគីនីមួយៗ ត្រូវប្រឹងប្រែងឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីផ្តល់ព័ត៌មានអំពីលក្ខខណ្ឌរបស់ខ្លួនចំពោះអ្នកចាប់អារម្មណ៍នៃភាគីដទៃទៀត រួមទាំងតម្រូវការឯកសារផ្សេងៗសម្រាប់បំពេញពាក្យស្នើសុំ ពាក់ព័ន្ធនឹងការផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ។

៦-	តាមសំណើជាលាយលក្ខណ៍អក្សររបស់អ្នកដាក់ពាក្យស្នើសុំ អាជ្ញាធរបញ្ញត្តិកម្មនៃភាគីមួយត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំ អំពីស្ថានភាពនៃពាក្យស្នើសុំរបស់គេជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអាជ្ញាធរត្រូវការព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យស្នើសុំ ខ្លួនត្រូវឱ្យដំណឹងទៅកាន់អ្នកដាក់ពាក្យស្នើសុំ ដោយគ្មានការយឺតយ៉ាវហួសហេតុទេ ។

៧-	អាជ្ញាធរបញ្ញត្តិកម្មនៃភាគីនីមួយៗ ត្រូវធ្វើការសម្រេចរដ្ឋបាលលើពាក្យស្នើសុំរបស់អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុរបស់ភាគីផ្សេងទៀតដែលប្រាថ្នាផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ នៅក្នុងដែនដីរបស់ភាគីខ្លួនក្នុងអំឡុងពេល ១៨០ ថ្ងៃ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ពីសេចក្តីសម្រេចនោះដល់អ្នកដាក់ពាក្យស្នើសុំដោយគ្មានការយឺត យ៉ាវហួសហេតុទេ :

(ក)	ពាក្យស្នើសុំមិនត្រូវបានចាត់ទុកថាចប់សព្វគ្រប់ឡើយ លុះណាតែបានអនុវត្តគ្រប់ដំណើរការសំខាន់ៗ ហើយ អាជ្ញាធរបញ្ញត្តិកម្មយល់ថាខ្លួនបានទទួលព័ត៌មានចំបាច់ទាំងអស់ហើយ

(ខ)	ចំពោះបញ្ហាណាដែលពុំអាចធ្វើសេចក្តីសម្រេចបានក្នុងអំឡុងពេល ១៨០ថ្ងៃ នោះអាជ្ញាធរបញ្ញត្តិកម្មត្រូវឱ្យដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកដាក់ពាក្យស្នើសុំ ដោយគ្មានការយឺតយ៉ាវ ហើយបន្ទាប់មកត្រូវព្យាយាមធ្វើសេចក្តីសម្រេចក្នុងអំឡុងពេលសមរម្យមួយ។

---

[៣] កថាខ័ណ្ឌនេះ សំដៅតែលើភាគីមួយ នៅពេលដែលភាគីនោះបង្កើតអង្គភាពស្វ័យបញ្ញត្តិកម្មរបស់ខ្លួន

[៤] ដើម្បីឱ្យច្បាស់ជាងនេះ ភាគីទាំងអស់បានឯកភាពគ្នាថាភាគីនីមួយៗអាចផ្សាយព័ត៌មានជាភាសារបស់ខ្លួន

[៥] ភាគីទាំងនោះបានបញ្ជាក់ពីការយល់ដឹងរបស់ពួកគេថា អ្នកចាប់អារម្មណ៍នៅក្នុងប្រការនេះ គឺជាអ្នកដែលមានផលប្រយោជន៍ហិរញ្ញ-វត្ថុផ្ទាល់របស់គេ រងប៉ះពាល់យ៉ាងខ្លាំងពីការគោរពតាមការអនុវត្តជាទូទៅនៃបញ្ញត្តិកម្ម

៨- យោងសំណើជាលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំដែលមិនបានជោគជ័យ អាជ្ញាធរបទប្បញ្ញត្តិ ដែលបានបដិសេធពាក្យស្នើសុំ ត្រូវខិតខំផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ដល់អ្នកស្នើសុំអំពីមូលហេតុនៃការបដិសេធ ពាក្យស្នើសុំនោះ ។

## ប្រការ ៦

## ករណីលើកលែងចំពោះសេវាហិរញ្ញវត្ថុ

គ្មានអ្វីត្រូវបកស្រាយក្នុងជំពូកនេះ ដែលរារាំងការដាក់ចុះ ឬការអនុវត្តដោយភាគីមួយ នូវវិធានការចាំបាច់ដើម្បីធានាការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលមានសង្គតិភាពនឹងជំពូកនេះឡើយ រួមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការទប់ស្កាត់ការបន្លំបោកប្រាស់ ឬដើម្បីដោះស្រាយនូវផលប៉ះពាល់ពីការខានមិនបានអនុវត្តកិច្ចសន្យាហិរញ្ញវត្ថុនៅក្នុងលក្ខខណ្ឌជានិច្ច ថាវិធានការនេះមិនត្រូវបានអនុវត្តក្នុងលក្ខណៈមួយ ដែលជាមធ្យោបាយរំលោភបំពាន ឬរើសអើងរវាងប្រទេសនៅទីណាដែលមានស្ថានភាពដូចគ្នានោះ ការរឹតត្បិតដោយបិទបាំងលើការវិនិយោគក្នុងគ្រឹះស្ថានហិរញ្ញវត្ថុ ឬពាណិជ្ជកម្មលើសេវាហិរញ្ញវត្ថុ ។

## ប្រការ ៧

## ការផ្ទេរព័ត៌មាន និងកិច្ចដំណើរការព័ត៌មាន

១- ភាគីមួយមិនត្រូវមានវិធានការដែល :

(ក) រារាំងការផ្ទេរព័ត៌មាន រួមទាំងការផ្ទេរទិន្នន័យតាមមធ្យោបាយអេឡិកត្រូនិក ដែលចាំបាច់ក្នុងការអនុវត្តពាណិជ្ជកិច្ចធម្មតារបស់អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ

(ខ) រារាំងកិច្ចដំណើរការព័ត៌មាន ដែលចាំបាច់ក្នុងការអនុវត្តពាណិជ្ជកិច្ចធម្មតារបស់អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ឬ

(គ) រារាំងការផ្ទេរឧបករណ៍ ដែលចាំបាច់ក្នុងការអនុវត្តពាណិជ្ជកិច្ចធម្មតារបស់អ្នកផ្គត់ផ្គង់សេវាហិរញ្ញវត្ថុ ប៉ុន្តែត្រូវយោងតាមវិធាននៃការនាំចូលដែលមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងអន្តរជាតិ ។

២- មិនមានអ្វី ក្នុងកថាខណ្ឌ១ ÷

(ក) កំណត់សិទ្ធិរបស់ភាគីមួយក្នុងការការពារទិន្នន័យផ្ទាល់ខ្លួន ភាពឯកជនផ្ទាល់ខ្លួន និងការសម្ងាត់នៃបញ្ជីការ និងគណនីឯកជន រួមទាំងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិក្នុងប្រទេសរបស់ខ្លួនផង ដរាបណាសិទ្ធិទាំងឡាយនោះមិនត្រូវប្រើប្រាស់ជាមធ្យោបាយដើម្បីបញ្ចៀសការសន្យា ឬកាតព្វកិច្ចទាំងឡាយណារបស់ភាគីនោះដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះ

(ខ) ការពារបញ្ញត្តិកររបស់ភាគីមួយ ដើម្បីមូលហេតុបញ្ញត្តិកម្ម និងការប្រុងប្រយ័ត្នពីការទាមទារចំពោះអ្នកផ្គត់ផ្គង់ផ្នែកសេវាហិរញ្ញវត្ថុនៅក្នុងដែនដីរបស់ខ្លួន ឱ្យប្រតិបត្តិតាមបទប្បញ្ញត្តិក្នុងប្រទេសដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការរក្សាទុកទិន្នន័យ និងការថែរក្សាប្រព័ន្ធទិន្នន័យក៏ដូចជា ក្នុងការរក្សាទុកច្បាប់ចម្លងនៃបញ្ជីការទាំងឡាយក្នុងដែនដីរបស់ខ្លួន ឬ

(គ) ត្រូវបានបកស្រាយ ដើម្បីទាមទារឱ្យភាគីមួយអនុញ្ញាតឱ្យមានការផ្គត់ផ្គង់អន្តរជាតិ ឬការប្រើប្រាស់នៅបរទេសនូវសេវាដែលភាគីនោះមិនបានធ្វើការសន្យាជាក់លាក់ឡើយ រួមទាំងការអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់ផ្នែកសេវាហិរញ្ញវត្ថុបរទេស ធ្វើការផ្គត់ផ្គង់ក្នុងឋានៈជាមេការតាមរយៈអន្តរការី ឬក៏ធ្វើជាអន្តរការីដោយខ្លួនឯង ផ្តល់និងផ្ទេរនូវព័ត៌មានហិរញ្ញវត្ថុ និងដំណើរការទិន្នន័យហិរញ្ញវត្ថុ ដូចបានចែងក្នុងមាត្រា ២ (ក) (xv) (និយមន័យ) ឡើយ។

## ប្រការ ៨
## ការដោះស្រាយវិវាទ

សមាជិករបស់សាលាក្តីអាជ្ញាកណ្តាល បង្កើតឡើងអនុលោមតាមជំពូកទី ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) សម្រាប់វិវាទស្តីពីបញ្ហាទាក់ទងនឹងបទប្បញ្ញត្តិប្រុងប្រយ័ត្ន និងបញ្ហាហិរញ្ញវត្ថុផ្សេងទៀត ត្រូវមានជំនាញចាំបាច់ពាក់ព័ន្ធនឹងសេវាហិរញ្ញវត្ថុជាក់លាក់ក្រោមវិវាទ។

## ឧបសម្ព័ន្ធ

## ស្តីពីទូរគមនាគមន៍

### មាត្រា ១

### វិសាលភាព និង ដែនកំណត់

១.	ឧបសម្ព័ន្ធនេះ ត្រូវបានប្រើប្រាស់ជាឧបករណ៍សំរាប់វាស់វែង ដោយភាគីមួយ ដែលមានឥទ្ធិពលក្នុងការធ្វើពាណិជ្ជកម្មផ្នែកបណ្តាញដឹកជញ្ជូនសារទូរគមនាគមន៍ និងសេវាជាទូទៅ ។

២.	ថ្វីបើមានកថាខ័ណ្ឌទី ១ ខាងលើក៏ដោយ ក៏ឧបសម្ព័ន្ធនេះនឹងមិនត្រូវបានប្រើប្រាស់សំរាប់ធ្វើការវាស់វែងដោយភាគីណាមួយ ដែលមានឥទ្ធិពលនៅក្នុងការផ្តល់សេវា បែងចែកផ្នែកសម្លេង និងរូបភាពឡើយ ដូចដែលបានកំណត់ដោយច្បាប់ក្នុងស្រុករបស់ភាគីនីមួយៗរួចហើយ ។

៣.	ឧបសម្ព័ន្ធនេះ គ្មានអ្វីដែលត្រូវធ្វើការបកស្រាយ ក្នុងន័យតំរូវឱ្យភាគីណាមួយអនុញ្ញាតឱ្យមានការផ្គត់ផ្គង់បណ្តាញដឹកជញ្ជូនសារទូរគមនាគមន៍ និងសេវាជាទូទៅ ដោយមានការពាក់ព័ន្ធណាមួយ ដែលមិនបានធ្វើការសន្យាដោយជាក់លាក់នៅក្នុងជំពូកនេះ ។

### មាត្រា ២

### និយមន័យ

សំរាប់ជាគោលបំណងនៃឧបសម្ព័ន្ធនេះ :

(ក)	**ទីតាំង-រួមគ្នា (ជាធម្មជាតិ)** មានន័យថា សិទ្ធិនៃការចូលទៅប្រើប្រាស់លំហ ធ្វើការតម្លើង, ថែទាំ ឬ ជួសជុលគ្រឿងបរិក្ខារ ដើម្បីធ្វើការផ្គត់ផ្គង់សេវាដឹកជញ្ជូនសារទូរគមនាគមន៍ជាទូទៅនៅក្នុងបរិវេណដែលបានកាន់កាប់ ឬត្រួតពិនិត្យ និងបានប្រើប្រាស់ ដោយអ្នកផ្គត់ផ្គង់មុន ។

(ខ)	**ការកំណត់-ថ្លៃដើម** មានន័យថា ត្រូវយកថ្លៃដើមធ្វើជាគោល និងអាចរួមបញ្ចូលនូវប្រាក់ចំណេញសមស្រមណាមួយ និងអាចពាក់ព័ន្ធទៅនឹងវិធីសាស្ត្រនៃការគណនាថ្លៃដើមផ្សេងគ្នាចំពោះឧបករណ៍, បរិក្ខារ ឬ សេវាកម្មផ្សេងគ្នា ។

(គ)	**បរិក្ខារ-សារវន្ត** មានន័យថា ជាបរិក្ខារនៃប្រព័ន្ធដឹកជញ្ជូនសារទូរគមនាគមន៍ទូទៅ ឬ សេវាកម្មដែល :

(១) មិនរាប់បញ្ចូល ឬ មានចំនួនច្រើនលើសលប់ ដែលត្រូវបានផ្ដល់ឱ្យដោយអ្នកផ្គត់ផ្គង់មួយ ឬ ស្ថិតក្នុងចំនួនកំណត់ណាមួយ, និង

(២) មិនអាចធ្វើឱ្យមានតំលៃថោក ឬក៏មានបច្ចេកទេសណាមួយមកជំនួសបាននៅក្នុងការផ្ដល់សេវាកម្ម ។

(ឃ) **អ្នកផ្គត់ផ្គង់គ្រឿងបរិក្ខារ-មូលដ្ឋាន** មានន័យថា អ្នកផ្គត់ផ្គង់ប្រព័ន្ធដឹកជញ្ជូនសារទូរគមនាគមន៍សាធារណៈ ឬ សេវាកម្ម នោះគឺ :

(១) ជាអាជ្ញាប័ណ្ណដែលទទួលបាន សម្រាប់ការបញ្ជូននៅក្នុងប្រទេសអូស្ត្រាលី ។

(២) ជាចំណាត់ថ្នាក់ ឬក្រុម ក្នុងពេលដែលមានអ្នកស្នើសុំ ដោយផ្អែកតាមច្បាប់ទូរគមនាគមន៍ ២០០១ ដែលបានធ្វើវិសោធនកម្មបន្តបន្ទាប់នៅក្នុងប្រទេសណូវែលហ្សេឡង់ ។

(៣) ជាអ្នកផ្ដល់ហេដ្ឋារចនាសម្ព័ន្ធ សំរាប់ឧស្សាហកម្មទូរគមនាគមន៍ (InTi) ដែលទទួលបានអាជ្ញាប័ណ្ណ នៅក្នុងប្រទេស ប្រ៊ុយណេដារុស្សាឡាម ។

(៤) ជាអាជ្ញាប័ណ្ណដែលទទួលបាន ក្នុងនាមជាអ្នកស្ថាបនា មធ្យោបាយ បណ្ដាញ និងក្នុងនាមជាអ្នកផ្ដល់អាជ្ញាប័ណ្ណលើការងារសេវាកម្មបណ្ដាញ ដោយស្ថិតក្រោមច្បាប់នៃប្រទេសកម្ពុជា ។

(៥) ជាអាជ្ញាប័ណ្ណដែលទទួលបាន ក្នុងនាមជាអ្នកផ្គត់ផ្គង់បណ្ដាញទូរគមនាគមន៍នៃប្រទេសឥណ្ឌូណេស៊ី ។

(៦) ជាការផ្ដល់សិទ្ធិក្នុងការបង្កើតជាសហគ្រាស ដើម្បីផ្ដល់សេវាកម្មផ្នែកទូរគមនាគមន៍ ដោយស្ថិតនៅក្រោមច្បាប់ទូរគមនាគមន៍ ឆ្នាំ២០០១ នៅក្នុងប្រទេសឡាវ ។

(៧) ជាអាជ្ញាប័ណ្ណដែលទទួលបាន ក្នុងនាមជាអ្នកស្ថាបនា បណ្ដាញ និងផ្គត់ផ្គង់សេវាកម្មបណ្ដាញ នៅក្នុងប្រទេសម៉ាឡេស៊ី ។

(៨) ជាអាជ្ញាប័ណ្ណដែលទទួលបាន ក្នុងវិស័យទូរគមនាគមន៍ ក្នុងនាមជាអ្នកផ្គត់ផ្គង់បណ្ដាញ និង-ឬជាអ្នកផ្ដល់សេវាកម្ម និង ជាប្រតិបត្តិករដែលទទួលបានសិទ្ធិពីក្រសួងទូរគមនាគមន៍, ប្រៃសណីយ៍ និង ទូរលេខ ដើម្បីផ្ដល់សេវាជាមូលដ្ឋាន នៅក្នុងប្រទេសភូមា ។

(៩) ជាក្រុមហ៊ុនទូរគមនាគមន៍សាធារណៈ ដែលទទួលបានអាជ្ញាប័ណ្ណ និងមានការកំណត់ច្បាស់លាស់នៅក្នុងគោលនយោបាយនិយ័តទូរគមនាគមន៍ នៃប្រទេសហ្វីលីពីន ។

(១០) ជាប្រតិបត្តិករ ផ្គត់ផ្គង់គ្រឿងបរិក្ខារជាមូលដ្ឋាន នៅក្នុងប្រទេសសឹង្ហបុរី ។

(១១) ជាអ្នកមានភារៈក្នុងការផ្គត់ផ្គង់គ្រឿងបរិក្ខារជាមូលដ្ឋាន ដោយស្ថិតនៅក្រោមច្បាប់នៃប្រទេសថៃឡង់ដ៏ និង

(១២) ជាប្រតិបត្តិករ ដែលទទួលបានអាជ្ញាប័ណ្ណផ្នែកផ្គត់ផ្គង់គ្រឿងបរិក្ខារជាមូលដ្ឋាន នៅក្នុងប្រទេសវៀតណាម ។

(ង) **ការភ្ជាប់បណ្តាញ** មានន័យថា ជាការតភ្ជាប់គ្នានៃបណ្តាញ ឬសេវាកម្មផ្នែកដឹកជញ្ជូនទូរគមនាគមន៍ទូទៅ របស់អ្នកផ្គត់ផ្គង់នានា ដើម្បីអនុញ្ញាតឱ្យអតិថិជន ជាអ្នកប្រើប្រាស់សេវារបស់អ្នកផ្គត់ផ្គង់មួយ អាចទាក់ទងជាមួយអតិថិជន ជាអ្នកប្រើប្រាស់សេវារបស់អ្នកផ្គត់ផ្គង់នានាដទៃទៀត និងអាចចូលទៅទទួលយកសេវាកម្ម ដែលផ្តល់ឱ្យដោយអ្នកផ្គត់ផ្គង់នានាដទៃទៀតបាន ។

(ច) **ការជួលបរិបទ**[១] មានន័យថា ជាគ្រឿងបរិក្ខារទូរគមនាគមន៍ រវាងពីរ ឬច្រើនចំណុច ដែលបានធ្វើការកំណត់ទុកជាមុននោះ ត្រូវបានតំឡើងសំរាប់ដាក់ឱ្យប្រើប្រាស់ ឬដើម្បីជាប្រយោជន៍របស់អ្នកប្រើប្រាស់ណាមួយ ។

(ឆ) **អ្នកផ្គត់ផ្គង់មេ** មានន័យថា ជាអ្នកផ្គត់ផ្គង់ណាមួយដែលមានសមត្ថភាព និងឥទ្ធិពលពិតប្រាកដនៅក្នុងអំឡុងពេលនៃសហប្រតិបត្តិការ ដោយគោរពតាមតំលៃ និងការផ្គត់ផ្គង់ នៅក្នុងទីផ្សារដែលពាក់ព័ន្ធ ដើម្បីផ្តល់ប្រព័ន្ធដឹកជញ្ជូនទូរគមនាគមន៍ទូទៅ ឬសេវាកម្ម ឬជាផ្នែកនៃបរិក្ខារក្នុងការ :

(១) ត្រួតពិនិត្យលើគ្រឿងបរិក្ខារជាសារវន្ត ឬ

(២) ប្រើប្រាស់មុខងាររបស់វានៅក្នុងទីផ្សារ ។

---

[១] ករណីនៃប្រទេសថៃឡង់ដ៏ " ការជួលបរិបទ " មានន័យថា ជាគ្រឿងបរិក្ខារទូរគមនាគមន៍ រវាងពីរចំណុច ដែលបានធ្វើការកំណត់ទុកជាមុននោះ ត្រូវបានតំឡើងសំរាប់ដាក់អោយប្រើប្រាស់ ឬ ដើម្បីជាប្រយោជន៍របស់អ្នកប្រើប្រាស់ណាមួយ ។

(ជ) **ភាពពុំមានការរើសអើង** មានន័យថា ការធ្វើប្រព្រឹត្តិកម្មមិនឱ្យទទួលបានភាពអនុគ្រោះតិច ឬ ទាបជាង បើធៀបទៅនឹងអ្នកប្រើប្រាស់ដទៃទៀត ដែលស្ថិតក្នុងស្ថានភាពនៃប្រព័ន្ធដឹកជញ្ជូនទូរគមនាគមន៍ទូទៅ ឬ សេវាកម្ម ដូចគ្នានោះ ។

(ឈ) **ប្រព័ន្ធដឹកជញ្ជូនសារទូរគមនាគមន៍ទូទៅ** មានន័យថា ជាហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ទូទៅមួយដែលអនុញ្ញាតឱ្យធ្វើការទាក់ទងបានរវាងគ្នា និង ក្នុងចំណោមចំណុចបញ្ចប់នៃបណ្ដាញដែលបានធ្វើការកំណត់ទុកឱ្យ ។

(ញ) **សេវាដឹកជញ្ជូនសារទូរគមនាគមន៍ទូទៅ** មានន័យថា ជាសេវាដឹកជញ្ជូនសារទូរគមនាគមន៍មួយដែលតម្រូវឱ្យភាគីមួយ ធ្វើការកំណត់ឱ្យជាក់លាក់ ឬឱ្យមានប្រសិទ្ធភាព ដើម្បីបំរើសាធារណៈទូទៅ ។ សេវាទាំងនោះរួមមាន ការទាក់ទងផ្ទៃក្នុង, ទូរលេខ, ទូរស័ព្ទ និង ប្រភេទដែលពាក់ព័ន្ធនឹងការបញ្ជូនទិន្នន័យជាក់លាក់នៃពត៌មានរបស់អតិថិជន ដែលបានផ្ដល់ឱ្យរវាងចំណុចពីរ ឬ ច្រើន ដោយមិនមានប្ដូរទ្រង់ទ្រាយ ឬ កម្មវិធីសេវា នៃព័ត៌មានរបស់អតិថិជន ពីចុងម្ខាងទៅចុងម្ខាងឡើយ ។

(ដ) **ទូរគមនាគមន៍** មានន័យថា ជាការបញ្ជូន និង ទទួលសញ្ញាតាមរយៈ វិធីការនៃមេដែកអគ្គិសនី ។

(ឋ) **គណៈនិយ័តកម្មទូរគមនាគមន៍** មានន័យថា ជាតួអង្គដែលស្ថិតក្នុងការត្រួតត្រារបស់ភាគីមួយដែលទទួលខុសត្រូវដោយស្ថិតនៅក្រោមច្បាប់នៃប្រទេសមួយ សំរាប់ធ្វើនិយ័តកម្មវិស័យទូរគមនាគមន៍ និង

(ឌ) **អ្នកប្រើប្រាស់** មានន័យថា ជាអ្នកប្រើប្រាស់សេវា និង អ្នកផ្ដល់សេវាបន្ត ។

## មាត្រា ៣

## ការចាត់ចែងក្នុងអន្តរកាល

១. ការកត់សំគាល់នៃភាគីនីមួយៗ ដែលមានផែនការអភិវឌ្ឍផ្សេងគ្នា និងការកត់សំគាល់នៃភាគីនីមួយៗ ដែលបានធ្វើការសន្យាផ្ដល់ស្ថិតក្រោម (GATS) កិច្ចព្រមព្រៀងទូទៅស្ដីពីពាណិជ្ជកម្មសេវាកម្ម, ភាគីនោះអាចពន្យារការអនុវត្តមាត្រា ៤ (ការប្រកួតប្រជែងដោយមានការការពារ), មាត្រា ៦ (ការភ្ជាប់បណ្ដាញជាមួយគ្នា),

មាត្រា ៧ (ទីតាំងរួមគ្នា), មាត្រា ៨ (សេវាកម្មជួលបរិបទ) និង មាត្រា ៩.២ (ការដោះស្រាយវិវាទ) ដោយផ្អែកតាមកាលវិភាគ ដែលកំណត់នៅក្នុងសេចក្ដីបន្ថែមស្ដីពីការចាត់ចែងក្នុងអន្តរកាល នៃឧបសម្ព័ន្ធនេះ។

## មាត្រា ៤
## ការប្រកួតប្រជែងដោយមានការការពារ

១. ជាកម្មវត្ថុចំពោះ មាត្រា ៣ (ការចាត់ចែងក្នុងអន្តរកាល) ភាគីនីមួយៗត្រូវការពារអ្នកផ្គត់ផ្គង់បណ្ដាញ ឬ សេវានៃការដឹកជញ្ជូនសារទូរគមនាគមន៍ជាឯកជន ឬ រួមគ្នាទាំងឡាយណា ដែលជាអ្នកផ្គត់ផ្គង់ធំស្ថិតក្នុងទីតាំងត្រួតត្រារបស់ខ្លួនឱ្យផុតពីការចុះកិច្ចសន្យា ឬ បន្តអនុវត្តប្រឆាំងទល់នឹងការប្រកួតប្រជែង។

២. ការអនុវត្តប្រឆាំងទល់នឹងការប្រកួតប្រជែង ដែលទាក់ទងក្នុងមាត្រានេះ រួមមាន :

(ក) ការចុះកិច្ចសន្យាប្រឆាំងទល់នឹងការប្រកួតប្រជែង ដោយឆ្លងតាមការឧបត្ថម្ភទុន។

(ខ) ការប្រើប្រាស់ព័ត៌មានដែលទទួលបានពីគូប្រកួតប្រជែង ជាមួយនឹងលទ្ធផលប្រឆាំងទល់នឹងការប្រកួតប្រជែង និង

(គ) មិនធ្វើអ្វីដែលជាប្រយោជន៍ដល់អ្នកផ្គត់ផ្គង់បណ្ដាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ដទៃទៀតឡើយ នៅក្នុងដំណាក់កាលទំនើបកម្មផ្នែកបច្ចេកទេសព័ត៌មាននៃគ្រឿងបរិក្ខារសារវ័ន្ត ឬ ព័ត៌មានដែលមានតំលៃខាងពាណិជ្ជកម្ម សំរាប់អ្នកផ្គត់ផ្គង់បណ្ដាញ ឬសេវាដឹកជញ្ជូនសារទូរគមនាគមន៍។

## មាត្រា ៥
## ការផ្ដល់អាជ្ញាប័ណ្ណ

១. ភាគីនីមួយៗនឹងត្រូវធ្វើឱ្យប្រាកដថា នៅពេលដែលតំរូវឱ្យមានអាជ្ញាប័ណ្ណ, និងរាល់វិធានការដែលពាក់ព័ន្ធជាមួយនឹងការផ្ដល់អាជ្ញាប័ណ្ណលើការងារផ្គត់ផ្គង់បណ្ដាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន គឺត្រូវធ្វើការផ្សព្វផ្សាយ ឬក៏ត្រូវប្រកាសថា កន្លែងណាខ្លះដែលមិនអាចផ្ដល់អាជ្ញាប័ណ្ណបាន។ ដោយឡែក សំរាប់ព័ត៌មានដែលធ្វើឱ្យគេអាចរកបានជាសាធារណៈនោះ រួមមាន :

(ក) ករណីនីមួយៗដែលតំរូវឱ្យមានអាជ្ញាប័ណ្ណ

(ខ) នីតិវិធីនៃការស្នើសុំអាជ្ញាប័ណ្ណ

(គ) លក្ខណៈវិនិច្ឆ័យដែលបានប្រើប្រាស់ក្នុងការវាយតំលៃលើការស្នើសុំអាជ្ញាប័ណ្ណ

(ឃ) បទដ្ឋានពេលវេលា និង លក្ខខណ្ឌ ក្នុងការស្នើសុំអាជ្ញាប័ណ្ណ

(ង) ត្រូវកំណត់រយៈពេលជាធម្មតាមួយ ដើម្បីឈានដល់ការពិចារណាធ្វើសេចក្ដីសំរេចចិត្តលើការស្នើសុំអាជ្ញាប័ណ្ណមួយ ។

(ច) ត្រូវកំណត់តំលៃ និង/ឬ កម្រៃឈ្នួល ក្នុងការស្នើសុំ និង/ឬ ផ្ដល់អាជ្ញាប័ណ្ណឱ្យ, និង

(ឆ) រយៈពេលសុពលភាពនៃអាជ្ញាប័ណ្ណ ។

២. ភាគីនីមួយៗត្រូវបញ្ជាក់ប្រាប់អ្នកស្នើសុំអាជ្ញាប័ណ្ណឱ្យបានដឹងច្បាស់លាស់អំពី ហេតុផលនៃការបដិសេធមិនផ្ដល់អាជ្ញាប័ណ្ណឱ្យ នៅក្នុងអំឡុងពេលនៃការស្នើសុំអាជ្ញាប័ណ្ណនោះ ។

## មាត្រា ៦

## ការភ្ជាប់បណ្ដាញជាមួយគ្នា[២]

១. ជាកម្មវត្ថុចំពោះមាត្រា ៣ (ការចាត់ចែងក្នុងអន្តរកាល) ភាគីនីមួយៗនឹងត្រូវធ្វើឱ្យប្រាកដថា អ្នកផ្គត់ផ្គង់ធំដែលមានទីតាំងស្ថិតនៅក្នុងដែនដីរបស់ខ្លួន ត្រូវផ្ដល់ការតភ្ជាប់បណ្ដាញជាមួយគ្នាឱ្យអ្នកផ្ដល់បណ្ដាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ របស់ភាគីដទៃទៀត ដោយស្របតាមលក្ខណៈបច្ចេកទេសដែលអាចធ្វើទៅបាន ។ ការភ្ជាប់បណ្ដាញជាមួយគ្នា នឹងត្រូវ :

(ក) ផ្ដល់ឱ្យដែលស្ថិតក្នុងដំណាក់កាលទំនើបកម្ម ស្របតាមពេលវេលា និង លក្ខខណ្ឌ (ដោយរួមទាំងបទដ្ឋានបច្ចេកទេស និង ការកំណត់ជាក់លាក់) និង ស្ថិតក្នុងអត្រាតំលៃត្រឹមត្រូវសមរម្យ (ត្រូវតែគិតចំពោះលទ្ធភាពសេដ្ឋកិច្ច) ដោយគ្មានការរើសអើង និង មានតម្លាភាព ។

(ខ) មិនមានចំនួនច្រើន តែគ្រប់គ្រាន់ល្មម, គឺថា អ្នកផ្ដល់បណ្ដាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ អាចស្វែងរកការភ្ជាប់បណ្ដាញជាមួយគ្នា ដោយមិនចាំបាច់បង់ចំណាយទៅលើឧបករណ៍តម្លើងបណ្ដាញ ឬ គ្រឿងបរិក្ខារនានា ដែលមិនសំខាន់ក្នុងការផ្ដល់សេវាកម្ម ។

---

[២] សំរាប់ជាប្រយោជន៍នៃតម្លាភាព, នៅក្នុងមាត្រានេះនឹងមិនមានអ្វីត្រូវធ្វើការបកស្រាយ ដើម្បីតំរូវឱ្យប្រទេសថៃឡង់ដ៍ ឬ វៀតណាមអនុញ្ញាត ឱ្យមានការឧបត្ថម្ភធនឆ្លងកាត់ព្រំប្រទល់ ដល់អ្នកដែលមានទំនាក់ទំនង សំរាប់បំរើឱ្យការផ្ដល់បណ្ដាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ នៅក្នុងទីណាមួយដែលខ្លួនមិនបានបញ្ជាក់ក្នុងការសន្យាដែលស្ថិតនៅក្នុងជំពូកនេះ ។

(គ) ចំពោះគុណភាពសេវាវិញ គឺមិនត្រូវមានកំរិតទាបជាងគុណភាពនៃសេវា ដែលអ្នកផ្គត់ផ្គង់ធំបានផ្តល់ដោយផ្ទាល់ខ្លួននោះទេ, ឬក៏ខុសគ្នាជាមួយអ្នកផ្គត់ផ្គង់សេវាដែលមិនមែនជាសមាជិក ឬក៏សំរាប់សាខារបស់ខ្លួន ឬក៏សំរាប់សមាជិកដទៃទៀត, និង

(ឃ) ត្រូវធ្វើការផ្តល់ឱ្យនៅពេលមានសំណើ, នៅក្នុងករណីបន្ថែមចំណុចតភ្ជាប់ នៅខាងចុងរបស់បណ្តាញដែលបានផ្តល់អ្នកប្រើប្រាស់ក្នុងចំនួនច្រើននោះ គឺនឹងត្រូវបង់ប្រាក់ ដោយផ្អែកតាមតំលៃនៃការស្ថាបនាគ្រឿងបរិក្ខារចាំបាច់ ដែលបានបន្ថែមឱ្យនោះ។

២. ភាគីនីមួយៗនឹងត្រូវធ្វើឱ្យប្រាកដថា ពេលវេលា, លក្ខខ័ណ្ឌ និង អត្រាកំណត់ (ដោយរួមបញ្ចូលទាំងបទដ្ឋានបច្ចេកទេស និងមាត្រដ្ឋាន) សំរាប់ធ្វើការតភ្ជាប់បណ្តាញជាមួយគ្នារវាងអ្នកផ្គត់ផ្គង់ធំ ដែលស្ថិតក្នុងដែនរបស់ខ្លួន ជាមួយនឹងអ្នកផ្តល់បណ្តាញ ឬ សេវា ដឹកជញ្ជូនសារទូរគមនាគមន៍នៃភាគីដទៃទៀត ដែលអាចបង្កើតឡើងបាន (យ៉ាងហោចណាស់ ក៏):

(ក) តាមរយៈការចរចាផ្អែកពាណិជ្ជកម្ម, ឬ

(ខ) យោងទៅតាមការកំណត់នៃបទដ្ឋានពេលវេលា, លក្ខខណ្ឌ និងអត្រាកំណត់ដែលអ្នកផ្គត់ផ្គង់ធំបានផ្តល់ជាទូទៅដល់អ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ដទៃទៀត ដែលទាំងនោះ គឺជាសច្ចានុម័ត ឬ ជាការកំណត់ដោយអង្គទូរគមនាគមន៍និយ័ត។

## មាត្រា ៧
## ទីតាំងរួមគ្នា

១. ជាកម្មវត្ថុចំពោះ មាត្រា ៣ (ការចាត់ចែងក្នុងអន្តរកាល) ភាគីនីមួយៗ នឹងត្រូវធ្វើឱ្យប្រាកដថា អ្នកផ្គត់ផ្គង់ធំ ដែលមានទីតាំងស្ថិតនៅក្នុងដែនដីរបស់ខ្លួន :

(ក) ត្រូវផ្តល់នូវរូបសាស្ត្រនៃទីតាំងរួមគ្នា សំរាប់ដាក់បរិក្ខារចាំបាច់ដើម្បីបំរើឱ្យការភ្ជាប់បណ្តាញ ជាមួយគ្នាឱ្យដល់អ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍នៃភាគីដទៃទៀត ដែលជាអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខារជាមូលដ្ឋានស្ថិតក្នុងដែនដីរបស់ភាគីខ្លួន។

(ខ) ក្នុងស្ថានភាពណាដែលមានរូបសាស្ត្រនៃទីតាំងរួមគ្នា ដូចបានបញ្ជាក់នៅក្នុងអនុកថាខ័ណ្ឌ (ក) ខាងលើ គឺមិនត្រូវបានប្រតិបត្តិសំរាប់ហេតុផលបច្ចេកទេស ឬ ព្រោះតែទីលំហមានដែនកំណត់ទេ។ ត្រូវសហប្រតិបត្តិការជាមួយអ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ នៃ

ភាគីដទៃទៀត ដែលជាអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខាជាមូលដ្ឋានស្ថិតក្នុងដែនដីរបស់ភាគីនោះ ដើម្បីស្វែងរក និងធ្វើប្រតិបត្តិការ និងអាចរកដំណោះស្រាយបែបពាណិជ្ជកម្មផ្សេងទៀតបាន[៣] ។

២. ភាគីនីមួយៗ នឹងត្រូវធ្វើប្រាកដថា អ្នកផ្គត់ផ្គង់ធំ ដែលមានទីតាំងស្ថិតនៅក្នុងដែនដីរបស់ខ្លួននោះ នឹងផ្តល់ឱ្យនូវរូបសាស្ត្រនៃទីតាំងរួមគ្នា ឬ ការធ្វើប្រតិបត្តិការ និង ដំណោះស្រាយបែបពាណិជ្ជកម្មផ្សេងទៀត ដោយផ្អែកតាមកថាខ័ណ្ឌ ១ ដែលស្ថិតក្នុងដំណាក់កាលទំនើបកម្ម, ទាន់ពេលវេលា និងជាកំហិត (រួមបញ្ចូលទាំង បទដ្ឋានបច្ចេកទេស និង ការកំណត់ជាក់លាក់) ហើយស្ថិតក្នុងអត្រាសមស្រប (គឺត្រូវគោរពតាមស្ថានភាពសេដ្ឋកិច្ច ដែលអាចធ្វើទៅបាន) ពុំមានការរើសអើង និង មានតម្លាភាព ។

៣. ភាគីនីមួយៗអាចធ្វើការសំរេចចិត្ត ដោយផ្អែកតាមនិយ័តកម្ម និងច្បាប់ផ្ទៃក្នុងនៃប្រទេសរបស់ខ្លួន ក្នុងការតំរូវឱ្យអ្នកផ្គត់ផ្គង់ធំក្នុងស្រុកធ្វើការផ្តល់នូវរូបសាស្ត្រនៃទីតាំងរួមគ្នា ឬក៏ការធ្វើប្រតិបត្តិការ និង ដំណោះស្រាយបែបពាណិជ្ជកម្មផ្សេងទៀត ដូចបានបញ្ជាក់ក្នុងកថាខ័ណ្ឌ១។

## មាត្រា ៨
## សេវាកម្មជូលបរិបទ

ជាកម្មវត្ថុចំពោះមាត្រា ៣ (ការចាត់ចែងក្នុងអន្តរកាល) ភាគីនីមួយៗត្រូវធ្វើឱ្យប្រាកដថា អ្នកផ្គត់ផ្គង់ក្នុងស្រុកផ្តល់នូវសេវាកម្មជូលបរិបទ ក្នុងករណីមានលទ្ធភាពផ្នែកបច្ចេកទេស (នោះគឺ ការផ្តល់សេវាដឹកជញ្ជូនសារទូរគមនាគមន៍ទូទៅ) ដែលជាផ្នែកមួយអាចធ្វើទៅបានសំរាប់ភាគីអ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ដទៃទៀត ដែលស្ថិតក្នុងដំណាក់កាលទំនើបកម្ម, ទាន់ពេលវេលា និងជាកំហិត (រួមបញ្ចូលទាំងបទដ្ឋានបច្ចេកទេស និងការកំណត់ជាក់លាក់) ហើយស្ថិតក្នុងអត្រាសមស្រប (គឺត្រូវគោរពតាមស្ថានភាពសេដ្ឋកិច្ចដែលអាចធ្វើទៅបាន) ពុំមានការរើសអើង និង មានតម្លាភាព។

---

[៣] ដំណោះស្រាយទាំងនោះ រួមមាន :

(ក) ការអនុញ្ញាតឱ្យអ្នកផ្គត់ផ្គង់គ្រឿងបរិក្ខាជាមូលដ្ឋាន ចោះទីតាំងគ្រឿងឧបករណ៍របស់ខ្លួននៅជិតនឹងអគារ និង អាចតភ្ជាប់ឧបករណ៍នោះ ជាមួយនឹងបណ្តាញរបស់អ្នកផ្គត់ផ្គង់ធំ ។

(ខ) ជាក់លក្ខខណ្ឌបន្ថែម ចំពោះទីលំហនៃគ្រឿងឧបករណ៍ ឬ តាមភាពជាក់ស្តែងនៃទីតាំងរួមគ្នា។

(គ) ធ្វើអោយមានភាពប្រសើរឡើង នៃការប្រើប្រាស់ទីលំហរដែលមាននោះ ។ និង

(ឃ) ធ្វើការស្វែងរក ទីលំហដែលស្ថិតនៅជាប់គ្នានោះ ។

## មាត្រា ៩
## ការដោះស្រាយវិវាទ

១. ភាគីនីមួយៗត្រូវធ្វើប្រាកដថា អ្នកផ្គត់ផ្គង់បណ្តាញ ឬសេវាដឹកជញ្ជូនសារទូរគមនាគមន៍របស់ភាគីផ្សេងណាមួយ ដែលបានស្នើសុំភ្ជាប់បណ្តាញជាមួយអ្នកផ្គត់ផ្គង់ធំ ដែលជាអ្នកមានសិទ្ធិក្នុងការផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍នៅក្នុងដែនដីរបស់ភាគីខ្លួននោះ គឺត្រូវពឹងផ្អែកលើអង្គនិយ័តទូរគមនាគមន៍ ដើម្បីដោះស្រាយវិវាទ ដែលពាក់ព័ន្ធទៅនឹងការភ្ជាប់បណ្តាញជាមួយគ្នា រួមទាំងរយៈពេល, លក្ខខណ្ឌ ឬអត្រាកំណត់ :

(ក) នៅក្នុងចន្លោះនៃរយៈពេលសមស្របមួយ ដោយផ្អែកតាមនីតិវិធីដូចដែលបានប្រកាសផ្សាយ ឬក៏របស់ផ្សេងទៀតដែលអាចរកបានជាសាធារណៈ, និង

(ខ) នៅពេលមានការស្នើសុំពីភាគីផ្សេងណា ដែលមានឥទ្ធិពលក្នុងការផ្តល់បណ្តាញ ឬសេវាដឹកជញ្ជូនសារទូរគមនាគមន៍។

២. ជាកម្មវត្ថុចំពោះ មាត្រា ៣ (ការចាត់ចែងក្នុងអន្តរកាល) ភាគីនីមួយៗ ត្រូវធ្វើឱ្យប្រាកដថា អ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍នៃភាគីណាមួយ ដែលស្នើសុំដាក់ទីតាំងរួមគ្នា ឬ ជួលសេវាបរិបទ ពីអ្នកផ្គត់ផ្គង់ធំដែលមានសិទ្ធិក្នុងការផ្តល់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ ដែលស្ថិតក្នុងដែនដីរបស់ភាគីខ្លួននោះ គឺត្រូវពឹងផ្អែកលើអង្គនិយ័តទូរគមនាគមន៍ ឬ បទប្បញ្ញត្តិនៃការប្រកួតប្រជែង ដើម្បីសម្តែងចេញរាល់បញ្ហាពាក់ព័ន្ធ ដូចជា ការភ្ជាប់បណ្តាញជាមួយគ្នា ឬ ការជួលសេវាបរិបទ ដោយរួមទាំងការទាក់ទងទៅនឹងពេលវេលា, លក្ខខណ្ឌ ឬ អត្រាកំណត់ :

(ក) នៅក្នុងចន្លោះនៃរយៈពេលសមស្របមួយ ដោយផ្អែកតាមនីតិវិធីដូចដែលបានប្រកាសផ្សាយ ឬក៏របស់ផ្សេងទៀតដែលអាចរកបានជាសាធារណៈ, និង

(ខ) នៅពេលមានការស្នើសុំពីភាគីផ្សេងណាដែលមានឥទ្ធិពលក្នុងការផ្តល់បណ្តាញ ឬសេវាដឹកជញ្ជូនសារទូរគមនាគមន៍។

៣. ភាគីនីមួយៗ ត្រូវធ្វើឱ្យប្រាកដថា អង្គនិយ័តទូរគមនាគមន៍ នឹងជួយដល់ភាគីអ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍សាធារណៈណាមួយ នៅពេលមានការស្នើសុំ ហើយសេចក្តីពន្យល់ជាលាយលក្ខណ៍អក្សរនៃការវិនិច្ឆ័យដោយអង្គនិយ័តទូរគមនាគមន៍ណាមួយនោះ គឺត្រូវមានឥទ្ធិពលទៅលើអ្នកផ្គត់ផ្គង់បណ្តាញ ឬ

សេវាដឹកជញ្ជូនសារទូរគមនាគមន៍ដទៃទៀត។ បើសិនពុំមានសេចក្តីពន្យល់ទេនោះ គឺត្រូវមានរបស់ផ្សេងទៀត ដែលអាចរកបានជាសាធារណៈ។

## មាត្រា ១០

## តម្លាភាព

១. ភាគីនីមួយៗ គួរតែប្រឹងខ្នះខ្នែងធ្វើយ៉ាងណា រាល់ពត៌មានដែលភាគីបានស្នើសុំចាំបាច់ត្រូវធ្វើការបោះពុម្ពផ្សាយ ឬ អាចរកបានជាសាធារណៈ ដោយអនុលោមតាមឧបសម្ព័ន្ធនេះ គឺ អាចមាននៅលើអ៊ីនធឺណែត។

## មាត្រា ១១

## គណៈនិយ័តកម្មទូរគមនាគមន៍

១. ភាគីនីមួយៗ គួរបង្កើត ឬ រក្សាទុក អង្គនិយ័តទូរគមនាគមន៍ឱ្យស្ថិតនៅជាផ្នែកមួយនៃច្បាប់ក្នុងប្រទេសរបស់ផងខ្លួន។

២. ភាគីនីមួយៗ គួរធ្វើឱ្យប្រាកដថា រាល់អង្គនិយ័តទូរគមនាគមន៍ ដែលបានបង្កើត ឬ រក្សាទុកនោះ គឺត្រូវបានបំបែកចេញពី និងមិនស្ថិតក្រោមការគ្រប់គ្រងនៃអ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍ណាមួយឡើយ។

៣. ភាគីនីមួយៗ គួរធ្វើឱ្យប្រាកដថា មុខងារ និងការទទួលខុសត្រូវនៃអង្គនិយ័តទូរគមនាគមន៍ នឹងត្រូវដាក់បញ្ចូលនូវការជំរុញឱ្យអនុវត្តតាមកិច្ចសន្យា ដូចបានកំណត់ក្នុងមាត្រា ៦ (ការភ្ជាប់បណ្តាញជាមួយគ្នា) និងអំណាចនៃការធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនទាំងអស់ ដែលត្រូវបានកំណត់ក្នុងច្បាប់ ឬ បទប្បញ្ញត្តិក្នុងប្រទេសរបស់ភាគីនោះ។

៤. ភាគីនីមួយៗ គួរធ្វើឱ្យប្រាកដថា ការវិច្ឆ័យ និង នីតិវិធី ដែលអង្គនិយ័តទូរគមនាគមន៍ប្រើប្រាស់នោះ គឺមានភាពយុត្តិធម៌ សំរាប់បុគ្គលគ្រប់រូប។

៥. ភាគីនីមួយៗ គួរធ្វើឱ្យប្រាកដថា រាល់អ្នកផ្គត់ផ្គង់បណ្តាញ ឬ សេវាដឹកជញ្ជូនសារទូរគមនាគមន៍របស់ភាគីផ្សេងៗណា ដែលបានទទួលការកើតទុក្ខមិនសុខចិត្ត ឬ ទទួលរងនូវឥទ្ធិពលមិនល្អទាំងឡាយ ដោយសារការសំរេចរបស់អង្គនិយ័តទូរគមនាគមន៍នៃភាគីខ្លួននោះ គឺអាចទទួលបានការពិនិត្យសើរើឡើងវិញ ចំពោះសេចក្តីសំរេចចិត្ត ឬ ការសំរេចបែបរដ្ឋបាល, អាជ្ញាកណ្តាល ឬ សាលាជំរះក្តី ឬ អាជ្ញាធរ ឬ យោងតាមចំណាត់ការរបស់ចៅក្រម ឬ

នីតិវិធីតុលាការ ។ នៅទីណាដែលអង្គនិយ័តទូរគមនាគមន៍ពុំមានភាពឯករាជ្យនោះ គឺភាគីនីមួយៗគួរធ្វើឱ្យ ប្រាកដថា នីតិវិធីដែលផ្តល់ឱ្យចំពោះមុខនេះ គឺសំរាប់ពិនិត្យមើលភាពមិនលំអៀង និង យុត្តិធម៌ ។

## មាត្រា ១២
## សេវាកម្មសាកល

១. ភាគីនីមួយៗ មានសិទ្ធិដើម្បីកំណត់ប្រភេទសេវាកម្មសាកល ដែលជាតំរូវការចាំបាច់ ដោយខ្លួនមានបំណងធ្វើការថែរក្សាទុក ។ តំរូវការទាំងនោះ រួមមាន គោលនយោបាយឧបត្ថម្ភធនឆ្លងកាត់ព្រំប្រទល់ ដែលបានកំណត់ក្នុងច្បាប់នៃប្រទេសរបស់ភាគីនីមួយៗ គឺនឹងមិនត្រូវបានគិតដូចជាការប្រឆាំងទល់នឹងការប្រកួតប្រជែង *per se* ដោយបានផ្តល់ឱ្យពួកគេនូវការគ្រប់គ្រងដោយតម្លាភាព ពុំមានការរើសអើង និងមានការប្រកួតប្រជែង តាមបែបធម្មជាតិ និង មិនឱ្យធ្ងន់ធ្ងរជាងភាពចាំបាច់នៃសេវាកម្មសាកល ដែលបានកំណត់ដោយភាគីនីមួយៗ នោះទេ ។

## មាត្រា ១៣
## ការបែងចែក និង ការប្រើប្រាស់ធនធានកម្រ[៤]

១. ភាគីនីមួយៗ គួរតែគ្រប់គ្រងនិតិវិធីរបស់ខ្លួន ដើម្បីធ្វើការបែងចែក និងការប្រើប្រាស់ធនធានកម្រ រួមមាន ប្រេកង់ និង លេខ ប្រកបដោយគោលដៅច្បាស់លាស់, កាលានុវត្តភាព, តម្លាភាព និង មិនមានឥរិយាបទរើសអើង ។

២. ភាគីនីមួយៗ គួរតែធ្វើការបោះពុម្ពផ្សាយ ឬក៏អាចឱ្យគេស្វែងរកបានជាសាធារណៈ នៃការបែងចែករលកប្រេកង់ ដែលមានក្នុងបច្ចុប្បន្នភាព ។[៥]

៣. ភាគីទាំងអស់ គឺមិនតំរូវឱ្យធ្វើការបោះពុម្ពផ្សាយ អំពីអត្តសញ្ញាណនៃការបែងចែកប្រេកង់ សំរាប់ឱ្យរដ្ឋាភិបាលប្រើប្រាស់ផ្ទាល់ ឬ ក៏អាចធ្វើឱ្យគេរកបានជាសាធារណៈនោះទេ ។

---

[៤] សេចក្តីសំរេចលើការបែងចែក និង កិច្ចការនៃវិសាលគម និង ការគ្រប់គ្រងប្រេកង់ គឺមិនត្រូវបានវាស់វែងទំហំថាជា per se ដែលមិនត្រូវគ្នាជាមួយ មាត្រា ៤ (ការបើកច្រកទីផ្សារ) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ។ ដូច្នេះ ភាគីនីមួយៗ រក្សាទុកសមត្ថភាព ដើម្បីប្រើប្រាស់វិសាលគម និង អនុវត្តគោលនយោបាយគ្រប់គ្រងប្រេកង់របស់ខ្លួន ដែលអាចមានឥទ្ធិពលលើ ចំនួនអ្នកផ្គត់ផ្គង់សេវា ដូចដែលបានផ្តល់ឱ្យរួចហើយ ដោយមានលក្ខណៈស្របគ្នាជាមួយជំពូកនេះ ។ ភាគីនីមួយៗក៏រក្សាបាននូវសិទ្ធិ ក្នុងការបែងចែករលកប្រេកង់ ដែលមានក្នុងបញ្ជី និង សំរាប់ជាតំរូវការនាពេលអនាគតផងដែរ ។

[៥] ភាគីទាំងអស់ គឺមិនតំរូវឱ្យធ្វើការបោះពុម្ពផ្សាយពត៌មាន ស្តីពីការបែងចែកប្រេកង់របស់ផងខ្លួន ទៅឱ្យអ្នកដែលគេប្រគល់អាជ្ញាប័ណ្ណ ឱ្យដោយចំពោះនោះទេ ។

# សេចក្តីបន្ថែម ស្តីពីការចាត់ចែងក្នុងអន្តរកាល

| ភាគី | មាត្រា ៤ | មាត្រា ៦ | មាត្រា ៧ | មាត្រា ៨ | មាត្រា ៩.២ |
|---|---|---|---|---|---|
| ប្រ៊ុយណេ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីថ្ងៃទី ១ ខែ មករា ២០០៩ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីថ្ងៃទី ១ ខែ មករា ២០០៩ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីថ្ងៃទី ១ ខែ មករា ២០០៩ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីថ្ងៃទី ១ ខែ មករា ២០០៩ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីថ្ងៃទី ១ ខែ មករា ២០០៩ |
| កម្ពុជា | | | ជាកាតព្វកិច្ចត្រូវអនុវត្ត គឺមិនអោយយូរជាងបីឆ្នាំ បន្ទាប់ពីពេលដែលកិច្ចព្រមព្រៀងនេះបានចូលជាសុពលភាព។ | ជាកាតព្វកិច្ចត្រូវអនុវត្ត គឺមិនអោយយូរជាងមួយឆ្នាំ បន្ទាប់ពីពេលដែលច្បាប់ស្តីពីទូរគមនាគមន៍បានចូលជាសុពលភាព។ កម្ពុជា គួរខិតខំ ដើម្បីធ្វើអោយប្រាកដថា ច្បាប់ស្តីពីទូរគមនាគមន៍ ចូលជាសុពលភាព នៅចន្លោះរយៈពេល ៣ឆ្នាំនៃការចូលជាសុពលភាពរបស់កិច្ចព្រមព្រៀងនេះ។ | ជាកាតព្វកិច្ចត្រូវអនុវត្ត ចាប់ពីពេលមានការអនុវត្តនៃមាត្រា ៧ សំរាប់ (ទីតាំងរូមគ្នា) និង ៨ សំរាប់ (សេវាកម្មជួលបរិបទ) រៀង១ខ្លួន។ |
| ឡាវ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពី<br>(១) ក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីពេលដែល ឡាវ បានចូលក្នុង WTO ឬ<br>(២) រយៈពេលបីឆ្នាំបន្ទាប់ពីពេលដែល ចូលជាសុពលភាពនៃការប្រតិបត្តិច្បាប់ក្នុងស្រុកសំរាប់កាតព្វកិច្ចនេះ។<br>មួយណាដល់មុនក៏បាន | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពី<br>(១) ក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីពេលដែល ឡាវ បានចូលក្នុង WTO ឬ<br>(២) រយៈពេលបីឆ្នាំបន្ទាប់ពីពេលដែល ចូលជាសុពលភាពនៃការប្រតិបត្តិច្បាប់ក្នុងស្រុកសំរាប់កាតព្វកិច្ចនេះ។<br>មួយណាដល់មុនក៏បាន | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីរយៈពេលបីឆ្នាំបន្ទាប់ពីពេល<br>(១) ដែលឡាវបានចូលក្នុង WTO ឬ<br>(២) ចូលជាសុពលភាពនៃការប្រតិបត្តិច្បាប់ក្នុងស្រុកសំរាប់កាតព្វកិច្ចនេះ។<br>មួយណាដល់មុនក៏បាន | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីរយៈពេលបីឆ្នាំបន្ទាប់ពីពេល<br>(១) ដែល ឡាវ បានចូលក្នុង WTO ឬ<br>(២) ចូលជាសុពលភាពនៃការប្រតិបត្តិច្បាប់ក្នុងស្រុកសំរាប់កាតព្វកិច្ចនេះ។<br>មួយណាដល់មុនក៏បាន | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីរយៈពេលបីឆ្នាំបន្ទាប់ពីពេល<br>(១) ដែល ឡាវ បានចូលក្នុង WTO ឬ<br>(២) ចូលជាសុពលភាពនៃការប្រតិបត្តិច្បាប់ក្នុងស្រុកសំរាប់កាតព្វកិច្ចនេះ។<br>មួយណាដល់មុនក៏បាន |

| ភាគី | មាត្រា ៤ | មាត្រា ៦ | មាត្រា ៧ | មាត្រា ៨ | មាត្រា ៩.២ |
|---|---|---|---|---|---|
| ភូមា | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីពេលបញ្ចប់នៃការពិនិត្យឡើងវិញ លើគោលនយោបាយរបស់វិស័យនាពេលបច្ចុប្បន្ន និង ការចាត់ចែងនិយ័តករ ដែលទទួលបានការអនុញ្ញាត ពហុ-ថៃលក្ខូអោយចូលរួមក្នុងសេវាកម្មទូរគមនាគមន៍ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីពេលបញ្ចប់នៃការពិនិត្យឡើងវិញ លើគោលនយោបាយរបស់វិស័យនាពេលបច្ចុប្បន្ន និង ការចាត់ចែងនិយ័តករ ដែលទទួលបានការអនុញ្ញាត ពហុ-ថៃលក្ខូអោយចូលរួមក្នុងសេវាកម្មទូរគមនាគមន៍ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីពេលបញ្ចប់នៃការពិនិត្យឡើងវិញ លើគោលនយោបាយរបស់វិស័យនាពេលបច្ចុប្បន្ន និង ការចាត់ចែងនិយ័តករ ដែលទទួលបានការអនុញ្ញាត ពហុ-ថៃលក្ខូអោយចូលរួមក្នុងសេវាកម្មទូរគមនាគមន៍ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីពេលបញ្ចប់នៃការពិនិត្យឡើងវិញ លើគោលនយោបាយរបស់វិស័យនាពេលបច្ចុប្បន្ន និង ការចាត់ចែងនិយ័តករ ដែលទទួលបានការអនុញ្ញាត ពហុ-ថៃលក្ខូអោយចូលរួមក្នុងសេវាកម្មទូរគមនាគមន៍ ។ | ជាកាតព្វកិច្ចត្រូវអនុវត្ត ចាប់ពីពេលដែលច្បាប់ទូរគមនាគមន៍ថ្មី បានចូលជាសុពលភាព ។ |
| សិង្ហបូរី | ប្តេជ្ញាអនុវត្តមាត្រានេះ នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាសុពលភាព ។ | ប្តេជ្ញាអនុវត្តមាត្រានេះ នៅលើមូលដ្ឋាន ទៅវិញទៅមក ឧទាហរណ៍ : សិង្ហបូរី នឹងផ្តល់ការសន្យាដែលពាក់ព័ន្ធជាមួយមាត្រានេះ ទៅអោយភាគីណាមួយ បើសិន ឬ នៅពេលណាដែលភាគីនោះបានធ្វើការសន្យាដូចគ្នានេះរួចហើយ ។ | ប្តេជ្ញាអនុវត្តមាត្រានេះ នៅលើមូលដ្ឋាន ទៅវិញទៅមក ឧទាហរណ៍ : សិង្ហបូរី នឹងផ្តល់ការសន្យាដែលពាក់ព័ន្ធជាមួយមាត្រានេះ ទៅអោយភាគីណាមួយ បើសិន ឬ នៅពេលណាដែលភាគីនោះបានធ្វើការសន្យាដូចគ្នានេះរួចហើយ ។ | ប្តេជ្ញាអនុវត្តមាត្រានេះ នៅលើមូលដ្ឋាន ទៅវិញទៅមក ឧទាហរណ៍ : សិង្ហបូរី នឹងផ្តល់ការសន្យាដែលពាក់ព័ន្ធជាមួយមាត្រានេះ ទៅអោយភាគីណាមួយ បើសិន ឬ នៅពេលណាដែលភាគីនោះបានធ្វើការសន្យាដូចគ្នានេះរួចហើយ ។ | ប្តេជ្ញាអនុវត្តមាត្រានេះ នៅលើមូលដ្ឋាន ទៅវិញទៅមក ឧទាហរណ៍ : សិង្ហបូរី នឹងផ្តល់ការសន្យាដែលពាក់ព័ន្ធជាមួយមាត្រានេះ ទៅអោយភាគីណាមួយ បើសិន ឬ នៅពេលណាដែលភាគីនោះបានធ្វើការសន្យាដូចគ្នានេះរួចហើយ ។ |
| ថៃឡង់ដ៏ (1) | ជាកាតព្វកិច្ចត្រូវអនុវត្តបន្ទាប់ពីបញ្ចប់កិច្ចសន្យាសម្បទានចុងក្រោយ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តបន្ទាប់ពីបញ្ចប់កិច្ចសន្យាសម្បទានចុងក្រោយ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តបន្ទាប់ពីបញ្ចប់កិច្ចសន្យាសម្បទានចុងក្រោយ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តបន្ទាប់ពីបញ្ចប់កិច្ចសន្យាសម្បទានចុងក្រោយ ។ | ជាកាតព្វកិច្ចត្រូវអនុវត្តចាប់ពីពេលដែលកិច្ចព្រមព្រៀងនេះចូលជាសុពលភាព ។ |

(1) កិច្ចសន្យាចុងក្រោយ នឹងត្រូវផុតកំណត់ ក្នុងឆ្នាំ ២០១៨ ។

| ភាគី | មាត្រា ៤ | មាត្រា ៦ | មាត្រា ៧ | មាត្រា ៨ | មាត្រា ៩.២ |
|---|---|---|---|---|---|
| វៀតណាម | | | ធ្វើការអនុវត្តក្នុងរយៈពេល បីឆ្នាំ បន្ទាប់ពីកាតព្វកិច្ចទាំងនេះត្រូវបានឆ្លុះបញ្ចាំងដោយសមស្រប ជាមួយច្បាប់ និង និយ័តកម្ម ក្នុងប្រទេសវៀតណាម ។ | ធ្វើការអនុវត្តក្នុងរយៈពេល បីឆ្នាំ បន្ទាប់ពីកាតព្វកិច្ចទាំងនេះត្រូវបានឆ្លុះបញ្ចាំងដោយសមស្រប ជាមួយច្បាប់ និង និយ័តកម្ម ក្នុងប្រទេសវៀតណាម ។ | ធ្វើការអនុវត្តក្នុងរយៈពេល បីឆ្នាំ បន្ទាប់ពីកាតព្វកិច្ចទាំងនេះត្រូវបានឆ្លុះបញ្ចាំងដោយសមស្រប ជាមួយច្បាប់ និង និយ័តកម្ម ក្នុងប្រទេសវៀតណាម ។ |

# ជំពូក ៩
# ការបំលាស់ទីនៃរូបវន្តបុគ្គល

## មាត្រា ១
## កម្មវត្ថុ

កម្មវត្ថុនៃជំពូកនេះ មានដូចខាងក្រោម :

ក. ចែងអំពីសិទ្ធិ និង កាតព្វកិច្ច បន្ថែមពីការចែងក្នុងជំពូក៨ (ពាណិជ្ជកម្មសេវាកម្ម) និង ជំពូក ១១ (វិនិយោគ) ទាក់ទងទៅនឹងការបំលាស់ទីនៃរូបវន្តបុគ្គល រវាងភាគីនៅក្នុងគោលបំណងពាណិជ្ជកម្ម

ខ. សម្របសម្រួលបំលាស់ទីរបស់រូបវន្តបុគ្គល នៅក្នុងការធ្វើពាណិជ្ជកម្ម និង វិនិយោគរវាងភាគី

គ. ធ្វើឱ្យមានប្រសិទ្ធភាព និង នីតិវិធីតម្លាភាពសម្រាប់ការបំពេញបែបបទអន្តោប្រវេសន៍នៃការចេញចូលបណ្តោះអាសន្នរបស់រូបវន្តបុគ្គល ដែលជំពូកនេះចង្អុលទៅលើ, និង

ឃ. ការពារបូរណភាពព្រំដែនរបស់ភាគី និង ការពារកំលាំងពលកម្មក្នុងស្រុក និង អាជីពជាអចិន្ត្រៃយ៍នៅក្នុងដែនដីនៃភាគី ។

## មាត្រា ២
## វិសាលភាព

១. ជំពូកនេះត្រូវអនុវត្ត ដូចមានចែងនៅក្នុងតារាងនៃការសន្យាជាក់លាក់ក្នុងឧបសម្ព័ន្ធ ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវន្តបុគ្គល) ដើម្បីវាស់វែងអំពីផលប៉ះពាល់លើការចេញចូលជាបណ្តោះអាសន្នរបស់រូបវន្តបុគ្គល នៃភាគីមួយ ទៅដែនដីរបស់ភាគីមួយផ្សេងទៀត ។ បុគ្គលទាំងនោះរួមមាន :

ក. ភ្ញៀវជាធុរជន

ខ. អ្នកតម្លើង ឬ អ្នកផ្តល់សេវាកម្ម

គ. ក្រុមប្រឹក្សាភិបាលនៃការិយាល័យកណ្តាល ដែលស្ថិតនៅក្នុងភាគីមួយ បង្កើតសាខាថ្មី ឬ អ្នកតំណាងពាណិជ្ជកម្មផ្សេងទៀត ដែលមានទីតាំងស្ថិតនៅក្នុងភាគីនោះ

ឃ. បុគ្គលដែលត្រូវផ្លាស់ប្តូរខាងក្នុងសាជីវកម្មមួយ

ង. អ្នកផ្គត់ផ្គង់សេវាដែលជាប់កិច្ចសន្យា ។

២. ជំពូកនេះមិនត្រូវបានគេអនុវត្ត ដើម្បីកំណត់អំពីផលប៉ះពាល់ទៅលើរូបវន្តបុគ្គលដែលព្យាយាមចូលទៅទីផ្សារការងាររបស់ភាគីមួយទៀត និង មិនត្រូវអនុវត្ត ដើម្បីវាស់វែងដោយផ្អែកទៅលើមូលដ្ឋាននៃសញ្ជាតិ លំនៅដ្ឋាន ឬ ការងារជាអចិន្ត្រៃយ៍ ។

## មាត្រា ៣
## និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ :

ក. ភាគីដែលត្រូវអនុញ្ញាត មានន័យថា ភាគីដែលទទួលបែបបទសម្រាប់ចេញចូលបណ្តោះអាសន្ន ពីរូបវន្តបុគ្គលនៃភាគីមួយទៀតដែលមានចែងនៅក្នុងមាត្រា ២.១ (វិសាលភាព)

ខ. នីតិវិធីអន្តោប្រវេសន៍ មានន័យថា ទិដ្ឋាការ លិខិតអនុញ្ញាត ប័ណ្ណអនុញ្ញាតឱ្យចូល ឬឯកសារផ្សេងទៀត ឬ ការអនុញ្ញាតដោយអេឡិចត្រូនិចពីអាជ្ញាធរដល់រូបវន្តបុគ្គលនៃភាគីមួយ នូវសិទ្ធិឆ្លងចូលស្នាក់នៅ ឬ ធ្វើការ ឬ អនុញ្ញាតឱ្យមានវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគី ដែលត្រូវអនុញ្ញាត

គ. រូបវន្តបុគ្គលនៃភាគីមួយ មានន័យថា រូបវន្តបុគ្គលនៃភាគីមួយ ដែលមានចែងក្នុងមាត្រា ២ (៣) (និយមន័យ) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) និង

ឃ. ការចេញចូលបណ្តោះអាសន្ន មានន័យថា ការចេញចូលរបស់រូបវន្តបុគ្គល ដែលមានចែងក្នុងជំពូកនេះ ដោយមិនមែនក្នុងគោលបំណងដើម្បីស្នាក់នៅជាអចិន្ត្រៃយ៍ ។

## មាត្រា ៤
## ការផ្តល់សិទ្ធិចេញចូលបណ្តោះអាសន្ន

១. អនុលោមតាមតារាងនៃការសន្យាជាក់លាក់ក្នុងឧបសម្ព័ន្ធ ៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវន្តបុគ្គល) ភាគីនីមួយៗត្រូវផ្តល់សិទ្ធិចេញចូលបណ្តោះអាសន្ន ឬ ពន្យាររយៈពេលស្នាក់នៅបណ្តោះអាសន្ន ស្របតាមជំពូកនេះ ទៅដល់រូបវន្តបុគ្គលដែលមកពីភាគីមួយទៀត ដោយតម្រូវឱ្យរូបវន្តបុគ្គលទាំងនោះ :

ក. អនុវត្តតាមនីតិវិធីបំពេញបែបបទអន្តោប្រវេសន៍ ដែលបានកំណត់ និង

ខ. បំពេញរាល់តម្រូវការដែលពាក់ព័ន្ធ សម្រាប់ចេញចូលទៅកាន់ភាគីដែលអនុញ្ញាត ។

២. កំរិណាមួយដែលបានកំណត់ ទាក់ទងទៅនឹងការបំពេញបែបបទអន្តោប្រវេសន៍ ត្រូវមានលក្ខណៈសមរម្យ និង ស្របទៅតាមច្បាប់ក្នុងស្រុក ។

៣. ភាគីមួយអាចបដិសេធក្នុងការផ្តល់សិទ្ធិចេញចូលបណ្តោះអាសន្ន ឬ ពន្យាររយៈពេលស្នាក់នៅដល់រូបវន្តបុគ្គល ដែលមកពីភាគីមួយផ្សេងទៀតបាន ប្រសិនបើពួកគេមិនបានបំពេញតាមលក្ខខណ្ឌដូចចែងក្នុងកថាខណ្ឌ ១ ក និង ខ ខាងលើ ។

## មាត្រា ៥
## តារាងនៃការសន្យាសម្រាប់ការចូល និង ការស្នាក់នៅបណ្តោះអាសន្ននៃរូបវន្តបុគ្គល

ភាគីនីមួយៗត្រូវកំណត់នូវកាលវិភាគ ដែលមានចែងអំពីការសន្យាសម្រាប់ការចូល និងការស្នាក់នៅបណ្តោះអាសន្ននៃរូបវន្តបុគ្គល ដូចមានកំណត់ក្នុងមាត្រា ២.១ (វិសាលភាព) ដែលមកពីភាគីមួយទៀតនៅក្នុងដែនដីរបស់ខ្លួន នៅក្នុងឧបសម្ព័ន្ធទី៤ (តារាងនៃការសន្យាអំពីបំលាស់ទីនៃរូបវន្តបុគ្គល)។ កាលបរិច្ឆេទទាំងនោះ ត្រូវមានកំណត់លក្ខខណ្ឌ និងព្រំដែនកម្រិត ដែលគ្រប់គ្រងលើការសន្យានោះ ដោយរួមមានទាំងរយៈពេលនៃការស្នាក់នៅ សម្រាប់ប្រភេទនីមួយៗនៃរូបវន្តបុគ្គល ដែលមាននៅក្នុងតារាងនៃការសន្យារបស់ភាគីនីមួយៗ ។

## មាត្រា ៦
## ដំណើរការនៃការដាក់ពាក្យស្នើសុំ

១. នៅពេលដែលមានតម្រូវការឱ្យបំពេញតាមនីតិវិធីអន្តោប្រវេសន៍ពីភាគីមួយ ភាគីនោះត្រូវពិនិត្យលើពាក្យស្នើសុំបែបបទអន្តោប្រវេសន៍ ឬ ការស្នើសុំពន្យារភ្លាម ពីពេលដែលបានទទួលពាក្យសុំនោះពីរូបវន្តបុគ្គល ដែលមកពីភាគីមួយទៀត ដូចមានកំណត់ក្នុងមាត្រា ២.១ (វិសាលភាព) ។

២. នៅពេលដែលមានការស្នើសុំ និងក្នុងអំឡុងពេលវេលាសមរម្យ បន្ទាប់ពីបានទទួលពាក្យស្នើសុំបែបបទអន្តោប្រវេសន៍ ពីរូបវន្តបុគ្គលដែលមកពីភាគីមួយទៀត ដូចមានកំណត់ក្នុងមាត្រា ២.១ (វិសាលភាព) ភាគីនីមួយៗត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំនូវ :

ក. បង្កាន់ដៃទទួលពាក្យស្នើសុំ

ខ. អំពីស្ថានភាពនៃពាក្យស្នើសុំ និង

គ. ការសម្រេចលើពាក្យស្នើសុំ រួមទាំងរយៈពេលនៃការស្នាក់នៅ និងលក្ខខណ្ឌផ្សេងទៀត ប្រសិនបើមានការសម្រេច ។

## មាត្រា ៧
## វិធានការអន្តោប្រវេសន៍

១. មិនមានការចែងនៅក្នុងជំពូកនេះ ជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ឬ ជំពូក ១១ (វិនិយោគ) អាចបង្ការមិនឱ្យភាគីអនុវត្តវិធានការដើម្បីត្រួតពិនិត្យការចេញចូលរបស់រូបវន្តបុគ្គល ដែលមកពីភាគីមួយផ្សេងទៀត ឬការស្នាក់នៅបណ្តោះអាសន្នរបស់ពួកគេនៅក្នុងដែនដីរបស់ភាគីនោះ ដោយរួមទាំងវិធានការចាំបាច់ទាំងឡាយ ដើម្បីការពារបូរណភាពដែនដី និងដើម្បីធានានូវបំលាស់ទីរបស់រូបវន្តបុគ្គល ឱ្យមានសណ្តាប់ធ្នាប់ល្អក្នុងការឆ្លងកាត់ព្រំដែន របស់ភាគីនោះ ដោយចាត់ទុកថា វិធានការទាំងនោះមិនត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឱ្យបាត់បង់ ឬ អន់ថយនូវប្រយោជន៍ដែលភាគីនឹងទទួលបានក្នុងជំពូកនេះ ឬ ធ្វើឱ្យអន់ថយហួសហេតុ ឬ ពន្យារពេលការធ្វើពាណិជ្ជកម្មទំនិញ ឬ សេវាកម្ម ឬ ដំណើរការសកម្មភាពវិនិយោគ ស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ។

២. មូលហេតុចំបងដែលតម្រូវឱ្យបុគ្គល ត្រូវបំពេញតាមតម្រូវការចាំបាច់ជាមុន នឹងចេញចូលទៅភាគីមួយទៀត មិនត្រូវចាត់ទុកថាជាការធ្វើឱ្យបាត់បង់ ឬ អន់ថយនូវផលប្រយោជន៍ ដែលភាគីនឹងទទួលបានក្នុងជំពូកនេះ ឬ ធ្វើឱ្យអន់ថយហួសហេតុ ឬ ពន្យារពេលការធ្វើពាណិជ្ជកម្មលើទំនិញ ឬ សេវាកម្ម ឬ ដំណើរការសកម្មភាពវិនិយោគស្ថិតក្រោមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៨
## តម្លាភាព

ភាគីនីមួយៗត្រូវ :

ក. បោះពុម្ពផ្សាយ ឬបើមិនដូច្នោះទេ បង្កើតឱ្យមានជាឯកសារពន្យល់នូវរាល់បែបបទអន្តោប្រវេសន៍ដែលនឹងប៉ះពាល់ដល់ការអនុវត្តជំពូកនេះ

ខ. ផ្សព្វផ្សាយនូវតម្រូវការសម្រាប់ចេញចូលបណ្ដោះអាសន្ន ដូចមានចែងក្នុងជំពូកនេះ ដោយរួមទាំងឯកសារសម្រាប់ពន្យល់ និង ទម្រង់បែបបទដែលពាក់ព័ន្ធ និង ឯកសារដទៃទៀត ដែលអាចឱ្យរូបវន្តបុគ្គលដែលមកពីភាគីដទៃទៀតបានដឹងនូវតម្រូវការទាំងនោះ ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ បន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងនេះចូលជាធរមានត្រូវបានផ្សព្វផ្សាយ ដូចជា នៅតាមគេហទំព័ររបស់អង្គភាពអន្តោប្រវេសន៍ ឬ បើមិនដូច្នោះទេ ត្រូវធ្វើឱ្យសាធារណៈជននៅក្នុងដែនដីរបស់ខ្លួនបានដឹងឮ និង បុគ្គលនៅក្នុងដែនដីរបស់ភាគីដទៃទៀតផងដែរ. និង

គ. នៅពេលដែលមានការកែប្រែ ឬវិសោធនកម្មលើវិធានការអន្តោប្រវេសន៍ណាមួយ ដែលប៉ះពាល់ដល់ការចេញចូលជាបណ្ដោះអាសន្នរបស់រូបវន្តបុគ្គល ដែលមកពីភាគីផ្សេងទៀតត្រូវធានាថា ព័ត៌មានទាំងនោះត្រូវបានផ្សព្វផ្សាយ ឬ បើមិនដូច្នោះទេ ធ្វើឱ្យស្របទៅតាមកថាខណ្ឌ ខ ខាងលើ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ ។

## មាត្រា ៩

## ការអនុវត្តជំពូក ១៧ (ការពិគ្រោះយោបល់ និង ការដោះស្រាយវិវាទ)

១. ភាគីត្រូវព្យាយាមដោះស្រាយរាល់ភាពមិនស្របគ្នា ដែលកើតចេញអំពីការអនុវត្តជំពូកនេះ តាមរយៈការពិគ្រោះយោបល់ ។

២. ភាគីមួយមិនត្រូវស្វែងរកដំណោះស្រាយពីជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) ដែលទាក់ទងទៅនឹងការបដិសេធក្នុងការផ្ដល់ការអនុញ្ញាតឱ្យចេញចូល ដូចមានចែងក្នុងជំពូកនេះ លុះត្រាតែ :

ក. បញ្ហាពាក់ព័ន្ធនឹងទម្រង់នៃការអនុវត្ត លើផ្នែកនៃភាគីដែលត្រូវផ្ដល់ការអនុញ្ញាត និង

ខ. រូបវន្តបុគ្គលដែលពាក់ព័ន្ធ បានប្រើប្រាស់រាល់ដំណោះស្រាយក្នុងស្រុកដែលមាន លើបញ្ហាជាក់លាក់នោះរួចហើយ ។

# ជំពូក ១០
# ពាណិជ្ជកម្មអេឡិចត្រូនិច

## មាត្រា ១
## គោលបំណង

គោលបំណងនៃជំពូកនេះគឺ :

ក- ជម្រុញពាណិជ្ជកម្មអេឡិចត្រូនិច ជាមួយប្រទេសសមាជិក

ខ- បង្កើនសហប្រតិបត្តិការជាមួយប្រទេសសមាជិក ក្នុងការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិច

គ- ជម្រុញការប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិចឱ្យបានទូលាយ និងទូទាំងពិភពលោក

## មាត្រា ២
## និយមន័យ

គោលបំណងនៃជំពូកនេះ គឺពន្យល់នូវពាក្យសំខាន់ៗ ដូចតទៅ :

ក- **វិញ្ញាបនបត្រឌីជីថល** ជាឯកសារ ឬបណ្ណុំឯកសារអេឡិចត្រូនិចដែលត្រូវប្រើប្រាស់ ឬភ្ជាប់ទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ ការប្រាស្រ័យទាក់ទងគ្នាតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីបង្កើតអត្តសញ្ញាណអ្នកប្រើប្រាស់

ខ- **ការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិច** គឺជាវិធីសាស្ត្រនៃការបញ្ជាក់ភស្តុតាងលើលិខិត ឬ ពាក្យទាមទារ ដើម្បីបង្កើតកម្រិតនៃការជឿទុកចិត្តលើលិខិតឬពាក្យទាមទារនោះ

គ- **ហត្ថលេខាអេឡិចត្រូនិច** ត្រូវបានប្រទេសសមាជិកបានដាក់និយមន័យនេះនៅក្នុងច្បាប់ និងបទដ្ឋានគតិយុត្ត

ឃ- **ឯកសារអេឡិចត្រូនិច** គឺជាឯកសារនៅក្នុងទម្រង់អេឡិចត្រូនិច ដែលបានសរសេរដោយប្រទេសសមាជិក ដោយរួមមាន ឯកសារដែលបានផ្ញើតាមទូរសារ (Fax)

ង- **ឯកសាររដ្ឋបាលពាណិជ្ជកម្ម** គឺជាលិខិតស្នាមដែលបានផ្តល់ ឬត្រួតពិនិត្យដោយសមាជិកណាម្នាក់ ដែលត្រូវបំពេញដោយ ឬសម្រាប់អ្នកនាំចេញឬនាំចូលនៅក្នុងការនាំទំនិញចេញឬនាំទំនិញចូល និង

ច- **UNCITRAL** គឺជាគណៈកម្មការរបស់អង្គការសហប្រជាជាតិផ្នែកច្បាប់ពាណិជ្ជកម្មអន្តរជាតិ

## មាត្រា ៣

## តម្លាភាព

១- ភាគីនីមួយៗ ត្រូវតែផ្សព្វផ្សាយជាប្រញាប់នូវចំណុចណាដែលអនុវត្តបានល្អ ឬមិនអាចអនុវត្តបាន បើមិនដូច្នោះទេ ចាត់វិធានការជាសាធារណៈដែលអាចធ្វើទៅបានក្នុងការអនុវត្តជាទូទៅ ក្នុងប្រតិបត្តិការជំពូកនេះ ។

២- ភាគីនីមួយៗ ត្រូវឆ្លើយតបឱ្យបានប្រញាប់នូវរាល់សំណើរពាក់ព័ន្ធនានា របស់សមាជិកដទៃទៀត នូវព័ត៌មានពិសេសលើវិធានការនានានៃការអនុវត្តទូទៅនៃជំពូកនេះ ។

## មាត្រា ៤

## ក្របខ័ណ្ឌបទប្បញ្ញត្តិក្នុងស្រុក

ភាគីនីមួយៗត្រូវរក្សា ឬអនុម័តឱ្យបានឆាប់នូវច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកទាក់ទងទៅនឹងកិច្ចការអេឡិចត្រូនិច ដោយពិចារណាដល់គំរូច្បាប់ស្តីពីពាណិជ្ជកម្មអេឡិចត្រូនិច ឆ្នាំ ១៩៩៦ របស់ UNCITRAL ។

## មាត្រា ៥

## ការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិច និងវិញ្ញាបនបត្រឌីជីថល

១- ភាគីនីមួយៗ ត្រូវរក្សា ឬអនុម័តឱ្យបានឆាប់នូវវិធានការនានា ដោយផ្អែកតាមបទដ្ឋានអន្តរជាតិ នៃការបញ្ជាក់លិខិតយថាភូតតាមប្រព័ន្ធអេឡិចត្រូនិច ដែល :

ក- អនុញ្ញាតឱ្យអ្នកប្រើប្រាស់ ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិច អាចកំណត់នូវបច្ចេកវិជ្ជានៃការបញ្ជាក់លិខិតយថាភូត និងការអនុវត្តរូបមន្ត ដែលសមរម្យសម្រាប់ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិចរបស់ពួកគាត់

ខ- មិនត្រូវកម្រិតការទទួលស្គាល់នូវគំរូអនុវត្តន៍ និងបច្ចេកវិជ្ជានៃការបញ្ជាក់លិខិតយថាភូតឡើយ. និង

គ- អនុញ្ញាតឱ្យអ្នកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច មានឱកាសបញ្ជាក់ថា ទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិចរបស់ពួកគាត់អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិក្នុងស្រុកនានា របស់ភាគី ។

២- ភាគីទាំងអស់ ត្រូវព្យាយាមធ្វើការងារឆ្ពោះទៅរកការទទួលស្គាល់ទៅវិញទៅមក នូវវិញ្ញាបនបត្រឌីជីថល និង ហត្ថលេខាអេឡិចត្រូនិច ដែលចេញ ឬទទួលស្គាល់ដោយរដ្ឋាភិបាលដោយផ្អែកតាមស្តង់ដាអន្តរជាតិ ។

៣- ភាគីទាំងអស់ ត្រូវលើកទឹកចិត្តឱ្យពាណិជ្ជករប្រើប្រាស់វិញ្ញាបនបត្រឌីជីថល ឱ្យបានទូលំទូលាយ ។

## មាត្រា ៦

## ការការពារអ្នកប្រើប្រាស់តាមប្រព័ន្ធអេឡិចត្រូនិច

១- យោងតាមកថាខណ្ឌ ២ ភាគីនីមួយៗ ត្រូវផ្តល់ការការពារដល់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឱ្យបានស្មើនឹងការការពារដែលបានផ្តល់ដល់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមលក្ខណៈផ្សេងៗទៀត ដែលស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ បទដ្ឋានគតិយុត្ត និងគោលនយោបាយដែលពាក់ព័ន្ធ ។

២- ភាគីមួយ មិនមានកាតព្វកិច្ចអនុវត្តកថាខណ្ឌ ១ មុនកាលបរិច្ឆេទនៃការអនុម័តច្បាប់ ឬបទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ឬអនុម័តគោលនយោបាយនៃការការពារអ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចឡើយ ។

## មាត្រា ៧

## ការការពារទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិច

១- យោងតាមកថាខណ្ឌ២ ភាគីនីមួយៗត្រូវការពារទិន្នន័យឯកជនរបស់អ្នកប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិច ។

២- ភាគីមួយមិនមានកាតព្វកិច្ចអនុវត្តកថាខណ្ឌ ១ មុនកាលបរិច្ឆេទនៃការអនុម័តច្បាប់ ឬ បទប្បញ្ញត្តិក្នុងស្រុករបស់ខ្លួន ក្នុងការការពារទិន្នន័យរបស់អ្នកប្រើប្រាស់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចឡើយ ។

៣- ក្នុងការអភិវឌ្ឍស្តង់ដានៃការការពារទិន្នន័យ ភាគីនីមួយៗត្រូវពិចារណាលើស្តង់ដាអន្តរជាតិ និងលក្ខខណ្ឌ នៃអង្គការអន្តរជាតិដែលពាក់ព័ន្ធ ។

## មាត្រា ៨
## ការធ្វើពាណិជ្ជកម្មដោយមិនប្រើប្រាស់ក្រដាសស្នាម

១- ភាគីនីមួយៗ ត្រូវព្យាយាមធ្វើការងារឆ្ពោះទៅរកការអនុវត្តគំនិតផ្តួចផ្តើមក្នុងការធ្វើពាណិជ្ជកម្ម ដោយមិនប្រើប្រាស់ក្រដាសស្នាម ។

២- ភាគីទាំងអស់ ត្រូវសហប្រតិបត្តិការក្នុងឆាកអន្តរជាតិ ដើម្បីបង្កើនការឯកភាពគ្នាលើការប្រើប្រាស់ឯកសាររដ្ឋបាលសម្រាប់ធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ។

៣- ក្នុងការងារឆ្ពោះទៅអនុវត្តគំនិតផ្តួចផ្តើម ធ្វើពាណិជ្ជកកម្មដោយមិនប្រើប្រាស់ក្រដាសស្នាម ភាគីនីមួយៗត្រូវគិតគូរទៅដល់គំរូដែលបានឯកភាពដោយអង្គការអន្តរជាតិនានា រួមទាំង អង្គការគយពិភពលោក ។

៤- ភាគីនីមួយៗ ត្រូវខិតខំធ្វើឱ្យមានជាសាធារណៈនូវឯកសាររដ្ឋបាលពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិច ។

## មាត្រា ៩
## កិច្ចសហប្រតិបត្តិការលើពាណិជ្ជកម្មអេឡិចត្រូនិច

១- ដោយទទួលស្គាល់ប្រភេទពាណិជ្ជកម្មអេឡិចត្រូនិចអន្តរជាតិ ភាគីទាំងអស់ត្រូវជម្រុញកិច្ចសហប្រតិបត្តិការក្នុងសកម្មភាពសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ដែលអាចបង្កើនការអភិវឌ្ឍវិស័យពាណិជ្ជកម្មអេឡិចត្រូនិច ។ សកម្មភាពសិក្សាស្រាវជ្រាវ និង កិច្ចសហប្រតិបត្តិការទាំងនោះ មានដូចជា តែមិនកម្រិត :

- ក- ជម្រុញការប្រើប្រាស់ឯកសាររដ្ឋបាលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ដោយភាគីណាមួយ ឬ ភាគីទាំងអស់
- ខ- ជួយសហគ្រាសធុនតូច និងមធ្យម ដែលជួបឧបសគ្គក្នុងការប្រើប្រាស់ពាណិជ្ជកម្មអេឡិចត្រូនិច
- គ- ផ្លាស់ប្តូរព័ត៌មាន និងបទពិសោធ និងបញ្ជាក់ពីការអនុវត្តច្បាប់ និងគោលនយោបាយជាតិបានល្អ លើពាណិជ្ជកម្មអេឡិចត្រូនិច ដែលរួមមាន ការការពារទិន្នន័យរក្សាការសំងាត់ ផ្តល់ការជឿទុកចិត្តដល់អ្នកប្រើប្រាស់ សន្តិសុខ ហត្ថលេខាអេឡិចត្រូនិច កម្មសិទ្ធិបញ្ញា និងរដ្ឋាភិបាលអេឡិចត្រូនិច
- ឃ- លើកទឹកចិត្តឱ្យមានសកម្មភាពសហប្រតិបត្តិការ ដើម្បីជម្រិញវិស័យពាណិជ្ជកម្មអេឡិចត្រូនិច ដែលអាចបង្កើនសុពលភាព និង ប្រសិទ្ធភាពចំពោះពាណិជ្ជកម្មអេឡិចត្រូនិច

ង-	ស្វែងរកមធ្យោបាយនានា ដែលភាគីអភិវឌ្ឍន៍មួយ ឬភាគីអភិវឌ្ឍន៍ទាំងឡាយ អាចផ្តល់ជំនួយដល់ភាគីដែលកំពុងអភិវឌ្ឍន៍ ក្នុងការអនុវត្តច្បាប់ពាណិជ្ជកម្មអេឡិចត្រូនិច

ច-	លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការ រវាងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្រួលដល់ការស៊ើបអង្កេតជាបន្ទាន់ និងដោះស្រាយការក្លែងបន្លំទាំងឡាយ ទាក់ទងនឹងកិច្ចការពាណិជ្ជកម្មអេឡិចត្រូនិច

ឆ-	លើកទឹកចិត្តដល់ការអភិវឌ្ឍដោយវិស័យឯកជន លើវិធីសាស្ត្រនៃការបង្កើតបទដ្ឋាន ដោយខ្លួនឯងរួមមាន បទបញ្ជាផ្ទៃក្នុង កិច្ចសន្យាគំរូ សេចក្តីណែនាំ និងយន្តការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីពង្រឹងពាណិជ្ជកម្មអេឡិចត្រូនិច និង

ជ-	សកម្មចូលរួមក្នុងវេទិកាតំបន់ និងពហុភាគី ដើម្បីជម្រុញការអភិវឌ្ឍពាណិជ្ជកម្មអេឡិចត្រូនិច។

២-	ភាគីទាំងអស់ ត្រូវលើកទឹកចិត្តអនុវត្តគ្រប់ទំរង់នៃកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើតឡើងនូវគំនិតផ្តួចផ្តើមថ្មី ហើយដែលមិនត្រួតគ្នានឹងគំនិតផ្តួចផ្តើមដែលមានស្រាប់ តាមវេទិកាអន្តរជាតិ។

## មាត្រា ១០
## ការមិនអនុវត្តជំពូក ១៧ (ការពិគ្រោះយោបល់ និង ការដោះស្រាយវិវាទ)

ជំពូកទី១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) មិនត្រូវអនុវត្តលើបញ្ហាដែលកើតឡើងក្រោមជំពូកនេះទេ។

# ជំពូក ១១
# វិនិយោគ

## ផ្នែក ក

### មាត្រា ១
### ទំហំ

១. ជំពូកនេះត្រូវអនុវត្តលើវិធានការទាំងឡាយ ដែលបានអនុម័ត ឬរក្សាទុកដោយភាគីមួយពាក់ព័ន្ធនឹង :

(ក) អ្នកវិនិយោគនៃភាគីម្ខាងទៀត និង

(ខ) ដែនវិនិយោគ

២. ជំពូកនេះមិនអនុវត្តចំពោះ :

(ក) លទ្ធកម្មសាធារណ:

(ខ) ការឧបត្ថម្ភធន ឬការផ្តល់ជំនួយដោយភាគីមួយ, និង

(គ) សេវាកម្មផ្គត់ផ្គង់ស្ថិតក្នុងការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាល ដោយស្ថាប័នពាក់ព័ន្ធ ឬអាជ្ញាធរនៃភាគីមួយ។ សំរាប់គោលបំណងនៃជំពូកនេះ ការផ្គត់ផ្គង់សេវាស្ថិតក្នុងការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាល មានន័យសំដៅលើសេវាណាមួយ ដែលត្រូវបានផ្គត់ផ្គង់ដោយមិនផ្អែកទាំងលើមូលដ្ឋានពាណិជ្ជកម្ម ទាំងលើមូលដ្ឋានប្រកួតប្រជែងជាមួយអ្នកផ្គត់ផ្គង់សេវាមួយ ឬច្រើននោះឡើយ។

### មាត្រា ២
### និយមន័យ

ក្នុងគោលបំណងនៃជំពូកនេះ :

(ក) **ដែនវិនិយោគ** មានន័យសំដៅលើ ភាគីមួយ, វិនិយោគមួយក្នុងដែនដីវិនិយោគនៃភាគីដទៃទៀត ដែលមានស្រាប់ គិតត្រឹមកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឬដែលបានបង្កើត

ឡើង. បានទិញយក ឬបានពង្រីកក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងដែលត្រូវបានអនុញ្ញាត[១] ដោយភាគីម្ចាស់ផ្ទះដោយអនុលោមទៅតាមច្បាប់ បទប្បញ្ញត្តិ និង គោលនយោបាយរបស់គេ ។

(ខ) **រូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី** មានន័យសំដៅលើ រូបិយប័ណ្ណអាចប្រើប្រាស់បានដោយសេរី ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) អនុលោមតាមមាត្រានៃកិច្ចព្រមព្រៀង IMF និងវិសោធនកម្មនានា ដែលមានក្នុងនោះ ។

(គ) **ការវិនិយោគ**[២] មានន័យសំដៅលើ ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលជាកម្មសិទ្ធិ ឬគ្រប់គ្រងដោយអ្នកវិនិយោគ ដោយរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះទ្រព្យសម្បត្តិ ដូចខាងក្រោមនេះទេ :

(i) ចលនទ្រព្យ និងអចលនទ្រព្យ និងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត ដូចជា អចលនទ្រព្យដាក់បញ្ចាំ សិទ្ធិលើទ្រព្យធានារបស់ម្ចាស់បំណុល ឬប្រាក់សន្យាផ្ដល់ឱ្យ

(ii) ភាគហ៊ុន ហ៊ុន សញ្ញាប័ណ្ណ ប័ណ្ណបំណុល និងទំរង់នៃការចូលរួមផ្សេងទៀត របស់នីតិបុគ្គល និង សិទ្ធិដែលកើតចេញពីការចូលរួមនោះ

(iii) កម្មសិទ្ធិបញ្ញាដែលបានទទួលស្គាល់ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីនីមួយៗ និងដោយសុឆន្ទៈ

(iv) ការទាមទារសំណងជាប្រាក់ ឬការទាមទារជាការអនុវត្តកិច្ចសន្យាទាក់ទងនឹងធុរកិច្ច ដែលមានតំលៃហិរញ្ញវត្ថុ[៣] ។

---

[១] ដើម្បីឱ្យកាន់តែប្រាកដ :

(ក) ក្នុងករណីប្រទេសថៃ កិច្ចការពារនៅក្នុងជំពូកនេះ ត្រូវស្របជាមួយនឹងដែនវិនិយោគដែលបានអនុម័តជាក់លាក់ជាលាយលក្ខណ៍អក្សរ សំរាប់កិច្ចការពារដោយអាជ្ញាធរមានសមត្ថកិច្ច ។

(ខ) ក្នុងករណីប្រទេសវៀតណាម "បានអនុញ្ញាត" មានន័យសំដៅលើ "បានចុះបញ្ជី ឬក៏ទទួលការអនុម័តជាក់លាក់ជាលាយលក្ខណ៍អក្សរ ជាករណីដែលអាចមាន"

[២] ពាក្យ "ការវិនិយោគ" មិនរាប់បញ្ចូលនូវបទបញ្ជា ឬការវិនិច្ឆ័យចូលក្នុងសកម្មភាពច្បាប់ ឬសកម្មភាពរដ្ឋបាលឡើយ ។

[៣] ដើម្បីឱ្យកាន់តែប្រាកដ ការវិនិយោគមិនមានន័យសំដៅលើការទាមទារប្រាក់ដែលកើតចេញតែពី :

(ក) កិច្ចសន្យាពាណិជ្ជកម្មចំពោះរាល់ការលក់ទំនិញឬសេវាកម្ម ឬ

(ខ) ការពង្រីកឥណទានោ ដែលទាក់ទងជាមួយនិងកិច្ចសន្យាពាណិជ្ជកម្មប្រភេទនេះឡើយ ។

(v) សិទ្ធិផ្សេងៗ ក្រោមកិច្ចសន្យារួមបញ្ចូលទាំង កិច្ចសន្យាទទួលយកសមិទ្ធផលរួចស្រេច ជាស្ថាពរ ការសាងសង់ ការគ្រប់គ្រង ការផលិត ឬកិច្ចសន្យាចែករំលែកចំណូល, និង

(vi) សម្បទានពាណិជ្ជកម្ម ដែលតម្រូវចំពោះដំណើរការសកម្មភាពសេដ្ឋកិច្ច និងមានតំលៃហិរញ្ញវត្ថុ ដែលបានផ្តល់ឱ្យដោយច្បាប់ ឬក្រោមកិច្ចសន្យា រាប់បញ្ចូលទាំងសម្បទាន ដើម្បីស្រាវជ្រាវ ដាំដុះ ធ្វើនិស្សារណកម្ម ឬធ្វើអាជីវកម្មធនធានធម្មជាតិ។ សំរាប់គោលបំណងនៃនិយមន័យ "ការវិនិយោគ" ក្នុងមាត្រានេះ ចំណូលដែលបានពីការវិនិយោគ ត្រូវចាត់ទុកថា ជាការវិនិយោគ និងទំរង់ណាមួយផ្សេងទៀតដែលទ្រព្យសម្បត្តិត្រូវបានវិនិយោគ ឬវិនិយោគឡើងវិញ នឹងមិនប៉ះពាល់ដល់ប្រភេទនៃការវិនិយោគឡើយ។

(ឃ) **អ្នកវិនិយោគនៃភាគីមួយ** មានន័យសំដៅលើ រូបវន្តបុគ្គល ឬនីតិបុគ្គលនៃភាគីមួយ ដែលស្វែងរកការវិនិយោគ[៤] កំពុងវិនិយោគ ឬបានវិនិយោគក្នុងដែនដីនៃភាគីមួយទៀត។

(ង) **នីតិបុគ្គល** មានន័យសំដៅលើ អង្គភាពដែលបានបង្កើត ឬបានរៀបចំឡើងតាមបែបផ្សេងទៀតត្រឹមត្រូវតាមច្បាប់ជាធរមាន មិនថា ដើម្បីស្វែងរកចំណេញ ឬក្រៅពីនេះ និងមិនថាជាកម្មសិទ្ធិរបស់ឯកជន ឬរបស់រដ្ឋ រាប់បញ្ចូលទាំងសាជីវកម្ម ប្រតិសិទ្ធកម្ម ភាពជាដៃគូសម្ព័ន្ធអាជីវកម្ម ឯកកម្មសិទ្ធិ សមាគម ឬអង្គការដែលមានលក្ខណៈស្រដៀងគ្នា។

(ច) **នីតិបុគ្គលនៃភាគីមួយ** មានន័យសំដៅលើ នីតិបុគ្គលដែលបានបង្កើត ឬរៀបចំឡើងក្រោមច្បាប់នៃភាគីនោះ។

(ឆ) **វិធានការ** មានន័យសំដៅលើ វិធានការណាមួយរបស់ភាគីមួយ ទោះជាស្ថិតក្នុងទំរង់នៃច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច និងសកម្មភាពរដ្ឋបាល ឬទំរង់ណាមួយផ្សេងទៀតក៏ដោយ។

(ជ) **វិធានការដោយភាគីមួយ** រាប់បញ្ចូលទាំងវិធានការទាំងឡាយ ដែលប្រកាន់យកដោយ :

---

[៤] ដើម្បីឱ្យកាន់តែប្រាកដ ភាគីទាំងអស់យល់ឃើញថាអ្នកវិនិយោគដែល "ស្វែងរកធ្វើ" ការវិនិយោគគឺសំដៅ លើអ្នកវិនិយោគ នៃភាគីម្ខាងទៀតដែលចាត់វិធានការសកម្មដើម្បីធ្វើការវិនិយោគ។ នៅពេលដែលសេចក្តីជូនដំណឹង ឬនីតិវិធីអនុម័តតំរូវឱ្យសំរាប់ការធ្វើវិនិយោគនោះ អ្នកវិនិយោគដែល "ស្វែងរកធ្វើ" ការវិនិយោគសំដៅលើអ្នកវិនិយោគនៃភាគីមួយទៀត ដែលបានចាប់ផ្តើមបំពេញនូវសេចក្តីជូនដំណឹង ឬនីតិវិធី អនុម័តនេះ។

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន និង

(ii) ស្ថាប័នមិនមែនរដ្ឋាភិបាលស្ថិតក្នុងការអនុវត្តសិទ្ធិអំណាច ដែលត្រូវបានធ្វើប្រតិភូកម្ម ដោយរដ្ឋាភិបាល ឬអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន។

(ឈ) **រូបវន្តបុគ្គលនៃភាគីមួយ** មានន័យសំដៅលើ រូបវន្តបុគ្គលដែលមានសញ្ជាតិឬការទទួលបានសញ្ជាតិ ឬ សិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងទឹកដីនៃភាគីនោះ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនោះ. និង

(ញ) **ចំណូលពីការវិនិយោគ** មានន័យសំដៅលើ ចំណូលប្រមូលបាន ឬបានមកពីការវិនិយោគដោយរាប់បញ្ចូលទាំង ប្រាក់ចំណេញ ភាគលាភ ការប្រាក់ ចំណេញមូលធន កំរៃសួយសារ និងចំណូលស្របច្បាប់ដទៃទៀត។

## មាត្រា ៣
## ទំនាក់ទំនងជាមួយជំពូកផ្សេងទៀត

១. ជំពូកនេះ មិនអនុវត្តចំពោះវិធានការទាំងឡាយដែលបានអនុម័ត ឬរក្សាទុកដោយភាគីមួយ ក្នុងពេលដែលវិធានការទាំងនោះត្រូវបានគ្របដណ្តប់ដោយជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ឬ ជំពូក ៩ (ការបំលាស់ទីនៃរូបវន្តបុគ្គល)។

២. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ មាត្រា ៦ (ប្រព្រឹត្តិកម្មវិនិយោគ), មាត្រា ៧ (សំណងទូទាត់ចំពោះការខាតបង់), មាត្រា ៨ (ការផ្ទេរ), មាត្រា ៩ (ការដកហូត និងសំណង), មាត្រា ១០ (ឧបាទេសកម្ម), និងផ្នែក (ខ) (វិវាទវិនិយោគរវាងភាគីមួយ និងវិនិយោគិនមួយ) ត្រូវអនុវត្ត mutatis mutandis ចំពោះវិធានការណាមួយដែលប៉ះពាល់ ដល់ការផ្គត់ផ្គង់សេវាដោយអ្នកផ្គត់ផ្គង់សេវានៃភាគីមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគីណាមួយ ក្នុងចំណោមភាគីផ្សេងទៀត អនុលោមតាមជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ប៉ុន្តែសំរាប់តែករណីដែលវិធានការទាំងនេះពាក់ព័ន្ធដែនវិនិយោគ និងកាតព្វកិច្ចនៅក្រោមជំពូកនេះប៉ុណ្ណោះ ដោយមិនគិតដល់ការពាក់ព័ន្ធនឹងវិស័យសេវាកម្មដែលបានកំណត់ក្នុងតារាងកាតព្វកិច្ច នៃការសន្យាវិស័យសេវាកម្មជាក់លាក់របស់ភាគីមួយនៅក្នុងឧបសម្ព័ន្ធ ៣ (តារាងសន្យាពន្ធគយ) ឡើយ។

## មាត្រា ៤
## ប្រព្រឹត្តិកម្មជាតិ[៥]

ភាគីនីមួយៗ ត្រូវយល់ព្រមផ្ដល់ជូនអ្នកវិនិយោគនៃភាគីមួយទៀត និងដល់ដែនវិនិយោគដែលពាក់ព័ន្ធដល់ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង ការដឹកនាំ ការប្រតិបត្តិ ការរំលាយ ការលក់ ការផ្ទេរ ឬទំរង់ពាក់ព័ន្ធផ្សេងទៀតនៃការវិនិយោគ នូវប្រព្រឹត្តិកម្មវិនិយោគមិនតិចជាងអ្វី ដែលខ្លួនបានយល់ព្រមផ្ដល់ឱ្យអ្នកវិនិយោគរបស់ខ្លួន និងការវិនិយោគរបស់គេក្នុងកាលៈទេសៈដូចគ្នានោះឡើយ ។

## មាត្រា ៥
## ការហាមឃាត់នូវការតម្រូវឱ្យបំពេញភាពព្វកិច្ច

ពុំមានភាគីណាមួយត្រូវអនុវត្តនូវវិធានការណាមួយពាក់ព័ន្ធនឹងការបង្កើត ការទិញ ការពង្រីក ការគ្រប់គ្រង ការដឹកនាំ ការប្រតិបត្តិ ឬការលក់ ឬទំរង់ផ្សេងទៀតនៃការវិនិយោគនៃអ្នកវិនិយោគរបស់ភាគីមួយ នៅក្នុងទឹកដីរបស់ខ្លួនដែលពុំមានសង្គតិភាពជាមួយកិច្ចព្រមព្រៀងស្ដីពីវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ក្នុងឧបសម្ព័ន្ធ ១ (ក) នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកឡើយ ។

## មាត្រា ៦
## ប្រព្រឹត្តិកម្មវិនិយោគ

១. ភាគីនីមួយៗ ត្រូវយល់ព្រមផ្ដល់ដល់ដែនវិនិយោគនូវប្រព្រឹត្តិកម្មសមភាព និងយុត្តិធម៌ព្រមទាំងការការពារ និង សុវត្ថិភាពពេញលេញ ។

២. ដើម្បីឱ្យកាន់តែប្រាកដ[៦] :

(ក) ប្រព្រឹត្តិកម្មសមភាព និងយុត្តិធម៌ ទាមទារឱ្យភាគីនីមួយៗ មិនត្រូវបដិសេធចោលនូវយុត្តិធម៌ ក្នុងដំណើរការតាមផ្លូវច្បាប់ ឬតាមផ្លូវរដ្ឋបាលណាមួយឡើយ ។

---

[៥] ការអនុវត្តនៃមាត្រានេះ ត្រូវធ្វើឡើងពាក់ព័ន្ធនឹងមាត្រា១៦ "កម្មវិធីការងារ" ។

[៦] ក្នុងករណីប្រទេសឥណ្ឌូនេស៊ី មានតែកថាខ័ណ្ឌ២ (ក) និង (ខ) ប៉ុណ្ណោះត្រូវអនុវត្តនៅពេលដែលប្រទេសឥណ្ឌូនេស៊ី ជាភាគីស្របតាមប្រព្រឹត្តិកម្មស្ថិតក្រោមមាត្រានេះ ។

(ខ) ការការពារ និងសុវត្ថិភាពពេញលេញ ទាមទារឱ្យភាគីនីមួយៗ ចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីធានានូវការការពារ និងសុវត្ថិភាពនៃដែនវិនិយោគ, និង

(គ) ទស្សនទាននៃ "ប្រព្រឹត្តិកម្មសមភាព និងយុត្តិធម៌" និង "ការការពារ និងសុវត្ថិភាពពេញលេញ" មិនទាមទារនូវប្រព្រឹត្តិកម្មបន្ថែម ឬហួសពីអ្វីដែលតំរូវក្រោមច្បាប់ប្រពៃណីអន្តរជាតិ និងមិនបង្កើតសិទ្ធិសំខាន់ៗ បន្ថែមទៀតឡើយ ។

៣. សេចក្តីសំរេចណាមួយ ដែលមានចរិតបំពានចំពោះបញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងអន្តរជាតិដោយឡែកទៀតនោះ ពុំមានន័យថា ជាការរំលោភបំពានដល់មាត្រានេះឡើយ ។

## មាត្រា ៧
## សំណងទូទាត់ចំពោះការខាតបង់

ភាគីនីមួយៗ ត្រូវយល់ព្រមផ្តល់ជូនអ្នកវិនិយោគនៃភាគីមួយទៀត និងដែនវិនិយោគពាក់ព័ន្ធនឹងវិធានការទាំងឡាយដែលភាគីនោះបានអនុម័ត ឬរក្សាទុកទាក់ទិននឹងការខាតបង់ដែលទទួលរងដោយការវិនិយោគ ស្ថិតនៅក្នុងដែនដីរបស់ខ្លួន បណ្តាលមកពីជំលោះប្រដាប់អាវុធ កលយុគស៊ីវិល ឬការដាក់រដ្ឋឱ្យស្ថិតក្នុងស្ថានការប្រកាសអាសន្ន នូវប្រព្រឹត្តិកម្មវិនិយោគមិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមក្នុងកាលៈទេសៈដូចគ្នាចំពោះ :

(ក) អ្នកវិនិយោគរបស់ខ្លួន និងការវិនិយោគរបស់ពួកគេ, និង

(ខ) អ្នកវិនិយោគនៃភាគីមួយផ្សេងទៀត ឬភាគីមិនស្ថិតក្នុងកិច្ចព្រមព្រៀង និងការវិនិយោគរបស់គេ ។

## មាត្រា ៨
## ការផ្ទេរ

១. ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យធ្វើការផ្ទេរចូល ឬការផ្ទេរចេញនៅក្នុងដែនដីរបស់ខ្លួនដោយសេរី និង ដោយគ្មានការយឺតយ៉ាវពាក់ព័ន្ធនឹងដែនវិនិយោគ ។ ការផ្ទេរទាំងនេះរាប់បញ្ចូលទាំង :

(ក) វិភាគទានចំពោះមូលធន រាប់បញ្ចូលទាំងវិភាគទានជាបឋម

(ខ) ប្រាក់ចំណេញ ចំណូលជាមូលធន ភាគលាភ កំរៃសួយសា កំរៃអាជ្ញាប័ណ្ណ ជំនួយបច្ចេកទេស និង កំរៃគ្រប់គ្រង និងបច្ចេកទេស ការប្រាក់ និងប្រាក់ចំណូលដទៃទៀត ដែលកើនពីដែនវិនិយោគណាមួយ

(គ) ផលទទួលបានពីការលក់សរុប ឬការលក់មួយផ្នែក ឬការរំលាយក្រុមហ៊ុននៃដែនវិនិយោគណាមួយ

(ឃ) ការទូទាត់សងធ្វើឡើងក្រោមកិច្ចសន្យា រួមទាំងកិច្ចព្រមព្រៀងប្រាក់កម្ចី

(ង) ការទូទាត់សងធ្វើឡើងដោយស្របតាមមាត្រា ៧ (សំណងទូទាត់ចំពោះការខាតបង់) និងមាត្រា ៩ (ការដកហូត និងសំណង)

(ច) ការទូទាត់សងកើតមានឡើងពីការដោះស្រាយវិវាទ ដោយមធ្យោបាយណាមួយរាប់បញ្ចូលទាំងការវិនិច្ឆ័យមជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងនៃភាគីមានវិវាទ និង

(ឆ) ប្រាក់ចំណូល និងប្រាក់បៀវត្សបុគ្គលិកនិយោជិតពីខាងក្រៅ ពាក់ព័ន្ធក្នុងការវិនិយោគនោះ។

២. ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យធ្វើការផ្ទេរទាក់ទងនឹងដែនវិនិយោគ នូវរូបិយប័ណ្ណអាចប្រើប្រាស់បានដោយសេរី តាមអត្រាប្តូរប្រាក់ទីផ្សារក្នុងពេលនៃការផ្ទេរនោះ។

៣. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ១ និង ២ ខាងលើក៏ដោយ ភាគីមួយអាចទប់ស្កាត់ ឬពន្យារពេលនៃការផ្ទេរតាមរយៈច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួនដោយសមធម៌ គ្មានការរើសអើង និងដោយបំណងល្អ ទាក់ទងនឹង :

(ក) ការក្ស័យធន ភាពមិនអាចសងបំណុលបាន ឬការការពារសិទ្ធិនៃឥណទានករ

(ខ) ការចេញផ្សាយ ការធ្វើពាណិជ្ជកម្ម ឬការចែកចាយមូលប័ត្រអាជីវកម្ម អនាគត ជម្រើស ឬការទិញភាគហ៊ុន

(គ) បទល្មើសឧក្រិដ្ឋកម្ម ឬបទល្មើសព្រហ្មទណ្ឌ និងប្រាក់ដែលទទួលបានពីរឿងក្តីនៃបទឧក្រិដ្ឋកម្ម

(ឃ) របាយការណ៍ហិរញ្ញវត្ថុ ឬការរក្សាទុកនូវកំណត់ត្រានៃការផ្ទេរនៅពេលចាំបាច់ ដើម្បីជួយដល់ការអនុវត្តច្បាប់ ឬអាជ្ញាធរនិយ័តកម្មហិរញ្ញវត្ថុ

(ង) ធានានូវការអនុវត្តតាមដីកា ឬសាលក្រមក្នុងកិច្ចដំណើរការតាមផ្លូវតុលាការ ឬតាមផ្លូវរដ្ឋបាល

(ច) ពន្ធដារ

(ឆ) សុវត្ថិភាពសង្គម ការចូលនិវត្តន៍សាធារណៈ ឬតំរោងសន្សំចាំបាច់ និង

(ជ) ការកាត់ចេញនូវសិទ្ធិជានិយោជិត

៤. មិនមានអ្វីនៅក្នុងជំពូកនេះ ធ្វើប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃភាគីនីមួយៗជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិក្រោមមាត្រានៃកិច្ចព្រមព្រៀងមូលនិធិរូបិយវត្ថុអន្តរជាតិឡើយ រាប់បញ្ចូលទាំងការប្រើប្រាស់សកម្មភាពប្តូរប្រាក់ ដែលអនុលោមតាមមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងលក្ខខណ្ឌថា ភាគីមួយនឹងមិនដាក់ការកំហិតកំណត់លើកិច្ចការជំនួញមូលធនណាមួយ ដែលគ្មានសង្គតិភាពជាមួយការសន្យាជាក់លាក់របស់ខ្លួនក្រោមជំពូកនេះ ទាក់ទងនឹងកិច្ចការជំនួញនេះ លើកលែងតែនៅក្រោមមាត្រា ៤ (វិធានការការពារតុល្យភាពចំណាយ) នៃជំពូក ១៥ (បទប្បញ្ញត្តិទូទៅ និងការលើកលែង) ឬតបតាមការស្នើសុំនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ។

## មាត្រា ៩
## ការដកហូត និងសំណង[៧]

១. ភាគីមួយ មិនត្រូវដកហូត ឬធ្វើជាតូបនីយកម្មនូវដែនវិនិយោគមួយ ទោះបីដោយផ្ទាល់ ឬតាមរយៈវិធានការប្រហាក់ប្រហែលនឹងការដកហូត ឬការធ្វើជាតូបនីយកម្ម (ការដកហូត) ឡើយ លើកលែងតែ :

(ក) សំរាប់គោលបំណងសាធារណៈ[៨]

(ខ) លើមូលដ្ឋានមិនរើសអើង

(គ) មានការទូទាត់សំណងភ្លាមៗ សមរម្យ និងមានប្រសិទ្ធភាព, និង

(ឃ) អនុលោមតាមដំណើរការនៃច្បាប់

២. សំណងដែលយោងដល់កថាខ័ណ្ឌ ១ (គ) ត្រូវ :

(ក) ទូទាត់ដោយគ្មានការពន្យារពេល[៩]

(ខ) សមមូលជាមួយតំលៃទីផ្សារសមរម្យ ចំពោះការវិនិយោគដែលបានដកហូតក្នុងពេល ឬមុនពេលដែលការដកហូតត្រូវបានប្រកាសជាសាធារណៈ[១០] ឬពេលដែលការដកហូតបានកើតឡើងដោយជំរើសមួយណា ដែលអាចអនុវត្តបាន

---

[៧] ចំពោះមាត្រានេះ ត្រូវបានបកស្រាយដោយស្របតាមឧបសម្ព័ន្ធនៃជំពូកនេះ ស្តីពីការដកហូតនិងសំណង ។

[៨] ដើម្បីជៀសវាងការភាន់ច្រឡំ ប្រសិនបើប្រទេសម៉ាឡេស៊ីជាភាគីដកហូតនោះវិធានការនៃការដកហូតណាមួយពាក់ព័ន្ធដីធ្លី ត្រូវស្ថិតក្នុងគោលដៅដែលមានចែងក្នុងច្បាប់និងបទបញ្ញត្តិក្នុងស្រុកពាក់ព័ន្ធនឹងការបានមកជាកម្មសិទ្ធិដីធ្លី ។

[៩] ភាគីទាំងអស់យល់ឃើញថា អាចមានដំណើរការនៃនីតិវិធីច្បាប់ និងរដ្ឋបាល ចាំបាច់ត្រូវពិនិត្យមើល មុនពេលការទូទាត់សងត្រូវបានធ្វើ ។

(គ) មិនឆ្លុះបញ្ចាំងពីការប្រែប្រួលក្នុងតំលៃ ដោយសារបំណងនៃការដកហូតនេះ ត្រូវបានដឹងជាមុន. និង

(ឃ) ត្រូវទទួលបាន និងផ្ទេរបានដោយសេរី រវាងដែនដីរបស់ភាគីទាំងអស់

៣. សំណងដែលយោងដល់កថាខ័ណ្ឌ ១ (គ) ត្រូវរាប់បញ្ចូលទាំងការប្រាក់សមស្រប ។ សំណងនេះរាប់បញ្ចូលទាំងការប្រាក់ដែលកើនឡើង ត្រូវទូទាត់ជារូបិយប័ណ្ណនៃភាគីដកហូត ឬបើមានការស្នើសុំដោយអ្នកវិនិយោគ ជារូបិយប័ណ្ណដែលអាចប្រើប្រាស់បានដោយសេរី ។

៤. ប្រសិនបើអ្នកវិនិយោគ ស្នើឱ្យមានការទូទាត់ជារូបិយប័ណ្ណដែលអាចប្រើប្រាស់បានដោយសេរីនោះ សំណងដែលយោងដល់កថាខ័ណ្ឌ ១ (គ) រាប់បញ្ចូលទាំង ការប្រាក់ដែលទទួលបានត្រូវប្តូរទៅជារូបិយប័ណ្ណនៃការទូទាត់ តាមអត្រាប្តូរប្រាក់ទីផ្សារនៅថ្ងៃទូទាត់សំណងនោះ ។

៥. មាត្រានេះ មិនអនុវត្តចំពោះការចេញនូវអាជ្ញាប័ណ្ណចាំបាច់ ដែលត្រូវផ្តល់ទាក់ទងនឹងកម្មសិទ្ធិបញ្ញាទេ ដោយអនុលោមតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) ។

៦. ថ្វីបើមានចែងនៅក្នុងកថាខ័ណ្ឌ ១ ដល់កថាខ័ណ្ឌ ៤ ក្នុងករណីប្រទេសសឹង្ហបុរី ឬ សាធារណរដ្ឋសង្គមនិយមវៀតណាម គឺភាគីដកហូត វិធានការនៃការដកហូតណាមួយទាក់ទងនឹងការដកហូតដីធ្លី ដែលបានកំណត់ដោយច្បាប់ក្នុងស្រុកដែលកំពុងអនុវត្តរបស់ភាគីដកហូត នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន ត្រូវស្ថិតក្នុងគោលបំណងនៃការទូទាត់សងចំពោះសំណងត្រូវធ្វើឡើងស្របតាមនីតិវិធីច្បាប់ ដែលបានពោលពីខាងដើម ។ សំណងនេះត្រូវអនុលោមទៅតាមការធ្វើវិសោធនកម្មបន្តបន្ទាប់ ចំពោះច្បាប់ដែលបានពោលខាងលើ ទាក់ទងនឹងចំនួនទឹកប្រាក់នៃសំណង ហើយការធ្វើវិសោធនកម្មនេះ ត្រូវអនុវត្តតាមនិន្នាការទូទៅនៃតំលៃទីផ្សារដីធ្លី ។

## មាត្រា ១០

## ឧបាទេសកម្ម

១. ប្រសិនបើភាគី ឬភ្នាក់ងារមួយ ដែលបានតែងតាំងដោយភាគីមួយ ធ្វើការទូទាត់សងដល់អ្នកវិនិយោគនៃភាគីនោះ ក្រោមការធានាកិច្ចសន្យាធានារ៉ាប់រង ឬទំរង់ផ្សេងទៀតនៃសំណងដែលបានផ្តល់ឱ្យសំរាប់ហានិភ័យមិនមែនពាណិជ្ជកម្មដែលទាក់ទងនឹងការវិនិយោគមួយនោះ ភាគីមួយទៀតត្រូវទទួលស្គាល់នូវឧបាទេសកម្ម ឬការផ្ទេរនៃសិទ្ធិ

---

[១០] ករណីប្រទេសហ្វីលីពីន នៅពេលដែល ឬការដកហូតធ្វើឡើងភ្លាមៗមុនការប្រកាសជាសាធារណៈ សំដៅ លើកាលបរិច្ឆេទ នៃការដាក់បណ្តឹងទាមទារចំពោះការដកហូតនេះ ។

ឬបណ្តឹងទាមទារណាមួយដែលទាក់ទងដល់ការវិនិយោគនេះ។ សិទ្ធិនៃឧបាទេសកម្ម ឬ សិទ្ធិ ដែលបានផ្ទេរ ឬ បណ្តឹងទាមទារមិនត្រូវធំជាងសិទ្ធិ ឬបណ្តឹងទាមទារដើមរបស់អ្នកវិនិយោគឡើយ។

២. ភាគី ឬភ្នាក់ងារនៃភាគីមួយ ដែលបានធ្វើការទូទាត់ឱ្យអ្នកវិនិយោគនៃភាគីនោះ ហើយបានកាន់កាប់នូវរាល់សិទ្ធិ និងការទាមទាររបស់អ្នកវិនិយោគ អ្នកវិនិយោគនោះមិនត្រូវអនុវត្តសិទ្ធិ និងការទាមទារទាំងនោះ ប្រឆាំងនឹងភាគីផ្សេងទៀតឡើយ លើកលែងតែបានទទួលការអនុញ្ញាតឱ្យដើរតួនាទីជំនួសភាគី ឬភ្នាក់ងារដែលត្រូវធ្វើការទូទាត់សងទេនោះ។

៣. នៅក្នុងដំណើរការកាត់ក្តីណាមួយពាក់ព័ន្ធនឹងវិវាទវិនិយោគ ភាគីមួយមិនត្រូវអះអាងជាការការពារ ជាការធ្វើបណ្តឹងតប ជាសិទ្ធិទាមទារទូទាត់ ឬជាសិទ្ធិផ្សេងទៀត ដើម្បីឱ្យអ្នកវិនិយោគ ឬដែនវិនិយោគនោះបានទទួល ឬនឹងទទួលបាននូវការប៉ះប៉ូវសំណង ឬប្រភេទសំណងផ្សេងទៀតសំរាប់ទាំងស្រុង ឬមួយផ្នែកនៃការខាតបង់ណា ដែលគ្មានឯកសារបញ្ជាក់ អនុលោមតាមការធានារ៉ាប់រង ឬកិច្ចសន្យាធានានោះឡើយ។

## មាត្រា ១១
## ការបដិសេធផលប្រយោជន៍

១. ក្រោយសេចក្តីជូនដំណឹង ភាគីមួយអាចបដិសេធផលប្រយោជន៍នៃជំពូកនេះ ចំពោះ :

(ក) អ្នកវិនិយោគនៃភាគីមួយទៀត ដែលជានីតិបុគ្គលនៃភាគីនោះ និងចំពោះការវិនិយោគរបស់គេ បើសិនអ្នកវិនិយោគនៃភាគី មិនស្ថិតក្នុងកិច្ចព្រមព្រៀងធ្វើជាម្ចាស់កម្មសិទ្ធិ ឬត្រួតត្រាលើនីតិបុគ្គល ហើយនីតិបុគ្គលនេះ ពុំមានប្រតិបត្តិការធុរកិច្ចសំខាន់នៅក្នុងដែនដីនៃភាគីម្ខាងទៀតទេនោះ។

(ខ) អ្នកវិនិយោគនៃភាគីមួយទៀត ដែលជានីតិបុគ្គលនៃភាគីនោះ និងចំពោះការវិនិយោគរបស់គេ បើសិនអ្នកវិនិយោគនៃភាគីដែលបដិសេធផលប្រយោជន៍ធ្វើជាម្ចាស់កម្មសិទ្ធិ ឬត្រួតត្រាលើនីតិបុគ្គល ហើយនីតិបុគ្គលនេះ ពុំមានប្រតិបត្តិការធុរកិច្ចសំខាន់នៅក្នុងដែនដីនៃភាគីណា ក្រៅពីភាគីបដិសេធផលប្រយោជន៍ទេនោះ។

២. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ និងអនុលោមតាមសេចក្តីជូនដំណឹងជាមុន និងការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ប្រទេសថៃអាចបដិសេធផលប្រយោជន៍នៅក្នុងជំពូកនេះ ក្រោមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ខ្លួន ដែលកំពុងអនុវត្តពាក់ព័ន្ធនឹងការអនុញ្ញាត ការបង្កើត ការទិញ និងការពង្រីក ការវិនិយោគ ចំពោះអ្នកវិនិយោគ

នៃភាគីមួយទៀត ដែលជានីតិបុគ្គលនៃភាគីនោះ និងការវិនិយោគរបស់គេ ដោយប្រទេសថៃបង្ហាញថា នីតិបុគ្គលនោះត្រូវបានគ្រប់គ្រងកម្មសិទ្ធិ ឬត្រួតត្រាកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនៃភាគីមិនស្ថិតក្នុងកិច្ចព្រមព្រៀង ឬភាគីបដិសេធផលប្រយោជន៍។

៣. សំរាប់ករណីប្រទេសថៃ នីតិបុគ្គល គឺ :

(ក) **កាន់កាប់** ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនៃភាគីមួយ ឬភាគីមិនស្ថិតក្នុងកិច្ចព្រមព្រៀង ប្រសិនបើភាគហ៊ុនលើសពី ៥០% ឡើងទៅកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនេះ។

(ខ) **ត្រួតត្រា** ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលនៃភាគីមួយ ឬភាគីមិនស្ថិតក្នុងកិច្ចព្រមព្រៀង ប្រសិនបើបុគ្គលនេះមានសិទ្ធិអំណាច ដើម្បីតែងតាំងក្រុមប្រឹក្សាភិបាលរបស់ខ្លួនលើសពីពាក់កណ្តាល ឬក្រៅពីនេះ អាចដឹកនាំដោយស្របច្បាប់លើសកម្មភាពរបស់នីតិបុគ្គលនោះ។

៤. ក្រោយសេចក្តីជូនដំណឹង និងដោយពុំមានប៉ះពាល់ដល់កថាខ័ណ្ឌ ១ ប្រទេសហ្វីលីពីនអាចបដិសេធផលប្រយោជន៍នៃជំពូកនេះ ចំពោះអ្នកវិនិយោគនៃភាគីមួយទៀត និងចំពោះការវិនិយោគរបស់គេនៅពេលវាយតំលៃបានថា អ្នកវិនិយោគនោះបានធ្វើការវិនិយោគរំលោភទៅលើបញ្ញត្តិនៃច្បាប់រដ្ឋសភាធនលេខ ១០៨ ស្តី "An Act to Punish Acts of Evasion of Laws on the Nationalization of Certain Rights, Franchises, or Privileges" ដែលធ្វើវិសោធនកម្មដោយក្រឹត្យប្រធានាធិបតីលេខ ៧១៥ ត្រូវបានស្គាល់ថា ជាច្បាប់ "The Anti-Dummy Law" ដែលអាចត្រូវធ្វើវិសោធនកម្ម។

## មាត្រា ១២
## ការបំរុងទុក[១១]

១. មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) និងសំរាប់ករណីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៥ (ការហាមឃាត់នូវការតំរូវឱ្យបំពេញកាតព្វកិច្ច) មិនត្រូវអនុវត្តចំពោះ :

(ក) វិធានការមានស្រាប់ណាមួយ ដែលមិនស្របទៅនឹងមាត្រាទាំងនោះ ដែលត្រូវបានរក្សាទុកដោយភាគីមួយនៅ :

[១១] ការអនុវត្តនៃកិច្ចព្រមព្រៀងនេះ ធ្វើឡើងចំពោះមាត្រា១៦ ស្តីពី "កម្មវិធីការងារ"

(i) រដ្ឋាភិបាលថ្នាក់កណ្តាលដូចមានចែងដោយភាគីនោះ នៅក្នុងតារាងកាតព្វកិច្ចរបស់ខ្លួន ក្នុងបញ្ជីបំរុងទុក ១ (List I)

(ii) រដ្ឋាភិបាលថ្នាក់តំបន់ដូចមានចែងដោយភាគីនោះ នៅក្នុងតារាងកាតព្វកិច្ចរបស់ខ្លួន ក្នុងបញ្ជីបំរុងទុក ១ (List I) ឬ

(iii) រដ្ឋាភិបាលថ្នាក់មូលដ្ឋាន

(ខ) ការបន្ត ឬការពន្យារពេលជាបន្ទាន់នូវវិធានការណាមួយ យោងដល់អនុកថាខ័ណ្ឌ (ក), ឬ

(គ) ការធ្វើវិសោធនកម្មចំពោះវិធានការណាមួយ យោងដល់អនុកថាខ័ណ្ឌ (ក) ក្នុងលក្ខខណ្ឌដែលការធ្វើវិសោធនកម្មនេះ មិនធ្វើឱ្យចុះថយនូវភាពស្របគ្នានៃវិធានការមានស្រាប់នៅពេលតារាងកាតព្វកិច្ចមួយ នៃភាគីចូលជាធរមានជាមួយមាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) និងសំរាប់ករណីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៥ ស្តីពី (ការហាមឃាត់នូវការតំរូវឱ្យបំពេញកាតព្វកិច្ច) ។

២. មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) និងសំរាប់ករណីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៥ (ការហាមឃាត់នូវការតំរូវឱ្យបំពេញកាតព្វកិច្ច) មិនអនុវត្តចំពោះវិធានការណាមួយ ដែលភាគីមួយអនុម័ត ឬ រក្សាទុកពាក់ព័ន្ធនឹងវិស័យ អនុវិស័យ ឬសកម្មភាពផ្សេងៗ ដូចមានចែងក្នុងតារាងនៃបញ្ជី ២ (List II) របស់ខ្លួន ។

៣. ក្រៅពីអនុលោមតាមនីតិវិធីណាមួយនៃការកែសំរួលតារាងនៃបញ្ជីបំរុងទុក និងក្រោមវិធានការណាមួយ ដែលបានអនុម័តក្រោយកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ហើយគ្របដណ្តប់ដោយតារាងនៃបញ្ជី ២ ភាគីមួយមិនអាចតំរូវឱ្យអ្នកវិនិយោគនៃភាគីមួយទៀត ដោយសារហេតុផលសញ្ជាតិ ធ្វើការលក់ ឬរំលាយចោលការវិនិយោគដែលមានស្រាប់នៅពេលដែលវិធានការ នេះចូលជាធរមានបានឡើយ ។

## មាត្រា ១៣

## តម្លាភាព

១. ភាគីនីមួយៗ ត្រូវធ្វើការផ្សព្វផ្សាយជាប្រញាប់ យ៉ាងយឺតបំផុតនៅពេលវិធានការទាំងនេះ ចូលជាធរមាននូវរាល់វិធានការពាក់ព័ន្ធនឹងការអនុវត្តទូទៅ ដែលគ្របដណ្តប់ដោយជំពូកនេះ លើកលែងតែស្ថានភាពមានអាសន្ន។ រាល់កិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធ ឬប៉ះពាល់ដល់អ្នកវិនិយោគ ឬ សកម្មភាពវិនិយោគទាំងអស់ដែលភាគីមួយ ជាភាគីហត្ថលេខី ក៏គប្បីត្រូវធ្វើការផ្សព្វផ្សាយផងដែរ ។

២.	តាមលទ្ធភាពដែលអាចធ្វើទៅបានយោងកថាខ័ណ្ឌ ១ ភាគីនីមួយៗ ត្រូវផ្សព្វផ្សាយតាមប្រព័ន្ធអ៊ិនធឺណែត នូវរាល់វិធានការ និងកិច្ចព្រមព្រៀងអន្តរជាតិគ្រប់ប្រភេទ។

៣.	ក្នុងខណៈដែលការផ្សព្វផ្សាយ យោងកថាខ័ណ្ឌ ១ និងកថាខ័ណ្ឌ ២ មិនអាចអនុវត្តបាននោះ ភាគីទាំងអស់ត្រូវធ្វើយ៉ាងណាផ្សព្វផ្សាយព័ត៌មានទាំងនេះ[១២] ឱ្យបានជ្រួតជ្រាបជាសាធារណៈ តាមមធ្យោបាយដែលមានផ្សេងទៀត។

៤.	តាមលទ្ធភាពដែលអាចផ្តល់បានក្រោមក្របខ័ណ្ឌច្បាប់ក្នុងស្រុក និងយោងកថាខ័ណ្ឌ ១ ភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងផ្តល់នូវកាលានុវត្តភាពសមស្របដល់បុគ្គលពាក់ព័ន្ធ ដើម្បីធ្វើការផ្តល់មតិលើរាល់វិធានមុនពេលអនុម័ត។

៥.	ភាគីនីមួយៗ ត្រូវបង្កើតទីកន្លែងសំរាប់ទំនាក់ទំនងមួយ ដើម្បីសំរួលដល់ការប្រាស្រ័យទាក់ទងគ្នារវាងភាគីទាំងអស់ លើបញ្ហាណាមួយដែលគ្របដណ្តប់ដោយជំពូកនេះ។ យោងតាមសំណើរបស់ភាគីមួយទៀត ទីកន្លែងសំរាប់ទំនាក់ទំនងត្រូវ :

(ក)	កំណត់នូវការិយាល័យ ឬមន្ត្រីទទួលខុសត្រូវចំពោះបញ្ហាដែលពាក់ព័ន្ធ និង

(ខ)	ជួយតាមតំរូវការ ក្នុងការសំរបសំរួលការប្រាស្រ័យទាក់ទងជាមួយភាគីស្នើសុំពាក់ព័ន្ធនឹងបញ្ហានោះ។

៦.	ភាគីនីមួយៗ ត្រូវឆ្លើយតបរាល់សំណើទាំងអស់របស់ភាគីណាមួយផ្សេងទៀត ក្នុងពេលវេលាមួយសមស្រប នូវរាល់ពត៌មានច្បាស់លាស់អំពី :

(ក)	វិធានការ ឬកិច្ចព្រមព្រៀងអន្តរជាតិណាមួយ យោងកថាខ័ណ្ឌ ១

(ខ)	រាល់វិធានការថ្មី ឬការផ្លាស់ប្តូរណាមួយចំពោះវិធានការមានស្រាប់ ឬគោលការណ៍ណែនាំរដ្ឋបាលដែលពាក់ព័ន្ធខ្លាំងដល់អ្នកវិនិយោគ ឬដែនវិនិយោគ ថាតើភាគីផ្សេងទៀតបាន ឬមិនបានជូនដំណឹងជាមុន ស្តីអំពីវិធានការ ឬគោលការណ៍ណែនាំរដ្ឋបាលថ្មី ឬដែលបានផ្លាស់ប្តូរ។

៧.	សេចក្តីជូនដំណឹង ឬការប្រាស្រ័យទាក់ទងណាមួយជាភាសាអង់គ្លេសក្រោមមាត្រានេះ ត្រូវផ្តល់ដល់ភាគីផ្សេងទៀត តាមរយៈកន្លែងទំនាក់ទំនងព័ត៌មានដែលពាក់ព័ន្ធ។

---

[១២] ដើម្បីឱ្យកាន់តែប្រាកដ ភាគីទាំងអស់បានឯកភាពថា ព័ត៌មានប្រភេទនេះអាចត្រូវបានធ្វើការផ្សព្វ ផ្សាយជាភាសាដែលភាគីនីមួយៗ បានជ្រើសរើសយក។

៨. ពុំមានអ្វីនៅក្នុងមាត្រានេះ ត្រូវបានបកស្រាយថា ជាការតំរូវឱ្យភាគីមួយផ្តល់ព័តិមានសំងាត់ ដែលការផ្សព្វផ្សាយព័តិមាននេះ នឹងធ្វើឱ្យមានផលលំបាកដល់ការអនុវត្តច្បាប់ ឬម្យ៉ាងទៀតវាមានលក្ខណៈផ្ទុយនឹងផលប្រយោជន៏សាធារណៈ ឬវាប៉ះពាល់ដល់ផលប្រយោជន៏ធុរកិច្ចស្របច្បាប់នៃនីតិបុគ្គលផ្ទាល់ជាសាធារណៈ ឬឯកជននោះឡើយ ។

៩. ភាគីនីមួយៗ ត្រូវប្រាកដថា ក្នុងដំណើរការកាត់ក្តីផ្នែករដ្ឋបាលរបស់ខ្លួន ពាក់ព័ន្ធនឹងការអនុវត្តនូវវិធានការទាំងឡាយយោងកថាខ័ណ្ឌ ១ ចំពោះអ្នកវិនិយោគផ្ទាល់ ឬការវិនិយោគនៃភាគីផ្សេងទៀត សំរាប់ករណីច្បាស់លាស់ :

(ក) អ្វីដែលមានចែងក្រោមក្របខ័ណ្ឌច្បាប់ផ្ទៃក្នុងរបស់ខ្លួន និងអាចអនុវត្តបានចំពោះបុគ្គលនៃភាគីផ្សេងទៀត ដែលប៉ះពាល់ផ្ទាល់ដោយដំណើរការកាត់ក្តី ត្រូវបានផ្តល់នូវសេចក្តីជូនដំណឹងសមស្រប នៅពេលដែលដំណើរការកាត់ក្តីនេះចាប់ផ្តើម ។

(ខ) អ្វីដែលមានចែងក្រោមក្របខ័ណ្ឌច្បាប់ផ្ទៃក្នុងរបស់ខ្លួន ភាគីនីមួយៗត្រូវខិតខំផ្តល់កាលានុវត្តភាពសមស្របដល់អ្នកវិនិយោគនេះ ដើម្បីបង្ហាញឱ្យឃើញពីស្ថានភាពរបស់ពួកគេ មុនសកម្មភាពរដ្ឋបាលចុងក្រោយណាមួយ ត្រូវបានអនុវត្តនៅពេលដែលទំរង់ការរដ្ឋបាល និងផលប្រយោជន៏សាធារណៈអនុញ្ញាតឱ្យ, និង

(គ) រាល់នីតិវិធីទាំងឡាយ ត្រូវអនុលោមតាមច្បាប់របស់ខ្លួន ។

១០. ភាគីនីមួយៗ ត្រូវរក្សាទុកនូវនីតិវិធី ឬតុលាការរដ្ឋបាល ឬជំរះក្តីក្នុងគោលបំណងពិនិត្យឡើងវិញជាបន្ទាន់[១៣] និងកែតម្រូវសកម្មភាពរដ្ឋបាលចុងក្រោយ ពាក់ព័ន្ធនឹងបញ្ហាទាំងឡាយគ្របដណ្តប់ដោយជំពូកនេះ ។ នៅពេលដែលនីតិវិធី ឬតុលាការជំរះក្តីនៃស្ថាប័នទទួលបន្ទុកសកម្មភាពរដ្ឋបាលពាក់ព័ន្ធមិនមានលក្ខណៈឯករាជ្យនោះ ភាគីនីមួយៗត្រូវប្រាកដថា តុលាការ ឬនីតិវិធីកំណត់ចេញនូវការពិនិត្យឡើងវិញមានគោលដៅច្បាស់លាស់ និងមិនលំអៀង ។

១១. ភាគីនីមួយៗ ត្រូវប្រាកដថា ក្នុងនីតិវិធីតុលាការ ឬនីតិវិធីណាមួយ ភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងដំណើរការកាត់ក្តីនេះមានសិទ្ធិទទួលបាននូវ :

(ក) កាលានុវត្តភាពសមស្រប ដើម្បីគាំទ្រ ឬការពារនូវជំហររបស់គេ, និង

(ខ) សេចក្តីសំរេចដែលអនុលោមតាមច្បាប់របស់ភាគីនោះ

---

[១៣] ដើម្បីចៀសវាងការភ័ន្តច្រឡំ ទំរង់នៃ "ការពិនិត្យឡើងវិញ" ត្រូវធ្វើដូចដែលមានចែងនៅក្នុងច្បាប់របស់ភាគីទាំងអស់ ។

១២. ចំពោះការប្ដឹងឧទ្ធរណ៍ ឬការបន្តពិនិត្យឡើងវិញដូចមានចែងក្នុងច្បាប់របស់ខ្លួន ភាគីនីមួយៗ ត្រូវប្រាកដថា សេចក្ដីសំរេចណាមួយយោងកថាខ័ណ្ឌ ១១ (ខ) ត្រូវបានអនុវត្តស្របតាមច្បាប់របស់ខ្លួន។

## មាត្រា ១៤

## ទម្រង់ការពិសេស និងការចែកចាយព័ត៌មាន

១. ពុំមានអ្វីនៅក្នុងមាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) ត្រូវបានបកស្រាយ ដើម្បីរារាំងភាគីមួយពីការអនុម័ត ឬរក្សាទុកនូវវិធានបញ្ជាក់ច្បាស់ អំពីទំរង់ការពិសេសទាក់ទងនឹងដែនវិនិយោគ ដោយរាប់បញ្ចូលទាំង តំរូវការដែលដែនវិនិយោគនោះ ត្រូវបានបង្កើតឡើងស្របតាមច្បាប់ ឬបទប្បញ្ញត្តិនៃភាគីក្នុងលក្ខខ័ណ្ឌ ដែលទំរង់ការពិសេសនេះ មិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់កិច្ចការពារផ្ដល់ឱ្យដោយភាគីមួយចំពោះអ្នកវិនិយោគ និងដែនវិនិយោគនៃភាគីផ្សេងទៀត ស្របតាមជំពូកនេះ។

២. ថ្វីបើមានចែងក្នុងមាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) ភាគីមួយអាចតំរូវឱ្យអ្នកវិនិយោគ ឬដែនវិនិយោគនៃភាគីផ្សេងទៀត ផ្ដល់ពត៌មានពាក់ព័ន្ធនឹងការវិនិយោគ ដើម្បីគោលបំណងស្ថិតិ ឬពត៌មានតែប៉ុណ្ណោះ។ តាមលទ្ធភាពអាចធ្វើបាន ភាគីត្រូវការពារឱ្យបាននូវពត៌មានសំងាត់ក្នុងពេលដែលការផ្សព្វផ្សាយ នឹងធ្វើឱ្យប៉ះពាល់ផលប្រយោជន៍ធុរកិច្ចស្របច្បាប់នៃអ្នកវិនិយោគ ឬដែនវិនិយោគនោះ។ ពុំមានអ្វីនៅក្នុងកថាខ័ណ្ឌនេះត្រូវបានបកស្រាយ ដើម្បីរារាំងភាគីមួយពីការទទួល ឬផ្ដល់ពិតមាន ស្របតាមការអនុវត្តច្បាប់ប្រកបដោយសមធម៌ និងបំណងល្អនៃច្បាប់របស់ខ្លួននោះឡើយ។

## មាត្រា ១៥

## ប្រព្រឹត្តិកម្មពិសេស និងដោយឡែកសំរាប់រដ្ឋសមាជិកអាស៊ានថ្មី

ដើម្បីបង្កើនផលប្រយោជន៍នៃជំពូកនេះសំរាប់រដ្ឋជាសមាជិកអាស៊ានថ្មី និងអនុលោមតាមគោលបំណង និងបុព្វកថានៃកិច្ចព្រមព្រៀងនេះ និងគោលបំណងនៃជំពូក ១២ (សហប្រតិបត្តិការសេដ្ឋកិច្ច) ភាគីទាំងអស់ទទួលស្គាល់នូវសារៈសំខាន់នៃការផ្ដល់នូវប្រព្រឹត្តិកម្មពិសេស និងដោយឡែកនៅក្នុងជំពូកនេះ ចំពោះរដ្ឋជាសមាជិកអាស៊ានថ្មីតាមរយៈ :

(ក) ជំនួយបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពពួកគេ ទាក់ទងនឹងគោលនយោបាយ និងការជំរុញវិនិយោគ រួមទាំងវិស័យនានា ដូចជា ការអភិវឌ្ឍធនធានមនុស្ស

(ខ) ទទួលបាននូវពត៌មានស្ដីពីគោលនយោបាយវិនិយោគរបស់ភាគីផ្សេងទៀត ដូចជា ពត៌មានធុរកិច្ច ទិន្នន័យពាក់ព័ន្ធនឹងកន្លែងទំនាក់ទំនងពត៌មាន សំរាប់ភ្នាក់ងារជំរុញការវិនិយោគ ។

(គ) ការសន្យានានា ក្នុងក្របខ័ណ្ឌនៃផលប្រយោជន៍ចំពោះរដ្ឋសមាជិកអាស៊ានថ្មី, និង

(ឃ) ទទួលស្គាល់ថា ការសន្យាដោយរដ្ឋនីមួយៗជាសមាជិកអាស៊ានថ្មី អាចត្រូវបានធ្វើឡើង ដោយអនុលោមតាមដំណាក់កាលអភិវឌ្ឍរៀងៗខ្លួន ។

## មាត្រា ១៦

## កម្មវិធីការងារ

១. ភាគីទាំងអស់ ត្រូវពិភាក្សាលើ :

(ក) តារាងនៃបញ្ជីបំរុងទុកនៃជំពូកនេះ, និង

(ខ) ប្រព្រឹត្តកម្មវិនិយោគក្នុងសេវាកម្ម ដែលពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាវត្ថុមានពាណិជ្ជកម្មក្នុងជំពូក ៨ ស្ដីពី (ពាណិជ្ជកម្មសេវាកម្ម) ។

២. ភាគីទាំងអស់ ត្រូវពិភាក្សាផងដែរ ដើម្បីឯកភាពទស្សនៈគ្នាលើ :

(ក) ការអនុវត្តប្រព្រឹត្តិកម្មនៃប្រជាជាតិដែលមានលក្ខណៈអនុគ្រោះបំផុតក្នុងជំពូកនេះ រាប់បញ្ចូលទាំងតារាងនៃបញ្ជីបំរុងទុក, និង

(ខ) នីតិវិធីទាំងឡាយសំរាប់ការកែតម្រូវតារាងនៃបញ្ជីបំរុងទុក

៣. យោងកថាខ័ណ្ឌ ១ និងកថាខ័ណ្ឌ ២ ភាគីទាំងអស់ត្រូវបញ្ចប់ការពិភាក្សា ក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការព្រមព្រៀងគ្នាក្រៅពីនេះទេនោះ ។ ការពិភាក្សាទាំងនេះ ត្រូវបានពិនិត្យដោយគណៈកម្មាធិការវិនិយោគ ដែលបង្កើតឡើងស្របតាមមាត្រា ១៧ (គណៈកម្មាធិការវិនិយោគ) ។

៤.	យោងកថាខ័ណ្ឌ ១ តារាងនៃបញ្ជីបំរុងទុកក្នុងជំពូកនេះ ត្រូវចូលជាធរមាន នៅពេលមានការឯកភាពយល់ព្រមពីគ្រប់ភាគីទាំងអស់ ។

៥.	ថ្វីបើមានអ្វីមួយមានលក្ខណៈផ្ទុយក្នុងជំពូកនេះក៏ដោយ មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) និងមាត្រា ១២ (ការបំរុងទុក) មិនត្រូវអនុវត្តទេ រហូតទាល់តែតារាងនៃបញ្ជីបំរុងទុករបស់ភាគីទាំងអស់នៃជំពូកនេះ បានចូលជាធរមានសិន អនុលោមតាមកថាខ័ណ្ឌ ៤ ។

## មាត្រា ១៧

## គណៈកម្មាធិការវិនិយោគ

១.	តាមរយៈនេះ ភាគីទាំងអស់បង្កើតគណៈកម្មាធិការវិនិយោគ (គណៈកម្មាធិការវិនិយោគ) មួយដោយមានតំណាងពីគ្រប់ភាគីទាំងអស់ ។

២.	គណៈកម្មាធិការវិនិយោគត្រូវជួបប្រជុំគ្នាក្នុងកំឡុងពេលមួយឆ្នាំ ចាប់គិតពីកាលបរិច្ឆេទចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះ ហើយបន្ទាប់មក កិច្ចប្រជុំនេះនឹងត្រូវកំណត់ឡើងតាមការឯកភាពគ្នារវាងភាគីទាំងអស់ ។ កិច្ចប្រជុំនេះអាចធ្វើឡើងដោយផ្ទាល់ ឬដោយមធ្យោបាយផ្សេងទៀតតាមការឯកភាពគ្នារវាងភាគីទាំងអស់ ។

៣.	គណៈកម្មាធិការវិនិយោគ ត្រូវមានភារកិច្ច :

(ក)	ត្រួតពិនិត្យការពិភាក្សា យោងមាត្រា ១៦.១ និងមាត្រា ១៦.២ (កម្មវិធីការងារ)

(ខ)	ពិនិត្យឡើងវិញការអនុវត្តនៅក្នុងជំពូកនេះ

(គ)	ពិចារណាលើបញ្ហាផ្សេងទៀតទាក់ទងនឹងជំពូកនេះ ដែលកំណត់ដោយភាគីទាំងអស់ និង

(ឃ)	ធ្វើរបាយការណ៍ទៅគណៈកម្មាធិការចម្រុះនៃតំបន់ពាណិជ្ជកម្មសេរី ប្រសិនបើមានតំរូវការ ។

## ផ្នែក ខ
## វិវាទវិនិយោគរវាងភាគី និងវិនិយោគិនមួយ

### មាត្រា ១៨
### វិសាលភាព និងនិយមន័យ

១. ជំពូកនេះ ត្រូវអនុវត្តចំពោះវិវាទរវាងភាគីមួយ និងអ្នកវិនិយោគនៃភាគីមួយទៀត ដែលមានការពាក់ព័ន្ធដល់ការចោទប្រកាន់ពីបទរំលោភនូវកាតព្វកិច្ចរបស់ភាគីក្នុងផ្នែក (ក) ដែលបណ្តាលឱ្យមានការខាតបង់ ឬ ខូចខាតដល់ដែនវិនិយោគនៃអ្នកវិនិយោគ ។

២. ជំពូកនេះ មិនអនុវត្តចំពោះវិវាទវិនិយោគដែលកើតឡើង មុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះទេ ។

៣. រូបវន្តបុគ្គលដែលមានសញ្ជាតិ ឬទទួលបានសញ្ជាតូបនីយកម្មនៃភាគីមួយ មិនអាចដាក់បណ្តឹងតវ៉ាប្រឆាំងនឹងភាគីនោះ នៅក្នុងផ្នែកនេះឡើយ ។

៤. សំរាប់គោលបំណងនៃផ្នែកនេះ :

(ក) **អាជ្ញាធរតែងតាំង** មានន័យថា :

(i) សំរាប់ករណីមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ២១.១ (ខ) ឬ (គ) (ការដាក់បណ្តឹងទាមទារ) អគ្គលេខាធិការនៃមជ្ឈមណ្ឌលអន្តរជាតិ សំរាប់ដោះស្រាយវិវាទវិនិយោគ ICSID

(ii) សំរាប់ករណីនៃមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ២១.១ (ឃ) ឬ (ង) (ការដាក់បណ្តឹងទាមទារ) អគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តវិនិច្ឆ័យ ឬ

(iii) បុគ្គលណាមួយ ដែលមានការឯកភាពគ្នារវាងភាគីមានវិវាទ

(ខ) **ភាគីមានវិវាទ** មានន័យថា ភាគីប្រឆាំងជំទាស់ដែលបណ្តឹងទាមទារត្រូវបានធ្វើនៅក្រោមផ្នែកនេះ

(គ) **ភាគីមានវិវាទ** មានន័យថា អ្នកវិនិយោគមានវិវាទមួយ ឬ ភាគីមានវិវាទមួយ

(ឃ) **ភាគីនានាមានវិវាទ** មានន័យថា អ្នកវិនិយោគមានវិវាទមួយ និង ភាគីមានវិវាទមួយ

(ង) **អ្នកវិនិយោគមានវិវាទ** មានន័យថា អ្នកវិនិយោគនៃភាគីមួយធ្វើបណ្តឹងក្នុងនាមផ្ទាល់ខ្លួន ប្រឆាំងនឹងភាគីមួយទៀតក្រោមផ្នែកនេះ និងផ្នែកពាក់ព័ន្ធឯទៀត រាប់បញ្ចូលទាំងអ្នកវិនិយោគនៃភាគីមួយដែលធ្វើបណ្តឹងក្នុងនាមនីតិបុគ្គលនៃភាគីមានវិវាទ ដែលអ្នកវិនិយោគកាន់កាប់ ឬត្រួតត្រា។

(ច) ICSID មានន័យថា មជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ

(ឆ) ICSID Convention មានន័យថា អនុសញ្ញាស្តីពីការដោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋដទៃទៀត ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៦៥ នៅទីក្រុងវ៉ាស៊ីនតោន

(ជ) ICSID Additional Facility Rules មានន័យថា វិធានគ្រប់គ្រងយន្តការបន្ថែមសំរាប់រដ្ឋបាល នៃដំណើរការក្តី ដោយលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ

(ឈ) non- disputing Party មានន័យថា ភាគីមួយនៃអ្នកវិនិយោគកំពុងមានវិវាទ

(ញ) New York Convention មានន័យថា អនុសញ្ញាទីក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការអនុវត្តសាលក្រមមជ្ឈត្តវិនិច្ឆ័យបរទេស ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី១០ ខែ មិថុនា ឆ្នាំ ១៩៥៨, និង

(ច) UNCITRAL Arbitration Rules មានន័យថា វិធានមជ្ឈត្តវិនិច្ឆ័យនៃគណៈកម្មការអង្គការសហប្រជាជាតិ ស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ អនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៧៦។

## មាត្រា ១៩

## ការពិគ្រោះយោបល់

១. ក្នុងព្រឹត្តិការណ៍ដែលវិវាទវិនិយោគ យោងមាត្រា ១៨.១ (វិសាលភាព និងនិយមន័យ) ភាគីមានវិវាទទាំងអស់ត្រូវដោះស្រាយឱ្យអស់លទ្ធភាពតាមដែលអាចធ្វើទៅបាន តាមរយៈការពិគ្រោះយោបល់ក្នុងគោលដៅសំរេចឱ្យបាននូវដំណោះស្រាយប្រកបដោយមិត្តភាព។ ការពិគ្រោះយោបល់នេះ អាចរួមបញ្ចូលទាំងការប្រើប្រាស់នូវនីតិវិធី នៃភាគីទីបី ដែលពុំមែនជាការចាប់បង្ខំ ត្រូវផ្តើមចេញពីសំណើជាលាយលក្ខណ៍អក្សរ សំរាប់ការពិគ្រោះយោបល់របស់អ្នកវិនិយោគមានវិវាទជូនទៅភាគីមានវិវាទ។

២.	ក្នុងគោលបំណងដោះស្រាយវិវាទវិនិយោគ តាមរយៈការពិគ្រោះយោបល់ វិនិយោគិនមានវិវាទត្រូវផ្តល់ព័ត៌មានទាក់ទងនឹងច្បាប់ និងអង្គហេតុសំរាប់វិវាទវិនិយោគជូនភាគីមានវិវាទ មុនការចាប់ផ្តើមនៃការពិគ្រោះយោបល់ ។

## មាត្រា ២០

## បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ

យោងតាមមាត្រានេះ ប្រសិនបើវិវាទវិនិយោគមិនត្រូវបានដោះស្រាយក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណើសុំធ្វើការពិគ្រោះយោបល់ដោយភាគីមានវិវាទ អ្នកវិនិយោគមានវិវាទអាចដាក់សំណើធ្វើការផ្សះផ្សា ឬមជ្ឈត្តវិនិច្ឆ័យនូវបណ្តឹងទាមទារថា :

(ក)	ភាគីមានវិវាទខកខានមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ៤ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៦ (ប្រព្រឹត្តិកម្មវិនិយោគ) មាត្រា ៧ (សំណងចំពោះការខាតបង់) មាត្រា ៨ (ការផ្ទេរ) និងមាត្រា ៩ (ការដកហូត និងសំណង) ពាក់ព័ន្ធដល់ការគ្រប់គ្រង ការដឹកនាំ ការប្រតិបត្តិ ឬលក់ ឬការរំលាយដទៃទៀត នៃដែនវិនិយោគ, និង

(ខ)	អ្នកវិនិយោគមានវិវាទ ឬដែនវិនិយោគបានរងការបាត់បង់ ឬខូចខាតដោយមូលហេតុមកពីការខកខានមិនបានបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យា ។

## មាត្រា ២១

## ការដាក់បណ្តឹងទាមទារ

១.	អ្នកវិនិយោគមានវិវាទអាចដាក់បណ្តឹងទាមទារ យោងមាត្រា ២០ (បណ្តឹងទាមទារដោយអ្នកវិនិយោគ នៃភាគីមួយ) តាមជំរើសរបស់អ្នកវិនិយោគមានវិវាទ :

(ក)	ទៅតុលាការ ឬសាលាជំរះក្តីនៃភាគីនោះ ប្រសិនបើតុលាការ ឬសាលាជំរះក្តីនោះ មានយុត្តាធិការគ្រប់ដណ្តប់លើបណ្តឹងទាមទារប្រភេទនេះ ខណៈដែលប្រទេសហ្វីលីពីន ឬប្រទេសវៀតណាម ជាភាគីមានវិវាទ ឬ

(ខ) ក្រោមអនុសញ្ញា ICSID និងវិធាន ICSID នៃនីតិវិធីសំរាប់ដំណើរការក្តីមជ្ឈត្តវិនិច្ឆ័យ[១៤] ប្រសិនបើ ភាគីមានវិវាទ និងភាគីមិនមានវិវាទនោះ ជាភាគីនៃអនុសញ្ញា ICSID ឬ

(គ) ក្រោមវិធានយន្តការបន្ថែមនៃមជ្ឈមណ្ឌលអន្តរជាតិ សំរាប់ដោះស្រាយវិវាទវិនិយោគ (ICSID Additional Facility Rules) ប្រសិនបើ ភាគីមានវិវាទ ឬភាគីមិនមានវិវាទជាភាគីនៃអនុសញ្ញា ICSID ឬ

(ឃ) ក្រោមវិធានមជ្ឈត្តវិនិច្ឆ័យនៃ UNCITRAL (UNCITRAL Arbitration Rules) ឬ

(ង) ប្រសិនបើ ភាគីមានវិវាទយល់ព្រមទៅរកស្ថាប័នមជ្ឈត្តវិនិច្ឆ័យ ឬក្រោមវិធានមជ្ឈត្តវិនិច្ឆ័យដទៃទៀត ក្រោមលក្ខខ័ណ្ឌថា ការសំរេចរបស់វេទិកាមជ្ឈត្តវិនិច្ឆ័យណាមួយ ក្រោមអនុកថាខ័ណ្ឌ (ក) ដល់ (ង) មិនរាប់បញ្ចូលនូវការសំរេចរបស់មជ្ឈត្តវិនិច្ឆ័យណាមួយផ្សេងទៀតឡើយ ។

២. បណ្តឹងទាមទារមួយត្រូវបានចាត់ទុកថា បានដាក់ជូនទៅមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រានេះ នៅពេលដែលការជូនដំណឹងរបស់អ្នកវិនិយោគមានវិវាទ ឬសំណើសុំសំរាប់មជ្ឈត្តវិនិច្ឆ័យធ្វើឡើង អនុលោមតាមផ្នែកនេះ (សេចក្តីជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យ) ត្រូវបានទទួលក្រោមវិធានមជ្ឈត្តវិនិច្ឆ័យដែលកំពុងអនុវត្ត ។

៣. វិធានមជ្ឈត្តវិនិច្ឆ័យកំពុងអនុវត្តក្រោមកថាខ័ណ្ឌ ១(ខ) ដល់ (ង) មានប្រសិទ្ធភាពនៅថ្ងៃដែលបណ្តឹងទាមទារ ត្រូវបានដាក់ជូនសុំធ្វើមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រានេះ លើកលែងតែមានការកែតម្រូវណាមួយក្នុងផ្នែកនេះ ។

៤. ទាក់ទងនឹងវិវាទវិនិយោគជាក់លាក់ ឬលំដាប់ថ្នាក់នៃវិវាទ វិធានមជ្ឈត្តវិនិច្ឆ័យកំពុងអនុវត្ត អាចត្រូវបានបដិសេធ ផ្លាស់ប្តូរ ឬកែតម្រូវ ដោយកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សររវាងភាគីមានវិវាទ ។ វិធានទាំងនោះ ត្រូវបានគោរពដោយសាលាជំរះក្តីពាក់ព័ន្ធ ឬសាលាជំរះក្តី ដែលបានបង្កើតឡើង អនុលោមតាមផ្នែកនេះ និងដោយមជ្ឈត្តករផ្ទាល់ដែលបំរើការងារនៅក្នុងសាលាជំរះក្តីនោះ ។

៥. អ្នកវិនិយោគមានវិវាទ ត្រូវផ្តល់ជូនមជ្ឈត្តវិនិច្ឆ័យនូវការប្រកាសអំពី :

(ក) ឈ្មោះនៃមជ្ឈត្តករដែលអ្នកវិនិយោគមានវិវាទតែងតាំង ឬ

---

[១៤] ករណីប្រទេសហ្វីលីពីន ការដាក់បណ្តឹងទាមទារក្រោមអនុសញ្ញា ICSID និង ICSID Rules of Procedure for Arbitration Proceeding ត្រូវមានការយល់ព្រមជាលាយល័ក្ខអក្សររវាងភាគីមានវិវាទ ក្នុងព្រឹត្តិការណ៍ដែលកើតមាន វិវាទវិនិយោគ ។

(ខ) ការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកវិនិយោគមានវិវាទ សំរាប់អាជ្ញាធរមានសមត្ថកិច្ច ធ្វើការតែងតាំងមជ្ឈត្តករនោះ ។

## មាត្រា ២២
## លក្ខខណ្ឌ និងការកំរិតស្តីពីការដាក់ពាក្យបណ្តឹងទាមទារ

១. អនុលោមតាមផ្នែកនេះ ការដាក់បណ្តឹងទាមទារនៃវិវាទដែលមានចែងក្នុងមាត្រា ២០ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ) ដើម្បីផ្សះផ្សា ឬធ្វើមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ២១.១ (ខ) ដល់ (ង) (ការដាក់បណ្តឹងទាមទារ) ត្រូវធ្វើតាមលក្ខខណ្ឌដូចតទៅ :

(ក) ការដាក់សំណើនៃវិវាទវិនិយោគដើម្បីផ្សះផ្សា ឬធ្វើមជ្ឈត្តវិនិច្ឆ័យក្នុងរង្វង់ ៣ ឆ្នាំ ចាប់ពីពេលដែលអ្នកវិនិយោគមានវិវាទបានដឹង ឬទទួលដំណឹងដោយសមហេតុផលអំពីការខកខានមិនបានបំពេញកាតព្វកិច្ច យោងមាត្រា ២០ (ក) (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ) ដែលបណ្តាលឱ្យមានការបាត់បង់ ឬខូចខាតដល់អ្នកវិនិយោគមានវិវាទ ឬដែនវិនិយោគ ។

(ខ) អ្នកវិនិយោគមានវិវាទ ផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដែលត្រូវបានដាក់ជូនយ៉ាងតិចរយៈពេល ៩០ថ្ងៃ មុនពេលបណ្តឹងទាមទារត្រូវបានដាក់ជូនភាគីមានវិវាទ ក្នុងគោលបំណងដាក់វិវាទវិនិយោគនេះ ធ្វើការផ្សះផ្សា ឬធ្វើមជ្ឈត្តវិនិច្ឆ័យ ហើយដែលត្រូវធ្វើការសង្ខេបពីការចោទប្រកាន់អំពីការខកខានមិនបានបំពេញកាតព្វកិច្ចនៃភាគីមានវិវាទ (រាប់បញ្ចូលទាំង មាត្រា ឬបញ្ញត្តិ ដែលបានចោទប្រកាន់ថា បានខកខាន មិនបំពេញកាតព្វកិច្ចផង) និងការបាត់បង់ ឬការខូចខាតដែលប៉ះពាល់ដល់អ្នកវិនិយោគមានវិវាទ ឬដែនវិនិយោគ, និង

(គ) ការជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យ អមដោយបណ្តឹងជាលាយលក្ខណ៍អក្សររបស់អ្នកវិនិយោគ មានវិវាទស្តីពីការលើកលែងសិទ្ធិរបស់ខ្លួន ដើម្បីចាប់ផ្តើម ឬបន្តដំណើរការកាត់ក្តីណាមួយនៅមុខតុលាការ ឬតុលាការរដ្ឋបាលនៃភាគីណាមួយ ឬនីតិវិធីដោះស្រាយវិវាទផ្សេងទៀតនៃដំណើរការក្តីណាមួយ ពាក់ព័ន្ធនឹងវិធានការណាមួយ ដែលអះអាងថា មានករណីរំលោភ យោងតាមមាត្រា ២០ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ) ។

២.	ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ (គ) ពុំមានភាគីណាមួយត្រូវរារាំងអ្នកវិនិយោគមានវិវាទពីការផ្តួចផ្តើម ឬបន្ត សកម្មភាពស្វែងរកវិធានការអន្តរកាលនៃការការពារ សំរាប់គោលបំណងទោលនៃការការពារនូវសិទ្ធិ និងប្រយោជន៍ របស់ខ្លួន ព្រមទាំងគ្មានពាក់ព័ន្ធនឹងការទូទាត់នៃការខូចខាត ឬដំណោះស្រាយនៃបញ្ហាក្នុងវិវាទឡើយ នៅមុខតុលាការ ឬតុលាការរដ្ឋបាលនៃភាគីមានវិវាទ។

៣.	ពុំមានភាគីណាមួយ ត្រូវផ្តល់ការការពារជាលក្ខណៈការទូត ឬនាំយកបណ្តឹងទាមទារជាលក្ខណៈអន្តរជាតិ ពាក់ព័ន្ធនឹងវិវាទមួយ ដែលបានដាក់ជូនធ្វើការផ្សះផ្សា ឬមជ្ឈត្តវិនិច្ឆ័យនៅក្រោមមាត្រានេះឡើយ លុះត្រាតែភាគី ម្ខាងទៀតខកខានក្នុងការប្រព្រឹត្ត និងគោរពតាមសាលក្រម ដែលបានប្រកាសក្នុងវិវាទនេះ។ សំរាប់គោលបំណងនៃ កថាខ័ណ្ឌនេះ ការការពារជាលក្ខណៈការទូតមិនត្រូវរាប់បញ្ចូលផងទេ នូវការផ្លាស់ប្តូរយោបល់ខាងការទូតមិនផ្លូវការ សំរាប់គោលបំណងទោលនៃការសំរួលដំណោះស្រាយវិវាទនេះ។

៤.	ភាគីមានវិវាទ មិនត្រូវអះអាងជាការការពារខ្លួន ជាបណ្តឹងតប ជាសិទ្ធិទាមទារការទូទាត់ ឬករណីផ្សេងៗ ទៀតឡើយថា អ្នកវិនិយោគមានវិវាទ ឬដែនវិនិយោគបានទទួល ឬនឹងទទួលយោងតាមកិច្ចសន្យាធានារ៉ាប់រង ឬកិច្ច សន្យាផ្តល់ការធានានូវសំណងជំងឺចិត្ត ឬការសងទាំងអស់ ឬជាផ្នែកនៃការខាតបង់ផ្សេងៗទៀត។

## មាត្រា ២៣
## ការជ្រើសរើសមជ្ឈត្តករ

១.	លើកលែងតែភាគីមានវិវាទមិនយល់ព្រម ក្រៅពីនេះតុលាការជំរះក្តីត្រូវមានមជ្ឈត្តករ ចំនួនបីរូប :

(ក)	ភាគីមានវិវាទនីមួយៗ ត្រូវតែងតាំងមជ្ឈត្តករមួយរូប និង

(ខ)	មជ្ឈត្តករទី៣ ដែលត្រូវជាមជ្ឈត្តករអធិបតី និងដែលតែងតាំងដោយមានការឯកភាពពីភាគីមាន វិវាទទាំងអស់ ត្រូវជាប្រជាជននៃភាគីមិនមែនសមាជិក ដែលមានចំណងការទូតជាមួយភាគីមាន វិវាទ និងភាគីមិនមានវិវាទ និងមិនមានទីលំនៅអចិន្ត្រៃយ៍ក្នុងទឹកដីភាគីមានវិវាទ ឬភាគីមិនមាន វិវាទទេ។

២.	មជ្ឈត្តករទាំងអស់ ត្រូវមានជំនាញឯកទេស ឬបទពិសោធន៍ក្នុងវិស័យច្បាប់អន្តរជាតិសាធារណៈ ច្បាប់ពាណិ ជ្ជកម្មអន្តរជាតិ ឬវិធាននានានៃការវិនិយោគអន្តរជាតិ ហើយមានឯករាជ្យភាព មិនមានការពាក់ព័ន្ធជាមួយ ឬទទួល យកការណែនាំពីភាគីមានវិវាទ ភាគីមិនមានវិវាទ ឬអ្នកវិនិយោគមានវិវាទឡើយ។

៣. អាជ្ញាធរទទួលការតែងតាំង ត្រូវបំពេញតួនាទីជាអាជ្ញាធរតែងតាំងសំរាប់ការធ្វើមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រានេះ ។

៤. ប្រសិនបើតុលាការជំរះក្តី មិនអាចបង្កើតបានក្នុងរយៈពេល ៧៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលបណ្តឹងទាមទារ ត្រូវបានប្រគល់ជូនទៅមជ្ឈត្តវិនិច្ឆ័យស្ថិតក្រោមផ្នែកនេះ អាជ្ញាធរទទួលការតែងតាំងដែលមានអំណាចឆន្ទានុសិទ្ធិ ត្រូវជ្រើសតាំងមជ្ឈត្តករមួយរូប ឬច្រើនរូបដែលមិនធ្លាប់បានតែងតាំងពីមុនមកតាមការស្នើសុំរបស់ភាគីមានវិវាទ ។

៥. ភាគីមានវិវាទទាំងឡាយ អាចបង្កើតវិធាននានាពាក់ព័ន្ធ និងចំណាយក្នុងដំណើរការកាត់ក្តី ដោយរាប់បញ្ចូលទាំងលាភការរបស់មជ្ឈត្តករផងដែរ ។

៦. នៅពេលមជ្ឈត្តករណាមួយ ដែលបានតែងតាំងដូចមានចែងក្នុងមាត្រានេះ សុំលាលែង ឬ អសមត្ថភាពក្នុងការបំពេញការងារ អ្នកស្នងត្រូវបានតែងតាំងក្នុងលក្ខខណ្ឌដូចគ្នា ដូចមានចែងក្នុងការតែងតាំងនៃមជ្ឈត្តករដើម ហើយអ្នកស្នងនេះត្រូវមានសិទ្ធិនិងករណីយកិច្ចទាំងអស់របស់មជ្ឈត្តករដើម ។

## មាត្រា ២៤
## ការរួមបញ្ចូលគ្នា

ពេលដែលបណ្តឹងទាមទារពីរ ឬក៏ច្រើន ត្រូវបានដាក់ចូលដោយឡែកពីគ្នាទៅមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ២០ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ) និងបណ្តឹងទាមទារទាំងឡាយមានបញ្ហាច្បាប់ ឬអង្គហេតុជារួម និងកើតឡើងក្នុងព្រឹត្តិការណ៍ឬកាលៈទេសៈតែមួយ ឬប្រហាក់ប្រហែលគ្នា គ្រប់ភាគីមានវិវាទដែលពាក់ព័ន្ធ អាចយល់ព្រមបង្រួបបង្រួមនូវបណ្តឹងទាមទារទាំងនោះក្នុងស្ថានភាពណាមួយ ដែលគេយល់ឃើញថាសមរម្យ ។

## មាត្រា ២៥
## ការប្រព្រឹត្តនៃមជ្ឈត្តវិនិច្ឆ័យ

១. ពេលបញ្ហាពាក់ព័ន្ធ និងយុត្តាធិការ ឬការអនុញ្ញាតបានត្រូវបានគេលើកឡើងជាការជំទាស់បឋមនោះតុលាការជំរះក្តីត្រូវសំរេចលើអង្គហេតុមុននឹងគិតពីអង្គច្បាប់ ។

២. រយៈពេល ៣០ ថ្ងៃយ៉ាងយូរក្រោយពេលកំណត់បាននូវតុលាការជំរះក្តី ភាគីមានវិវាទអាចប្តឹងជំទាស់ថាបណ្តឹងទាមទារជាករណីលើកឡើងគ្មានអង្គច្បាប់ ។ ភាគីមានវិវាទក៏អាចប្តឹងជំទាស់ដែរថាបណ្តឹងទាមទារ គឺនៅក្រៅ

យុត្តាធិការ ឬក្រៅសមត្ថកិច្ចនៃតុលាការជំរះក្តី។ ភាគីមានវិវាទត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ តាមដែលអាចធ្វើទៅបាននូវមូលដ្ឋាននៃការជំទាស់។

៣. តុលាការជំរះក្តី ត្រូវដោះស្រាយបណ្តឹងជំទាស់ណាមួយជាសំណួរបឋម ក្រៅពីអង្គច្បាប់នៃបណ្តឹងទាមទារ។ ភាគីមានវិវាទទាំងអស់ ត្រូវបានផ្តល់នូវកាលានុវត្តភាពដ៏សមហេតុផលមួយ ដើម្បីបង្ហាញពីទស្សនៈ និងការសង្កេតរបស់ពួកគេចំពោះតុលាការជំរះក្តី។ ប្រសិនបើតុលាការជំរះក្តីសំរេចថា បណ្តឹងទាមទារដែលលើកឡើង គ្មានអង្គច្បាប់ ឬថាបណ្តឹងទាមទារមិននៅក្នុងយុត្តាធិការ ឬសមត្ថកិច្ចនៃតុលាការជំរះក្តីទេ តុលាការជំរះក្តីត្រូវសំរេចក្តីទៅតាមនោះ។

៤. ប្រសិនបើមានការធានា តុលាការជំរះក្តីអាចសំរេចឱ្យភាគីឈ្នះនូវថ្លៃសមហេតុផល និងកំរៃដែលកើតឡើងក្នុងការដាក់ពាក្យ ឬការប្រឆាំងជំទាស់។ ក្នុងការកំណត់ថា ការសំរេចនោះត្រូវបានធានា ឬយ៉ាងណានោះ តុលាការជំរះក្តីត្រូវពិចារណាថា តើបណ្តឹងទាមទារ ឬបណ្តឹងជំទាស់ជាករណីមិនអាចយកជាការបាន ឬគ្មានពាក់ព័ន្ធអង្គច្បាប់ ហើយត្រូវផ្តល់ឱ្យភាគីមានវិវាទនូវកាលានុវត្តភាពសមហេតុផលមួយ ដើម្បីផ្តល់មតិ។

៥. លើកលែងតែភាគីមានវិវាទទាំងអស់មិនយល់ព្រម ក្រៅពីនេះ តុលាការជំរះក្តីត្រូវកំណត់ទីកន្លែងនៃមជ្ឈត្តវិនិច្ឆ័យអនុលោមតាមវិធានមជ្ឈត្តវិនិច្ឆ័យដែលកំពុងអនុវត្ត ក្នុងលក្ខខណ្ឌដែលទីកន្លែងនោះត្រូវស្ថិតក្នុងដែនដីនៃរដ្ឋមួយ ដែលជាភាគីនៃអនុសញ្ញាទីក្រុងញូវយ៉ក (New York Convention)។

៦. នៅពេលអ្នកវិនិយោគដាក់បណ្តឹងទាមទារថា ភាគីមានវិវាទបានរំលោភលើមាត្រា ៩ (ការដកហូត និងសំណង) ដោយការអនុម័ត ឬការអនុវត្តវិធានការពន្ធដារនោះ ភាគីមានវិវាទ និងភាគីមិនមានវិវាទនៅពេលបានទទួលសំណើពីភាគីមានវិវាទ ត្រូវរៀបចំកិច្ចពិគ្រោះយោបល់គ្នាមួយដើម្បីកំណត់ថា វិធានការពន្ធដារ ដែលចោទជាបញ្ហានោះ មានផលប៉ះពាល់សមមូលទៅនឹងការដកហូត ឬការធ្វើជាតូបនីយកម្មដែរឬទេ។ តុលាការជំរះក្តីមួយ ដែលអាចត្រូវបានបង្កើតឡើងអនុលោមតាមផ្នែកនេះ ត្រូវពិនិត្យពិចារណាដោយយកចិត្តទុកដាក់ចំពោះសេចក្តីសំរេចនៃភាគីទាំងពីរក្រោមកថាខ័ណ្ឌនេះ។

៧. ប្រសិនបើភាគីទាំងពីរ ខកខានក្នុងការផ្តួចផ្តើមការពិគ្រោះយោបល់យោងតាមកថាខ័ណ្ឌ ៦ ឬខកខានក្នុងការកំណត់ថា តើវិធានការពន្ធដារនេះ មានផលប៉ះពាល់សមមូលនឹងការដកហូត ឬការធ្វើជាតូបនីយកម្ម ក្នុងរយៈពេល ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណើសុំពិគ្រោះយោបល់យោងតាមមាត្រា ១៥ (ការពិគ្រោះយោបល់) ដែរឬទេ នោះអ្នកវិនិយោគមានវិវាទមិនត្រូវបានរារាំងពីការដាក់បណ្តឹងទាមទាររបស់ខ្លួនទៅមជ្ឈត្តវិនិច្ឆ័យ អនុលោមតាមផ្នែកនេះឡើយ។

## មាត្រា ២៦
## តម្លាភាពនៃដំណើរក្តីរបស់មជ្ឈត្តវិនិច្ឆ័យ

១. ផ្អែកតាមកថាខ័ណ្ឌ ២ និង ៣ ភាគីមានវិវាទអាចផ្តល់ពត៌មានជាសាធារណៈអំពីសាលក្រម និងសេចក្តីសំរេចរបស់សាលាជំរះក្តី ។

២. ភាគីមានវិវាទណាមួយ ដែលមានបំណងប្រើប្រាស់ព័ត៌មានដែលជាពត៌មានសំងាត់ក្នុងការកាត់សេចក្តី ត្រូវតែប្រឹក្សាជាមួយសាលាជំរះក្តី ។ សាលាជំរះក្តី ត្រូវធ្វើការរៀបចំឱ្យបានសមរម្យ ដើម្បីការពារពត៌មានពីការផ្សព្វផ្សាយ ជាសាធារណៈ ។

៣. ពត៌មានណាមួយដែលបានកំណត់ជាក់លាក់ថា ជាពត៌មានសំងាត់ ហើយបានផ្ញើជូនទៅសាលាជំរះក្តី ឬភាគីមានវិវាទ ត្រូវបានការពារពីការផ្សព្វផ្សាយជាសាធារណៈ ។

៤. ភាគីមានវិវាទ អាចផ្តល់ទៅបុគ្គលផ្សេងទៀត ដោយផ្ទាល់នូវពត៌មានសំងាត់ទាក់ទងនឹងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យដែលមានសារៈសំខាន់សំរាប់ការរៀបចំនៃរឿងក្តីនោះ ប៉ុន្តែពត៌មានសំងាត់ទាំងនោះត្រូវបានការពារ ។

៥. សាលាជំរះក្តី នឹងមិនតម្រូវឱ្យភាគីមួយផ្តល់ ឬអនុញ្ញាតឱ្យទទួលបាននូវពត៌មាន ដែលការផ្សព្វផ្សាយជាសាធារណៈនូវពត៌មាននោះនឹងរាំងស្ទះដល់ការអនុវត្តច្បាប់ ឬផ្ទុយនឹងការសំងាត់របស់រដ្ឋាភិបាលស្តីពីច្បាប់ការពារ ភាគីភាពជាឯកជនរបស់បុគ្គល ឬកិច្ចការហិរញ្ញវត្ថុ និងគណនីនៃអតិថិជន ឯកត្តជននៃស្ថាប័នហិរញ្ញវត្ថុ ឬអ្វីដែលសាលាជំរះក្តីកំណត់ថា មានភាពផ្ទុយទៅនឹងសន្តិសុខជាសារៈសំខាន់របស់គេនោះឡើយ ។

៦. ភាគីមិនមានវិវាទ ត្រូវបានផ្តល់សិទ្ធិ ដើម្បីទទួលបាននូវអត្ថបទចំលងនៃសេចក្តីប្រកាសរបស់មជ្ឈត្តវិនិច្ឆ័យ ពីភាគីមានវិវាទ មិនលើសពី ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលឯកសារនោះ ត្រូវបានបញ្ជូនទៅឱ្យភាគីមានវិវាទ ដោយរ៉ាប់រងចំណាយខ្លួនឯង ។ ភាគីមានវិវាទត្រូវជូនដំណឹងទៅគ្រប់ភាគីដទៃទៀត ពីការទទួលបាននូវសេចក្តីជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យ ក្នុងរយៈពេល ៣០ ថ្ងៃ ។

## មាត្រា ២៧
## ច្បាប់គ្រប់គ្រង

១. ផ្អែកតាមកថាខ័ណ្ឌ ២ និង ៣ ពេលបណ្តឹងទាមទារត្រូវបានដាក់ជូនក្រោមមាត្រា ២០ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃភាគីមួយ) សាលាជំរះក្តី ត្រូវសំរេចបញ្ហាវិវាទ អនុលោមតាមកិច្ចព្រមព្រៀងនេះ តាមកិច្ចព្រម

ព្រៀងណាមួយផ្សេងទៀត ដែលកំពុងអនុវត្តរវាងភាគីទាំងអស់ និងតាមវិធានណា មួយនៃច្បាប់អន្តរជាតិពាក់ព័ន្ធនឹងភាគីទាំងអស់ និងពេលណាដែលអាចអនុវត្តបានតាមច្បាប់ក្នុងស្រុកពាក់ព័ន្ធណាមួយនៃភាគីមានវិវាទ។

២. សាលាជំរះក្តី តាមការយល់ឃើញផ្ទាល់ខ្លួន ឬតាមសំណើសុំនៃភាគីមានវិវាទ ត្រូវស្នើសុំឱ្យមានការបកស្រាយរួមនូវបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ដែលជាបញ្ហានៃវិវាទ។ ភាគីទាំងអស់ ត្រូវផ្ញើជូនជាលាយលក្ខណ៍អក្សរ នូវសេចក្តីសំរេចរួមណាមួយ ដែលប្រកាសពីការបកស្រាយរបស់គេទៅឱ្យសាលាជំរះក្តីក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីថ្ងៃដែលប្រគល់សំណើ។ ដោយគ្មានផលប៉ះពាល់ចំពោះកថាខ័ណ្ឌ ៣ ប្រសិនបើភាគីទាំងអស់ខកខានក្នុងការចេញនូវសេចក្តីសំរេចនេះក្នុងរយៈពេល ៦០ ថ្ងៃ នោះ ការបកស្រាយណាមួយដែលបានដាក់ជូនដោយភាគីមួយ ត្រូវផ្ញើទៅភាគីមានវិវាទ និងសាលាជំរះក្តី ហើយសាលាជំរះក្តីត្រូវសំរេចបញ្ហាតាមការយល់ឃើញផ្ទាល់ខ្លួន។

៣. សេចក្តីសំរេចរួមមួយនៃភាគីទាំងអស់ ដែលប្រកាសពីការបកស្រាយរបស់ពួកគេចំពោះបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបានសាលាជំរះក្តីចាត់ទុកជាផ្លូវការ ហើយសេចក្តីសំរេច ឬសាលក្រមណាមួយដែលចេញដោយសាលាជំរះក្តីមួយ ត្រូវតែមានសង្គតិភាពជាមួយសេចក្តីសំរេចរួមនោះ។

## មាត្រា ២៨

## សេចក្តីសំរេចមជ្ឈត្តវិនិច្ឆ័យ "សាលក្រម" (AWARDS)

១. នៅពេលសាលាជំរះក្តីចេញសាលក្រមស្ថាពរ ជំទាស់នឹងភាគីមានវិវាទណាមួយនោះ សាលាជំរះក្តីអាចចេញសាលក្រមដាច់ដោយឡែក ឬដោយបញ្ចូលគ្នាសំរាប់តែ :

(ក) សំណងជាប្រាក់សំរាប់ការខូចខាត និងការប្រាក់ដែលត្រូវទទួលបាន និង

(ខ) បដិទាននៃទ្រព្យសម្បត្តិ ក្នុងករណីនេះសាលក្រមត្រូវបញ្ជាក់ថា ភាគីមានវិវាទអាចទូទាត់សំណងជាប្រាក់សំរាប់ការខូចខាត និងការប្រាក់ដែលត្រូវទទួលបានជំនួសឱ្យបដិទាន។

២. សាលាជំរះក្តី អាចចេញផងដែរនូវសាលក្រមចំពោះតម្លៃ និងកំរៃរបស់មេធាវី ដោយអនុលោមតាមផ្នែកនេះ និងវិធានទាំងឡាយនៃមជ្ឈត្តវិនិច្ឆ័យកំពុងអនុវត្ត។

៣. សាលាជំរះក្តី មិនអាចចេញសាលក្រមស្តីពីការខូចខាតជាលក្ខណៈទណ្ឌកម្មបានឡើយ។

៤. សាលក្រមដែលចេញដោយសាលាជំរះក្តី ជាសេចក្តីសំរេចចុងក្រោយ និងត្រូវអនុវត្តដោយភាគីមានវិវាទទាំងអស់។ សាលក្រមពុំមានជាប់ជាកាតព្វកិច្ចឡើយ លើកលែងតែរវាងភាគីមានវិវាទ និងពាក់ព័ន្ធដល់ករណីដោយឡែក។

៥. ផ្អែកតាមកថាខ័ណ្ឌ ៦ និងនីតិវិធីត្រួតពិនិត្យឡើងវិញដែលកំពុងអនុវត្ត សំរាប់ការចេញនូវសាលក្រមបណ្តោះអាសន្ន ភាគីមានវិវាទត្រូវអនុវត្ត និងប្រតិបត្តិតាមសាលក្រមដោយពុំមានការពន្យារពេល[១៥] ឡើយ ។

៦. ភាគីមានវិវាទ មិនអាចស្វែងរកការអនុវត្តសាលក្រមស្ថាពរបានឡើយ លុះត្រាតែ :

(ក) ក្នុងករណីសាលក្រមស្ថាពរក្រោមអនុសញ្ញា ICSID :

(i) ១២០ ថ្ងៃបានកន្លងទៅ ចាប់ពីកាលបរិច្ឆេទដែលសាលក្រមត្រូវបានចេញ និងគ្មានភាគីមានវិវាទណាមួយបានស្នើសុំធ្វើការសើរើ ឬធ្វើមោឃភាពនូវសាលក្រម ឬ

(ii) ដំណើរការសើរើ ឬដំណើរការធ្វើមោឃភាពបានត្រូវបញ្ចប់ជាស្ថាពរ

(ខ) ក្នុងករណីនៃសាលក្រមស្ថាពរ ក្រោមវិធានជាយន្តការបន្ថែមរបស់ ICSID វិធានមជ្ឈត្តវិនិច្ឆ័យនៃ UNCITRAL ឬវិធានដែលបានជ្រើសរើស អនុលោមតាមមាត្រា ២១.១ (ង) (ការដាក់បណ្តឹងទាមទារ) :

(i) ៩០ថ្ងៃបានកន្លងទៅ ចាប់ពីកាលបរិច្ឆេទដែលសាលក្រមត្រូវបានចេញ ហើយគ្មានភាគីមានវិវាទណាមួយ បានចាប់ផ្តើមនូវដំណើរការ ដើម្បីសើរើធ្វើឱ្យទៅជាមោឃៈ ឬ ទុកជាមោឃៈនូវសាលក្រម, ឬ

(ii) តុលាការមួយ បានច្រានចោលឬអនុញ្ញាតឱ្យមានការសើរើ ឬធ្វើមោឃភាពនៃសាលក្រម និងគ្មានការប្តឹងឧទ្ធរណ៍ជាបន្ត ។

៧. ភាគីនីមួយៗ ត្រូវអនុវត្តសាលក្រមនេះនៅក្នុងដែនដីរបស់ខ្លួន ។

---

[១៥] ភាគីទាំងអស់យល់ឃើញថា អាចមាននីតិវិធីច្បាប់ និងនីតិវិធីរដ្ឋបាលក្នុងស្រុកដែលចាំបាច់ត្រូវសិក្សា ពិនិត្យ មុនពេលដែលសេចក្តីសំរេចតុលាការត្រូវបានអនុវត្ត ។

## ឧបសម្ព័ន្ធ ស្តីពីការដកហូត និងសំណង

១. សកម្មភាពមួយ ឬកំរងសកម្មភាពពាក់ព័ន្ធដោយភាគីមួយ មិនអាចចាត់ទុកថា ជាការដកហូតបានឡើយ ល្គឹក ណាវាមិនជ្រៀតជ្រែកជាមួយសិទ្ធិនៃទ្រព្យសម្បត្តិរូបី និងអរូបី ឬប្រយោជន៍នៃទ្រព្យសម្បត្តិក្នុងដែនវិនិយោគនោះ ។

២. មាត្រា ៩.១ (ការដកហូត និងសំណង) នៃជំពូក ១១ (វិនិយោគ) លើកឡើងនូវស្ថានភាពចំនួនពីរ :

(ក) ស្ថានភាពទី១ គឺការដកហូតផ្ទាល់ ដោយដែនវិនិយោគត្រូវបានធ្វើជាតូបនីយកម្ម ឬត្រូវបានធ្វើការដកហូតដោយផ្ទាល់ផ្សេងទៀត តាមរយៈការផ្ទេរជាផ្លូវការនូវកម្មសិទ្ធិ ឬការរឹបអូសទាំងស្រុង. និង

(ខ) ស្ថានភាពទី២ គឺជាសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធ ដោយភាគីមួយមានផលប៉ះពាល់ដូចគ្នានឹងការដកហូតដោយផ្ទាល់ ដោយគ្មានការផ្ទេរជាផ្លូវការនូវកម្មសិទ្ធិ ឬការរឹបអូសទាំងស្រុង ។

៣. ការកំណត់ថា តើសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធ ដោយភាគីមួយក្នុងស្ថានភាពជាក់ស្តែងមួយចាត់ទុកថា ជាការដកហូតនៃប្រភេទដែលបានយោងនៅក្នុងកថាខ័ណ្ឌ ២ (ខ) តំរូវឱ្យមានការស៊ើបអង្កេតដោយយកអង្គហេតុជាមូលដ្ឋាន តាមករណីដែលត្រូវវិភាគក្នុងចំណោមកត្តាដទៃទៀត :

(ក) ឥទ្ធិពលសេដ្ឋកិច្ចនៃសកម្មភាពរបស់រដ្ឋាភិបាល ថ្វីបើអង្គហេតុដែលសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធដោយភាគីមួយ មានផលប៉ះពាល់មិនល្អចំពោះតំលៃសេដ្ឋកិច្ចនៃការវិនិយោគមួយក៏ដោយ ករណីដោយឡែកមិនមានន័យថា ការដកហូតបានកើតឡើងនោះទេ ។

(ខ) ថាតើសកម្មភាពរបស់រដ្ឋាភិបាល បានរំលោភលើការសន្យាជាលាយលក្ខណ៍អក្សររបស់រដ្ឋាភិបាលចំពោះអ្នកវិនិយោគ មិនថាជាកិច្ចសន្យា អាជ្ញាប័ណ្ណ ឬឯកសារច្បាប់ដទៃទៀត. និង

(គ) ចរិតលក្ខណៈនៃសកម្មភាពរបស់រដ្ឋាភិបាល រាប់បញ្ចូលទាំងគោលបំណងនៃសកម្មភាពនោះ និងថាតើសកម្មភាពមានវិសមាមាត្រទៅនឹងគោលបំណងសាធារណៈ[១] ដែរឬទេ? ។

៤. សកម្មភាពស្របច្បាប់ដែលគ្មានការរើសអើងដោយភាគីមួយ ដែលត្រូវបានកំណត់ និងអនុវត្ត ដើម្បីសំរេចឱ្យបាននូវគោលបំណងសុខុមាលភាពសាធារណៈស្របច្បាប់ ដូចជា ការការពារសុខភាពសាធារណៈ សុវត្ថិភាព និងបរិដ្ឋាន ពុំបានចាត់ទុកថា ជាការដកហូតនៃប្រភេទដែលយោងដល់កថាខ័ណ្ឌ ២ (ខ) ឡើយ ។

[១] "គោលបំណងសាធារណៈ" ត្រូវអានដោយយោងមាត្រា ៩.១ (ក) និងមាត្រា ៩.៦ (ការដកហូត និងសំណង) នៃជំពូក ១១ (វិនិយោគ)

# ជំពូក ១២
# សហប្រតិបត្តិការសេដ្ឋកិច្ច

## មាត្រា ១
## ទំហំ និង ទិសដៅ

១- ភាគីទាំងអស់បានបញ្ជាក់ឡើងវិញ នូវសារៈសំខាន់នៃគំនិតផ្តួចផ្តើមសហប្រតិបត្តិការសេដ្ឋកិច្ច ដែលកំពុងកើតមានឡើងរវាងអាស៊ាន អូស្ត្រាលី និងណូវែលហ្សេឡង់ និង បានឯកភាពដើម្បីបំពេញនូវភាពជាដៃគូផ្នែកសេដ្ឋកិច្ច ដែលមានស្រាប់របស់ខ្លួនក្នុងគ្របវិស័យ ដែលភាគីទាំងអស់មានចំណាប់អារម្មណ៍ទៅវិញទៅមក ដោយពិចារណានូវកំរិតនៃការអភិវឌ្ឍផ្សេងៗគ្នា នៃភាគីទាំងអស់។

២- ភាគីទាំងអស់ទទួលស្គាល់បទប្បញ្ញត្តិនានា ដើម្បីលើកទឹកចិត្ត និង ជួយសម្រួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដោយរាប់បញ្ចូលនូវជំពូកផ្សេងៗទៀត នៃកិច្ចព្រមព្រៀងនេះ។

៣- កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច នៅក្រោមជំពូកនេះ និងជួយគាំទ្រដល់ការអនុវត្តកិច្ចព្រមព្រៀងនេះឆ្លងតាមសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ឬ វិនិយោគ ដូចដែលបានបញ្ជាក់នៅក្នុងកម្មវិធីការងារ។

## មាត្រា ២
## និយមន័យ

ដើម្បីជំពូកនេះ :

ក- **ភាគីដែលកំពុងអនុវត្ត ឬ បណ្តាភាគីដែលកំពុងអនុវត្ត** មានន័យថា សំរាប់សមាសភាគនីមួយៗនៃកម្មវិធីការងារ, ភាគី ឬ បណ្តាភាគីដែលទទួលខុសត្រូវ សម្រាប់ការអនុវត្តនៃសមាសភាគនោះ

ខ- **កម្មវិធីការងារ** មានន័យថា កម្មវិធីសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ច ដែលបានរៀបចំទៅជាសមាសភាគ ដែលបានបញ្ជាក់នូវអត្តសញ្ញាណទៅវិញទៅមក ដោយភាគីទាំងអស់មុនពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣
## ធនធាន

១- ដោយមានការទទួលស្គាល់នូវគម្លាតអភិវឌ្ឍ ក្នុងចំណោមបណ្តារដ្ឋសមាជិកអាស៊ាន និង ក្នុងចំណោមភាគីភាគីទាំងអស់នឹងចូលរួមវិភាគទានសមស្រប ដើម្បីអនុវត្តនៃកម្មវិធីការងារនេះ ។

២- ក្នុងការបញ្ជាក់នូវអត្តសញ្ញាណកិរិតនៃការចូលរួមវិភាគទានសមស្របដល់កម្មវិធីការងារ ភាគីទាំងអស់នឹងលើកយកមកពិចារណានូវ :

(ក) កំរិតនៃការអភិវឌ្ឍផ្សេងៗគ្នា និង សមត្ថភាពនៃភាគីទាំងអស់

(ខ) ការចូលរួមវិភាគទាន ដែលនឹងអនុវត្តបានចំពោះសមាសភាគកម្មវិធីការងារ ដោយភាគីទាំងអស់

(គ) កំរិតនៃការចូលរួមវិភាគទានសមស្រប ធ្វើឱ្យប្រសើរដល់ទំនាក់ទំនង និងនិរន្តរភាពនៃកិច្ចសហប្រតិបត្តិការ ពង្រឹងភាពជាដៃគូរវាងភាគីទាំងអស់ និងកសាងនូវការសន្យា ដែលបានចូលរួមដោយភាគីទាំងអស់ ដើម្បីអនុវត្ត និងការត្រួតពិនិត្យឱ្យមានប្រសិទ្ធភាព នូវសមាសភាគកម្មវិធីការងារ ។

## មាត្រា ៤

## កម្មវិធីការងារសហប្រតិបត្តិការសេដ្ឋកិច្ច

១- សមាសភាគកម្មវិធីការងារនីមួយៗ នឹង :

ក- ជាប់ទាក់ទងដល់វិស័យពាណិជ្ជកម្ម និងវិនិយោគ និង គាំទ្រដល់ការអនុវត្តនៃកិច្ចព្រមព្រៀងនេះ

ខ- ត្រូវបានបញ្ជាក់នៅក្នុងកម្មវិធីការងារ

គ- ជាប់ពាក់ព័ន្ធជាអប្បបរមានៃរដ្ឋសមាជិកអាស៊ាន ២ អូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់

ឃ- ថ្លែងបញ្ជាក់នូវអត្ថិភាពទៅវិញទៅមកនៃភាគីទាំងអស់ដែលបានកំពុងចូលរួម, និង

ង- ចៀសវាងការជាន់គ្នានូវសកម្មភាពសហប្រតិបត្តិការសេដ្ឋកិច្ចដែលមានស្រាប់ ប្រសិនបើអាចធ្វើបាន

២- ការពណ៌នានូវសមាសភាគ នៃកម្មវិធីការងារនីមួយៗ គួរបញ្ជាក់ឱ្យបានពិស្តារដែលចាំបាច់ផ្តល់នូវភាពច្បាស់លាស់ ដល់ភាគីទាំងអស់ដោយយោងទៅលើគោលដៅ និងគោលបំណងនៃសមាសភាគទាំងនោះ ។

## មាត្រា ៥

## ចំណុចប្រសព្វសំរាប់ការអនុវត្ត

១- ភាគីនីមួយៗ ត្រូវតែងតាំងនូវចំនុចប្រសព្វសំរាប់បញ្ហាទាំងឡាយ ដែលទាក់ទងនឹងការអនុវត្តកម្មវិធីការងារ និងត្រូវឱ្យភាគីទាំងអស់ធ្វើទំនើបកម្មទៅលើភាពពិស្តារនៃចំនុចប្រសព្វរបស់ខ្លួននីមួយៗ ។

២- ចំនុចប្រសព្វទាំងអស់នឹងត្រូវទទួលខុសត្រូវ និងរាយការណ៍ពីការអនុវត្តកម្មវិធីការងារ ដោយអនុលោមតាមមាត្រា៦ (ការអនុវត្ត និងការវាយតំលៃទៅលើសមាសភាគនៃកម្មវិធីការងារ) និងមាត្រា៧ (ការពិនិត្យមើលឡើងវិញនូវកម្មវិធីការងារ) និងសម្រាប់ឆ្លើយតបទៅនឹងសំនួរទាំងឡាយពីភាគីណាមួយ ទាក់ទងទៅនឹងកម្មវិធីការងារ ។

## មាត្រា ៦

## ការអនុវត្ត និងការវាយតំលៃទៅលើសមាសភាគនៃកម្មវិធីការងារ

១- មុនពេលចាប់ផ្តើមអនុវត្តសមាសភាពកម្មវិធីការងារនីមួយៗ ភាគីណាមួយ ឬទាំងអស់ ដែលកំពុងពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ត្រូវបង្កើតផែនការអនុវត្តន៍ទៅលើសមាសភាគនៃកម្មវិធីការងារនោះ និងត្រូវផ្តល់ផែនការនោះទៅគ្រប់ភាគីទាំងអស់ ។

២- ភាគីអនុវត្តន៍ណាមួយ ឬទាំងអស់ ទៅលើសមាសភាគនៃកម្មវិធីការងារ អាចប្រើយន្តការដែលមានស្រាប់សំរាប់ធ្វើការអនុវត្តទៅលើសមាសភាគនោះ ។

៣- រហូតដល់ការបញ្ចប់នៃសមាសភាគកម្មវិធីការងារ ភាគីអនុវត្តន៍ណាមួយ ឬទាំងអស់ ត្រូវធ្វើការពិនិត្យមើល និងវាយតំលៃឱ្យបានទៀងទាត់ ទៅលើសមាសភាគដែលជាប់ទាក់ទង និងផ្តល់នូវរបាយការណ៍ឱ្យបានទៀងទាត់ ជូនទៅភាគីនីមួយៗ ដោយរួមទាំងរបាយការណ៍ចុងក្រោយនៃការបញ្ចប់របស់សមាសភាគនោះ ។

## មាត្រា ៧

## ការពិនិត្យមើលឡើងវិញនូវកម្មវិធីការងារ

គេត្រូវពិនិត្យមើលកម្មវិធីការងារឡើងវិញ នៅឯទីចាត់ការរបស់គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មសេរី ដើម្បីប៉ាន់ស្មានលើប្រសិទ្ធភាពជាទូទៅ និងដើម្បីផ្តល់នូវអនុសាសន៍នានា ។ គណៈកម្មាធិការចម្រុះតំបន់ពាណិជ្ជកម្មអាចកែសម្រួលកម្មវិធីការងារ និងអាចលើកមកពិចារណាពីការពិនិត្យឡើងវិញ និងធនធានដែលមាន ។

## មាត្រា ៨

## ការមិនអនុវត្តជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ)

ជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) មិនអាចអនុវត្តទៅលើបញ្ហាណាមួយដែលកើតឡើងនៅក្រោមជំពូកនេះទេ ។

# ជំពូក ១៣
# កម្មសិទ្ធិបញ្ញា

## មាត្រា ១
## គោលបំណង

ភាគីនីមួយៗ ប្តេជ្ញាកាត់បន្ថយនូវឧបសគ្គក្នុងការធ្វើពាណិជ្ជកម្ម និងវិនិយោគ ដោយលើកកំពស់សមាហរណកម្មសេដ្ឋកិច្ចឱ្យបានស៊ីជម្រៅថែមទៀត តាមរយៈការបង្កើត ការប្រើប្រាស់ ការការពារ និង ការអនុវត្តកម្មសិទ្ធិបញ្ញាឱ្យបានពេញលេញប្រកបដោយប្រសិទ្ធភាព ដោយពិចារណាទៅលើកម្រិតខុសគ្នានៃសមត្ថភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងភាពខុសគ្នានៃប្រព័ន្ធច្បាប់ជាតិ និងភាពចាំបាច់ ដើម្បីរក្សាតុល្យភាពសមស្របរវាងម្ចាស់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់អ្នកប្រើប្រាស់ ចំពោះកម្មវត្ថុ ដែលត្រូវបានការពារដោយកម្មសិទ្ធិបញ្ញា។

## មាត្រា ២
## និយមន័យ

ក្នុងគោលបំណងនៃជំពូកនេះ :

ក. កម្មសិទ្ធិបញ្ញា សំដៅទៅលើសិទ្ធិអ្នកនិពន្ធ និង សិទ្ធិប្រហាក់ប្រហែល សិទ្ធិលើម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ គំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម និង គំនូសនៃសៀគ្វីបង្រួមបញ្ចូលគ្នា ពូជថ្មីនៃដំណាំ និង ព័ត៌មានសម្ងាត់ ដូចមានក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា. និង

ខ. WIPO មានន័យថា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

## មាត្រា ៣
## ការបញ្ជាក់របស់កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

ភាគីនីមួយៗ ប្រកាសទទួលស្គាល់សិទ្ធិ និង កាតព្វកិច្ចគ្នាទៅវិញទៅមក ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា។

## មាត្រា ៤
## ប្រព្រឹត្តិកម្មជាតិ

១. ភាគីនីមួយៗ ត្រូវផ្តល់ប្រព្រឹត្តិកម្មជាតិឱ្យគ្នាទៅវិញទៅមក មិនឱ្យតិចជាងអ្វីដែលបានផ្តល់ដល់ជាតិសាសន៍របស់ខ្លួន ពាក់ព័ន្ធនឹងការការពារ[១] នៃកម្មសិទ្ធិបញ្ញា លើកលែងតែមានចែងនៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា និង កិច្ចព្រមព្រៀងពហុភាគីដែលបានចុះហត្ថលេខា ក្រោមក្របខ័ណ្ឌអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

២. ភាគីនីមួយៗ អាចប្រើប្រាស់អញ្ញត្រកម្ម ដូចមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីរដ្ឋបាល និង នីតិវិធីតុលាការរបស់ខ្លួន រួមបញ្ចូលទាំងការតម្រូវឱ្យប្រជាជាតិនៃភាគីដទៃទៀត ផ្តល់នូវអាសយដ្ឋានសម្រាប់ទាក់ទងក្នុងដែនដីរបស់ខ្លួន ឬចាត់តាំងភ្នាក់ងារណាម្នាក់ក្នុងដែនដីរបស់ខ្លួន ក្នុងករណីដែលអញ្ញត្រកម្ម នោះ :

ក. ចាំបាច់ធានាឱ្យមានអនុលោមភាពទៅតាមច្បាប់ និង បទប្បញ្ញត្តិ ដែលមិនផ្ទុយទៅនឹងជំពូកនេះ, និង

ខ. មិនបង្កឱ្យមានលក្ខណៈណាមួយ ដែលរឹតត្បិតទៅលើការធ្វើពាណិជ្ជកម្ម។

## មាត្រា ៥
## សិទ្ធិអ្នកនិពន្ធ

១. ភាគីនីមួយៗត្រូវ :

ក. ផ្តល់សិទ្ធិផ្តាច់មុខទៅឱ្យអ្នកនិពន្ធ[២] ក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយស្នាដៃរបស់ខ្លួនជាសាធារណៈ តាមរយៈប្រពន្ធ័ផ្សព្វផ្សាយមានខ្សែ ឬគ្មានខ្សែ

ខ. ផ្តន្ទាទោសតាមនីតិវិធីព្រហ្មទណ្ឌ និង ការដាក់ទណ្ឌកម្ម យ៉ាងហោចណាស់ក្នុងករណីដែលបុគ្គលមួយរំលោភសិទ្ធិអ្នកនិពន្ធដោយចេតនា ក្នុងគោលបំណងទាញយកអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម ឬទទួលផលហិរញ្ញវត្ថុ, និង

---

[១] សំរាប់គោលបំណងនៃកថាខណ្ឌនេះ ការការពាររាប់បញ្ចូលទាំងបញ្ហានានាដែលជះឥទ្ធិពលលើ ភាពសម្បូរបែប ការទាញយកចំណេះដឹង វិសាលភាព ការថែរក្សា និងការអនុវត្តកម្មសិទ្ធិបញ្ញាដូច ដែលមានក្នុងជំពូកនេះ។ លើសពីនេះសំរាប់គោលបំណងនៃកថាខ័ណ្ឌនេះ ការការពារក៏រាប់បញ្ចូលផងដែរនូវការហាមឃាត់ទៅលើការរំលោភនៃ វិធានការបច្ចេកវិទ្យា ដែលប្រកប ដោយប្រសិទ្ធភាពដូចមានចែងក្នុងមាត្រា៥។

[២] សំរាប់គោលបំណងនៃជំពូកនេះ ស្នាដៃ រួមបញ្ចូលទាំងការថតបញ្ចូលជាខ្សែភាពយន្ត។

គ. ជម្រុញឱ្យមានការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមដ៏សមស្របមួយ និង លើកទឹកចិត្តអង្គភាពនោះ ដើម្បីធ្វើប្រតិបត្តិការឱ្យមានប្រសិទ្ធភាព តម្លាភាពជាសាធារណៈ និង ការទទួលខុសត្រូវចំពោះសមាជិករបស់ខ្លួន។

២. ភាគីនីមួយៗត្រូវ ខិតខំប្រឹងប្រែង :

ក. ផ្តល់សិទ្ធិផ្តាច់មុខឱ្យអ្នកថតសម្លេង[៣] ក្នុងការអនុញ្ញាតឱ្យផ្សព្វផ្សាយជាសាធារណៈ នូវការថតសម្លេងរបស់ខ្លួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយមានខ្សែ ឬ គ្មានខ្សែ

ខ. ផ្តល់ការការពារតាមផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ និង មធ្យោបាយផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងទៅនឹងការគេចវេះពីវិធានការបច្ចេកវិទ្យា[៤] ដែលបានប្រើប្រាស់ដោយម្ចាស់សិទ្ធិពាក់ព័ន្ធនឹងការប្រើសិទ្ធិអ្នកនិពន្ធរបស់ពួកគេ និង វិធានការដែលរឹតត្បិត នូវសកម្មភាពនានាដែលពាក់ព័ន្ធនឹងស្នាដៃរបស់ពួកគេ ដោយពុំមានការអនុញ្ញាតពីម្ចាស់សិទ្ធិអ្នកនិពន្ធដែលពាក់ព័ន្ធ ឬ មិនត្រូវបានអនុញ្ញាតដោយច្បាប់, និង

គ. ផ្តន្ទាទោសតាមនីតិវិធីព្រហ្មទណ្ឌ និង ដាក់ទណ្ឌកម្មយ៉ាងហោចណាស់ ក្នុងករណីដែលបុគ្គលមួយរំលោភធ្ងន់ធ្ងរដោយចេតនា ទៅលើសិទ្ធិអ្នកនិពន្ធ ដែលច្បាប់ហាមឃាត់ ទោះបីមិនមានបំណងទាញយកអត្ថប្រយោជន៍ផ្នែកពាណិជ្ជកម្ម ឬ ទទួលផលហិរញ្ញវត្ថុ ប៉ុន្តែវាធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់ម្ចាស់សិទ្ធិអ្នកនិពន្ធ។

## មាត្រា ៦

## ការប្រើប្រាស់សូហ្វវែររបស់រដ្ឋាភិបាល

ភាគីនីមួយៗ ត្រូវបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួន :

---

[៣] ក្នុងករណីដែលភាគីមួយជាសមាជិក ឬ នឹងក្លាយជាសមាជិកនៃ សន្ធិសញ្ញាហ្សឺណែវក្រោម និង ការសម្តែងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក កាតព្វកិច្ចរបស់ភាគីនៅក្នុងកថាខណ្ឌនេះ ត្រូវអនុលោមទៅតាមការប្តេជ្ញាចិត្ត និងការរក្សាទុក ដែលភាគីនោះបានធ្វើឡើងក្រោមសន្ធិសញ្ញាហ្សឺណែវក្រោម និងការសម្តែងរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

[៤] សំរាប់គោលបំណងនៃជំពូកនេះ "វិធានការបច្ចេកវិទ្យាប្រកបដោយប្រសិទ្ធភាព" មានន័យថា ជាបច្ចេកវិទ្យា ឧបករណ៍ ឬ សមាសភាពណាមួយដែលបានប្រើប្រាស់ដោយម្ចាស់សិទ្ធិអ្នកនិពន្ធ ដែលពាក់ពន្ធ័ទៅនឹងការប្រើប្រាស់សិទ្ធិអ្នកនិពន្ធរបស់ពួកគេ និងវិធានការដែលរឹតត្បិតនូវសកម្មភាពនានា ដែលពាក់ព័ន្ធនឹងស្នាដៃរបស់ពួកគេ ឬ ការថតសម្លេង ដែលពុំមានការអនុញ្ញាតដោយម្ចាស់សិទ្ធិសិទ្ធិអ្នកនិពន្ធដែលពាក់ព័ន្ធ ឬ មិនត្រូវបានអនុញ្ញាតដោយច្បាប់។

ក. រក្សាច្បាប់ បទប្បញ្ញត្តិ ឬ គោលនយោបាយ ដែលរៀបចំសម្រាប់ភ្នាក់ងាររដ្ឋាភិបាលកណ្ដាលរបស់ខ្លួន ដើម្បីបន្តការប្រើប្រាស់សូហ្វវែកុំព្យូទ័រស្របច្បាប់តាមរបៀប ដែលច្បាប់អនុញ្ញាត និងអនុលោមតាមជំពូកនេះ. និង

ខ. លើកទឹកចិត្តរដ្ឋាភិបាលក្នុងស្រុក និងតំបន់នីមួយៗ ដើម្បីរក្សា ឬអនុម័តវិធានការប្រហាក់ប្រហែល ។

## មាត្រា ៧

## ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

១. ភាគីនីមួយៗត្រូវរក្សាប្រព័ន្ធចំណាត់ថ្នាក់ម៉ាក អនុលោមទៅតាមកិច្ចព្រមព្រៀងទីក្រុងនីសស្ដីអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវា សំរាប់ការចុះបញ្ជីម៉ាក ដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

២. ភាគីនីមួយៗ ត្រូវផ្ដល់សិទ្ធិការពារម៉ាក ដែលប្រកបដោយគុណភាពខ្ពស់ តាមរយៈការត្រួតពិនិត្យខ្លឹមសារម៉ាក បែបបទដាក់ពាក្យ និង តាមរយៈប្ដឹងជំទាស់ និង នីតិវិធីលុបម៉ាក ។

៣. ភាគីនីមួយៗ ត្រូវការពារម៉ាក ដែលបានចុះបញ្ជីក្រោមយុត្តាធិការរបស់ខ្លួន មុនម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយអនុលោមទៅតាមច្បាប់ក្នុងស្រុក និង កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

៤. ភាគីនីមួយៗត្រូវទទួលស្គាល់ថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចត្រូវបានការពារតាមរយៈប្រព័ន្ធម៉ាក ។

## មាត្រា ៨

## ប្រភពជីវសាស្ត្រចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក

អនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ភាគីនីមួយៗអាចដាក់ចេញវិធានការសមស្រប ដើម្បីការពារប្រភពជីវសាស្ត្រចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក ។

## មាត្រា ៩

## កិច្ចសហប្រតិបត្តិការ

១. ភាគីទាំងអស់ទទួលស្គាល់ភាពខុសគ្នាខ្លាំងនៃសមត្ថភាពរបស់ភាគីមួយចំនួន លើវិស័យកម្មសិទ្ធិបញ្ញា ។ ដោយយកចិត្តទុកដាក់ពីបញ្ហានេះ នៅពេលដែលភាគីមួយមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តជំពូកនេះ ភាគីផ្សេង

ក.	រក្សាច្បាប់ បទប្បញ្ញត្តិ ឬ គោលនយោបាយ ដែលរៀបចំសម្រាប់ភ្នាក់ងាររដ្ឋាភិបាលកណ្តាលរបស់ខ្លួន ដើម្បីបន្តការប្រើប្រាស់សូហ្វវែកុំព្យូទ័រស្របច្បាប់តាមរបៀប ដែលច្បាប់អនុញ្ញាត និងអនុលោមតាមជំពូកនេះ. និង

ខ.	លើកទឹកចិត្តរដ្ឋាភិបាលក្នុងស្រុក និងតំបន់នីមួយៗ ដើម្បីរក្សា ឬអនុម័តវិធានការប្រហាក់ប្រហែល ។

## មាត្រា ៧
## ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

១.	ភាគីនីមួយៗត្រូវរក្សាប្រព័ន្ធចំណាត់ថ្នាក់ម៉ាក អនុលោមទៅតាមកិច្ចព្រមព្រៀងទីក្រុងនីសស្តីអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញ និងសេវា សំរាប់ការចុះបញ្ជីម៉ាក ដែលបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

២.	ភាគីនីមួយៗ ត្រូវផ្តល់សិទ្ធិការពារម៉ាក ដែលប្រកបដោយគុណភាពខ្ពស់ តាមរយៈការត្រួតពិនិត្យខ្លឹមសារម៉ាក បែបបទដាក់ពាក្យ និង តាមរយៈប្តឹងជំទាស់ និង នីតិវិធីលុបម៉ាក ។

៣.	ភាគីនីមួយៗ ត្រូវការពារម៉ាក ដែលបានចុះបញ្ជីក្រោមយុត្តាធិការរបស់ខ្លួន មុនម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដោយអនុលោមទៅតាមច្បាប់ក្នុងស្រុក និង កិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

៤.	ភាគីនីមួយៗត្រូវទទួលស្គាល់ថា ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ អាចត្រូវបានការពារតាមរយៈប្រព័ន្ធម៉ាក ។

## មាត្រា ៨
## ប្រភពជីវសាស្ត្រចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក

អនុលោមតាមកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ភាគីនីមួយៗអាចដាក់ចេញវិធានការសមស្រប ដើម្បីការពារប្រភពជីវសាស្ត្រចម្រុះ ចំណេះដឹងប្រពៃណី និង ទំនៀមទំលាប់អ្នកស្រុក ។

## មាត្រា ៩
## កិច្ចសហប្រតិបត្តិការ

១.	ភាគីទាំងអស់ទទួលស្គាល់ភាពខុសគ្នាខ្លាំងនៃសមត្ថភាពរបស់ភាគីមួយចំនួន លើវិស័យកម្មសិទ្ធិបញ្ញា ។ ដោយយកចិត្តទុកដាក់ពីបញ្ហានេះ នៅពេលដែលភាគីមួយមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តជំពូកនេះ ភាគីផ្សេង

ទៀត ក្នុងករណីសមស្រប និងតាមសំណើ ត្រូវតែខិតខំប្រឹងប្រែងផ្តល់កិច្ចសហប្រតិបត្តិការឱ្យទៅភាគីនោះ ដើម្បីជួយអនុវត្តជំពូកនេះ ។

២. តាមសំណើរបស់ភាគីមួយ ភាគីដទៃទៀតអាចផ្តល់ជាជំនួយទៅឱ្យភាគីដែលស្នើសុំក្នុងគោលបំណង ដើម្បីលើកកំពស់ក្របខណ្ឌជាតិ ដើម្បីការទទួលបានចំណេះដឹង ការការពារ ការអនុវត្ត ការប្រើប្រាស់ និង ការបង្កើតកម្មសិទ្ធិបញ្ញា ក្នុងទស្សនវិស័យអភិវឌ្ឍន៍ប្រព័ន្ធកម្មសិទ្ធិបញ្ញា ដែលជំរុញឱ្យមានការច្នៃប្រឌិតក្នុងស្រុក នៅក្នុងប្រទេសដែលជាភាគីស្នើសុំ ។

៣. ភាគីទាំងអស់ព្រមព្រៀងលើកកំពស់កិច្ចចរចា អំពីកម្មសិទ្ធិបញ្ញា ដោយរួមបញ្ចូល :

ក. ការចាត់តាំងអង្គភាពទំនាក់ទំនងនៅតាមភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនានា ដែលរួមបញ្ចូលអង្គភាពទំនាក់ទំនងសម្រាប់ ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញានៅតាមព្រំដែន

ខ. ការជម្រុញទំនាក់ទំនងគ្នា រវាងអ្នកជំនាញខាងកម្មសិទ្ធិបញ្ញា ក្នុងគោលបំណងពង្រីកការយល់ដឹង ឱ្យកាន់តែទូលំទូលាយ អំពីប្រព័ន្ធកម្មសិទ្ធិបញ្ញារៀង១ខ្លួន, និង

គ. ផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងការរំលោភកម្មសិទ្ធិបញ្ញា អនុលោមទៅតាមច្បាប់របស់ភាគីនីមួយៗ ។

៤. ភាគីទាំងអស់ត្រូវខិតខំធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីលើកកំពស់ប្រសិទ្ធភាព និងតម្លាភាពនៃប្រព័ន្ធចុះបញ្ជី និង ប្រព័ន្ធរដ្ឋបាលកម្មសិទ្ធិបញ្ញា ដោយរួមបញ្ចូល ការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធទាំងនេះ និង ការអភិវឌ្ឍការចូលទៅកាន់ប្រព័ន្ធទិន្នន័យចុះបញ្ជីជាសាធារណៈ ។

៥. ភាគីទាំងអស់ត្រូវខិតខំធ្វើកិច្ចសហប្រតិបត្តិការ ដើម្បីលើកកំពស់ការអប់រំ និងចំណេះដឹង ទាក់ទងទៅនឹងផលប្រយោជន៍នៃការការពារ និង ការអនុវត្តកម្មសិទ្ធិបញ្ញាប្រកបដោយប្រសិទ្ធភាព ។

៦. ភាគីទាំងអស់ត្រូវចូលរួមសហប្រតិបត្តិការលើវិធានការតាមព្រំដែន ក្នុងទស្សនវិស័យលុបបំបាត់ពាណិជ្ជកម្មដែលរំលោភបំពានកម្មសិទ្ធិបញ្ញា ។ ភាគីដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ត្រូវសហការគ្នាទៅវិញទៅមក ក្នុងការគាំទ្រការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃតំរូវការនានាដែលទាក់ទងទៅនឹងវិធានការតាមព្រំដែន ដែលបានកំណត់នៅក្នុងមាត្រា ៥១ ដល់មាត្រា ៦០ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធកម្មសិទ្ធិបញ្ញា ។

៧. ដោយទទួលស្គាល់សារៈសំខាន់នៃការសម្រេចឱ្យបានគោលបំណងនៃជំពូកនេះ ក្នុងករណីដែលភាគីណាមួយមានបំណងចូលជាសមាជិកសន្ធិសញ្ញាណាមួយខាងក្រោមនេះ ភាគីនោះអាចស្វែងរកកិច្ចសហប្រតិបត្តិការជាមួយភាគីដទៃទៀត ដើម្បីគាំទ្រដំណើរការចូលជាសមាជិករបស់ខ្លួន និង ការអនុវត្តសន្ធិសញ្ញាខាងក្រោម :

ក. សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ១៩៧០

ខ. កិច្ចព្រមព្រៀងទីក្រុងស្ត្រាសបឺកស្តីពីចំណាត់ថ្នាក់ប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ឆ្នាំ ១៩៧១

គ. សន្ធិសញ្ញាទីក្រុងប៊ុយដាប៉ែសស្តីពីការទទួលស្គាល់ជាអន្តរជាតិ នៃការតម្កល់អតិសុខុមប្រាណ សំរាប់គោលបំណងនៃនីតិវិធីប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ១៩៧៧

ឃ. ពិធីសារទាក់ទងទៅនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីតស្តីពីការចុះបញ្ជីម៉ាកជាអន្តរជាតិ ឆ្នាំ ១៩៨៩

ង. សន្ធិសញ្ញាច្បាប់ប្រកាសនីយបត្រតក្កកម្ម ឆ្នាំ ២០០០

ច. អនុសញ្ញាអន្តរជាតិស្តីពីការការពារពូជថ្មីនៃដំណាំ ឆ្នាំ ១៩៩១

ឆ. កិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ជ. សន្ធិសញ្ញាសិង្ហបូរី ស្តីពីច្បាប់ម៉ាក ឆ្នាំ ២០០៦

ឈ. សន្ធិសញ្ញា ស្តីពីសិទ្ធិអ្នកនិពន្ធរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកឆ្នាំ ១៩៩៦

ញ. សន្ធិសញ្ញា ស្តីពីការសម្តែង និង ហ្វូណូក្រាមរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ឆ្នាំ ១៩៩៦

៨. តាមសំណើ និងការពិចារណាដោយសមរម្យ ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងធ្វើកិច្ចសហប្រតិបត្តិការក្នុងការគាំទ្រភាគីណាមួយ ក្នុងការអនុវត្តប្រព័ន្ធរួម[៥] មួយនៃការចុះបញ្ជីម៉ាក។

៩. រាល់កិច្ចសហប្រតិបត្តិការអនុលោមតាមមាត្រានេះ គឺយោងទៅតាមធនធានដែលមាន។

---

[៥] ប្រព័ន្ធរួមនៃម៉ាកមិនកម្រិតទៅលើ វិសាលភាពនៃម៉ាក ដែលអាចចុះបញ្ជីបាន ហើយម៉ាកដែលអនុញ្ញាតអោយចុះបញ្ជីបាន លុះត្រាតែវាមានលក្ខណៈខុសគ្នានៃទំនិញ ឬ សេវា ដូចជាទ្រង់ទ្រាយ រូបភាពនៃសំបកវេចខ្ចប់ ម៉ាកដែលមានពណ៌មួយ ឬ មានពណ៌ចំរុះ សម្លេង និងក្លិន។

## មាត្រា ១០

## តម្លាភាព

១. ភាគីនីមួយៗ ត្រូវធានាថា ច្បាប់ និង បទប្បញ្ញត្តិរបស់ខ្លួនដែលអនុវត្តជាទូទៅ ទាក់ទងទៅនឹងភាពសម្បូរបែប វិសាលភាព ការទទួលបាន ការអនុវត្ត និង ការទប់ស្កាត់នៃការរំលោភកម្មសិទ្ធិបញ្ញា ត្រូវបង្កើតឱ្យមានជាសាធារណៈ យ៉ាងហោចណាស់ជាភាសាជាតិ នៃភាគីនោះ ឬជាភាសាអង់គ្លេស ។ ភាគីនីមួយៗ ត្រូវខិតខំប្រឹងប្រែងដាក់អោយមានជាសាធារណៈ នូវសេចក្តីសម្រេចចុងក្រោយរបស់តុលាការ និង វិធានរដ្ឋបាល ដែលពាក់ព័ន្ធទៅនឹងបញ្ហា ដែលបាននិយាយខាងលើ យ៉ាងហោចណាស់ក៏បានជាភាសាជាតិរបស់ខ្លួន ឬជាភាសាអង់គ្លេស ។

២. យោងតាមកថាខណ្ឌ ១ ភាគីនីមួយៗត្រូវខិតខំបង្កើតព័ត៌មានឱ្យមានជាសាធារណៈ ជាភាសាអង់គ្លេស និង ផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត ។

៣. ភាគីនីមួយៗត្រូវខិតខំបង្កើតប្រព័ន្ធទិន្នន័យ នៃសិទ្ធិម៉ាកដែលបានចុះបញ្ជី និង ម៉ាកដែលបានព្យួរទុកនៅក្នុងយុត្តាធិការរបស់ខ្លួន ដាក់នៅលើប្រព័ន្ធអ៊ិនធឺណែត ។

## មាត្រា ១១

## ការទទួលស្គាល់សម័យអន្តរកាល
## ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា

អ្វីដែលមានចែងក្នុងជំពូកនេះ មិនត្រូវធ្វើបដិបញ្ញត្តិទៅនឹងសម័យអន្តរកាលណាមួយ ដែលត្រូវអនុវត្តនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងកម្មសិទ្ធិបញ្ញា ដែលត្រូវបានយល់ព្រម ឬ អាចនឹងយល់ព្រមដោយក្រុមប្រឹក្សាទិដ្ឋភាពកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលបានបង្កើតឡើងតាមមាត្រា ៤ នៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ទាំងមុន និង ក្រោយពីការចូលជាធរមានរបស់កិច្ចព្រមព្រៀងនេះ ។

## មាត្រា ១២

## គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា

១. ដោយទទួលស្គាល់សារៈសំខាន់នៃការធ្វើឱ្យសម្រេចគោលបំណងនៃជំពូកនេះ ភាគីទាំងអស់ត្រូវបង្កើតគណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា រួមមានអ្នកតំណាងរបស់ភាគីនានា ដើម្បីត្រួតពិនិត្យមើលការអនុវត្ត និងការគ្រប់គ្រង នៃជំពូកនេះ ។

២.	គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា ត្រូវជួបប្រជុំគ្នាប្រចាំឆ្នាំ ឬតាមការកំណត់រវាងគ្នារបស់ភាគីទាំងឡាយ ។ កិច្ចប្រជុំ អាចធ្វើឡើងដោយទល់មុខគ្នា ឬ តាមមធ្យោបាយផ្សេងៗទៀត ដែលកំណត់ឡើងដោយភាគីទាំងអស់ ។

៣.	គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា ត្រូវកំណត់ការងាររបស់ខ្លួន ដោយអនុលោមតាមជំពូកនេះ ។

៤.	គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា ត្រូវកំណត់កម្មវិធីការងារអាទិភាពរបស់ខ្លួន ដែលរៀបចំដោយភាគីទាំងអស់ ។

៥.	ក្នុងពេលកំពុងបំពេញមុខងាររបស់ខ្លួន គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា អាចប្រើប្រាស់យន្តការដែលមានស្រាប់ ឬបង្កើតយន្តការថ្មី ដើម្បីធ្វើឱ្យប្រសើរឡើង និងលើកកំពស់ការចរចាស្តីពីបញ្ហាកម្មសិទ្ធិបញ្ញារវាងភាគីទាំងអស់ រួមទាំង ការផ្តល់កាលានុវត្តភាពសម្រាប់អ្នកដែលមានការពាក់ព័ន្ធ ដើម្បីផ្សារភ្ជាប់ជាមួយភាគីទាំងអស់លើបញ្ហានេះ ។

៦.	ភាគីនីមួយៗ ត្រូវជូនដំណឹងទៅឱ្យគណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញាជាប្រចាំឆ្នាំ ស្តីពីដំណើរការរីកចម្រើនចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន ដែលមានចែងក្នុងមាត្រា ៥ (សិទ្ធិអ្នកនិពន្ធ) និងវឌ្ឍនភាពដែលទាក់ទងទៅនឹងការចូលជាសមាជិកសន្ធិសញ្ញា ដូចមានចែងក្នុងមាត្រា ៩.៧ (កិច្ចសហប្រតិបត្តិការ) ។ សេចក្តីជូនដំណឹងទាំងអស់ ត្រូវបញ្ជូនឱ្យគណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា យ៉ាងហោចណាស់ ៣០ ថ្ងៃ មុនកិច្ចប្រជុំប្រចាំឆ្នាំលើកទី១ របស់គណៈកម្មាធិការស្តីពីកម្មសិទ្ធិបញ្ញា ។

# ជំពូក ១៤
# ការប្រកួតប្រជែង

## មាត្រា ១
## គោលការណ៍គ្រឹះ

១- ភាគីទាំងអស់ ទទួលស្គាល់នូវសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការ ស្តីពីការជម្រុញផ្នែកប្រកួតប្រជែង ប្រសិទ្ធភាពសេដ្ឋកិច្ច សុខុមាលភាពអ្នកប្រើប្រាស់ និង កាត់បន្ថយការអនុវត្តប្រឆាំងនឹងការប្រកួតប្រជែង។

២- ភាគីទាំងអស់ ទទួលស្គាល់ភាពខុសគ្នាសំខាន់ៗនៃសមត្ថភាពរវាងប្រទេសសមាជិកអាស៊ាន អូស្ត្រាលី និង ណូវែលហ្សេឡង់ នៅក្នុងវិស័យនយោបាយប្រកួតប្រជែង។

៣- ភាគីទាំងអស់ គោរពសិទ្ធិអធិបតេយ្យភាពរបស់ភាគីនីមួយៗ ដើម្បីអភិវឌ្ឍ រៀបចំ គ្រប់គ្រង និងអនុវត្ត ច្បាប់ និង នយោបាយស្តីពីការប្រកួតប្រជែងរបស់ប្រទេសនីមួយៗ។

៤- នៅក្នុងជំពូកនេះ មិនតម្រូវឱ្យភាគីម្ខាង អភិវឌ្ឍការប្រកួតប្រជែងពិសេស ដើម្បីតម្រូវការអនុវត្តនៃការ ប្រឆាំងនឹងការប្រកួតប្រជែង ឬការពារភាគីណាមួយពីការអនុម័តនយោបាយនៅក្នុងវិស័យផ្សេងៗ ដូចជា ដើម្បី ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។

## មាត្រា ២
## សហប្រតិបត្តិការ

១- ភាគីទាំងអស់ អាចភ្ជាប់ចំណងកិច្ចសហប្រតិបត្តិការដូចមានចែងក្នុងមាត្រា១ លើវិស័យប្រកួតប្រជែង ដែលរួមមាន :

(ក) ផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងការជំរុញ និងការអនុវត្តច្បាប់ និងនយោបាយប្រកួតប្រជែង

(ខ) ផ្លាស់ប្តូរព័ត៌មានជាសាធារណៈ ស្តីពីច្បាប់ និងនយោបាយប្រកួតប្រជែង

(គ) ផ្លាស់ប្តូរមន្ត្រីក្នុងគោលបំណង ដើម្បីចូលរួមវគ្គបណ្តុះបណ្តាល

(ឃ) ផ្លាស់ប្តូរទីប្រឹក្សា និងជំនាញការទាក់ទងនឹងច្បាប់ និងនយោបាយប្រកួតប្រជែង

(ង) ការចូលរួមនៃមន្ត្រីក្នុងនាមជា គ្រូបង្រៀន/ទីប្រឹក្សា/អ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីច្បាប់ និងនយោបាយប្រកួតប្រជែង

(ច)　ការចូលរួមនៃមន្ត្រីក្នុងកម្មវិធីជួយឧបត្ថម្ភ

(ឆ)　សកម្មភាពផ្សេងៗទាក់ទងនឹងសេចក្តីផ្តើមនៃច្បាប់ប្រកួតប្រជែង. និង

(ជ)　បែបបទផ្សេងៗនៃសហប្រតិបត្តិការបច្ចេកទេស យោងតាមការឯកភាពរបស់ភាគី

២-　នៅពេលដែលការប្រតិបត្តិជំពូកនេះត្រូវបានហាមឃាត់ដោយការបង្ខំ ប្រទេសអូស្ត្រាលី និង ណូវ៉ែលហ្សេឡង់ អាចផ្តល់នូវកិច្ចសហប្រតិបត្តិការដែលពួកគេគិតថាសមហេតុផល ដើម្បីជួយប្រទេសសមាជិកអាស៊ាន។ កិច្ចសហប្រតិបត្តិការ គឺជាកម្មវត្ថុនៃទំនាក់ទំនងនយោបាយប្រកួតប្រជែង ដែលតម្រូវឱ្យកំណត់ធនធាន និងធនធានដែលមាន ដោយគោរពច្បាប់ និងបទប្បញ្ញត្តិរបស់ភាគី។

## មាត្រា ៣
## ចំណុចទំនាក់ទំនង

ដើម្បីធានាថា សហប្រតិបត្តិការផ្នែកបច្ចេកទេសក្នុងជំពូកនេះ កើតឡើងតាមគោលការណ៍គ្រឹះ ភាគីទាំងអស់ ត្រូវរៀបចំចំនុចទំនាក់ទំនងសំរាប់សហប្រតិបត្តិការផ្នែកបច្ចេកទេស និងការផ្លាស់ប្តូរព័តិមានក្នុងជំពូកនេះ។

## មាត្រា ៤
## ការមិនអនុវត្តយន្តការដោះស្រាយវិវាទ

នីតិវិធីនៃការដោះស្រាយវិវាទនៅក្នុងកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះបញ្ហាណាដែលកើតឡើងក្នុងជំពូកនេះ។

# ជំពូក ១៥
# បទប្បញ្ញត្តិទូទៅ និងការលើកលែង

## មាត្រា ១
## ការលើកលែងទូទៅ

១. គោលបំណងរបស់ជំពូក ២ (ពាណិជ្ជកម្មទំនិញ) ជំពូក ៣ (វិធានដើមកំណើត) ជំពូក ៤ (នីតិវិធីគយ) ជំពូក ៥ (វិធានការអនាម័យ និងភូតគាមអនាម័យ) និង ជំពូក ៦ (ស្តង់ដា បទបញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា) មាត្រា XX នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ (GATT 1994) នឹងត្រូវយកមកអនុវត្ត ហើយនឹងត្រូវយកមកដាក់នៅក្នុងផ្នែកនៃកិច្ចព្រមព្រៀងនេះ mutatis mutandis ។

២. គោលបំណងរបស់ជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ជំពូក ៩ (ការបំលាស់ទីនៃរូបវន្តបុគ្គល) និង ជំពូក ១១ (វិនិយោគ) មាត្រា ១៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម រួមបញ្ចូលទាំង លេខយោងនឹងត្រូវយកមកអនុវត្ត ហើយត្រូវយកមកដាក់នៅក្នុងផ្នែកនៃកិច្ចព្រមព្រៀងនេះ mutatis mutandis ។

៣. គោលបំណងនៃកិច្ចព្រមព្រៀងនេះ ភាគីនីមួយៗទទួលស្គាល់ថា វិធានការដែលអនុលោមទៅតាមមាត្រា XX(f) នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ រួមទាំង វិធានការសំខាន់ៗ ដើម្បីទប់ស្កាត់នូវការរក្សាទុកសម្បត្តិជាតិ ឬវិធានការដាក់លាក់នៃប្រវត្តិសាស្ត្រ ឬវាយតំលៃបុរាណវិទ្យា ឬវិធានការសំខាន់ៗ ដើម្បីគាំទ្រវិចិត្រសិល្បៈជាតិ ។

៤. គោលបំណងនៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម) ហើយជំពូក ១១ (វិនិយោគ) តំរូវឱ្យមិនអនុវត្តតាមលក្ខណៈមួយ ដែលបំពារបំពាន ឬការរើសអើងមិនសមហេតុផលរវាងសមាជិកនានា ដែលមានលក្ខណៈដូចគ្នា ឬក៏បង្ហាញពីការរឹតត្បិតលើពាណិជ្ជកម្មសេវាកម្ម ឬវិនិយោគ គ្មានអ្វីនៅក្នុងកថាភាគទាំងនេះត្រូវបកស្រាយដើម្បីទប់ស្កាត់ការអនុវត្ត ឬដាក់ឱ្យអនុវត្តដោយវិធានការចាំបាច់របស់សមាជិកណាមួយ ដើម្បីទប់ស្កាត់នូវការរក្សាទុកសម្បត្តិជាតិ ឬវិធានការដាក់លាក់នៃប្រវត្តិសាស្ត្រ ឬវាយតំលៃបុរាណវិទ្យា ឬ វិធានការសំខាន់ៗ ដើម្បីគាំទ្រវិចិត្រសិល្បៈជាតិ ។

៥. ភាគីនីមួយៗត្រូវចូលរួមពិគ្រោះយោបល់ ដោយប្រកាន់ទស្សនៈមួយ ដើម្បីឈានទៅឯកភាពគ្នាកែសំរួលចំនុចចាំបាច់ ដោយតំរូវឱ្យរក្សាតុល្យភាពការសន្យាទាំងអស់ ដែលបានដាក់ចេញដោយសមាជិកនីមួយៗ ក្រោមជំពូក ៨

(ពាណិជ្ជកម្មសេវាកម្ម) និងជំពូក ១១ (វិនិយោគ) ប្រសិនបើមានការស្នើដោយសមាជិកណាមួយ ដែលប៉ះពាល់ដោយសារវិធានការនានា នៅត្រង់កថាខ័ណ្ឌ ៤ ។

## មាត្រា ២
## ការធានាលើការលើកលែង

១. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ដែលត្រូវបកស្រាយអត្ថន័យ ៖

(ក) តំរូវឱ្យភាគីនីមួយៗ ផ្តល់នូវពត៌មាននានាឱ្យគេ ដែលគិតថាវាផ្ទុយទៅនឹងការធានាផលប្រយោជន៍សំខាន់ៗ ។

(ខ) ទប់ស្កាត់សមាជិកនីមួយៗ ពីការចាត់វិធានការណាមួយ ដែលគិតថាចាំបាច់សំរាប់ការពារដល់ការធានាផលប្រយោជន៍សំខាន់ៗ ។

(i) ពាក់ពន្ធ័នឹងការបែងចែកសម្ភារៈ ឬក៏សម្ភារៈដែលពួកគេប្រមូលបាន

(ii) ពាក់ពន្ធ័នឹងចរាចរណ៏គ្រឿងសព្វាវុធ គ្រាប់រំសេវ និងការធ្វើសង្គ្រាម និងការធ្វើចរាចរទំនិញផ្សេងទៀត ឬវត្ថុធាតុដើមផ្សេងៗ ឬក៏ទាក់ទងនឹងការផ្គត់ផ្គង់សេវាកម្មនានា ដូចជា ការអនុវត្តផ្ទាល់ ឬប្រយោលក្នុងបំណងសំរាប់ផ្គត់ផ្គង់ ឬផ្តល់គ្រឿងចំបាំងដល់ការបង្កើតទ័ព ។

(iii) ធ្វើដូច្នេះ ដើម្បីទប់ស្កាត់នូវការរិះគន់ហេដ្ឋារចនាសម្ពន្ធ័សាធារណៈ រួមមានការទំនាក់ទំនងហេដ្ឋារចនាសម្ព័ន្ធថាមពល និងទឹកបានមកពីការខិតខំគិតទុក សំរាប់បំណងឱ្យបាត់បង់នូវសមត្ថភាព ឬខូចខាតដល់ហេដ្ឋារចនាសម្ពន្ធ័នានា ។

(iv) យកពេលប្រកាសអាសន្នជាតិ ឬសង្គ្រាម ឬក៏ប្រកាសអាសន្នផ្សេងទៅដាក់ក្នុងទំនាក់ទំនងជាអន្តរជាតិ ។

(គ) ទប់ស្កាត់សមាជិកនីមួយៗពីការដាក់វិធានការនានា ដោយយកតាមការអនុវត្តកថាខ័ណ្ឌអង្គការសហប្រជាជាតិ ដើម្បីការពារសន្តិភាព និងសន្តិសុខអន្តរជាតិ ។

២. គណៈកម្មការចំរុះតំបន់ពាណិជ្ជកម្មសេរី ត្រូវតែជូនដំណឹង ដើម្បីបង្កើនវិធានការពេញលេញ តាមដែលអាចធ្វើទៅបាន ក្រោមកថាខណ្ឌ័ ១ (ក) និង (គ) និងការសំរេចចុងក្រោយរបស់គេ ។

## មាត្រា ៣
## វិធានការពន្ធដារ

១. លើកលែងតែអ្វីដែលមានចែងក្នុងមាត្រានេះ ប្រការដែលគ្មាននៅក្នុងកិច្ចព្រមព្រៀងនេះ និងត្រូវអនុវត្តតាមវិធានការពន្ធដារនានា។

២. កិច្ចព្រមព្រៀងនេះ គ្រាន់តែផ្តល់សិទ្ធិ ឬដាក់កាតព្វកិច្ចផ្សេងៗ ឱ្យគោរពទៅតាមវិធានការពន្ធដារនានា ដែល :

(ក) សិទ្ធិទទួលខុសត្រូវ និងកាតព្វកិច្ច គឺត្រូវប្រមូលយក និងប្រតិបត្តិតាមកិច្ចព្រមព្រៀង WTO

(ខ) ប្រមូល ឬឱ្យបង់ពន្ធដារ តាមមាត្រា ៨ (ការផ្ទេរ) នៃជំពូក ១១ (វិនិយោគ) ឬ

(គ) ប្រមូល ឬយកពន្ធតាមមាត្រា ៩ (ការដកហូត និងសំណង) នៃជំពូក ១១ (វិនិយោគ)។

៣. ពេលដែលកថាខ័ណ្ឌ ២ (ខ) ឬ (គ) យកមកអនុវត្តតាមច្បាប់គោលការណ៍ នោះផ្នែក ខ (វិវាទវិនិយោគរវាងភាគីមួយ និងវិនិយោគគិនមួយ) នៃជំពូក ១១ (វិនិយោគ) ត្រូវអនុវត្តតាមច្បាប់វិធានការពន្ធដារ។

៤. ប្រសិនបើមានវិវាទនៅក្នុងមាត្រា ១៨.១ (វិសាលភាព និងនិយមន័យ) នៃជំពូក ១១ (វិនិយោគ) ដែលពាក់ពន្ធ័នឹងវិធានការពន្ធដារ គឺភាគីពាក់ពន្ធ័នីមួយៗ រួមទាំងអ្នកតំណាងការិយាល័យពន្ធដាររបស់គេ ត្រូវប្រកាន់យកកិច្ចពិគ្រោះយោបល់ផងគ្នា។ តុលាការកាត់ក្តី បង្កើតឡើងបានដោយអនុលោមតាមផ្នែក ខ (វិវាទវិនិយោគរវាងភាគីមួយ និងវិនិយោគគិនមួយ) នៃជំពូក ១១ (វិនិយោគ) ត្រូវតែព្រមព្រៀងគ្នាតាមការពិចារណាដ៏ហ្មត់ចត់ ដើម្បីសំរេចយកចំណុចរួមទៅតាមភាគីនីមួយៗ ដូចនឹងអ្វីដែលចោទសួរតាមវិធានការពន្ធដារ។ គោលបំណងនៃមាត្រា ២៥.៧ (ការប្រព្រឹត្តនៃមជ្ឈត្តវិនិច្ឆ័យ) នៃជំពូក ១១ (វិនិយោគ) ត្រូវតែអនុវត្តតាមច្បាប់ គោលការណ៍ mutatis mutandis ។

៥. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃភាគីនានា ក្រោមអនុសញ្ញាពន្ធដារ ដែលត្រូវបង្ខំឱ្យគេចចេញពីការពិន័យពន្ធដារទ្វេដងរវាងភាគីនីមួយៗ។ ក្នុងករណីដែលមានការមិនស្របគ្នាពាក់ព័ន្ធនឹងវិធានពន្ធដារ រវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាពន្ធដារ. កិច្ចព្រមព្រៀងចុងក្រោយ ឬអនុសញ្ញាចុងក្រោយ ត្រូវយកមកអនុវត្ត។ កិច្ចពិគ្រោះយោបល់នានារវាងភាគីពាក់ពន្ធ័ អំពីភាពផ្ទុយគ្នាទាក់ទងនឹងវិធានការពន្ធដារ ត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចផ្នែកពន្ធដារ ដូចមានចែងក្រោមច្បាប់ និងបញ្ញត្តិក្នុងស្រុករបស់ភាគីពាក់ព័ន្ធ។ ការ

ស្នើសុំឱ្យមានកិច្ចពិគ្រោះយោបល់ ត្រូវធ្វើតាមរយៈចំណុចទំនាក់ទំនងដែលបានចាត់តាំង តាមមាត្រា ២ (ទំនាក់ទំនង) នៃជំពូក ១៦ (បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន) ។

៦. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ តម្រូវឱ្យភាគីមួយផ្តល់នូវផលប្រយោជន៍ដល់ភាគីមួយផ្សេងទៀត តាមប្រព្រឹត្តិកម្មអនុគ្រោះពិសេស ដែលបានមកពីអ្វីដែលមាន ឬការព្រមព្រៀងគ្នាជាបន្តបន្ទាប់ ជាមួយនឹងការគេចចេញពីការជាប់ពន្ធដារត្រួតគ្នា ឬពី ខ ចែងនៃការគេចពន្ធត្រួតគ្នា នៃកិច្ចព្រមព្រៀងអន្តរជាតិ ឬធ្វើឡើងដោយភាគីដែលបានចងកាតព្វកិច្ច ។

៧. គោលបំណងនៃមាត្រានេះ វិធានការពន្ធដារមិនដាក់បញ្ចូលនៅក្នុងពន្ធនាំចូល ឬពន្ធគយ ។

## មាត្រា ៤
## វិធានការការពារតុល្យភាពចំណាយ

១. នៅពេលដែលភាគីមួយមានបញ្ហាតុល្យភាពចំណាយធ្ងន់ធ្ងរ និងការលំបាកហិរញ្ញវត្ថុពីខាងក្រៅ ឬក្រោមការគំរាមកំហែង គឺអាច :

(ក) ក្នុងករណីពាណិជ្ជកម្មទំនិញ ដោយយោងតាមកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ ១៩៩៤ និងការយោគយល់គ្នាស្តីពី ខ ចែងតុល្យភាពចំណាយ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ឆ្នាំ១៩៩៤ ដូចមានក្នុងឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀង ដែលអនុមត័លើការរឹតត្បិតវិធានការនាំចូល ។

(ខ) ក្នុងករណីពាណិជ្ជកម្មសេវាកម្ម គឺការអនុវត្ត ឬរឹតត្បិតពាណិជ្ជកម្មសេវាកម្ម ដែលអាចមានលើការសន្យាជាក់លាក់ រួមទាំងការចំណាយ ឬការផ្ទេរបញ្ជូនសំរាប់សកម្មភាពពាណិជ្ជកម្មពាក់ពន្ធ័នឹងការសន្យាផ្តល់ឱ្យ ។

(គ) ក្នុងករណីវិនិយោគ គឺការអនុវត្ត ឬរឹតត្បិតលើការចំណាយ ឬផ្ទេរបញ្ជូនការវិនិយោគ ដូចដែលមានបង្ហាញនៅក្នុងមាត្រា ២ (ក) (និយមន័យ) នៃជំពូក ១១ (វិនិយោគ) ។

២. ការរឹតត្បិតនានា ដែលបានអនុវត្ត ឬរក្សាទុកនៅក្រោមកថាខណ្ឌ ១ (ខ) ឬ (គ) ត្រូវ :

(ក) ឱ្យស្របគ្នាជាមួយនឹងមាត្រា នៃកិច្ចព្រមព្រៀងរូបិយវត្ថុអន្តរជាតិ (IMF)

(ខ) ជៀសវាងការខូចខាតដែលមិនចាំបាច់ ទៅលើអត្ថប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៃភាគីណាមួយផ្សេងទៀត ។

(គ) មិនឱ្យលើសពីសេចក្តីត្រូវការមាននៅក្នុងករណី ដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ១

(ឃ) ដំណើរការបណ្តោះអាសន្ន និងជាជំហាន១ ដូចស្ថានភាពដែលកែសំរួលក្នុងកថាខណ្ឌ ១

(ង) មូលដ្ឋានអនុវត្តមិនរើសអើង ដូចដែលមិនឱ្យមានសមាជិកណាមួយ មានភាពអនុគ្រោះតិចជាងភាគីណាមួយទៀត ឬមិនមែនជាភាគីនៃកិច្ចព្រមព្រៀង

៣. ពាក់ព័ន្ធនឹងពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ :

(ក) ទទួលស្គាល់ថា គំនាបពិសេសលើតុល្យភាពចំណាយនៃភាគីមួយ នៅក្នុងដំណើរនៃការអភិវឌ្ឍសេដ្ឋកិច្ច ឬបំលាស់ប្តូរសេដ្ឋកិច្ច អាចនឹងតំរូវឱ្យប្រើប្រាស់នូវការដាក់កំរិតនានា ដើម្បីទប់ទល់រក្សានូវកំរិតសេដ្ឋកិច្ចបំរុងមធ្យម សំរាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច ឬការបំលាស់ប្តូរសេដ្ឋកិច្ច ។

(ខ) នៅក្នុងការសំរេចលើទង្វើនៃការរឹតត្បិត ភាគីមួយអាចផ្តល់អាទិភាពឱ្យវិស័យសេដ្ឋកិច្ចដែលជាវិស័យសំខាន់បំផុតដល់សេដ្ឋកិច្ច ឬកម្មវិធីអភិវឌ្ឍន៍របស់គេ។ ទោះបីយ៉ាងណាក៏ដោយ ការរឹតត្បិតនានានឹងមិនត្រូវបានអនុវត្ត ឬរក្សាទុកសំរាប់គោលបំណងរារាំងដល់វិស័យសំខាន់ណាមួយ ។

៤. ការរឹតត្បិតនីមួយ១ បានអនុវត្ត ឬរក្សាទុកដោយភាគីមួយ តាមកថាខណ្ឌ ១ ឬការកែប្រែណាមួយ ត្រូវជូនដំណឹងឱ្យបានឆាប់ដល់ភាគីដទៃទៀត ។

៥. ភាគីមួយ ដែលកំពុងអនុវត្ត ឬរក្សាទុកនូវការរឹតត្បិតនានាក្រោមកថាខណ្ឌ ១ ត្រូវ :

(ក) ករណីវិនិយោគ ឆ្លើយតបទៅសំណើឱ្យមានការពិគ្រោះយោបល់របស់ភាគីណាមួយ ពាក់ព័ន្ធនឹងការរឹតត្បិតដែលបានអនុម័តដោយភាគីនោះ ប្រសិនបើមិនមានកិច្ចពិគ្រោះយោបល់ទេ នោះវានឹងត្រូវស្ថិតក្រៅកិច្ចព្រមព្រៀងនេះ ។

(ខ) ករណីពាណិជ្ជកម្មសេវាកម្ម ប្រសិនបើកិច្ចពិគ្រោះយោបល់ពាក់ពន្ធ័នឹងការអនុវត្តការរឹតត្បិត ដែលមិនមាននៅក្នុង WTO នោះត្រូវតែមានកិច្ចពិគ្រោះយោបល់រួមជាបន្ទាន់ ជាមួយភាគីណាមួយ ប្រសិនបើមានការស្នើសុំរបស់ភាគីមួយ ។

## មាត្រា ៥

## សន្ធិសញ្ញា Waitangi

១. ចែងថា វិធានការនានាមិនប្រើប្រាស់មានន័យជាអាជ្ញាកណ្តាល ឬការរើសអើងមិនសមរម្យ ដើម្បីប្រឆាំងបុគ្គលណាមួយនៃភាគីដទៃទៀត ឬដាក់ការរឹតត្បិតលើពាណិជ្ជកម្មទំនិញ ឬសេវាកម្ម គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវរារាំងដល់ការអនុវត្ត ដូចដែលវិធានការរបស់ប្រទេសណូវែលហ្សេឡង់ ដែលគិតថាសំខាន់សំរាប់អនុវត្ត ផ្តល់ភាពអនុគ្រោះដល់ជនជាតិភាគតិចម៉ូរី (Maori) ក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់នៃកិច្ចព្រមព្រៀងនេះ រួមទាំងការបំពេញកាតព្វកិច្ចតាមសិទ្ធិសញ្ញា Waitangi ។

២. ភាគីនីមួយៗ ឯកភាពថា ការបកស្រាយសន្ធិសញ្ញា Waitangi រួមមាន ដូចជាសិទ្ធិ និងកាតព្វកិច្ច ដែលមាននៅកិច្ចព្រមព្រៀងនេះ មិនមែនជាប្រធានបទនៃ ខ ចែងសំរាប់ដោះស្រាយវិវាទនៃកិច្ចព្រមព្រៀងនេះទេ។ ជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) ត្រូវអនុវត្តតាមបែបផ្សេងពីមាត្រានេះ។ តុលាការកាត់ក្តីមួយ បានបង្កើតឡើងដោយអនុលោមតាមមាត្រា ១១ (ការបង្កើត និងការប្រជុំឡើងវិញរបស់សាលាក្តី) នៃជំពូក ១៧ (ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ) អាចនឹងស្នើសុំ ដើម្បីកំណត់លើវិធានការណាមួយ (ដូចមានក្នុងកថាខណ្ឌ ១) ដែលផ្ទុយនឹងសិទ្ធិរបស់គេនៃកិច្ចព្រមព្រៀងនេះ ។

# ជំពូក ១៦
# បទប្បញ្ញត្តិនៃការរៀបចំស្ថាប័ន

## មាត្រា ១
## គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

១. ភាគីទាំងអស់ តាមរយៈនេះ បង្កើតគណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី) រួមមានតំណាងពីភាគីទាំងអស់។

២. មុខងាររបស់គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវមាន :

(ក) ពិនិត្យឡើងវិញពីការអនុវត្ត និង ការប្រតិបត្តិនៃកិច្ចព្រមព្រៀងនេះ

(ខ) ពិចារណា និងផ្តល់អនុសាសន៍ទៅបណ្តាភាគីនូវការកែប្រែទៅនឹងកិច្ចព្រមព្រៀងនេះ

(គ) ណែនាំ និង សម្របសម្រួលការងារនៃបណ្តាស្ថាប័ន ដែលបានបង្កើតបន្ថែម អនុលោមតាមកិច្ចព្រមព្រៀងនេះ

(ឃ) ណែនាំ ទីណាដែលសមរម្យ សម្រេច និង ផ្តល់អនុសាសន៍ដល់បណ្តាស្ថាប័ន ដែលបានបង្កើតបន្ថែម អនុលោមទៅតាមកិច្ចព្រមព្រៀងនេះ

(ង) ពិចារណាបញ្ហាដទៃណាមួយ ដែលអាចប៉ះពាល់ទៅនឹងការប្រតិបត្តិកិច្ចព្រមព្រៀងនេះ ឬ ផ្ទុកផ្តាក់ទៅលើគណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដោយបណ្តាភាគី. និង

(ច) បំពេញការងារនៅរាល់មុខងារដទៃណាមួយ ដែលបណ្តាភាគីអាចព្រមព្រៀង។

៣. ក្នុងការបំពេញមុខងាររបស់ខ្លួន គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចបង្កើតស្ថាប័នជំនួយបន្ថែម រួមទាំងក្រុមការងារ Ad hoc និង ចាត់តាំងពួកគេឱ្យទទួលភារកិច្ចតាមផ្នែកមួយៗ ឬផ្តល់ការទទួលខុសត្រូវទៅឱ្យស្ថាប័នជំនួយ ដែលបានបង្កើតអនុលោមទៅតាមកិច្ចព្រមព្រៀងនេះ រួមមាន :

(ក) គណៈកម្មាធិការទំនិញ ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១១ (គណៈកម្មាធិការពាណិជ្ជកម្មទំនិញ) នៃជំពូក ២ (ពាណិជ្ជកម្មទំនិញ)។

(i) អនុគណៈកម្មការវិធានដើមកំណើត ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១៨ (អនុគណៈកម្មការវិធានដើមកំណើត) នៃជំពូក ៣ (វិធានដើមកំណើត)។

(ii) អនុគណៈកម្មការអនាម័យ និងភូតគាមអនាម័យ ដែលបានបង្កើតឡើងអនុលោមទៅតាមមាត្រា ១០ (ជំនួបក្នុងចំណោមបណ្ដាភាគី ស្ដីពីបញ្ហាអនាម័យ និងភូតគាមអនាម័យ) នៃជំពូក ៥ (វិធានការអនាម័យ និង ភូតគាមអនាម័យ), និង

(iii) អនុគណៈកម្មាធិការស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា អនុលោមទៅតាមមាត្រា ១៣ (អនុគណៈកម្មការស្ដីពីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា) នៃជំពូក ៦ (ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពស្របគ្នា)។

(ខ) គណៈកម្មាធិការសេវាកម្ម ដែលបានបង្កើតអនុលោមតាមមាត្រា ២៤ (គណៈកម្មាធិការពាណិជ្ជកម្មសេវាកម្ម) នៃជំពូក ៨ (ពាណិជ្ជកម្មសេវាកម្ម)។

(គ) គណៈកម្មាធិការវិនិយោគ ដែលបានបង្កើតអនុលោមតាមមាត្រា ១៧ (គណៈកម្មាធិការវិនិយោគ) នៃជំពូក ១១ (វិនិយោគ), និង

(ឃ) គណៈកម្មាធិការកម្មសិទ្ធិបញ្ញា ដែលបានបង្កើតអនុលោមទៅតាមមាត្រា ១២ (គណៈកម្មាធិការកម្មសិទ្ធិបញ្ញា) នៃជំពូក ១៣ (កម្មសិទ្ធិបញ្ញា)។

៤. គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវបង្កើតវិធាន និងនីតិវិធីរបស់ខ្លួននៅក្នុងកិច្ចប្រជុំលើកទីមួយរបស់ខ្លួន។

៥. លើកលែងតែបណ្ដាភាគីព្រមព្រៀងផ្សេងពីនេះ គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី រៀបចំប្រជុំលើកទី១ របស់ខ្លួនក្នុងកំឡុងមួយឆ្នាំបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ បណ្ដាកិច្ចប្រជុំបន្ទាប់ទៀតត្រូវតែរៀបចំទៅតាមទម្លាប់ដូចដែលបណ្ដាភាគីអាចកំណត់ទៅវិញទៅមក និងតាមការចាំបាច់តាមមុខងាររបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ។ គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវរៀបចំប្រជុំឆ្លាស់គ្នានៅក្នុងប្រទេសសមាជិកអាស៊ាន និង អូស្ត្រាលី និងញូវែលហ្សេឡង់ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ។ កិច្ចប្រជុំពិសេសនៃគណៈកម្មាធិការចំរុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចរៀបចំទៅតាមការព្រមព្រៀងរបស់បណ្ដាភាគីក្នុងកំឡុង ៣០ ថ្ងៃ បន្ទាប់ពីការស្នើសុំដោយភាគីមួយ។

៦. គណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ត្រូវរាយការណ៍ជាប្រចាំទៅកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីពាណិជ្ជកម្មអូស្ត្រាលី និង រដ្ឋមន្ត្រីពាណិជ្ជកម្មណូវែលហ្សេឡង់ តាមរយៈកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចរបស់ខ្លួន។

## មាត្រា ២
## ទំនាក់ទំនង

ភាគីនីមួយៗ ត្រូវចាត់តាំងចំណុចទំនាក់ទំនង ដើម្បីសម្របសម្រួលទំនាក់ទំនងក្នុងចំណោមបណ្តាភាគី ចំពោះបញ្ហាដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងនេះ។ រាល់ទំនាក់ទំនងផ្លូវការ ត្រូវតែធ្វើឡើងជាភាសាអង់គ្លេស។

# ជំពូក ១៧
# ការពិគ្រោះយោបល់ និងការដោះស្រាយវិវាទ

## ផ្នែក ក
## បទប្បញ្ញត្តិផ្តើម

### មាត្រា ១
### គោលបំណង

គោលបំណងនៃជំពូកនេះគឺ ផ្តល់ប្រសិទ្ធភាព សមត្ថភាព និងតំលាភាពនៃដំណើរការសំរាប់ការពិគ្រោះ និងការដោះស្រាយវិវាទដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ ។

### មាត្រា ២
### និយមន័យ

សម្រាប់គោលបំណងនៃជំពូកនេះ និយមន័យខាងក្រោមត្រូវអនុវត្ត លើកលែងតែអត្ថបទតម្រូវផ្សេងពីនេះ :

(ក) **ភាគីប្តឹងតវ៉ា** មានន័យថា ភាគី ឬបណ្តាភាគីណាមួយ ដែលស្នើសុំការពិគ្រោះយោបល់ក្រោមមាត្រា ៦ (ការពិគ្រោះយោបល់)

(ខ) **វិវាទកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ** មានន័យថា ការប្តឹងតវ៉ាដែលធ្វើដោយភាគីមួយពាក់ព័ន្ធទៅនឹងវិធានការប៉ះពាល់ដល់ការប្រតិបត្តិ ការអនុវត្ត ឬបែបបទផ្សេងៗនៃកិច្ចព្រមព្រៀងនេះ ដោយហេតុនោះ ផលប្រយោជន៍ណាមួយកើតឡើងទៅលើភាគីប្តឹងតវ៉ាដោយផ្ទាល់ ឬ ដោយប្រយោលក្រោមកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ជាមោឃភាព ឬបង្អាក់ ឬមិនបានសម្រេចទៅនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ដែលជាលទ្ធផលពីភាគីត្រូវឆ្លើយតបខកខានមិនបានបំពេញកាតព្វកិច្ច[១] នៅក្រោមកិច្ចព្រមព្រៀងនេះ[២] ។

---

[១] ខកខានមិនបានបំពេញកាតព្វកិច្ចរួមមានទាំងការអនុវត្តដោយភាគី ត្រូវឆ្លើយតបនូវរាល់វិធានការណាមួយ ដែលខ្វាស់ទៅនឹងបណ្តាកាតព្វកិច្ចនៅក្រោមកិច្ចព្រមព្រៀងនេះ ។

[២] ការប្តឹងតវ៉ាដែលមិនប្រព្រឹត្តល្មើសមិនអនុញ្ញាតក្រោមកិច្ចព្រមព្រៀងនះ ។

(គ) **បណ្តាភាគីនៃវិវាទ** មានន័យថា ភាគីប្តឹងតវ៉ា និង ភាគីត្រូវឆ្លើយតប

(ឃ) **ភាគីត្រូវឆ្លើយតប** មានន័យថា ភាគីណាមួយដែលការស្នើសុំសំរាប់ពិគ្រោះយោបល់បានធ្វើឡើងក្រោមមាត្រា ៦ (ការពិគ្រោះយោបល់), និង

(ង) **ភាគីទីបី** មានន័យថា ភាគីដែលបានជូនពតិមានពីផលប្រយោជន៍ពាណិជ្ជកម្មជាដុំកំភួន ឬ ផលប្រយោជន៍ដុំកំភួននៅក្នុងបញ្ហាយោងតាមមាត្រា ៦.៧ (ការពិគ្រោះយោបល់) ឬ មាត្រា ១០.១ (បណ្តាភាគី ទីបី) ។

## មាត្រា ៣
## វិសាលភាព និងការគ្របដណ្តប់

១. លើកលែងតែមានការចែងផ្សេងពីកិច្ចព្រមព្រៀងនេះ ជំពូកនេះត្រូវអនុវត្តដើម្បីចៀសវាង ឬ ដោះស្រាយវិវាទកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។ ជំពូកនេះមិនត្រូវបានអនុវត្ត ចំពោះការដោះស្រាយវិវាទកើតឡើងក្រោមជំពូក ៥ (វិធានការអនាម័យ និង ភូតគាមអនាម័យ) ជំពូក ១០ (ពាណិជ្ជកម្មអេឡិចត្រូនិច) ជំពូក ១២ (សហប្រតិបត្តិការសេដ្ឋកិច្ច) និង ជំពូក ១៤ (ការប្រកួតប្រជែង) ។

២. ជំពូកនេះត្រូវអនុវត្តចំពោះប្រធានបទនៃបទប្បញ្ញត្តិសំខាន់ និងបន្ថែមស្តីពីការដោះស្រាយវិវាទដែលមាននៅក្នុងជំពូកដទៃទៀត នៃកិច្ចព្រមព្រៀងនេះ។

៣. យោងតាមមាត្រា ៥ (ការជ្រើសរើសវេទិកា) ជំពូកនេះនឹងមិនធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ភាគីមួយ ក្នុងការឧបាស្រ័យទៅនឹងនីតិវិធីដោះស្រាយវិវាទ មានក្រោមកិច្ចព្រមព្រៀងដទៃទៀតដែលជាភាគីមួយ ។

៤. ជំពូកនេះអាចអនុវត្ត ដោយគោរពទៅតាមវិធានការដែលជះឥទ្ធិពលដល់ការអនុវត្តបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលប្រកាន់យកដោយរដ្ឋាភិបាល ឬអាជ្ញាធរកណ្តាល តំបន់ ឬក្នុងស្រុកនៅក្នុងដែនដីរបស់ភាគីមួយ ។

## មាត្រា ៤
## បទប្បញ្ញត្តិទូទៅ

១. កិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយអនុលោមទៅតាមបណ្តាវិធានដែលជាទម្លាប់នៃនៃការបកស្រាយសន្ធិសញ្ញានៃច្បាប់អន្តរជាតិជាសាធារណៈ ។

២.	រាល់ការជូនពត៌មាន ការស្នើសុំ និងការឆ្លើយតបត្រូវធ្វើដោយអនុលោមទៅតាមជំពូកនេះ ត្រូវជាលាយលក្ខណ៍អក្សរ ។

៣.	ភាគីមានវិវាទទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យខិតខំដោះស្រាយឱ្យអស់លទ្ធភាព នៅគ្រប់ដំណាក់កាលវិវាទ ដើម្បីឈានទៅរកការព្រមព្រៀងរួមគ្នាក្នុងការដោះស្រាយវិវាទនោះ ។ នៅពេលដែលសម្រេចបាននូវការព្រមព្រៀងទៅវិញទៅមក ពាក្យស័ព្ទ និង លក្ខខណ្ឌ នៃការព្រមព្រៀង ត្រូវតែជូនពតិមានទៅភាគីដទៃទៀត ។

៤.	លើកលែងតែមានចែងដោយឡែក ពេលវេលាដែលមានផ្តល់នៅក្នុងជំពូកនេះអាចកែប្រែដោយ មានការព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគីនៃវិវាទ ដោយផ្តល់ថា ការកែប្រែណាមួយមិនត្រូវខូចខាតសិទ្ធិរបស់ភាគីទីបី អនុលោមទៅតាមមាត្រា ១០ ( ភាគីទីបី) ។

## មាត្រា ៥
## ការជ្រើសរើសវេទិកា

១.	ពេលដែលវិវាទពាក់ព័ន្ធនឹងបញ្ហាណាមួយ កើតឡើងក្រោមកិច្ចព្រមព្រៀងនេះ និងក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ដែលបណ្តាភាគីនៃវិវាទជាភាគី ភាគីប្តឹងតវ៉ាអាចជ្រើសរើសវេទិកាដើម្បីបង្ហាញបញ្ហាវិវាទ ហើយវេទិកានោះ ត្រូវប្រើប្រាស់ដើម្បីដកចេញពីវេទិកាដទៃទៀតពាក់ព័ន្ធនឹងបញ្ហានោះ ។

២.	សំរាប់គោលបំណងនៃមាត្រានេះ ភាគីប្តឹងតវ៉ាអាចចាត់ទុកថា ជាអ្នកជ្រើសរើសវេទិកា ដើម្បីដោះស្រាយវិវាទពេលដែលត្រូវបានស្នើឱ្យបង្កើតសាលាក្តី អនុលោមទៅតាមមាត្រា ៨ ( ការស្នើសុំសម្រាប់បង្កើតសាលាក្តី) ឬ សំណើក្នុងការបង្កើតនៃ ឬបញ្ជូនបញ្ហាទៅ ដូចគ្នាទៅនឹងគណៈវិនិច្ឆ័យដោះស្រាយវិវាទ នៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត ។

៣.	មាត្រានេះមិនអាចអនុវត្តបាន ទីណាដែលបណ្តាភាគីនៃវិវាទបានឯកភាពជាលាយលក្ខណ៍អក្សរថា មាត្រានេះមិនត្រូវអនុវត្តចំពោះវិវាទដោយឡែក ។

## ផ្នែក ខ
## បទប្បញ្ញត្តិពិគ្រោះយោបល់

### មាត្រា ៦
### ការពិគ្រោះយោបល់

១. ភាគីណាមួយអាចស្នើសុំការពិគ្រោះយោបល់ជាមួយភាគីដទៃណាមួយទៀត ដោយគោរពតាមទៅនឹងវិវាទណាមួយដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ។ ភាគីត្រូវឆ្លើយតបត្រូវពិចារណាទៅនឹងការស្នើសុំពិគ្រោះយោបល់ ដែលធ្វើដោយភាគីប្តឹងតវ៉ា និងត្រូវផ្តល់ឱកាសសមរម្យសំរាប់ការពិគ្រោះយោបល់នោះ។

២. ការស្នើសុំពិគ្រោះយោបល់ណាមួយ ត្រូវផ្តល់មូលហេតុក្នុងការស្នើសុំ រួមបញ្ចូលទាំងការកំណត់វិធានការនៃបញ្ហា និងប្រាប់ពីមូលដ្ឋានច្បាប់នៃការប្តឹងតវ៉ា។

៣. ច្បាប់ចំលងនៃការស្នើសុំ ត្រូវផ្តល់ដំណាលគ្នាទៅភាគីទាំងអស់។ ភាគីឆ្លើយតប ត្រូវជូនដំណឹងពីការទទួលបានការស្នើសុំជាបន្ទាន់ទៅគ្រប់ភាគី ដោយប្រាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ។

៤. ភាគីឆ្លើយតប លើកលែងតែមានការព្រមព្រៀងទៅវិញទៅមក ត្រូវឆ្លើយតបទៅនឹងការស្នើសុំក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួល ហើយត្រូវចូលខ្លួនពិគ្រោះក្នុងរយៈពេលមិនលើសពី :

(ក) ដប់ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ ក្នុងករណីបន្ទាន់ រួមទាំងករណីដែលពាក់ព័ន្ធដល់ទំនិញឆាប់ស្អុយរលួយ ឬ

(ខ) សាមសិបថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំទៅនឹងរាល់បញ្ហាដទៃទៀត។

៥. ប្រសិនបើភាគីឆ្លើយតប មិនបានចូលខ្លួនពិគ្រោះយោបល់ក្នុងរយៈពេល ដែលបញ្ជាក់ក្នុងកថាខ័ណ្ឌ ៤ ឬ រយៈពេលដែលព្រមព្រៀងទៅវិញទៅមក ភាគីបណ្តឹងអាចដំណើរការផ្ទាល់ស្នើសុំបង្កើតសាលាក្តី អនុលោមទៅតាមមាត្រា ៨ (ការស្នើសុំបង្កើតសាលាក្តី)។

៦. ភាគីវិវាទទាំងអស់ ត្រូវខិតខំប្រឹងប្រែងដើម្បីឈានទៅរកដំណោះស្រាយដែលពេញចិត្តទៅវិញទៅមកតាមរយៈការពិគ្រោះយោបល់។ ក្នុងន័យនេះ ភាគីវិវាទទាំងអស់ត្រូវ :

(ក) ផ្តល់ពត៌មានគ្រប់គ្រាន់ដែលអាចពិនិត្យបញ្ហាបានពេញលេញ រួមបញ្ចូលទាំងវិធានការនៃបញ្ហា ដែលប៉ះពាល់ដល់ការអនុវត្ត ឬ បែបបទនៃកិច្ចព្រមព្រៀងនេះ។

(ខ) ចាត់ទុកពតិមានផ្ទាល់ខ្លួន និងសម្ងាត់ ដែលបានផ្លាស់ប្តូរក្នុងពេលពិគ្រោះយោបល់ លើមូលដ្ឋានដូចគ្នា ដែលភាគីផ្តល់ពតិមានផ្តល់ជូន. និង

(គ) ខិតខំបង្កើតឱ្យមានបុគ្គលិក ឬភ្នាក់ងាររដ្ឋាភិបាល ឬស្ថាប័នបញ្ញត្តិផ្សេងទៀតសម្រាប់ការពិគ្រោះយោបល់ ដែលមានការទទួលខុសត្រូវចំពោះ និង/ឬ ជំនាញក្នុងបញ្ហាពិគ្រោះយោបល់ ។

៧. នៅពេលដែលភាគីដទៃមួយ មិនមែនភាគីនៃវិវាទ ពិចារណាថា នោះមានផលប្រយោជន៍ពាណិជ្ជកម្មដ៏កំភួននៅក្នុងការពិគ្រោះ ភាគីនោះអាចជូនពតិមានទៅបណ្តាភាគីនៃវិវាទក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីសេចក្តីជូនដំណឹងនៃការស្នើសុំពិគ្រោះ តាមការសម្រេចរបស់គេក្នុងការចូលរួមពិគ្រោះ ។ សេចក្តីជូនដំណឹងនោះ ត្រូវផ្តល់ទៅបណ្តាភាគីក្នុងពេលតែមួយ ។ ភាគីនោះអាចចូលរួមក្នុងការពិគ្រោះ ប្រសិនបើ បណ្តាភាគីនៃវិវាទព្រមព្រៀង ។

## មាត្រា ៧
## ការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម

១. បណ្តាភាគីនៃវិវាទអាច គ្រប់ពេលវេលាព្រមព្រៀងទៅនឹងការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម ។ នីតិវិធីសម្រុះសម្រួល ស្រុះស្រួល និងសន្ធានកម្ម អាចចាប់ផ្តើមគ្រប់ពេលវេលា និងបញ្ចប់គ្រប់ពេលវេលា ។

២. ប្រសិនបើភាគីនៃវិវាទបានព្រមព្រៀង នីតិវិធីសម្រុះសម្រួល ស្រុះស្រួល និងសន្ធានកម្ម អាចបន្តនៅពេលដែលបញ្ហាកំពុងតែពិនិត្យដោយសាលាក្តីដែលបានបង្កើត ឬ ចូលប្រជុំវិញក្រោមជំពូកនេះ ។

៣. ទម្រង់ការនៃការសម្រុះសម្រួល ការស្រុះស្រួល និងសន្ធានកម្ម និងដោយឡែក គោលជំហរដែលប្រកាន់យកដោយបណ្តាភាគីនៃវិវាទក្នុងរយៈពេលទម្រង់ការត្រូវរក្សាទុកជាសម្ងាត់ និងមិនប៉ះពាល់ដល់សិទ្ធិនៃភាគីវិវាទណាមួយនៅក្នុងទម្រង់ការបន្ត ឬ ទម្រង់ការដទៃទៀត ។

## ផ្នែក គ
## បទប្បញ្ញត្តិការវិនិច្ឆ័យ

### មាត្រា ៨
### ការស្នើសុំបង្កើតសាលាក្តី

១. ភាគីប្តឹងតវ៉ាអាចស្នើសុំបង្កើតសាលាក្តី ដើម្បីពិចារណាទៅលើបញ្ហាប្រសិនបើ :

(ក) ភាគីប្តឹងតវ៉ាមិនចូលរួមក្នុងការពិគ្រោះ អនុលោមទៅតាមមាត្រា ៦.៤ (ការពិគ្រោះយោបល់) ឬ

(ខ) ប្រសិនបើការពិគ្រោះខកខានក្នុងការដោះស្រាយវិវាទក្នុងកំឡុង :

(i) ២០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការស្នើសុំពិគ្រោះក្នុងករណីបន្ទាន់ រួមទាំងករណី ដែលពាក់ព័ន្ធដល់ទំនិញឆាប់ស្អុយរលួយ ឬ

(ii) ៦០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលការស្នើសុំពិគ្រោះ ដែលពាក់ព័ន្ធទៅនឹងបញ្ហាដទៃ ឬ

(iii) រយៈពេលទាំងនោះដូចដែលបណ្តាភាគីនៃវិវាទអាចព្រមព្រៀង។

២. ការស្នើសុំដែលបានធ្វើអនុលោមទៅតាមកថាខណ្ឌ ១ ត្រូវបញ្ជាក់វិធានការដោយឡែកទៅ នឹងបញ្ហា និង ផ្តល់លំអិតពីកត្តាជាក់ស្តែង និងមូលដ្ឋានច្បាប់នៃការប្តឹងតវ៉ា (រួមបញ្ចូលទាំងបណ្តាបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ ដើម្បីបង្ហាញទៅសាលាក្តី) គ្រប់គ្រាន់ក្នុងការបង្ហាញច្បាស់លាស់ពីបញ្ហា។

៣. ច្បាប់ចំលងទាំងអស់នៃការស្នើសុំត្រូវផ្តល់ដំណាលគ្នាទៅបណ្តាភាគី។ ភាគីត្រូវឆ្លើយតប ត្រូវជូនពតិមាន បន្ទាប់ពីបានទទួលការស្នើសុំតាមការជូនដំណឹងទៅភាគីទាំងអស់ ដើម្បីបញ្ជាក់ពីកាលបរិច្ឆេទនៃការទទួលការស្នើសុំ។

៤. ទីណាដែលការស្នើសុំបានធ្វើឡើងអនុលោមទៅតាមកថាខណ្ឌ ១ សាលាក្តីត្រូវតែបង្កើត អនុលោមទៅតាមមាត្រា ១១ (ការបង្កើត និងការប្រជុំឡើងវិញរបស់សាលាក្តី)។

## មាត្រា ៩
## ឧបករណ៍សម្រាប់អ្នកប្ដឹងតវ៉ាច្រើន

១. នៅពេលដែលមានភាគីលើសពីមួយ ស្នើសុំបង្កើតសាលាក្ដីដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចគ្នា សាលាក្ដីតែមួយអាចបង្កើត ដើម្បីពិនិត្យទៅលើបណ្ដឹងតវ៉ាទាំងនោះ ប្រសិនបើបណ្ដាភាគីនៃវិវាទព្រមព្រៀង។ បណ្ដាភាគីនៃវិវាទអាចស្វែងរកការបង្កើតសាលាក្ដីមួយពេលដែលអាចធ្វើទៅបាន។

២. សាលាក្ដីតែមួយ ត្រូវរៀបចំការពិនិត្យ និងបង្ហាញពីការស្វែងរកឃើញ ដែលទាំងនោះសិទ្ធិរបស់បណ្ដាភាគីនៃវិវាទ ត្រូវបានពេញចិត្ត ការដែលមានសាលាក្ដីដោយឡែកពិនិត្យរាល់ការប្ដឹងតវ៉ា ជាវិធីសាស្ត្រដែលមិនអន់ខ្សោយ។

៣. ប្រសិនបើសាលាក្ដីច្រើនជាងមួយបានបង្កើតឡើងដើម្បីពិនិត្យទៅលើការប្ដឹងតវ៉ាដែលពាក់ព័ន្ធ ទៅនឹងបញ្ហាដូចបណ្ដាភាគីនៃវិវាទអាចនឹងត្រូវធ្វើឱ្យប្រាកដថា មនុស្សដែលជាអាជ្ញាកណ្ដាលដូចគ្នានៅគ្រប់សាលាក្ដី។ បណ្ដាសាលាក្ដីត្រូវពិគ្រោះឱ្យប្រាកដថា តាមលទ្ធភាពដែលអាចធ្វើទៅបាន កម្មវិធីនៃដំណើរការសាលាក្ដីត្រូវដូចគ្នា។

## មាត្រា ១០
## ភាគីទីបី

១. ភាគីណាមួយដែលមានចំណាប់អារម្មណ៍ជាដុំកំភួន ទៅនឹងបញ្ហាមុនពេលសាលាក្ដីអាចជូនពត៌មានទៅបណ្ដាភាគីនៃវិវាទនៃចំណាប់អារម្មណ៍នេះ មិនឱ្យតិចជាងដប់ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួល ដោយភាគីត្រូវឆ្លើយតបទៅនឹងការស្នើសុំចំពោះ Compliance Review Tribunal អនុលោមទៅតាមមាត្រា ១៦ (Compliance Review)។ ការជូនពត៌មាននោះត្រូវតែផ្ដល់ដំណាលគ្នាទៅគ្រប់បណ្ដាភាគី។ ភាគីណាមួយជូនដំណឹងពីការចាប់អារម្មណ៍ជាដំកំភួនត្រូវមានសិទ្ធិ និងកាតព្វកិច្ចនៃភាគីទីបី។

២. ភាគីទីបីត្រូវទទួល ការផ្ដល់ដោយបណ្ដាភាគីនៃវិវាទ កិច្ចប្រជុំជាដុំកំភួនដំបូងរបស់សាលាក្ដី ជាមួយនឹងបណ្ដាភាគីនៃវិវាទ។

៣. ភាគីទីបីត្រូវមានឱកាសក្នុងការសរសេរជាលាយលក្ខណ៍អក្សរយ៉ាងតិចមួយ ផ្ដល់ទៅសាលាក្ដី និងត្រូវមានឱកាសក្នុងសវនាការសាលាក្ដី នៅក្នុងកិច្ចប្រជុំជាដុំកំភួនដំបូងជាមួយនឹងបណ្ដាភាគីនៃវិវាទ។

៤.	បណ្តាភាគីនៃវិវាទអាចឯកភាពក្នុងការផ្តល់សិទ្ធិបន្ថែម ទៅបណ្តាភាគីទីបីពាក់ព័ន្ធទៅនឹងការចូលរួមទម្រង់ការសាលាក្តី។ ក្នុងការផ្តល់សិទ្ធិបន្ថែម បណ្តាភាគីនៃវិវាទអាចដាក់លក្ខខណ្ឌខ្លះ។ លើកលែងតែមានការព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ សាលាក្តីមិនត្រូវផ្តល់សិទ្ធិបន្ថែមទៅបណ្តាភាគីទីបីពាក់ព័ន្ធ ទៅនឹងការចូលរួមក្នុងទម្រង់ការសាលាក្តី។

៥.	ប្រសិនបើភាគីទីបីពិចារណាថា វិធានការដែលមានជាប្រធានបទនៃទម្រង់ការសាលាក្តី ប៉ះពាល់ ឬខូចខាតផលប្រយោជន៍នៅក្រោមកិច្ចព្រមព្រៀងនេះ ភាគីអាចឧបាស្រ័យទៅនីតិវិធីដោះស្រាយវិវាទក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា ១១
## ការបង្កើត និងការប្រជុំឡើងវិញរបស់សាលាក្តី

១.	សាលាក្តីដែលបានស្នើសុំ អនុលោមទៅតាមមាត្រា ៨ ( ការស្នើសុំសំរាប់បង្កើតសាលាក្តី) ត្រូវបង្កើតដោយយោងទៅតាមមាត្រានេះ។

២.	លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេង សាលាក្តីត្រូវរួមមានអាជ្ញាកណ្តាលបីរូប។ រាល់ការតែងតាំង និងការជ្រើសរើសអាជ្ញាកណ្តាលក្រោមមាត្រានេះ ត្រូវតែប្រតិបត្តិតាមពេញលេញជាមួយនឹងតម្រូវការក្នុងកថាខណ្ឌ ៩ និង ១០។

៣.	ក្នុងកំឡុងប្រាំថ្ងៃនៃកាលបរិច្ឆេទទទួលការស្នើសុំក្រោមមាត្រា ៨ (ការស្នើសុំសំរាប់បង្កើតសាលាក្តី) បណ្តាភាគីនៃវិវាទត្រូវចូលរួមពិគ្រោះក្នុងគំនិតឈានទៅរកការព្រមព្រៀងលើទម្រង់ការ សំរាប់សមាសធាតុសាលាក្តី ដោយយកចិត្តទុកដាក់ទៅលើកត្តាជាក់ស្តែង បច្ចេកទេស និងច្បាប់នៃវិវាទ។ បណ្តាភាគីនៃវិវាទអាចព្រមព្រៀងក្នុងការប្រើប្រាស់ទម្រង់ការណាមួយ ដែលមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ របស់ជំពូកនេះស្តីពីទម្រង់ការសម្រាប់សមាសធាតុសាលាក្តី។ ទម្រង់ការណាមួយសំរាប់សមាសធាតុសាលាក្តី ដែលបានព្រមព្រៀងក្រោមកថាខណ្ឌនេះ ត្រូវប្រើប្រាស់ សម្រាប់សមាសធាតុសាលាក្តី និងត្រូវប្រើប្រាស់ សម្រាប់គោលបំណងនៃកថាខណ្ឌ ១២ និង ១៣។

៤.	ប្រសិនបើបណ្តាភាគីវិវាទមិនមានលទ្ធភាព ក្នុងការឈានទៅរកការព្រមព្រៀងលើទម្រង់ការសម្រាប់សមាសធាតុសាលាក្តីក្នុងកំឡុង ១៥ ថ្ងៃ នៃកាលបរិច្ឆេទទទួលការស្នើសុំដែលបានផ្តល់នៅក្នុងកថាខណ្ឌ ៣ ភាគីណាមួយនៃវិវាទអាចគ្រប់ពេលវេលាបន្ទាប់ពីនោះ ជូនពតិមានទៅបណ្តាភាគីនៃវិវាទថា មានបំណងចង់ប្រើ

ទម្រង់ការដែលមានចែងនៅក្នុងកថាខណ្ឌ ៥ ទៅ ៧។ នៅពេលដែលការជូនពតិមាន នោះត្រូវបានធ្វើឡើង សាលាក្តីត្រូវមានសមាសធាតុអនុលោមទៅតាមកថាខណ្ឌ ៥ ទៅ ៧។

៥. ភាគីប្តឹងតវ៉ា ឬ បណ្តាភាគីត្រូវតែងតាំងអាជ្ញាកណ្តាលមួយរូបក្នុងកំឡុងដប់ថ្ងៃនៃការបរិច្ឆេទ ទទួលសេចក្តីជូនពតិដែលមានចែងនៅក្នុងកថាខណ្ឌ ៤។ ភាគីត្រូវឆ្លើយតប ត្រូវតែងតាំងអាជ្ញាកណ្តាល មួយរូបក្នុងកំឡុង ២០ ថ្ងៃ នៃកាលបរិច្ឆេទទទួលសេចក្តីជូនពតិមានដែលមានចែងនៅក្នុងកថាខណ្ឌ ៤។

៦. ទៅតាមការចាត់តាំងអាជ្ញាកណ្តាលយោងតាមកថាខណ្ឌ ៥ បណ្តាភាគីនៃវិវាទត្រូវព្រមព្រៀង ទៅលើការចាត់តាំងអាជ្ញាកណ្តាលទីបី ដែលជាអ្នកបំរើជាប្រធានសាលាក្តី។ ដើម្បីចូលរួមក្នុងការឈានទៅរកការព្រមព្រៀងនេះ បណ្តាភាគីនៃវិវាទនីមួយៗអាចផ្តល់ទៅបណ្តាភាគីវិវាទដទៃទៀតនូវបញ្ជីអ្នក ដែលត្រូវ ជ្រើសរើសបីរូបសម្រាប់ការតែងតាំងរបស់ប្រធានសាលាក្តី។ ប្រសិនបើបណ្តាភាគីនៃវិវាទមិនទាន់ព្រមព្រៀងលើប្រធានសាលាក្តី ក្នុងកំឡុង ១៥ ថ្ងៃ នៃការតែងតាំងអាជ្ញាកណ្តាលលើកទីពីរ អាជ្ញាកណ្តាល ដែលតែងតាំងទាំងពីររូបត្រូវជ្រើសរើស ដោយការព្រមព្រៀងរួមអាជ្ញាកណ្តាលទីបី ដែលជាប្រធានសាលាក្តី។

៧. ប្រសិនបើអាជ្ញាកណ្តាលទាំងបីមិនទាន់ត្រូវបានចាត់តាំងក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទទទួលសេចក្តីជូនពតិមាន យោងទៅតាមកថាខណ្ឌ ៤ ភាគីនៃវិវាទណាមួយអាចស្នើទៅអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីចាត់តាំងអ្នកដែលនៅសេសសល់ នៅក្នុងកំឡុង ១៥ ថ្ងៃខាងមុខ។ បញ្ជីអ្នកត្រូវបានជ្រើសរើស ណាមួយដែលផ្តល់ក្រោមកថាខណ្ឌ ៦ នឹងត្រូវផ្តល់ទៅអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក និងអាចប្រើសម្រាប់តម្រូវការចាត់តាំង។

៨. កាលបរិច្ឆេទនៃការបង្កើតសាលាក្តីត្រូវតែជាកាលបរិច្ឆេទនៃការចាត់តាំងអាជ្ញាកណ្តាលចុងក្រោយ។

៩. អាជ្ញាកណ្តាលទាំងអស់ត្រូវ :

(ក) មានជំនាញ ឬ បទពិសោធន៍ច្បាប់ពាណិជ្ជកម្មអន្តរជាតិ បញ្ហាផ្សេងដែលគ្របដណ្តប់ ដោយកិច្ចព្រមព្រៀងនេះ ឬ ការដោះស្រាយវិវាទផ្សេងៗដែលកើតឡើងពីបណ្តាកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ

(ខ) ត្រូវបានជ្រើសរើសដោយម៉ត់ចត់ដោយផ្អែកលើ កម្មវត្ថុ ភាពទុកចិត្តបាន និង យុត្តិធម៌

(គ) ត្រូវឯករាជ្យ និងមិនត្រូវទាក់ទង ឬ ទទួលយកការណែនាំពីភាគីណាមួយនៃវិវាទ

(ឃ) មិនត្រូវប្រព្រឹត្តិទៅនឹងបញ្ហាទៅតាមសមត្ថភាពណាមួយ និង

(ង) បង្ហាញទៅ បណ្តាភាគីនៃវិវាទ ពតិមានដែលអាចកើតមានចម្ងល់ ទៅនឹងឯករាជ្យភាព ឬ ជាភាពមិនលំអៀង ។

១០. លើកលែងតែភាគីនៃវិវាទព្រមព្រៀង អាជ្ញាកណ្តាលមិនត្រូវជាជនជាតិនៃភាគីមួយនៃវិវាទ ។ បន្ថែមពីនោះ ប្រធានសាលាក្តីមិនត្រូវមានទីលំនៅក្នុងដែនដីរបស់ភាគីមួយនៃវិវាទ ។

១១. អាជ្ញាកណ្តាលត្រូវតែបំរើទៅតាមសមត្ថភាពបុគ្គល និងមិនមែនជាតំណាងពីស្ថាប័នរដ្ឋ ព្រមទាំងមិនមែនជាតំណាងពីស្ថាប័នណាមួយ ។ បណ្តាភាគីមិនត្រូវផ្តល់ការណែនាំ ទាំងមិនត្រូវមានឥទ្ធិពលទៅលើពួកគេ ដោយបុគ្គល ដែលពាក់ព័ន្ធទៅនឹងបញ្ហាមុនសាលាក្តី ។

១២. ប្រសិនបើអាជ្ញាកណ្តាលចាត់តាំងក្រោមមាត្រានេះលាឈប់ ឬ មិនអាចមានលទ្ធភាពបន្ត អាជ្ញាកណ្តាលរង ត្រូវចាត់តាំងទៅតាមលំនាំដូច សម្រាប់ការចាត់តាំងអាជ្ញាកណ្តាលដើម និងមានអំណាច និងការងារទាំងអស់នៃអាជ្ញាកណ្តាលចាស់ ។ ការងាររបស់សាលាក្តីអាចពន្យារក្នុងដំណាក់កាលចាត់តាំង អាជ្ញាកណ្តាលរង ។

១៣. ទីណាដែលសាលាក្តីប្រជុំឡើញវិញក្រោមមាត្រា ១៦ (Compliance Review) ឬ មាត្រា ១៧ (ការទូទាត់សង និង ការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) បើអាចធ្វើទៅបាន សាលាក្តីប្រជុំឡើងវិញ ត្រូវមានអាជ្ញាកណ្តាល ដូចអាជ្ញាកណ្តាលដើម ។ ទីណាដែលមិនអាចទៅបាន ការផ្លាស់ប្តូរអាជ្ញាកណ្តាល ត្រូវតែចាត់តាំងទៅតាមលំនាំដូច សំរាប់ការចាត់តាំងអាជ្ញាកណ្តាលដើម និងត្រូវមានអំណាច និងការងាររបស់អាជ្ញាកណ្តាលដើម ។

## មាត្រា ១២
## មុខងារសាលាក្តី

១. សាលាក្តីត្រូវធ្វើការប្រមាណគោលដៅនៃបញ្ហាមុន រួមមានទាំងទិសដៅប៉ាន់ប្រមាណដូចជា :

(ក) ការពិតរបស់ករណី

(ខ) ភាពអាចអនុវត្តបាននៃបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ដែលបានដកស្រង់ដោយបណ្តាភាគីនៃវិវាទ

(គ) ពិនិត្យមើលថាតើភាគីត្រូវឆ្លើយតបខកខានមិនបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ។

២. សាលាក្តីត្រូវមានលក្ខខណ្ឌការងារ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះក្នុងកំឡុង ២០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តី :

"ពិនិត្យទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀងនេះ បញ្ហាដែលយោងទៅតាមការស្នើសុំបង្កើតសាលាក្តី ដែលបានធ្វើឡើងដោយអនុលោមទៅតាមមាត្រា ៨ (ការស្នើសុំសម្រាប់បង្កើតសាលាក្តី) និងត្រូវធ្វើការស្វែងរក និងប្រសិនបើអាចទៅបាន ធ្វើការសុំយោបល់ដែលមានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ។"

សាលាក្តីត្រូវស្វែងរកឱ្យឃើញ ទៅតាមកិច្ចព្រមព្រៀងនេះ។

៣. សាលាក្តីត្រូវធ្វើរបាយការណ៍ :

(ក) ផ្អែកពិពណ៌នាដោយសង្ខេបពីជម្លោះរបស់បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី

(ខ) ស្វែងរកការពិតនៃករណី និងភាពអាចអនុវត្តបានចំពោះបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ

(គ) ស្វែងរកមើលថា តើភាគីត្រូវឆ្លើយតបបានខកខានក្នុងការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ និង

(ឃ) មូលហេតុនៃការរកឃើញនៅក្នុងកថាខណ្ឌរង (ខ) និង គ)។

៤. ក្នុងការបន្ថែមទៅនឹងកថាខណ្ឌ ៣ អាចរួមបញ្ចូលទាំងរបាយការណ៍ និងការរកឃើញរបស់វា ជាមួយនឹងការចូលរួមជាមួយការស្នើរបស់ភាគីនៃវិវាទ។ សាលាក្តីអាចស្នើតាមវិធីសាស្ត្រដែលភាគីត្រូវឆ្លើយតបអាចអនុវត្តបាននៅការស្វែងរកឃើញ។

៥. លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ សាលាក្តីត្រូវផ្អែកទៅលើរបាយការណ៍របស់ខ្លួនដោះស្រាយលើបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងផ្តល់ និងជម្លោះរបស់បណ្តាភាគីនៃវិវាទ។ សាលាក្តីត្រូវធ្វើការរកឱ្យឃើញ និងស្នើយោបល់ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។

៦. បណ្តាភាគីទីបីដែលចាប់អារម្មណ៍ និងបណ្តាភាគីដទៃទាំងនោះត្រូវយកចិត្តទុកដាក់ឱ្យបានពេលលេញលើទម្រង់ការសាលាក្តី ការផ្តល់ដោយបណ្តាភាគីទីបីត្រូវតែមានចែងនៅក្នុងរបាយការណ៍របស់សាលាក្តី។

៧. ការរកឃើញ និងការផ្តល់យោបល់របស់សាលាក្តី មិនអាចបន្ថែម ឬ លុបចោលសិទ្ធិ និងកាតព្វកិច្ចដែលមានផ្តល់នៅក្នុងកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត។

៨. សាលាក្តីត្រូវពិគ្រោះជាប្រចាំជាមួយបណ្តាភាគីនៃវិវាទ និងផ្តល់ឱកាសគ្រប់គ្រាន់សម្រាប់អភិវឌ្ឍដំណោះស្រាយពេញចិត្តទៅវិញទៅមកទៅនឹងវិវាទ។

៩. សាលាក្តីប្រជុំឡើងវិញក្រោមជំពូកនេះ ត្រូវបំពេញមុខងារដែលពាក់ព័ន្ធជាមួយនឹង Compliance Review ក្រោមមាត្រា ១៦ (Compliance Review) និងសើរើឡើងវិញកំរិតនៃការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃក្រោមមាត្រា ១៧ (ការទូទាត់សង និងការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត)។ កថាខណ្ឌ ១ ដល់ ៣ មិនត្រូវអនុវត្តចំពោះសាលាក្តីប្រជុំឡើងវិញក្រោមមាត្រា ១៦ (Compliance Review) និង មាត្រា ១៧ (ការទូទាត់សង និងការព្យួរសម្បទាន ឬ កាតព្វកិច្ចដទៃទៀត)។

១០. សាលាក្តីត្រូវធ្វើការរកឱ្យឃើញដោយឯកភាពទូទៅ ដោយផ្តល់ថាទីណាដែលសាលាក្តីមិនអាចឈានទៅរកឯកភាពទូទៅ គឺអាចរកឃើញដោយធ្វើការបោះឆ្នោតដោយសំលេងភាគច្រើន។

## មាត្រា ១៣
## ទម្រង់ការសាលាក្តី

១. សាលាក្តីដែលបង្កើតអនុលោមទៅតាមមាត្រា ១១ (ការបង្កើត និងការប្រជុំឡើងវិញរបស់សាលាក្តី) ត្រូវតែប្រកាន់ភ្ជាប់ទៅនឹងជំពូកនេះ។ សាលាក្តីត្រូវអនុវត្តវិធាននៃទម្រង់ការដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃជំពូកនេះស្តីពី វិធានសំរាប់ទម្រង់ការសាលាក្តី (ឧបសម្ព័ន្ធស្តីពីវិធាននៃទម្រង់ការ) លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ។ ទៅតាមការស្នើដោយភាគីមួយនៃវិវាទ ឬទៅតាមដើមគំនិតរបស់ខ្លួន សាលាក្តីអាច បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ អនុម័តវិធានបន្ថែមនៃទម្រង់ការ ដែលមិនមានជម្លោះទៅនឹងបទប្បញ្ញត្តិនៃជំពូកនេះ ឬទៅនឹងឧបសម្ព័ន្ធនៃវិធានទម្រង់ការ។

២. សាលាក្តីប្រជុំឡើងវិញក្រោមមាត្រា ១៦ (Compliance Review) ឬ មាត្រា ១៧ (ការទូទាត់សង និងការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) អាចបង្កើតទម្រង់ការដោយផ្ទាល់ដែលមិនមានជម្លោះទៅនឹងជំពូកនេះ ឬ ទៅនឹងឧបសម្ព័ន្ធនៃវិធានទម្រង់ការ ដោយពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ ដែលធ្វើឡើងយ៉ាងសមរម្យពីជំពូកនេះ ឬ ទៅនឹងឧបសម្ព័ន្ធនៃវិធានទម្រង់ការ។

**តារាងពេលវេលា**

៣. បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ សាលាក្តីត្រូវឆាប់ដូចដែលអនុវត្តជាក់ស្តែង និង តាមពេលណាដែលអាចធ្វើទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីបង្កើតសាលាក្តីកំណត់តារាងពេលវេលាជាក់លាក់សំរាប់ដំណើរការសាលាក្តី។ ដំណើរការសាលាក្តី ចាប់ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តីរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយត្រូវទៅតាមវិធានទូទៅ មិនលើសពីរយៈពេលប្រាំបួនខែ លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ។

៤. ដូចគ្នាទៅនឹង Compliance Review Tribunal re-convened អនុលោមទៅតាមមាត្រា ១៦ (Compliance Review) ត្រូវឆាប់ដូចដែលអនុវត្តជាក់ស្តែង និងតាមពេលណាដែលអាចទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីប្រជុំឡើងវិញ កំណត់តារាងពេលវេលាជាក់លាក់ សម្រាប់ដំណើរការ Compliance review ដោយយកចិត្តទុកដាក់ទៅលើពេលវេលាបញ្ជាក់នៅក្នុងមាត្រា ១៦ (Compliance Review) ។

**ទម្រង់ការសាលាក្តី**

៥. ទម្រង់ការសាលាក្តីត្រូវផ្តល់ភាពទន់ភ្លន់គ្រប់គ្រាន់ ដើម្បីធានាលើរបាយការណ៍គុណភាពខ្ពស់ ដោយមិនជ្រុលពន្យារដំណើរការសាលាក្តី ។

៦. ការពិភាក្សារបស់សាលាក្តីត្រូវតែជាសម្ងាត់ ។ បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ត្រូវមានវត្តមានតែនៅពេលដែលអញ្ជើញដោយសាលាក្តីដើម្បីបង្ហាញមុនពេលសាលាក្តី ។ សាលាក្តីត្រូវរក្សា សវនាការដោយបិទជិត លើកលែងតែភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។ គ្រប់បទបង្ហាញ និងសុន្ទរកថា ត្រូវធ្វើឡើងដោយមានវត្តមានរបស់បណ្តាភាគីនៃវិវាទ ។ មិនត្រូវមានការទំនាក់ទំនងជាមួយសាលាក្តីពាក់ព័ន្ធនឹងបញ្ហាកំពុងតែស្ថិតនៅក្នុងការពិចារណា ។

**ការផ្តល់**

៧. ភាគីមួយនៃវិវាទ ត្រូវមានឱកាសក្នុងការសរសេរភាពជាក់ស្តែងរបស់ករណី ការជំទាស់ និងការជំទាស់តប ។ តារាងពេលវេលាដែលកំណត់ដោយសាលាក្តី ត្រូវរួមបញ្ចូលឱ្យច្បាស់លាស់កាលកំណត់ សម្រាប់ការផ្តល់ដោយបណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ។

**សវនាការ**

៨. តារាងពេលវេលាដែលកំណត់ដោយសាលាក្តីត្រូវផ្តល់យ៉ាងតិចសវនាការម្តង សម្រាប់បណ្តាភាគី នៃវិវាទដើម្បីបង្ហាញករណីរបស់ពួកគេទៅសាលាក្តី ។ តាមវិធានទូទៅ តារាងពេលវេលាមិនត្រូវឱ្យមានសវនាការលើសពីពីរ លើកលែងតែមានព្រឹត្តិការណ៍ពិសេស ។

៩. ទីកន្លែងសម្រាប់សវនាការ ត្រូវសម្រេចដោយព្រមព្រៀងទៅវិញទៅមករវាងបណ្តាភាគីនៃវិវាទ ។ ប្រសិនបើមិនមានការព្រមព្រៀង ទីកន្លែងត្រូវតែឆ្លាស់គ្នារវាងរាជធានីរបស់បណ្តាភាគីវិវាទ ដែលសវនាការទី១ ត្រូវប្រព្រឹត្តិទៅនៅក្នុងរាជធានីរបស់ភាគីត្រូវឆ្លើយតប ។

**ការសម្ងាត់**

១០. ការសរសេរផ្តល់ទៅសាលាក្តីត្រូវតែរក្សាជាសម្ងាត់ ប៉ុន្តែត្រូវធ្វើឱ្យរកបានទៅបណ្តាភាគីនៃវិវាទ។ មិនមានភាគីនៃវិវាទត្រូវបានរារាំងពីសន្និរកថាបង្ហាញពីជំហររបស់គេទៅសាធារណៈដោយផ្តល់ថា មិនមានការបង្ហាញពីពតិមានដែលកំណត់ថាសម្ងាត់ដោយភាគីមួយនៃវិវាទ ឬ ភាគីទីបី។ បណ្តាភាគីនៃវិវាទ បណ្តាភាគីទីបី និង សាលាក្តីត្រូវប្រព្រឹត្តជាសម្ងាត់នូវពតិមានដែលបានផ្តល់ដោយភាគីមួយនៃវិវាទ ទៅសាលាក្តីដែលភាគីនោះ បានចាត់ទុកថា ជាសម្ងាត់។ ភាគីមួយនៃវិវាទត្រូវ នៅពេលដែលមានការស្នើសុំដោយ ភាគីមួយផ្តល់ពតិមានសង្ខេបដែលមិនសម្ងាត់ នៅក្នុងការសរសេរផ្តល់ដែលសម្រាប់ បង្ហាញទៅសាធារណៈ។

**ពតិមានបន្ថែម និង ការណែនាំបច្ចេកទេស**

១១. បណ្តាភាគីនៃវិវាទ និង បណ្តាភាគីទីបីត្រូវឆ្លើយតបជាប្រញាប់ និងពេញលេញទៅនឹងការស្នើសុំណាមួយ ដោយសាលាក្តី ចំពោះពតិមានដែលសាលាក្តីពិចារណាថាសំខាន់ និងសមរម្យ។

១២. សាលាក្តីអាចសាកសួររកពតិមាន និងការណែនាំបច្ចេកទេសពីបុគ្គល ឬស្ថាប័នដែលខ្លួនយល់ថា សមរម្យ។ យ៉ាងណាក៏ដោយ មុនពេលធ្វើដូចនេះ សាលាក្តីត្រូវសាកសួរយោបល់ពីបណ្តាភាគីនៃវិវាទ។ ទីណាដែលបណ្តាភាគីនៃវិវាទព្រមព្រៀងថា សាលាក្តីមិនអាចសាកសួរពតិមានបន្ថែម ឬ ការណែនាំបច្ចេកទេស សាលាក្តីមិនត្រូវធ្វើដូចនេះឡើយ។ សាលាក្តីត្រូវផ្តល់ឱ្យបណ្តាភាគីនៃវិវាទនូវពតិមាន ឬ ការណែនាំ បច្ចេកទេសដែលទទួលបាន និង ឱកាសសម្រាប់ផ្តល់អនុសាសន៍។

**របាយការណ៍**

១៣. សាលាក្តីត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទរនូវរបាយការណ៍តំបូង ទៅតាមការតម្រូវ ដែលមានបញ្ជាក់នៅក្នុងមាត្រា ១២.៣ ( មុខងារសាលាក្តី )។

១៤. របាយការណ៍ដំបូងត្រូវផ្តល់យ៉ាងតិចបួនសប្តាហ៍ មុនកាលកំណត់ សម្រាប់បញ្ចប់ របាយការណ៍ចុងក្រោយ។ សាលាក្តីត្រូវផ្តល់ឱកាសគ្រប់គ្រាន់ទៅបណ្តាភាគីនៃវិវាទដើម្បីរំលឹកឡើងវិញនូវរបាយការណ៍ដំបូង ទាំងមូលមុនពេលបញ្ចប់ និងរួមបញ្ចូលការពិភាក្សាទៅលើអនុសាសន៍ណាមួយ ដែលបានធ្វើឡើងដោយបណ្តាភាគីនៃវិវាទ នៅក្នុងរបាយការណ៍ចុងក្រោយ។

១៥. របាយការណ៍ដំបូង និងចុងក្រោយរបស់សាលាក្តីត្រូវព្រាងដោយមិនមានវត្តមានរបស់បណ្តាភាគី នៃវិវាទ។ គំនិតដែលបញ្ចេញទៅក្នុងរបាយការណ៍របស់សាលាក្តីដោយសមាជិកម្នាក់ត្រូវតែអនាមិក។

១៦. សាលាក្តីត្រូវផ្តល់របាយការណ៍ចុងក្រោយរបស់ខ្លួន ទៅបណ្តាភាគីទាំងអស់ក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីរាយការណ៍ទៅបណ្តាភាគីវិវាទ និងគ្រប់ពេលវេលា ក្រោយពីពេលនោះមកភាគីមួយនៃវិវាទអាចរាយការណ៍ ដែលអាចរកបានជាសាធារណៈ ក្នុងគោលបំណងការពារនូវពត៌មានសម្ងាត់ដែលមានក្នុងរបាយការណ៍នោះ ។

## មាត្រា ១៤

## ការព្យួរ និងការបញ្ឈប់ទម្រង់ការ

១. បណ្តាភាគីនៃវិវាទអាចព្រមព្រៀងថា នឹងព្យួរការងារនៅក្នុងពេលណាមួយសំរាប់រយៈពេល ដែលមិនលើសពី ១២ ខែ ពីកាលបរិច្ឆេទនៃការព្រមព្រៀង ។ នៅក្នុងរយៈពេលនោះការព្យួរទម្រង់ការ សាលាក្តី ត្រូវតែបន្តនៅពេលដែលមានការស្នើសុំដោយភាគីវិវាទណាមួយ ។ ប្រសិនបើការងារសាលាក្តីត្រូវបានបន្តព្យួរលើសពី ១២ ខែ អំណាចនៃការបង្កើតសាលាក្តីត្រូវតែអស់សុពលភាព លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

២. បណ្តាភាគីនៃវិវាទអាចព្រមព្រៀងក្នុងការបញ្ឈប់ទម្រង់ការសាលាក្តី នៅក្នុងស្ថានការណ៍ដែលបាន រកឃើញដំណោះស្រាយទៅនឹងវិវាទដោយពេញចិត្តទៅវិញទៅមក ។

៣. មុនពេលដែលសាលាក្តីបង្ហាញពីរបាយការណ៍ចុងក្រោយ ថាអាចនៅក្នុងដំណាក់កាលណា ក៏ដោយនៃ ទម្រង់ការ ស្នើទៅបណ្តាភាគីនៃវិវាទថា វិវាទត្រូវបានដោះស្រាយដោយអធ្យាស្រ័យ ។

៤. បណ្តាភាគីនៃវិវាទត្រូវជូនពត៌មានទៅភាគីដទៃទៀតថា សាលាក្តីត្រូវបានព្យួរ បញ្ឈប់ ឬអំណាច របស់ខ្លួនត្រូវអស់សុពលភាពអនុលោមទៅតាមកថាខណ្ឌ ១ ។

# ផ្នែក ឃ

# បទប្បញ្ញត្តិអនុវត្ត

## មាត្រា ១៥

## ការអនុវត្ត

១. ទីណាដែលសាលាក្តីរកឃើញថា ភាគីត្រូវឆ្លើយតប ខកខានក្នុងការបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះភាគីត្រូវឆ្លើយតបត្រូវប្រតិបត្តិតាមកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ។

២. ក្នុងកំឡុង ៣០ ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តី ទៅបណ្តាភាគីនៃវិវាទ ភាគីដែលត្រូវឆ្លើយតបត្រូវជូនពត៌មានទៅភាគីប្តឹងតវ៉ា :

(ក) គោលបំណងនៃការគោរពទៅតាមការអនុវត្ត រួមបញ្ចូលទាំងការកំណត់ពីសកម្មភាព ដែលអាចអនុវត្ត ដើម្បីប្រតិបត្តិតាមកាតព្វកិច្ចនៅក្នុងកថាខណ្ឌ ១។

(ខ) ការអនុវត្តទាំងនោះអាចចាប់ផ្តើមភ្លាមៗ និង

(គ) ប្រសិនបើការអនុវត្តមិនអាចចាប់ផ្តើមភ្លាមៗ ពេលវេលាសមរម្យមួយដែលភាគីត្រូវឆ្លើយតបអាចត្រូវការសំរាប់ការអនុវត្ត។

៣. ប្រសិនបើមិនធ្លាប់មានការអនុវត្តភ្លាមៗជាមួយនឹងកាតព្វកិច្ច ដែលមាននៅក្នុងកថាខណ្ឌ ១ ភាគីត្រូវឆ្លើយតប ត្រូវមានពេលវេលាសមរម្យសំរាប់ធ្វើដូចនោះ។

៤. ប្រសិនបើតម្រូវទៅតាមពេលវេលាសមរម្យ វាអាចនៅពេលណាដែលអាចព្រមព្រៀងទៅវិញទៅមកដោយបណ្តាភាគីនៃវិវាទ។ ទីណាដែលបណ្តាភាគីនៃវិវាទមិនមានការព្រមព្រៀងទៅលើពេលវេលាសមរម្យ ក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តីទៅបណ្តាភាគីនៃវិវាទ ភាគីណាមួយនៃវិវាទ អាចស្នើសុំទៅប្រធានសាលាក្តីដើម្បីកំណត់ពេលវេលា។ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេង ការស្នើសុំត្រូវធ្វើឡើងមិនឱ្យតិចជាង ១២០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តី ទៅបណ្តាភាគីនៃវិវាទ។

៥. ទីណាដែលការស្នើសុំដែលបានធ្វើអនុលោមទៅតាមកថាខណ្ឌ ៤ ប្រធានសាលាក្តីត្រូវបង្ហាញ ទៅបណ្តាភាគីនៃវិវាទជាមួយនឹងរបាយការណ៍ដែលមានការកំណត់ពីពេលវេលាសមរម្យ និងមូលហេតុនៃការកំណត់នោះក្នុងកំឡុង ៤៥ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ ។

៦. ដូចដែលមាននៅក្នុងគោលការណ៍ណែនាំ ពេលវេលាដែលសមរម្យកំណត់ដោយប្រធានសាលាក្តីមិនត្រូវលើស ១៥ ខែ ពីកាលបរិច្ឆេទនៃការបង្ហាញរបាយការណ៍ចុងក្រោយរបស់សាលាក្តីទៅបណ្តាភាគីវិវាទ ។ យ៉ាងណាមិញ ពេលវេលាសមរម្យអាចខ្លីជាង ឬ វែងជាង ដោយផ្អែកទៅលើហេតុការណ៍ ជាក់លាក់ណាមួយ ។

## មាត្រា ១៦
## ការត្រួតពិនិត្យភាពស្របគ្នា

១. ទីណាដែលបណ្តាភាគីនៃវិវាទមិនមានការព្រមព្រៀងទៅលើភាពដែលមានស្រាប់ ឬ ភាពជាប់លាប់នៃវិធានការនៃកិច្ចព្រមព្រៀងនេះប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ ( ការអនុវត្ត) វិវាទទាំងនោះត្រូវសំរេចតាមរយៈបណ្តឹងសើរើ ទៅសាលាក្តីប្រជុំឡើងវិញ សម្រាប់គោលបំណង ( សាលាឧទ្ធរណ៍)[៣] ។ លើកលែងតែមានការចែងជាក់លាក់នៅក្នុងជំពូកនេះ សាលាឧទ្ធរណ៍អាចចាប់ផ្តើមទៅតាមការស្នើសុំរបស់ភាគីវិវាទណាមួយ ។

២. ការស្នើសុំនោះអាចធ្វើឡើងបន្ទាប់ពីមុនពេលកំណត់តែប៉ុណ្ណោះនៃ :

( ក ) ការផុតកំណត់នៃពេលវេលាសមរម្យ ឬ

( ខ ) ការជូនពត៌មានទៅភាគីប្តឹងតវ៉ាដោយភាគីត្រូវឆ្លើយតបថា បានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ ( ការអនុវត្ត) ។

៣. សាលាឧទ្ធរណ៍អាចធ្វើការប៉ាន់ប្រមាណមើលពីបញ្ហាមុន រួមទាំងការប៉ាន់ប្រមាណមើលលើ :

( ក ) ទ្រង់ទ្រាយពិតនៃការអនុវត្តសកម្មដោយភាគីត្រូវឆ្លើយតប និង

( ខ ) ថាតើភាគីត្រូវឆ្លើយតបបានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ ( ការអនុវត្ត)

៤. សាលាឧទ្ធរណ៍ត្រូវធ្វើរបាយការណ៍ :

( ក ) រៀបរាប់សង្ខេបពីផ្នែកជម្លោះរបស់បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ។

---

[៣] ការពិគ្រោះក្រោមមាត្រា ៦ ( ការពិគ្រោះយោបល់) មិនតម្រូវចំពោះទម្រង់ការទាំងនោះ ។

(ខ) រកឱ្យឃើញការពិតនៃករណី និង

(គ) រកឱ្យឃើញថាតើភាគីត្រូវឆ្លើយតបបានប្រព្រឹត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) ។

៥. សាលាឧទ្ធរណ៍ត្រូវ ទីណាដែលអាចបាន ផ្តល់នូវរបាយការណ៍ដំបូងទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៧៥ ថ្ងៃ នៃកាលបរិច្ឆេទចូលប្រជុំវិញ និងរបាយការណ៍ចុងក្រោយ ១៥ ថ្ងៃបន្ទាប់។ ពេលដែលសាលាឧទ្ធរណ៍ពិចារណាថា មិនអាចផ្តល់របាយការណ៍ទៅនឹងពេលវេលានោះ គឺត្រូវផ្តល់ទៅបណ្តាភាគីនៃវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុ និងប៉ាន់ស្មានពេលវេលាដែលនឹងត្រូវផ្តល់របាយការណ៍។

៦. ទីណាដែលសាលាក្តីត្រូវបានស្នើឡើងសំរាប់ប្រជុំឡើងវិញអនុលោមទៅតាមកថាខណ្ឌ ១ គឺ ត្រូវប្រជុំឡើងវិញក្នុងកំឡុង ១៥ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ។ រយៈពេលចាប់តាំងពីកាលបរិច្ឆេទនៃការស្នើសុំទៅសាលាក្តី ដើម្បីប្រជុំឡើងវិញ ដើម្បីផ្តល់របាយការណ៍ចុងក្រោយមិនត្រូវលើសពី ១២០ ថ្ងៃ លើកលែងតែមាត្រា ១១.១៧ (ការបង្កើតសាលាក្តី និងការប្រជុំឡើងវិញរបស់សាលាក្តី) អនុវត្ត ឬ បណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ។

## មាត្រា ១៧

## ការទូទាត់សង និងការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត

១. ការទូទាត់សង និងការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀតជាវិធានការបណ្តោះអាសន្នអាចរកបាន នៅពេលដែលភាគីត្រូវឆ្លើយតប មិនប្រតិបត្តិតាមកាតព្វកិច្ចនៅក្រោមមាត្រា ១៥.១ (ការអនុវត្ត)។ ទោះជាយ៉ាងណាក៏ដោយ ទាំងការទូទាត់សង ទាំងការពន្យារសម្បទាន ឬកាតព្វកិច្ចដទៃទៀត ត្រូវតែផ្អែកទៅលើកាតព្វកិច្ចក្រោមមាត្រា ១៥.១ (ការអនុវត្ត)។ ការទូទាត់សងគឺដោយស្ម័គ្រចិត្ត និងប្រសិនបើឱ្យ ត្រូវតែស្របទៅតាមកិច្ចព្រមព្រៀងនេះ។

២. ទីណាដែលហេតុការណ៍ទាំងនេះកើតមាន :

(ក) ភាគីឆ្លើយតប ត្រូវជូនពត៌មានទៅភាគីប្តឹងតវ៉ាថា វាមិនមានបំណងក្នុងការប្រតិបត្តិតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥. ១ (ការអនុវត្ត) ឬ

(ខ) ការខកខានមិនប្រតិបត្តិតាមទៅនឹងកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) បានបង្កើតយោងទៅតាមមាត្រា ១៦ (Compliance Review) ។

ភាគីត្រូវឆ្លើយតបត្រូវ ប្រសិនបើមានការស្នើដោយភាគីប្តឹងតវ៉ា ចូលចរចាក្នុងគំនិតអភិវឌ្ឍ ការទូទាត់សង ដែលអាចទទួលយកបានទៅវិញទៅមក។

៣. ប្រសិនបើការទូទាត់សងមិនមានការពេញចិត្ត ដូចដែលបានព្រមព្រៀងក្នុងកំឡុង ៣០ ថ្ងៃ នៃកាលបរិច្ឆេទស្នើសុំ ដែលបានធ្វើក្រោមកថាខណ្ឌ ២ ភាគីប្តឹងតវ៉ាអាច គ្រប់ពេលវេលាបន្ទាប់ពីជូនពត៌មានទៅភាគីត្រូវឆ្លើយតប និងបណ្តាភាគីដទៃទៀតដែលមានបំណងក្នុងការពន្យារការអនុវត្ត ទៅភាគីត្រូវឆ្លើយតបនូវសម្បទាន ឬ កាតព្វកិច្ចដទៃ មានតម្លៃស្មើទៅនឹងកំរិតមោឃភាព និងខូចខាត ត្រូវមានសិទ្ធិចាប់ផ្តើមពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ៣០ ថ្ងៃ បន្ទាប់ពីការទទួលការជូនពត៌មាន។

៤. សិទ្ធិក្នុងការពន្យារសម្បទាន ឬកាតព្វកិច្ចដែលកើតឡើងក្រោមកថាខណ្ឌ ៣ មិនត្រូវបានប្រើទីណា :

(ក) ការរំលឹកឡើងវិញកំពុងតែដំណើរការអនុលោមទៅតាមកថាខណ្ឌ ៨. ឬ

(ខ) ការឈានទៅដល់ដំណោះស្រាយដែលព្រមព្រៀងទៅវិញទៅមក។

៥. ការជូនពត៌មានដែលបានធ្វើនៅក្រោមកថាខណ្ឌ ៣ ត្រូវបញ្ជាក់ពីកំរិតសម្បទាន ឬ កាតព្វកិច្ចដទៃដែលភាគីប្តឹងតវ៉ាស្នើសម្រាប់ការពន្យារ និងជំពូក និងផ្នែកដែលពាក់ព័ន្ធទៅនឹងសម្បទាន ឬកាតព្វកិច្ច។

៦. ក្នុងការពិចារណាថា សម្បទាន ឬកាតព្វកិច្ចដើម្បីពន្យារ ភាគីប្តឹងតវ៉ាអាចអនុវត្តគោលការណ៍ ដូចខាងក្រោម :

(ក) ដំបូងបង្អស់ភាគីប្តឹងតវ៉ាត្រូវស្វែងរកការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ចំពោះវិស័យដូច ឬ វិស័យដែលបានប៉ះពាល់ដោយវិធានការ និង

(ខ) ភាគីប្តឹងតវ៉ាអាចពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃចំពោះវិស័យដទៃ ប្រសិនបើ ពិចារណាឃើញថា វាមិនអាចប្រព្រឹត្តិបាន ឬ ប៉ះពាល់ដល់ការពន្យារសម្បទាន ឬ កាតព្វកិច្ច ចំពោះវិស័យដូច។

៧. កំរិតនៃការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃ ត្រូវតែមានតម្លៃស្មើទៅនឹងកំរិតនៃ មោឃភាព និង ខូចខាត។

៨. ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលពត៌មានដែលបានធ្វើក្រោមកថាខណ្ឌ ៣ ប្រសិនបើភាគីត្រូវឆ្លើយតបបដិសេធទៅនឹងកំរិតស្នើសុំពន្យារ ឬ ពិចារណាថាគោលការណ៍ដែលមានចែងនៅក្នុងកថាខណ្ឌ ៦ មិនប្រតិបត្តិតាមភាគីត្រូវឆ្លើយតបអាចស្នើសុំទៅសាលាក្តី ដើម្បីប្រជុំឡើងវិញដើម្បីរកឱ្យឃើញបញ្ហា។ សាលាក្តីត្រូវ

ផ្តល់ការប៉ាន់ប្រមាណទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៣០ ថ្ងៃ នៃកាលបរិច្ឆេទការប្រជុំឡើងវិញនោះ។ ទីណាដែលសាលាក្តីត្រូវបានស្នើសុំឱ្យប្រជុំឡើងវិញ អនុលោមទៅ តាមកថាខណ្ឌនេះ លើកលែងតែមាត្រា ១១.១៧ (ការបង្កើត និងប្រជុំឡើងវិញរបស់សាលាក្តី) អនុវត្ត។

៩. ការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃត្រូវតែបណ្តោះអាសន្ន និងមិនត្រូវអនុវត្តរហូតដល់ពេលវេលាដែលកាតព្វកិច្ចនៅក្នុងមាត្រា ១៥.១ (ការអនុវត្ត) ត្រូវបានអនុវត្តជាមួយនឹង ឬ ឈានទៅដល់ដំណោះស្រាយពេញចិត្តទៅវិញទៅមក។

១០. ទីណាដែលសិទ្ធិសំរាប់ការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃត្រូវបានអនុវត្តក្រោមមាត្រានេះ ប្រសិនបើ ភាគីត្រូវឆ្លើយតបពិចារណាថា :

(ក) កំរិតនៃសម្បទាន ឬ កាតព្វកិច្ចដទៃពន្យារដោយភាគីប្តឹងតវ៉ា មិនមានតម្លៃស្មើទៅនឹងកំរិតនៃមោឃភាព និង ខូចខាត ឬ

(ខ) វាបានអនុវត្តទៅតាមកាតព្វកិច្ចនៅក្នុងមាត្រា ១៥. ១ (ការអនុវត្ត)។

វាអាចស្នើសុំទៅសាលាក្តីប្រជុំឡើងវិញដើម្បីពិនិត្យបញ្ហា[៤] ។

១១. ទីណាដែលសាលាក្តីប្រជុំឡើងវិញអនុលោមទៅតាមកថាខ័ណ្ឌ ១០ (ក) កថាខ័ណ្ឌ ៨ ត្រូវអនុវត្ត។ ទីណាដែលសាលាក្តីប្រជុំឡើងវិញអនុលោមទៅតាមកថាខ័ណ្ឌ ១០ (ខ) មាត្រា ១៦.៣ ដល់ ១៦. ៥ (Compliance Review) ត្រូវអនុវត្ត។

---

[៤] ទីណាដែលសាលាឧទ្ធរណ៍សម្រេចថា វិធានការដែលបានអនុវត្តដើម្បីប្រតិបត្តិតាម មិនសមស្របទៅនឹងកិច្ចព្រមព្រៀងនេះ វាអាចទៅលើការស្នើសុំប៉ាន់ប្រមាណថា កំរិតនៃការពន្យារសម្បទានដែលមានស្រាប់អាចយកបាន និងបើមិនអាចត្រូវធ្វើការប៉ាន់ប្រមាណកំរិតដែលអាចយកបាន។

## ផ្នែក ១

## អវសានបញ្ញត្តិ

### មាត្រា ១៨

### ប្រព្រឹត្តិកម្មពិសេស និងដោយឡែកពាក់ព័ន្ធនឹងសមាជិកអាស៊ានថ្មី

១. នៅគ្រប់ដំណាក់កាលនៃការកំណត់មូលហេតុវិវាទ និងនីតិវិធីដោះស្រាយវិវាទ ពាក់ព័ន្ធទៅនឹងសមាជិកថ្មីអាស៊ាន ការពិចារណាដោយអាណិតអាសូរដោយឡែកត្រូវផ្តល់ទៅតាមស្ថានភាពពិសេស ចំពោះសមាជិកថ្មីអាស៊ាន។ ដោយហេតុនេះ បណ្តាភាគីត្រូវអនុវត្តដោយបន្ថយនៅក្នុងការលើកឡើងនៃបញ្ហាក្រោមនីតិវិធីនេះ ដែលពាក់ព័ន្ធទៅនឹងភាគីដែលជាប្រទេសអភិវឌ្ឍន៍តិចតួច។ ប្រសិនបើ មោឃភាព និងការខូចខាតត្រូវបានរកឃើញ មកពីវិធានដែលបានប្រើប្រាស់ដោយភាគីដែលជាប្រទេសអភិវឌ្ឍន៍តិចតួច ភាគីប្តឹងតវ៉ាមួយ អាចអនុវត្តការបន្ធូរបន្ថយបញ្ហាពាក់ព័ន្ធគ្របដណ្តប់ក្រោមមាត្រា ១៧ (ការទូរទាត់សង និងការពន្យារសម្បទាន ឬ កាតព្វកិច្ចដទៃទៀត) ឬ កាតព្វកិច្ចដទៃ អនុលោមទៅតាមនីតិវិធីទាំងនេះ។

២. ទីណាដែលភាគីវិវាទមួយ ឬច្រើនជាសមាជិកថ្មីអាស៊ាន របាយការណ៍របស់សាលាក្តីត្រូវបញ្ជាក់ច្បាស់លាស់ ពីទម្រង់រឿងរ៉ាវដែលបានអនុវត្តពាក់ព័ន្ធទៅនឹងបទប្បញ្ញត្តិស្តីពីប្រព្រឹត្តិកម្មពិសេស និងដោយឡែកសម្រាប់សមាជិកអាស៊ានថ្មី ត្រូវជាផ្នែកមួយនៃកិច្ចព្រមព្រៀងនេះ ដែលត្រូវបានលើកឡើងដោយសមាជិកអាស៊ានថ្មីនៅក្នុងមូលហេតុនៃនីតិវិធីដោះស្រាយវិវាទ។

### មាត្រា ១៩

### សោហ៊ុយចំណាយ

១. លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀង ភាគីនីមួយៗនៃវិវាទត្រូវទទួលបន្ទុកលើសោហ៊ុយនៃការចាត់តាំងអាជ្ញាកណ្តាល និងសោហ៊ុយចំណាយផ្ទាល់ខ្លួន និងសោហ៊ុយផ្លូវច្បាប់។

២. លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀង សោហ៊ុយសម្រាប់ប្រធានសាលាក្តី និងសោហ៊ុយចំណាយដទៃទៀត ពាក់ព័ន្ធទៅនឹងការរៀបចំទម្រង់ការ ត្រូវចំណាយស្មើគ្នាដោយបណ្តាភាគីនៃវិវាទ។

## មាត្រា ២០

## ចំណុចទំនាក់ទំនង

១. ភាគីនីមួយៗត្រូវជ្រើសតាំងចំណុចទំនាក់ទំនងសំរាប់ជំពូកនេះ និងត្រូវជូនពត៌មានទៅបណ្តាភាគីដទៃលំអិតពីចំណុចទំនាក់ទំនងនេះក្នុងកំឡុង ៣០ ថ្ងៃ នៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ ភាគីនីមួយៗ ត្រូវជូនពត៌មានទៅបណ្តាភាគីដទៃនៃការផ្លាស់ប្តូរចំណុចទំនាក់ទំនង ។

២. ការស្នើសុំណាមួយ ផ្តល់ជាលាយលក្ខណ៍អក្សរ ឬ ឯកសារដទៃពាក់ព័ន្ធទៅនឹងទម្រង់ការណាមួយអនុលោមទៅតាមជំពូកនេះ ត្រូវជូនដល់ភាគីពាក់ព័ន្ធ ឬ បណ្តាភាគីតាមរយៈចំណុចទំនាក់ទំនងដែលបានចាត់តាំងជាអ្នកត្រូវផ្តល់ពត៌មានបញ្ជាក់នៃការទទួលឯកសារជាលាយលក្ខណ៍អក្សរទាំងនោះ ។

## មាត្រា ២១

## ភាសា

១. រាល់ទម្រង់ការអនុលោមទៅតាមជំពូកនេះត្រូវរៀបចំជាភាសាអង់គ្លេស ។

២. ឯកសារណាមួយដែលបានផ្តល់ សម្រាប់ប្រើប្រាស់នៅក្នុងទម្រង់ការអនុលោមទៅតាមជំពូក នេះត្រូវជាភាសាអង់គ្លេស។ ប្រសិនបើឯកសារដើមណាមួយមិនមែនជាភាសាអង់គ្លេស ភាគីមួយដែលផ្តល់ឱ្យសម្រាប់ប្រើនៅក្នុងទម្រង់ការ ត្រូវផ្តល់ការបកប្រែឯកសារនោះជាភាសាអង់គ្លេស ។

## ឧបសម្ព័ន្ធ ស្តីពីវិធាននៃនីតិវិធីសំរាប់ទម្រង់ការសាលាក្តី

១. ឯកសារយោងណាមួយបានធ្វើឡើងនៅក្នុងវិធានទាំងនេះទៅនឹងមាត្រាមួយ គឺជាឯកសារយោងសមរម្យទៅនឹងមាត្រានៅក្នុងជំពូក ១៧ ( ការពិគ្រោះ និងការដោះស្រាយវិវាទ) ។

**តារាងពេលវេលា**

២. បន្ទាប់ពីពិគ្រោះជាមួយបណ្តាភាគីវិវាទ សាលាក្តីត្រូវកាន់តែឆាប់ប្រតិបត្តិបាន និងពេលណាដែលអាចធ្វើទៅបានក្នុងកំឡុង ១៥ ថ្ងៃ បន្ទាប់ពីបង្កើតសាលាក្តី កំណត់តារាងពេលវេលាសម្រាប់ដំណើរការសាលាក្តី ។ ដំណើរការសាលាក្តី ពីកាលបរិច្ឆេទនៃការបង្កើត រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍ចុងក្រោយត្រូវដូចវិធានទូទៅមិនលើសពីរយៈពេលប្រាំបួនខែ លើកលែងតែបណ្តាភាគីនៃវិវាទព្រមព្រៀងផ្សេងពីនេះ ។

៣. ក្នុងការកំណត់តារាងពេលវេលា សម្រាប់ដំណើរការសាលាក្តី សាលាក្តីត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់បណ្តាភាគីនៃវិវាទរៀបចំការផ្តល់ជូនរបស់គេ ។ សាលាក្តីត្រូវចាត់កាលកំណត់សម្រាប់ការសរសេរផ្តល់ដោយបណ្តាភាគីនៃវិវាទ និងគេត្រូវគោរពទៅតាមកាលកំណត់នោះ ។ របាយការណ៍ដំបូង ត្រូវផ្តល់ឱ្យបានយ៉ាងតិចបំផុត បួនសប្តាហ៍មុនកាលកំណត់ សម្រាប់បញ្ចប់របាយការណ៍ចុងក្រោយ ។

៤. សាលាក្តីត្រូវបញ្ចេញទៅបណ្តាភាគីនៃវិវាទនូវរបាយការណ៍ចុងក្រោយក្នុងកំឡុង ១៨០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្កើតសាលាក្តី ។ ក្នុងករណីបន្ទាន់ រួមទាំងការពាក់ព័ន្ធទៅនឹងទំនិញឆាប់ពុកផុយរលួយ សាលាក្តីត្រូវមានបំណងក្នុងការចេញរបាយការណ៍ទៅបណ្តាភាគីនៃវិវាទក្នុងកំឡុង ៩០ ថ្ងៃ ពីកាលបរិច្ឆេទនៃការបង្កើត ។ ពេលណាដែលសាលាក្តីពិចារណាថា មិនអាចបញ្ចេញរបាយការណ៍ចុង ក្រោយក្នុងកំឡុង ១៨០ថ្ងៃ ឬ ក្នុងកំឡុង ៩០ ថ្ងៃ ក្នុងករណីបន្ទាន់ ត្រូវផ្តល់ពតិមានទៅបណ្តាភាគី នៃវិវាទជាលាយលក្ខណ៍អក្សរពីមូលហេតុនៃការយឺតយ៉ាវរួម ជាមួយនឹងការប៉ាន់ស្មានពេលវេលា ដែលអាចចេញរបាយការណ៍ ។

៥. ពេលវេលាណាមួយដែលអាចអនុវត្តបាន ទម្រង់ការសាលាក្តីពន្យារចំពោះរយៈពេលដែលចាប់ផ្តើមនៅចំកាលបរិច្ឆេទដែលសមាជិកណាមួយនៃសាលាក្តីលាឈប់ ឬ គ្មានលទ្ធភាពក្នុងការបំពេញការងារ និងបញ្ចប់នៅចំកាលបរិច្ឆេទដែលសមាជិកជំនួសត្រូវបានចាត់តាំង ។

៦.	លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយបណ្តាភាគីនៃវិវាទ សាលាក្តីអាចពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ កែប្រែពេលវេលាដែលអាចអនុវត្តបាន នៅក្នុងទម្រង់ការសាលាក្តី និងអាចធ្វើទម្រង់ការដទៃ ឬកែខៃរដ្ឋបាលដូចដែលអាចតម្រូវនៅក្នុងទម្រង់ការ ។

**ការប្រតិបត្តិនៃសាលាក្តី**

៧.	ប្រធានសាលាក្តីត្រូវធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ សាលាក្តីអាចផ្តល់អំណាចទៅឱ្យប្រធាន ដើម្បីធ្វើការងាររដ្ឋបាល និងទម្រង់ការសម្រេច ។

៨.	លើកលែងតែមានការផ្តល់ផ្សេងនៅក្នុងឧបសម្ព័ន្ធនេះ សាលាក្តីអាចរៀបចំធុរកិច្ចដោយគ្រប់មធ្យោបាយរួមទាំង ទូរស័ព្ទ ទូរសារ និងមធ្យោបាយដទៃណាមួយនៃការទំនាក់ទំនងអេឡិចត្រូនិច ។

៩.	មានតែសមាជិកនៃសាលាក្តីអាចមានចំណែកនៅក្នុងការពិភាក្សារបស់សាលាក្តី ។

១០.	សាលាក្តីអាច ពិគ្រោះជាមួយបណ្តាភាគីនៃវិវាទ រក្សាចំនួនជំនួយការ អ្នកបកប្រែ អ្នកកត់ត្រា ដែលបានចាត់តាំងដូចដែលតម្រូវសំរាប់ទម្រង់ការ និងអនុញ្ញាតឱ្យពួកគេមានវត្តមានក្នុងដំណើរការពិគ្រោះ។ ការរៀបចំណាមួយ ដែលបានបង្កើតដោយសាលាក្តីអាចកែប្រែដោយការព្រមព្រៀងរបស់បណ្តាភាគីនៃវិវាទ។

១១.	ការពិភាក្សារបស់សាលាក្តីត្រូវតែជាសម្ងាត់។ សមាជិករបស់សាលាក្តី និងបុគ្គលដែលរក្សា ដោយសាលាក្តីត្រូវរក្សាការសម្ងាត់នៃទម្រង់ការសាលាក្តី និងការពិភាក្សា។

១២.	មិនត្រូវមានទំនាក់ទំនងណាមួយមុន *(ex parte)* ជាមួយសាលាក្តីពាក់ព័ន្ធទៅនឹងបញ្ហា ក្រោមការពិចារណារបស់សាលាក្តី ។

១៣.	បណ្តាភាគីទីបីដែលមានចំណាប់អារម្មណ៍ និងបណ្តាភាគីដទៃទៀត ត្រូវយកចិត្តទុកដាក់នៅក្នុងរយៈពេលនៃទម្រង់ការសាលាក្តី ។

**ការសរសេរផ្តល់ និង ឯកសារដទៃ**

១៤.	ភាគីណាមួយនៃវិវាទ អាចបញ្ជូនទៅសាលាក្តីនៃការផ្តល់ដំបូងជាលាយលក្ខណ៍អក្សរដោយ ដាក់នូវការពិតរបស់ករណី និងជម្លោះរបស់វា។ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះដោយបណ្តាភាគី ភាគីប្តឹងតវ៉ាត្រូវបញ្ជូនការផ្តល់ដំបូងទៅសាលាក្តី និងទៅភាគីត្រូវឆ្លើយតបក្នុងកំឡុង ១៤ ថ្ងៃ បន្ទាប់ពីការបរិច្ឆេទនៃការបង្កើត

សាលាក្តី។ ភាគីត្រូវឆ្លើយតបត្រូវបញ្ជូនការផ្តល់ដំបូងទៅសាលាក្តី និងទៅភាគីប្តឹងតវ៉ាក្នុងកំឡុង ២១ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលការផ្តល់ដំបូងរបស់ភាគីប្តឹងតវ៉ា។ ការសរសេរផ្តល់បន្តបន្ទាប់ ត្រូវផ្តល់ដំណាលគ្នា។

១៥. ភាគីមួយនៃវិវាទត្រូវបញ្ជូនការសរសេរផ្តល់មិនឱ្យតិចជាងបួនច្បាប់ទៅសាលាក្តី និងមួយច្បាប់ទៅបណ្តាភាគីនៃវិវាទ។ បណ្តាភាគីទីបី ត្រូវទទួលការផ្តល់របស់បណ្តាភាគីនៃវិវាទនៃសារៈសំខាន់របស់សវនាការដំបូង។

១៦. ដោយគោរពទៅតាមការស្នើសុំណាមួយ កំណត់ត្រា ឬ ឯកសារដទៃពាក់ព័ន្ធទៅនឹងទម្រង់ការសាលាក្តី ដែលមិនគ្របដណ្តប់ដោយវិធាន ១៤ និង ១៥ ភាគីនីមួយៗនៃវិវាទអាចបញ្ជូនច្បាប់ចំលងនៃឯកសារ ទៅភាគីដទៃនៃវិវាទដោយទូរសារ អ៊ីម៉ែល ឬមធ្យោបាយបញ្ជូនអេឡិចត្រូនិចដទៃ។

១៧. ភាគីមួយនៃវិវាទអាច គ្រប់ពេលវេលាកែតម្រូវកំហុសតិចតួចនៃសហធម្មិកនៅក្នុងការស្នើសុំកំណត់ត្រា ការសរសេរផ្តល់ ឬ ឯកសារដទៃ ពាក់ព័ន្ធទៅនឹងទម្រង់ការសាលាក្តី ដោយបញ្ជូនឯកសារថ្មីបញ្ជាក់ច្បាស់ពីការកែប្រែ។

**សវនាការ**

១៨. នៅក្នុងសវនាការជុំកំភួនដំបូងជាមួយនឹងបណ្តាភាគីនៃវិវាទ ភាគីនីមួយៗនៃវិវាទត្រូវបង្ហាញការពិតនៃករណី និងជម្លោះរបស់ខ្លួន។ ភាគីប្តឹងតវ៉ាត្រូវបង្ហាញពីជំហរដំបូងរបស់ខ្លួន។ បណ្តាភាគីនៃវិវាទត្រូវឱ្យឱកាសសំរាប់សេចក្តីថ្លែងការណ៍ ជាមួយនិងការបង្ហាញសេចក្តីថ្លែងការណ៍របស់ភាគីប្តឹង តវ៉ាមុន។

១៩. បណ្តាភាគីទីបីទាំងអស់ត្រូវបានអញ្ជើញ ដើម្បីបង្ហាញពីគំនិតនៅក្នុងសម័យប្រជុំដោយឡែក នៃសវនាការជុំកំភួនដំបូងដែលបានរៀបចំសំរាប់គោលបំណងនោះ។ បណ្តាភាគីទីបីអាចបង្ហាញនៅក្នុងរយៈពេលកិច្ចប្រជុំទាំងមូល។

២០. បណ្តាភាគីនៃវិវាទ និងបណ្តាភាគីទីបី ត្រូវធ្វើឱ្យរកបាននូវការសរសេរនៃសេចក្តីថ្លែងការណ៍ ដោយមាត់សម្រាប់សាលាក្តី និងឆ្លើយតបទៅនឹងសំណួរដែលបានធ្វើនៅក្នុងសវនាការជាមួយនឹងសាលាក្តី។

**ពតិមានដែលអាចរកបាន**

២១. ការសរសេរផ្តល់ទៅសាលាក្តីត្រូវប្រព្រឹត្តជាសម្ងាត់ ប៉ុន្តែត្រូវធ្វើឱ្យអាចរកបានដោយបណ្តាភាគីនៃវិវាទ។ គ្មានភាគីនៃវិវាទត្រូវ រារាំងពីការបង្ហាញសេចក្តីថ្លែងការណ៍ពីគោលជំហររបស់ខ្លួនទៅសាធារណៈ ដោយផ្តល់ថាទាំងនោះមិនមែនបង្ហាញពតិមានដែលចាត់ទុកថាសម្ងាត់ដោយបណ្តាភាគីនៃវិវាទ ឬភាគីទីបី។ បណ្តាភាគីនៃវិវាទ

ភាគីទីបី និងសាលាក្ដី ត្រូវប្រព្រឹត្តិពតិជាសម្ងាត់ពតិមានដែលបាន ផ្ដល់ដោយ ភាគីដែលកំណត់ថាជាសម្ងាត់។ ភាគីមួយនៃវិវាទត្រូវ តាមការស្នើសុំរបស់ភាគីដទៃ ផ្ដល់ជាសង្ខេបមិនមែនសម្ងាត់នៃពតិមានដែលមាននៅក្នុងការសរសេរផ្ដល់ថា ជាពតិមានអាចបង្ហាញទៅសាធារណៈ។

**ប្រមូលផ្ដុំពតិមាន**

២២. បណ្ដាភាគីនៃវិវាទ និងបណ្ដាភាគីទីបីត្រូវឆ្លើយតបបន្ទាន់ និងពេញលេញទៅការស្នើសុំណាមួយដោយសាលាក្ដីដែលពតិមាននោះសាលាក្ដីពិចារណាថាសំខាន់ និងសមរម្យ។

២៣. សាលាក្ដីអាចស្វែងរកពតិមាន និងណែនាំបច្ចេកទេសពីបុគ្គល ឬ ស្ថាប័ន ដែលយល់ថាសមរម្យ។ យ៉ាងណាក៏ដោយ មុនពេលធ្វើដូចនោះ សាលាក្ដីត្រូវស្នើសុំយោបល់ពីបណ្ដាភាគីនៃវិវាទ។ ទីណា ដែលបណ្ដាភាគីនៃវិវាទព្រមព្រៀងថា សាលាក្ដីមិនត្រូវស្វែងរកពតិមានបន្ថែម ឬ ណែនាំបច្ចេកទេស សាលាក្ដីមិនត្រូវធ្វើដូច្នោះឡើយ។ សាលាក្ដីត្រូវផ្ដល់ទៅបណ្ដាភាគីនៃវិវាទជាមួយនិងពតិមានណាមួយ ឬ ការណែនាំណាមួយ ដែលខ្លួនទទួល និងឱកាសសំរាប់ផ្ដល់អនុសាសន៍។

**របាយការណ៍**

២៤. សាលាក្ដីត្រូវផ្ដល់ទៅបណ្ដាភាគីនៃវិវាទនូវរបាយការណ៍ដំបូង ជួបទៅនឹងតម្រូវការដែលបានបញ្ជាក់នៅក្នុងមាត្រា ១២.៣ (មុខងារសាលាក្ដី)។

២៥. របាយការណ៍ដំបូងត្រូវផ្ដល់យ៉ាងតិច ០៤ សប្ដាហ៍ មុនកាលកំណត់ សំរាប់ការបញ្ចប់របាយការណ៍ចុងក្រោយ។ សាលាក្ដីត្រូវផ្ដល់ឱកាសគ្រប់គ្រាន់ទៅបណ្ដាភាគីនៃវិវាទក្នុងការពិនិត្យឡើងវិញនូវរបាយការណ៍ទាំងមូលមុនពេលបញ្ចប់ និងត្រូវបញ្ចូលរាល់យោបល់រាល់ការពិភាក្សាធ្វើឡើងដោយបណ្ដាភាគីនៃវិវាទ នៅក្នុងរបាយការណ៍ចុងក្រោយ។

២៦. របាយការណ៍ដំបូង និងរបាយការណ៍ចុងក្រោយរបស់សាលាក្ដីត្រូវព្រាងដោយមិនមានវត្តមានរបស់បណ្ដាភាគីនៃវិវាទ។ មតិ យោបល់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍របស់សាលាក្ដីដោយបុគ្គលជាសមាជិកត្រូវតែអនាមិក។

**ទីកន្លែង**

២៧. ទីកន្លែងសវនាការសាលាក្តី ត្រូវតែសម្រេចដោយការព្រមព្រៀងទៅវិញទៅមក រវាងបណ្តាភាគីនៃវិវាទ។ ប្រសិនបើមិនមានការព្រមព្រៀង ទីកន្លែងត្រូវតែឆ្លាស់គ្នារវាងរាជធានីរបស់បណ្តាភាគីនៃវិវាទ ជាមួយនិងសវនាការដំបូងត្រូវតែប្រព្រឹត្តនៅក្នុងរាជធានីរបស់ភាគីប្តឹងតវ៉ា។

**លាភការ និងការទូទាត់ចំណាយ**

២៨. សាលាក្តីត្រូវរក្សាទុកនូវបញ្ជី និងផ្តល់គណនីចុងក្រោយនៃរាល់ខ្ទង់ចំណាយទូទៅដែលកើតមានឡើងពាក់ព័ន្ធទៅនឹងទម្រង់ការ រាប់បញ្ចូលទាំងបានចំណាយសំរាប់ជំនួយការ អ្នកកត់ត្រាដែលបានចាត់តាំង ឬបុគ្គលដទៃទៀតដែលខ្លួនបានរក្សាទុក អនុលោមទៅតាមមាត្រា ១០។

## ឧបសម្ព័ន្ធ ស្តីពីនីតិវិធីជ្រើសរើសសមាសភាពសាលាក្តី

ដូចដែលបានផ្តល់នៅក្នុងមាត្រា ១១.១៧ (ការបង្កើត និងការប្រជុំឡើងវិញរបស់សាលាក្តី) បណ្តាភាគីនៃវិវាទ អាចព្រមព្រៀងក្នុងការប្រើប្រាស់នីតិវិធីជម្រើសខាងក្រោម ឬ ការប្រែប្រួលរបស់វា សម្រាប់គោលបំណងនៃសមាសភាពសាលាក្តី។

**ជម្រើសនីតិវិធី ក**

១. ភាគីប្តឹងតវ៉ា និងភាគីត្រូវឆ្លើយតបត្រូវចាត់តាំងអាជ្ញាកណ្តាលមួយរូបក្នុងកំឡុង (រយៈពេលដែលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី។ ប្រសិនបើភាគីណាមួយ ខកខានក្នុងការចាត់តាំងអាជ្ញាកណ្តាលទៅក្នុងរយៈពេលនោះ នោះអាជ្ញាកណ្តាលដែលចាត់តាំងដោយភាគីដទៃ ត្រូវប្រតិបត្តិតែម្នាក់ឯងនៃសាលាក្តី។

២. ទីណាដែលអាជ្ញាកណ្តាលពីររូបត្រូវបានចាត់តាំងទៅតាមកថាខណ្ឌ ១ បណ្តាភាគីនៃវិវាទត្រូវចាត់តាំងដោយការព្រមព្រៀងរួមទៅនឹងអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី។ ប្រសិនបើបណ្តាភាគីវិវាទមិនទាន់បានចាត់តាំងប្រធានសាលាក្តីក្នុងកំឡុង (រយៈពេលដែលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការចាត់តាំងអាជ្ញាកណ្តាលទីពីរ អាជ្ញាកណ្តាលពីររូបដែលបានចាត់តាំងទៅតាមកថាខណ្ឌ ១ ត្រូវចាត់តាំងដោយព្រមព្រៀងរួមអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី ប្រសិនបើប្រធានសាលាក្តីមិនទាន់ត្រូវបានចាត់តាំងដោយអាជ្ញាកណ្តាលក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគី) នៃការចាត់តាំងអាជ្ញាកណ្តាលទីពីរ អគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក ត្រូវតាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ ចាត់តាំងប្រធានសាលាក្តីក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការស្នើសុំនោះ។

**ជម្រើសនីតិវិធី ខ**

១. ភាគីប្តឹងតវ៉ា និងភាគីឆ្លើយតប អាចចាត់តាំងអាជ្ញាកណ្តាលមួយក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគី) នៃកាលបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី។

២. បណ្តាភាគីនៃវិវាទត្រូវព្រមព្រៀងលើការចាត់តាំងនៃអាជ្ញាកណ្តាលទីបីក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការចាត់តាំងអាជ្ញាកណ្តាលទីបី ដែលជាអ្នកត្រូវធ្វើប្រធានសាលាក្តី។ ប្រសិនបើការចាត់តាំងទាំងបីមិនទាន់បានធ្វើក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) ការចាត់តាំងចាំបាច់

ត្រូវធ្វើទៅតាមការស្នើសុំរបស់ភាគីវិវាទណាមួយ ដោយអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក ក្នុងកំឡុងខាងមុខ (តាមរយៈការព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ)។

**ជម្រើសទីពីរវិធី គ**

១. ក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃកាលបរិច្ឆេទទទួលការស្នើសុំបង្កើតសាលាក្តី ភាគីនីមួយៗនៃវិវាទអាចផ្តល់ទៅបណ្តាភាគីដទៃនៃវិវាទ នូវបញ្ជីអ្នកដែលត្រូវជ្រើសរើស សំរាប់ចាត់តាំងជាអាជ្ញាកណ្តាល រួមបញ្ចូលយ៉ាងតិចបំផុតបុគ្គលពីររូប ដែលសក្តិសមសំរាប់ចាត់តាំងជាប្រធាន។ បណ្តាភាគីនៃវិវាទត្រូវបន្ទាប់ពីនោះ ពិគ្រោះគ្នាលើសមាសធាតុនៃសាលាក្តីក្នុងគោលបំណងចាត់តាំងអាជ្ញាកណ្តាល ចេញពីបញ្ជីអ្នកដែលត្រូវជ្រើសរើស។

២. ប្រសិនបើអាជ្ញាកណ្តាលមិនទាន់ត្រូវបានចាត់តាំងក្នុងកំឡុង (រយៈពេលព្រមព្រៀងដោយបណ្តាភាគីនៃវិវាទ) នៃការស្នើសុំបង្កើតសាលាក្តី អាជ្ញាកណ្តាលដែលនៅសេសសល់ ត្រូវចាត់តាំងទៅតាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ ដោយជ្រើសរើសយកបន្តបន្ទាប់ពីបញ្ជីអ្នកដែលត្រូវជ្រើសរើសដោយឡែក សំរាប់គោលបំណងនេះនៃបញ្ជីអ្នកដែលត្រូវជ្រើសរើសដោយឡែកសំរាប់ចាត់តាំងប្រធាន ឬ អាជ្ញាកណ្តាលធម្មតា។

# ជំពូក ១៨

# អវសានប្បញ្ញត្តិ

## មាត្រា ១

## ឧបសម្ព័ន្ធ សេចក្តីបន្ថែម និងលេខយោង

ឧបសម្ព័ន្ធ សេចក្តីបន្ថែម និងលេខយោងទាំងឡាយ គឺជាផ្នែកនៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២

## ទំនាក់ទំនងទៅកិច្ចព្រមព្រៀងផ្សេងទៀត

១- ភាគីនីមួយៗ បញ្ជាក់បន្ថែមទៀតពីសិទ្ធិ និងកាតព្វកិច្ច នៅក្រោមកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក (WTO) និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលភាគីទាំងនោះជាហត្ថលេខី ។

២- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយ ដើម្បីដកហូតសិទ្ធ ឬកាតព្វកិច្ចពីភាគីមួយនៅក្រោមកិច្ចព្រមព្រៀង WTO និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលភាគីទាំងនោះជាហត្ថលេខី ។

៣- ក្នុងករណីដែលមានភាពមិនស្របគ្នាណាមួយរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងផ្សេងទៀត ដែលមានភាគីពីរ ឬច្រើនជាហត្ថលេខី ភាគីនីមួយៗត្រូវពិគ្រោះយោបល់គ្នាភ្លាមៗ ដើម្បីស្វែងរកដំណោះស្រាយឱ្យមានការពេញចិត្តទាំងសងខាង ។

៤- គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងដល់ប្រទេសជាសមាជិកអាស៊ានណាមួយ ពីការចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម វិនិយោគ និង/ឬ វិស័យកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនានា ជាមួយប្រទេសសមាជិកអាស៊ានមួយ ឬច្រើន និង/ឬអូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់ ។

៥- បទបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មិនត្រូវយកទៅអនុវត្តទៅលើកិច្ចព្រមព្រៀងណាមួយ ក្នុងបណ្តាប្រទេសសមាជិកអាស៊ាន។ បទបញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តទៅលើកិច្ចព្រមព្រៀងផ្សេងៗ ដែលពាក់ពន្ធ័នឹងប្រទេសសមាជិកអាស៊ានណាមួយ និង/ឬ ប្រទេសអូស្ត្រាលី និង/ឬ ណូវែលហ្សេឡង់ ដរាបណាបានព្រមព្រៀងដោយភាគីណាមួយនៃកិច្ចព្រមព្រៀង ។

## មាត្រា ៣
## វិសោធនកម្ម ឬ អ្នកស្នងកិច្ចព្រមព្រៀងអន្តរជាតិ

ប្រសិនបើកិច្ចព្រមព្រៀងអន្តរជាតិណាមួយ ឬបទបញ្ញត្តិមួយយោងនៅក្នុងកិច្ចព្រមព្រៀងនេះ (ឬភ្ជាប់ជាមួយកិច្ចព្រមព្រៀងនេះ) បានធ្វើវិសោធនកម្ម នោះភាគីនីមួយៗ ត្រូវតែពិគ្រោះយោបល់ទៅលើអ្វីដែលចាំបាច់ ធ្វើវិសោធនកម្មក្នុងកិច្ចព្រមព្រៀង លើកលែងតែកិច្ចព្រមព្រៀងមានអ្វីផ្សេងក្រៅពីនេះ។

## មាត្រា ៤
## ការផ្សព្វផ្សាយព័ត៌មាន

លើកលែងតែអ្វីផ្តល់ដោយកិច្ចព្រមព្រៀងនេះ គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងដែលតំរូវឱ្យភាគីណាមួយផ្តល់នូវពត៌មានសំងាត់ ការផ្សព្វផ្សាយនិងត្រូវការការពារតាមការអនុវត្តដោយច្បាប់ ឬពត៌មានអ្វីផ្សេងពីនេះ គឺវាផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬដែលនឹងខូចប្រយោជន៍ពាណិជ្ជកម្មនៃសហគ្រិន វិស័យសាធារណៈ ឬឯកជន។

## មាត្រា ៥
## ការសំខាត់

